**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍទីក្រុងរណប ប្រោយចទ្វារទៅជាទីក្រុងឆ្លាតវៃ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ចាំង ម៉ុនធើម**

**ថៃ សាន**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** ឆ្នាំចូលរៀន ២០១៦

ជំនាន់ទី ២៥ (អាហារូបករណ៍) ឆ្នាំសរសេរសារណា ២០២០

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍទីក្រុងរណប ជ្រោយចង្វារទៅជាទីក្រុងឆ្លាតវៃ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ចាំង ប៊ុនធើម**

**ថៃ សាន**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៥ (អាហារូបករណ៍)

ឆ្នាំចូលរៀន ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ចាំង ម៉ុនធើម** និងខ្ញុំបាទឈ្មោះ **ថៃ សាន** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ អាហារូបករណ៍ ជំនាន់ទី២៥ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៦ - ២០២០៖

ជាបឋមយើងខ្ញុំទាំងពីរនាក់ មានកិត្តិយសសូមសេចក្តីអនុញ្ញាត ដើម្បីបានសម្តែងនូវភារកិច្ចគោរពដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះអ្នកមានគុណទាំងទ្វេគឺ **លោកឪពុក និងអ្នកម្តាយ** ដែលបានខិតខំប្រឹងប្រែងប្រកបដោយព្រហ្មវិហារធម៌ចិញ្ចឹមបីបាច់ ថែរក្សា លះបង់ទាំងកម្លាំងកាយ កម្លាំងចិត្ត លះបង់ទាំងធនធាន សេចក្តីស្រលាញ់ ភាពកក់ក្តៅសព្វបែបសព្វយ៉ាង ព្រមទាំងទឹកចិត្តដ៏បរិសុទ្ធចំពោះកូន និងបានខិតខំជម្រុញឱ្យកូនបានសិក្សារៀនសូត្របានខ្ពង់ខ្ពស់ដើម្បីឱ្យក្លាយជាពលរដ្ឋល្អនៅក្នុងសង្គម។

សូមគោរពថ្លែងអរគុណដល់ **ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាធិការរង គណៈគ្រប់គ្រង ព្រមទាំងសាស្ត្រាចារ្យ** ទាំងអស់ដែលបានខិតខំប្រឹងប្រែង និងលទ្ធភាពគ្រប់សព្វបែបយ៉ាងក្នុងការដឹកនាំក្នុងគោលបំណងបណ្តុះបណ្តាលមូលធនផ្នែកបញ្ញាស្មារតី ធនធានមនុស្សកម្ពុជាឱ្យមានចំណេះដឹង បទពិសោធន៍ សីលធម៌ ព្រមទាំងគុណធម៌ និងសមត្ថភាពខ្ពស់ ដើម្បីក្លាយជាសសរទ្រូងរបស់ប្រទេសកម្ពុជា ដែលស្របតាមកាលានុវត្តភាពនៃការអភិវឌ្ឍរបស់ប្រទេសជាតិ។

ជាពិសេសសូមគោរពអរគុណដល់ **លោកគ្រូសាស្ត្រាចារ្យ បណ្ឌិត អ៊ុន សកក្កដា** ដែលបានដឹកនាំកែលម្អ និងធ្វើការចង្អុលបង្ហាញតម្រង់ទិស ព្រមទាំងពន្យល់ពីវិធីសាស្ត្រល្អៗ ផ្តល់យោបល់ល្អៗទាក់ទងនឹងប្រធានបទសារណារបស់ខ្ញុំបាទ រួមទាំងការចំណាយពេលវេលាដ៏មានតម្លៃតាំងពីដើមរហូតដល់ការបញ្ចប់ការសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទ។

ជាចុងក្រោយ ខ្ញុំបាទមានកិត្តិយស សូមសេចក្តីអនុញ្ញាតគោរពជូនដល់អ្នកមានគុណទាំងទ្វេ សូមមេត្តាទទួលយកដោយក្តីអនុគ្រោះបំផុត នូវភក្តីភាព សេចក្តីស្រលាញ់ គោរពស្រលាញ់ ក្នុងភាពសុចរិតដែលប្រកបដោយគុណតម្លៃដ៏ឧត្តុងឧត្តមនៃសេចក្តីថ្លៃថ្នូរ ភាពចុំថ្មើន កិត្តិគុណដ៏ខ្ពង់ខ្ពស់ ព្រមទាំងកញ្ញូតាធម៌បំផុតអំពីខ្ញុំបាទ។

ជាទីបញ្ចប់សូមគោរពជូនពរ លោកអ្នកមានគុណទាំងទ្វេ សូមឱ្យទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ច និងកម្លាំងពលំមាំមួនខ្លាំងក្លា បញ្ញាញាណភ្លឺថ្លាវាងវៃ អាយុយឺនយូរ រកទទួលទានមានបាន គ្រប់ៗគ្នា ព្រមទាំងជួបនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីខ្ញុំបាទទាំងពីរនាក់បានសិក្សាថ្នាក់បរិញ្ញាបត្រ នៅក្នុងសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រ អស់រយៈពេលបីឆ្នាំកន្លងទៅនេះ ខ្ញុំបាទបានទទួលនូវចំណេះដឹងជាច្រើន ទាំងផ្នែកទ្រឹស្តី ព្រមទាំងការអនុវត្តនៅក្នុងនោះផងដែរ។ ក្នុងដំណាក់កាលនេះគឺជាឆ្នាំទី៤ របស់យើងខ្ញុំបាទទាំងពីរនាក់ ដោយផ្អែកទៅតាមលទ្ធភាពនៃចំណេះដឹងនៃការសិក្សាទាំងអស់នេះហើយ ជាកត្តាយ៉ាងសំខាន់ដែលអាចជម្រុញឱ្យខ្ញុំបាទទាំងពីរនាក់មានឱកាសក៏ដូចជាលទ្ធភាពដែលអាចសរសេរសារណាបញ្ចប់ការសិក្សាមួយទុកសម្រាប់ជាឯកសារជំនួយស្មារតីដល់និស្សិតសិស្សប្អូនជំនាន់ក្រោយ។ សារណាបញ្ចប់ការសិក្សាមួយនេះ គឺជាស្នាដៃដែលអាចអាសវាស់ស្ទង់សមត្ថភាព និងចំណេះរបស់ខ្ញុំបាទទាំងពីរនាក់ដែលមានតាំងពីមុនមក។ បរិបទបែបនេះ ជាហេតុបណ្តាលឱ្យខ្ញុំបាទពីរនាក់ បានពិភាក្សាគ្នាសម្រេចជាឯកច្ឆន្ទធ្វើការជ្រើសរើសប្រធានបទមួយដែលទាក់ទងនៅនឹង នីតិនគរូបនីយកម្ម និងសំណង់ ដែលស្តីពី **ការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារទៅជាទីក្រុងឆ្លាតវៃ** មកធ្វើជាប្រធានបទក្នុងការសរសេរសារណាបញ្ចប់ការសិក្សា។

កម្មវត្ថុសំខាន់មួយទៀត គឺចង់ឱ្យនិស្សិតជំនាន់ក្រោយ ក៏ដូចជាសាធារណៈជនបានសិក្សាស្វែងយល់បន្ថែម អំពីការអភិវឌ្ឍទីក្រុងរណបឱ្យក្លាយជាទីក្រុងឆ្លាតវៃ ព្រមទាំងបានបង្ហាញអំពីសោភណ្ឌភាពទីក្រុងប្រណីតភាពនៃសំណង់ ការរស់នៅ ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធបច្ចេកទេសទំនើបនៃការរៀបចំក្រុងរណបជ្រោយចង្វារផងដែរ។ លើសពីនេះទៅទៀត ចំពោះសារណាបញ្ចប់ការសិក្សាមួយនេះ ខ្ញុំបាទទាំងពីរនាក់ក៏មានគោលបំណងចង់បង្ហាញពីសក្តានុពលនៃការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារមួយនេះផងដែរ។

មុននឹងបញ្ចប់ ខ្ញុំបាទទាំងពីរនាក់សូមគោរព និងទទួលយកនូវរាល់កំហុសឆ្គងដែលកើតឡើងដោយចេតនាក្តី ឬអចេតនាក្តី ឬនៅមានភាពខ្វះចន្លោះនៅត្រង់កន្លែងណាមួយសូមមេត្តាខន្តី អភ័យទោស ប្រកបដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទទាំងពីរនាក់ ជាមួយគ្នានេះផងដែរខ្ញុំបាទទាំងពីរនាក់សូមស្វាគមន៍នូវរាល់មតិ រិះគន់ កែលម្អ នូវរាល់ចំណុចខ្វះខាតទាំងឡាយក្នុងអត្ថន័យស្ថាបនា ដើម្បីឱ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទទាំងពីរនាក់មានអត្ថន័យគ្រប់គ្រាន់ និងកាន់តែល្អប្រសើរឡើង។

ជាទីបញ្ចប់ខ្ញុំបាទទាំងពីរ សូមគោរពជូនពរឱ្យអ្នកអាន មិត្តនិស្សិតទាំងអស់គ្នា ឱ្យទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ច និងកម្លាំងពលំមាំមួនខ្លាំងក្លា បញ្ញាញាណភ្លឺថ្លាវាងវៃ មានអាយុយឺនយូរ រកទទួលទានមានបានគ្រប់ៗគ្នា ព្រមទាំងជួបនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារ**

**១.១. ទិដ្ឋភាពទូទៅនៃការរៀបចំទីក្រុងរណបជ្រោយចង្វារ** ........ ៤

**១.១.១. បរិបទទូទៅនៃតំបន់ទីក្រុងរណបជ្រោយចង្វារ** ........ ៥

១.១.១.១. និយមន័យ ........ ៥

១.១.១.២. ទីតាំងនៃតំបន់ជ្រោយចង្វារ ........ ៥

១.១.១.៣. កម្មវត្ថុនៃការរៀបចំទីក្រុងរណបជ្រោយចង្វារ ........ ៦

**១.១.២. មូលហេតុដែលនាំឱ្យមានការរៀបចំទីក្រុងរណបជ្រោយចង្វារ** ........ ៧

១.១.២.១. កំណើនប្រជាជន ........ ៧

១.១.២.២. ភាពក្រីក្រ ........ ៨

១.១.២.៣. គុណភាពនៃការរស់នៅ ........ ១០

១.១.២.៤. ការដាក់សម្ពាធបរិស្ថាន ........ ១០

**១.១.៣. ឥទ្ធិពលនៃការរៀបចំទីក្រុងរណបជ្រោយចង្វារ** ........ ១០

១.១.៣.១. គមនាគមន៍ ........ ១១

១.១.៣.២. បរិស្ថាន ........ ១២

១.១.៣.៣. គុណភាពការរស់នៅ ........ ១២

**១.២. ការរៀបចំទីក្រុងទីក្រុងរណបជ្រោយចង្វារប្រកបទៅដោយស្តង់ដារ** ........ ១៣

**១.២.១. ទីក្រុងដែលមានសណ្តាប់ធ្នាប់** ........ ១៣

១.២.១.១. សន្តិសុខ ........ ១៣

១.២.១.២. ភាពស្ងប់ស្ងៀម ........ ១៧

១.២.១.៣. ការថែរក្សាបរិស្ថាន ........ ១៧

**១.២.២. ទីក្រុងដែលមានសោភណ្ឌភាព** ........ ១៩

១.២.២.១. សោភណ្ឌភាពពេលថ្ងៃ............................................................................................១៩

១.២.២.២. សោភណ្ឌភាពពេលយប់.............................................................................................១៩

**១.២.៣. ទីក្រុងដែលគ្មានការបំពុលទាំង៥**..........................................................................................២០

១.២.៣.១. ការបំពុលទឹក និងវិធានការ....................................................................................២០

១.២.៣.២. ការបំពុលខ្យល់ និងវិធានការ ...............................................................................២១

១.២.៣.៣. ការបំពុលដី និងវិធានការ.......................................................................................២៣

១.២.៣.៤. ការបំពុលដោយសម្លេង និងវិធានការ.......................................................................២៤

១.២.៣.៥. ការបំពុលដោយកាកសំណល់រឹង រាវ និងវិធានការ ......................................................២៥

## ជំពូកទី២

## ការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារទៅជាទីក្រុងឆ្លាតវៃ

**២.១. ជំហាននៃការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារ**........................................................ ២៨

**២.១.១. ប្លង់គោល**..................................................................................................................... ២៨

២.១.១.១.សញ្ញាណទូទៅនៃប្លង់គោល.......................................................................................... ៣០

២.១.១.២. អត្ថប្រយោជន៍ប្លង់គោល .........................................................................................៣១

២.១.១.៣. ច្បាប់រដ្ឋធម្មនុញ្ញ និងលិខិតបទដ្ឋាន...........................................................................៣២

**២.១.២. ការរៀបចំផែនការសម្រាប់ទីក្រុងរណបជ្រោយចង្វារទៅជាទីក្រុងឆ្លាតវៃ** .......... ៣៣

២.១.២.១. ចរាចរណ៍ឆ្លាតវៃ ...................................................................................................... ៣៤

២.១.២.២. ចំណតឆ្លាតវៃ .......................................................................................................... ៣៥

២.១.២.៣. ភ្លើងបំភ្លឺផ្លូវឆ្លាតវៃ....................................................................................................... ៣៥

២.១.២.៤. ការគ្រប់គ្រងកាកសំណល់ឆ្លាតវៃ.................................................................................. ៣៦

២.១.២.៥. ប្រព័ន្ធកាមេរ៉ាសុវត្ថិភាពឆ្លាតវៃ.................................................................................... ៣៦

**២.១.៣. ហេដ្ឋារចនាសម្ព័ន្ធនៃសំណង់** ........................................................................................ ៣៩

២.១.៣.១. ទំនើបកម្មនៃសំណង់................................................................................................. ៣៩

២.១.៣.២. ប្រណីតភាពនៃហេដ្ឋារចនាសម្ព័ន្ធ..................................................................................៤១

២.១.៣.៣. ប្រណីតភាពនៃទំនើបកម្មសម្រាប់ការរស់នៅ....................................................................៤២
**២.២. សកម្មភាពអាទិភាពនៃការអភិវឌ្ឍទីក្រុងរណបក្រោយចទ្វារ**.......................... ៤៣
**២.២.១. សកម្មភាពអាទិភាពក្នុងវិស័យរៀបចំផែនការអភិវឌ្ឍទីក្រុង**............................... ៤៣
**២.២.២. សកម្មភាពអាទិភាពក្នុងវិស័យភាពងាយរងគ្រោះរបស់ទីក្រុង**............................. ៤៤
**២.២.៣. សកម្មភាពអាទិភាពក្នុងវិស័យដឹកជញ្ជូន** .............................................................. ៤៥
**២.២.៤. សកម្មភាពអាទិភាពក្នុងវិស័យបរិស្ថានសំណង់** ...................................................... ៤៥
**២.២.៥. សកម្មភាពអាទិភាពនៅក្នុងវិស័យអភិវឌ្ឍន៍ទីធ្លាសាធារណៈ និងបេតិកភណ្ឌវប្បធម៌** ............................................................................................................................៤៦
**សេចក្តីសន្និដ្ឋាន** ............................................................................................................... ៤៧
**អនុសាសន៍** .......................................................................................................................៤៨
**ឯកសារយោង**
**អនុសាសន៍**

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហា៖

ប្រទេសកម្ពុជាគឺជាប្រទេសមួយស្ថិតក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានព្រំប្រទល់ជាប់ជាមួយប្រទេសថៃ ឡាវ វៀតណាម និងមីយ៉ាន់ម៉ា ជាមួយគ្នានេះផងដែរប្រទេសកម្ពុជាក៏ធ្លាប់ឆ្លងកាត់នូវសង្គ្រាមរ៉ាំរ៉ៃជាច្រើនឆ្នាំ ដែលនាំឱ្យមានខូចខាតជាច្រើននូវហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ជាពិសេសបាត់បង់នូវធនធានមនុស្សផងដែរ។ យ៉ាងណាមិញបន្ទាប់ពីទទួលបាននូវសុខសន្តិភាពក្រោមគោលនយោបាយ ឈ្នះ-ឈ្នះ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា យើងសង្កេតឃើញថា ប្រទេសកម្ពុជាកំពុងតែមានការអភិវឌ្ឍរីកចម្រើនលូតលាស់លើគ្រប់វិស័យមិនថារដ្ឋ ឬឯកជន។ កាន់តែពិសេសជាងនេះទៅទៀត យើងឃើញថាវិស័យផ្សេងៗជាច្រើន ត្រូវបានរីកចម្រើនគួបផ្សំជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធគមនាគមន៍ សាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ វត្តអារាម គ្រឹះស្ថានស្ថាប័នរដ្ឋ និងគ្រឹះស្ថានឯកជន ព្រមទាំងសំណង់លំនៅឋានផ្សេងៗជាច្រើនបានរីករាលដាលជាបន្តបន្ទាប់នៅក្នុងដំណាក់កាលប្រមាណ ១៥ឆ្នាំចុងក្រោយនេះ។ ទន្ទឹមជាមួយគ្នានេះផងដែរ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានគិតគូរយ៉ាងយកចិត្តទុកដាក់បំផុតសម្រាប់ការរស់នៅ ជាពិសេសគឺការអភិវឌ្ឍនៅតំបន់ផ្សេងៗមិនថាទីក្រុង ឬទីជនបទក្នុងគោលបំណងដើម្បីបំពេញបាននូវតម្រូវការនៃការរស់នៅរបស់ប្រជាជនឱ្យកាន់តែប្រសើរឡើងជាមួយនឹងទំនើបកម្មនៃការរស់នៅ និងសោភណ្ឌភាពនៃទីក្រុង។

ខណៈពេលដែលប្រទេសកម្ពុជាស្ថិតក្នុងដំណាក់កាលជាប្រទេសកំពុងអភិវឌ្ឍ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំយកចិត្តទុកដាក់អភិវឌ្ឍន៍លើគ្រប់វិស័យ។ នៅក្នុងនោះផងដែរ ដើម្បីបង្កលក្ខណៈងាយស្រួលនៅក្នុងការអភិវឌ្ឍ រាជរដ្ឋាភិបាលបានដើរតួនាទីសំខាន់ក្នុងការរៀបចំការអភិវឌ្ឍលើគ្រប់វិស័យ ព្រមទាំងរៀបចំសណ្ដាប់ធ្នាប់ និងសោភណ្ឌភាពបរិស្ថាន ដែលកត្តាទាំងនោះគឺផ្ដោតសំខាន់ទៅលើបរិស្ថានទីក្រុងគ្មានការបំពុលផ្សេងៗសម្រាប់ការរស់នៅរបស់ប្រជាជន បូករួមទាំងសណ្ដាប់ធ្នាប់ល្អ សន្តិសុខ និងសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុង និងនៅក្នុងតំបន់ ជាពិសេសគឺទទួលបាននូវទំនើបកម្មនៃការរស់នៅសម្រាប់ប្រជាជននៅក្នុងតំបន់ជ្រោយចង្វារនោះផ្ទាល់តែម្ដង។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ៖

ដើម្បីឱ្យទទួលបាននូវលក្ខណៈស៊ីជម្រៅ ក៏ដូចជាភាពកាន់តែច្បាស់លាស់បន្ថែមទៀតនោះលើប្រធានបទសារណាខាងលើ យើងខ្ញុំទាំងពីរនាក់បានលើកឡើងនូវចំណោទបញ្ហាដើម្បីធ្វើការបកស្រាយដែលបញ្ហាទាំងអស់នោះរួមមាន៖ តើបុព្វហេតុអ្វីខ្លះដែលអាចធ្វើឱ្យការអភិវឌ្ឍទីក្រុងជ្រោយចង្វារទៅជាទីក្រុងឆ្លាតវៃជាមួយនឹងកត្តារួមផ្សំអ្វីខ្លះ? ម្យ៉ាងវិញទៀត តើគួរធ្វើយ៉ាងណាដើម្បីឱ្យការរៀបចំទីក្រុងរណបជ្រោយចង្វារនេះទទួលបាននូវលក្ខណៈល្អប្រសើរក៏ដូចជាមានភាពរីកចម្រើននៃការភិវឌ្ឍដើម្បីឱ្យតំបន់នោះក្លាយជាទៅទីក្រុងឆ្លាតវៃ?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

គោលបំណងក្នុងការកំណត់យកប្រធានបទទាក់ទងនឹងនីតិនគរូបនីយកម្មដែលស្ដីអំពី **ការរៀបចំទីក្រុងរណបជ្រោយចង្វារទៅជាទីក្រុងឆ្លាតវៃ** យកមកសរសេរជាប្រធានបទសម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ គឺមានគោលបំណងចង់បង្ហាញអំពីសក្ដានុពលនៃការអភិវឌ្ឍរបស់ខណ្ឌជ្រោយចង្វារ ពីព្រោះនាពេលបច្ចុប្បន្ននេះយើងឃើញថាទីក្រុងរណបជ្រោយចង្វារគឺបាននឹងកំពុងតែទាក់ទាញនូវការវិនិយោគជាច្រើន ក្នុងនោះផងដែរ មិនថាហេដ្ឋារចនាសម្ព័ន្ធ សំណង់អគារទំនើបៗ លំនៅឋានប្រណីតៗ ផ្សារ សាលារៀន មន្ទីរពេទ្យក៏ដូចជាកន្លែងកំសាន្តផ្សេងៗ សុទ្ធតែមានលក្ខណៈស្តង់ដារជាតិ និងអន្តរជាតិដែលអាចបម្រើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នោះកាន់តែមានភាពប្រសើរឡើង។

បន្ថែមពីនេះទៅទៀត គោលបំណងនៃការបង្កើតស្នាដៃនៃការសិក្សាស្រាវជ្រាវលើប្រធានបទសារណាមួយនេះ គឺមាននូវគោលបំណងក្នុងការបង្ហាញអំពីការអភិវឌ្ឍប្រកបដោយសក្ដានុពលនៃការរៀបចំទីក្រុងរណបជ្រោយចង្វារឱ្យប្រែក្លាយទៅជាទីក្រុងដែលមានសណ្ដាប់ធ្នាប់ល្អជាមួយនឹងសោភណ្ឌភាពនៅក្នុងទីក្រុង ជាមួយនឹងគុណភាពនៃការរស់នៅរបស់ប្រជាជននៅក្នុងតំបន់ជ្រោយចង្វារជាមួយនឹងការអភិវឌ្ឍលើគ្រប់វិស័យ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ជាការពិតណាស់រាល់ស្នាដៃសិក្សាស្រាវជ្រាវទាំងអស់ គឺសុទ្ធសឹងតែមានគោលបំណងសំខាន់ៗនៅក្នុងកិច្ចការស្រាវជ្រាវនោះ។ យ៉ាងណាមិញ ការសិក្សាស្រាវជ្រាវដែលទាក់ទងនឹងការអភិវឌ្ឍទីក្រុងជ្រោយចង្វារទៅជាទីក្រុងឆ្លាតវៃ គឺយើងខ្ញុំបាទចង់បកស្រាយ និងធ្វើការបង្ហាញនូវលក្ខណៈការអភិវឌ្ឍទីក្រុងជ្រោយចង្វារឱ្យទៅជាទីក្រុងឆ្លាតវៃ តាមរយៈការរៀបចំការអភិវឌ្ឍទៅតាមដំណាក់កាលនីមួយៗដែលស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាលក៏ដូចជាស្តង់ដារ និងប្រណីតភាពនៃការរស់នៅ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវទៅលើអត្ថបទសារណាមួយនេះ គឺមានគោលបំណងសំខាន់ដើម្បីផ្ដល់ជាសារៈប្រយោជន៍ដល់មិត្តនិស្សិត មិត្តអ្នកអាន អ្នកស្រាវជ្រាវ និងសាធារណៈជនទាំងអស់ឱ្យបានយល់ដឹងឱ្យកាន់តែច្បាស់ និងស៊ីជម្រៅអំពីផែនការសកម្មភាពនៃការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារទៅជាទីក្រុងឆ្លាតវៃជាមួយនឹងការអភិវឌ្ឍលើវិស័យផ្សេងៗមិនថាហេដ្ឋារចនាសម្ព័ន្ធ ការវិនិយោគ បច្ចេកទេសនៃការសាងសង់ និងការរៀបចំសំណង់ ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធទាំងអស់ដែលអាចអភិវឌ្ឍន៍ក្លាយជាទីក្រុងឆ្លាតវៃ។ មិនត្រឹមតែប៉ុណ្ណោះ អត្ថបទសារណាមួយនេះក៏បានចូលរួមចំណែកក្នុងការការបង្ហាញនៃការជំរុញឱ្យមាននូវការអភិវឌ្ឍថ្មីៗបន្ថែមទៀតផងដែរ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវចំពោះប្រធានបទសារណាមួយនេះ គឺយើងខ្ញុំបាទទាំងពីរនាក់បានស្វែងរកបណ្ដាឯកសារដែលពាក់ព័ន្ធនឹងប្រធានបទសារណា នៅក្នុងបណ្ណាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាលាខណ្ឌជ្រោយចង្វារ តាមរយៈប្រព័ន្ធអ៊ីនធឺណិត និងគេហទំព័រផ្សេងៗ ដោយក្នុងនោះយើងខ្ញុំបានប្រមូលឯកសារទាំងនោះយកមកវិភាគ និងសរសេរជាសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំបាទទាំងពីរនាក់។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ៖

សារណាបញ្ចប់ការសិក្សារបស់ខ្ញុំបាទទាំងពីរត្រូវបានបែងចែកជា ២ជំពូកគឺ៖

- **ជំពូកទី១ "សញ្ញាណទូទៅនៃការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារ"** ៖ នៅក្នុងជំពូកនេះខ្ញុំបាទនឹងបែងចែកជាពីរចំនុចបន្ថែមទៀត ដោយចំនុចទី១ និយាយអំពីទិដ្ឋភាពទូទៅនៃការរៀបចំទីក្រុងរណបជ្រោយចង្វារ និងចំនុចទី២ បង្ហាញអំពីការរៀបចំទីក្រុងទីក្រុងរណបជ្រោយចង្វារប្រកបទៅដោយស្តង់ដារ។
- **ជំពូកទី២ "ការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារទៅជាទីក្រុងឆ្លាតវៃ"** ៖ នៅក្នុងជំពូកនេះខ្ញុំបាទនឹងបែងចែកជាពីរចំនុចបន្ថែមទៀត ដោយចំនុចទី១ និយាយអំពីជំហាននៃការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារទៅជាទីក្រុងឆ្លាតវៃ និងចំនុចទី២ បង្ហាញអំពីសកម្មភាពអាទិភាពនៃការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារ។

# ជំពូកទី១
# សញ្ញាណទូទៅនៃការ
# អភិវឌ្ឍទីក្រុងរណបក្រោយចទ្វារ

# ជំពូកទី១

# សញ្ញាណទូទៅនៃការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារ

## ១.១. ទិដ្ឋភាពទូទៅនៃការរៀបចំទីក្រុងរណបជ្រោយចង្វារ

ជាបឋមមុននឹងឈានចូលទៅដល់ការរៀបរាប់អំពីការរៀបចំទីក្រុងរណបជ្រោយចង្វារ ក៏ដូចជាការអភិវឌ្ឍផ្សេងៗ យើងខ្ញុំសូមធ្វើការបង្ហាញត្រួសៗអំពីព័ត៌មាននៃខណ្ឌនៅក្នុងរាជធានីភ្នំពេញ ជាពិសេសខណ្ឌជ្រោយចង្វារ។ នៅក្នុងរាជធានីភ្នំពេញមានខណ្ឌចំនួន ១៤ខណ្ឌ និងសង្កាត់ចំនួន ១០៥ ។ ក្នុងចំណោមខណ្ឌទាំង ១៤ នោះ គឺមានខណ្ឌ ២ ដែលទើបបង្កើតថ្មី គឺខណ្ឌបឹងកេងកង និងខណ្ឌកំបូល។ ខណ្ឌថ្មីទាំង២នោះ បានកាត់សង្កាត់មួយចំនួនពីរខណ្ឌផ្សេងៗ ពោលគឺខណ្ឌបឹងកេងកង(ថ្មី)[1] និងខណ្ឌកំបូល(ថ្មី)[2] ។

ជាមួយគ្នានេះផងដែរ ប្រសិនបើយើងឈរនៅប៉ែកខាងលិចនៃមាត់ទន្លេ យើងតែងតែចូលចិត្តសម្លឹងមើលទៅកាន់ត្រើយម្ខាងទៀតនៃទន្លេនៅភាគខាងកើត ឈាងខាងជើងដែលជាតំបន់ជ្រោយចង្វារ ដែលកំពុងតែលូតលាស់យ៉ាងខ្លាំង និងជាផ្នែកដ៏សំខាន់មួយនៃទីក្រុងភ្នំពេញ។ ខណ្ឌជ្រោយចង្វារលាតសន្ធឹងចាប់ពីចន្លោះដងទន្លេមេគង្គ និងទន្លេសាប ទៅដល់តំបន់កោះដាច់ និងកោះឧកញ៉ាតី។

ខណ្ឌជ្រោយចង្វារ គឺជាផ្នែកមួយនៃខណ្ឌឫស្សីកែវ ដែលមានចំនួន ៥ សង្កាត់រួមមាន៖

១. ព្រែកលាប

២. ព្រែកតាសេក

៣. ជ្រោយចង្វារ

៤. បាក់ខែង

៥. កោះដាច់

តំបន់ជ្រោយចង្វាររត់កាត់តាមបណ្ដោយផ្លូវជាតិលេខ៦អា (6A) ដែលជាផ្លូវតភ្ជាប់ដ៏សំខាន់មួយនៅក្នុងតំបន់ពិសេសៗ និងរត់ត្រង់ទៅកាន់ខេត្តសំខាន់ៗដូចជា៖ ខេត្តសៀមរាប ខេត្តកំពង់ធំ និងខេត្តកំពង់ចាម។ ការណែនាំនេះនឹងផ្ដល់ឱ្យអ្នកនូវការយល់ដឹងអំពីស្ថានភាពអចលនទ្រព្យនៅតំបន់ជ្រោយចង្វារ និងអំពីការអភិវឌ្ឍថ្មីៗដែលមាននៅទីនោះ ក៏ដូចជាការរីកលូតលាស់របស់តំបន់នោះទាំងមូល។ ដោយស្ថិតនៅជាផ្នែកមួយនៃទីក្រុងភ្នំពេញ តំបន់ជ្រោយចង្វារគឺជាឈ្មោះនៃខណ្ឌមួយរបស់ទីក្រុងភ្នំពេញ និងជាឧបទ្វីបមួយស្ថិតនៅចន្លោះទន្លេសាប និងទន្លេមេគង្គប៉ែកខាងជើង ឈាងខាងកើតនៃរាជធានីភ្នំពេញ។ តំបន់ជ្រោយចង្វារនេះត្រូវបានពុះចែកពីតំបន់កណ្ដាលរាជធានីភ្នំពេញដោយទន្លេ។ ប៉ុន្តែតំបន់នេះត្រូវបានភ្ជាប់ទៅកណ្ដាលទីក្រុងដោយស្ពានមួយគូ គឺស្ពាន

[1] អនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្ដីពីការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ

[2] អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្ដីពីការបង្កើតខណ្ឌកំបូល នៃរាជធានីភ្នំពេញ

មិត្តភាពកម្ពុជា-ចិន និងស្ពានមិត្តភាពកម្ពុជា-ជប៉ុន ដែលស្ពានទាំងពីរនេះជាផ្នែកមួយដ៏សំខាន់ដែលជួយជំរុញដល់ការអភិវឌ្ឍនៅក្នុងតំបន់នេះ។ ស្ពានមិត្តភាពកម្ពុជា-ជប៉ុននេះ បានសាងសង់តាំងពីទសវត្សឆ្នាំ ១៩៦០ និងបានធ្វើការជួសជុលឡើងវិញម្តងទៀតកាលពីដើមឆ្នាំ២០១៩ ។[3]

### ១.១.១. បរិបទទូទៅនៃតំបន់ទីក្រុងរណបជ្រោយចង្វារ

#### ១.១.១.១. និយមន័យ

**អភិវឌ្ឍ** (កិ.) (បា.) (អៈភិវ័ត) ចម្រើនក្រៃលែង, លូតលាស់ច្រើន។ អភិវឌ្ឍន ឬ អភិវឌ្ឍន៍ ន. សេចក្តីចម្រើនក្រៃលែង។ អភិវឌ្ឍនភាព ភាពនៃសេចក្តីចម្រើន។ អភិវឌ្ឍនាការ អាការនៃអភិវឌ្ឍន៍។[4]

**ទីក្រុង** សំដៅដល់ទីកន្លែងមួយដែលមិនមានសកម្មភាពកសិកម្ម។ លក្ខណៈវិនិច្ឆ័យផ្សេងៗទៀតអាចរួមបញ្ចូលទាំងចំនួនប្រជាជន ទីធ្លាទំនេរ ដង់ស៊ីតេ ប្រជាជន និងចរន្តការនៃសេដ្ឋកិច្ច។[5]

**ទីក្រុង** សំដៅដល់នគរ រាជធានី បុរី។[6]

**ទីក្រុងឆ្លាតវៃ** គឺសំដៅដល់ការអភិវឌ្ឍទីក្រុងដែលប្រកបដោយភាពវៃឆ្លាតដែលមាននិរន្តរភាពប្រកដោយបច្ចេកវិទ្យាជាចម្បង ដើម្បីដោះស្រាយផលប៉ះពាល់ពីការរីកចម្រើនដ៏ឆាប់រហ័សនៃការធ្វើនគរូបនីយកម្មដូចជា៖ ការកកស្ទះចរាចរណ៍ គុណភាពទឹក ខ្យល់ សន្តិសុខ និងសុវត្ថិភាពជាដើម។[7]

#### ១.១.១.២. ទីតាំងនៃតំបន់ជ្រោយចង្វារ

តំបន់ជ្រោយចង្វារត្រូវបានបង្កើតឡើងនៅក្នុងរាជធានីភ្នំពេញដោយកាត់យកសង្កាត់ចំនួន០៥ ចេញពីខណ្ឌឫស្សីកែវនៃរាជធានីភ្នំពេញរួមមាន៖ សង្កាត់ជ្រោយចង្វារ សង្កាត់ព្រែកលាប សង្កាត់ព្រែកតាសេក សង្កាត់បាក់ខែង និងសង្កាត់កោះដាច់។ ព្រំប្រទល់រដ្ឋបាលខណ្ឌជ្រោយចង្វារត្រូវបានកំណត់ដូចមានចែងក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។[8] ទីតាំងសាលាខណ្ឌជ្រោយចង្វារស្ថិតនៅសង្កាត់ព្រែកលាប។[9]

ជាមួយគ្នានេះផងដែរ ការរៀបចំរចនាសម្ព័ន្ធ ព្រមទាំងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃខណ្ឌជ្រោយចង្វារ ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។[10]

---

[3] គេហទំព័រ https://www.realestate.com.kh/km/location-profiles/the-ultimate-guide-to-chroy-changvar/ ដកស្រង់ថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០២០

[4] វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត

[5] សៀវភៅ នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១

[6] វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត

[7] គេហទំព័រ https://www.postkhmer.com ដកស្រង់ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០

[8] មាត្រា១ នៃអនុក្រឹត្យលេខ ៥៧៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី ការបង្កើតខណ្ឌជ្រោយចង្វារនៃរាជធានីភ្នំពេញ

[9] មាត្រា២ នៃអនុក្រឹត្យលេខ ៥៧៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី ការបង្កើតខណ្ឌជ្រោយចង្វារនៃរាជធានីភ្នំពេញ

[10] មាត្រា៣ នៃអនុក្រឹត្យលេខ ៥៧៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី ការបង្កើតខណ្ឌជ្រោយចង្វារនៃរាជធានីភ្នំពេញ

### ១.១.១.៣. កម្មវត្ថុនៃការរៀបចំទីក្រុងរណបជ្រោយចង្វារ

ជាការពិតណាស់ក្រោមការដឹកនាំដោយឆ្លាតវៃរបស់រាជរដ្ឋាភិបាលកម្ពុជា បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិប្រកបដោយទៅដោយភាពរីកចម្រើនលើគ្រប់វិស័យ។ ជាមួយគ្នានេះផងដែរ កម្មវត្ថុដែលជាគោលបំណងយ៉ាងសំខាន់ក្នុងការរៀបចំទីក្រុងរណបជ្រោយចង្វារគឺមានទិសដៅ និងឥទ្ធិពលយ៉ាងខ្លាំងសម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋដែលមានបំណងចង់រស់នៅក្នុងតំបន់នោះផងដែរ។

ជាមួយគ្នានេះផងដែរ តំបន់ជ្រោយចង្វារគឺពិតជាមានសក្តានុពលខ្លាំងទៅលើសេដ្ឋកិច្ចសម្រាប់ប្រទេសកម្ពុជាទាំងមូល បានន័យថាទីក្រុងរណបជ្រោយចង្វារនឹងក្លាយជាទីក្រុងមួយប្រកបទៅដោយភាពរីករាយ និងរីកចម្រើនលើគ្រប់វិស័យដោយសារតែតំបន់នេះមានទីតាំងអំណោយផលសម្រាប់ការវិនិយោគ និងសម្រាប់ការរស់នៅប្រកបដោយប្រណីតភាព និងការរីកចម្រើនលូតលាស់ផ្សេងៗដែលកើតចេញពីទំនើបកម្មនៃការអភិវឌ្ឍនាពេលពេលបច្ចុប្បន្ន។ មិនត្រឹមតែប៉ុណ្ណោះការរៀបចំទីក្រុងរណបជ្រោយចង្វារ គឺបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែមានភាពរីកចម្រើនឡើង ព្រោះដោយហេតុថាទីក្រុងរណបមួយនេះនឹងក្លាយជាគោលដៅសេដ្ឋកិច្ចសម្រាប់វិនិយោគធំៗជាច្រើនមិនថាផ្នែកសំណង់ អគារ ការរស់នៅ ក៏ដូចជាការកំសាន្តទេសចរណ៍ជាដើម ជាមួយនឹងទីតាំងតំបន់ដែលអំណោយផលយ៉ាងខ្លាំង។

ស្របពេលជាមួយគ្នានេះផងដែរយើងក៏សង្កេតឃើញថាបច្ចុប្បន្ននេះ ទីក្រុងរណបជ្រោយចង្វារគឺពិតជាកំពុងអភិវឌ្ឍយ៉ាងសស្រាក់សស្រាំ ជាពិសេសលើការវិនិយោគដូចជាសំណង់អគារធំៗជាច្រើនដូចជា ខុនដូ អគារពាណិជ្ជកម្ម ផ្សារទំនើប កន្លែងកំសាន្ត ទីធ្លាសួនច្បារជាច្រើនបានកើនឡើង និងរីករាលដាលដូចផ្សិត។ បន្ថែមពីនេះទៅទៀតផងដែរ អគារដែលជាលំនៅឋានប្រណីតរបស់ក្រុមហ៊ុនវិនិយោគជាច្រើនបានបោះទុន និងកំពុងដំណើរការសាងសង់ជាច្រើនដែលលក្ខណៈទាំងអស់នេះហើយ បានបង្កជាភាពងាយស្រួលសម្រាប់បម្រើដល់ការរស់នៅរបស់ប្រជាជន នៅក្នុងតំបន់ជ្រោយចង្វារផ្ទាល់តែម្តង។ ដោយមើលឃើញពីសក្តានុពល ក៏ដូចជាភាពរីកចម្រើនបែបនេះហើយទើបរាជរដ្ឋាភិបាលកម្ពុជាបានខិតខំបន្ថែមទៀត ដើម្បីអភិវឌ្ឍនូវតំបន់នេះក៏ដូចជាតំបន់ផ្សេងៗនៅក្នុងប្រទេសកម្ពុជាដើម្បីទទួលបាននូវភាពល្អប្រសើរសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិឱ្យកាន់តែមានភាពរីកចម្រើន។

ជាពិសេសជាងនេះទៅទៀត កម្មវត្ថុសំខាន់នៅក្នុងការរៀបចំទីក្រុងរណបជ្រោយចង្វារនេះគឺមានភាពសមស្របទៅនឹងចក្ខុវិស័យនៅឆ្នាំ ២០៣០ របស់ទីក្រុងរណបនៅក្នុងទីក្រុងភ្នំពេញដែលនឹងក្លាយទៅជាទីក្រុងបៃតង និងប្រកបទៅដោយការប្រកួតប្រជែងដែលផ្តល់នូវការរស់នៅមានសុវត្ថិភាព និងមានគុណភាពដល់ប្រជាជនហើយមានគោលដៅដូចជាៈ

- ធ្វើឱ្យមានកំណើនសេដ្ឋកិច្ចដោយមិនប៉ះពាល់ដល់បរិស្ថាន

- បង្កើនសមាហរណកម្មក្នុងសង្គម កាត់បន្ថយភាពក្រីក្រ និងការកែលម្អសុខភាពទីក្រុង
- ប្រជាពលរដ្ឋទាំងអស់នៅក្នុងទីក្រុងមានភាពបន្សាំទៅនឹងហានិភ័យធម្មជាតិផ្សេងទៀត
- ផ្ដល់ភាពប្រកួតប្រជែង និងភាពទាក់ទាញនៅទីក្រុងដល់កិច្ចការជំនួញ
- ធ្វើឱ្យមានកំណើនសេដ្ឋកិច្ចដោយមិនប៉ះពាល់ដល់បរិស្ថាន
- ពង្រឹងបរិយាបន្នសង្គម[11] និងបង្កើនសុខមាលភាពទីក្រុង។[12]

### ១.១.២. មូលហេតុដែលនាំឱ្យមានការរៀបចំទីក្រុងរណបប្រោយចន្ទារ

ដោយសារតែមានដំណើរវិវត្តឥតឈប់ឈរសម្រាប់ការអភិវឌ្ឍប្រទេសពីមួយទស្សវត្ស ទៅមួយទស្សវត្សបាននាំមកនូវការផ្លាស់ប្ដូរយ៉ាងខ្លាំងក្លា និងឆាប់រហ័សបំផុតនៃបែបផែនសម្រាប់ការរស់នៅ ក៏ដូចជាបរិបទនៃការរស់នៅរបស់មនុស្សពីមួយជំនាន់ទៅមួយជំនាន់។ ដំណើរវិវត្តនេះបាននាំមកនូវភាពជឿនលឿនល្អប្រសើរ ក៏ដូចជាផ្ដល់នូវភាពងាយស្រួលដែលអាចបម្រើទៅដល់ការរស់នៅរបស់មនុស្សជាតិ និងធ្វើឱ្យមានគុណភាពនៃការរស់នៅ។ ទន្ទឹមនឹងវឌ្ឍនៈភាពនេះ វាក៏បានចោទជាបញ្ហារាប់រយរាប់ពាន់ជំពូកដែលអ្នកដឹកនាំ ឬអ្នកគ្រប់គ្រងរដ្ឋត្រូវតែដោះស្រាយឱ្យខានតែបាន។ ដើម្បីដោះស្រាយនូវចំណោទបញ្ហាទាំងអស់នោះ គឺរដ្ឋចាំបាច់ត្រូវតែមាននូវការរៀបចំក្រុង ចំណែកឯការរៀបចំក្រុងទៀតសោត គឺត្រូវធ្វើឡើងដោយសិក្សាសំខាន់ទៅលើទ្រឹស្ដី ឬវិធានដែលស្ដីពីនគរូបនីយកម្ម ក៏ដូចជាផ្អែកទៅលើមូលដ្ឋានគ្រឹះ ចំណេះដឹង និងបទពិសោធន៍ទើបប្រទេសជាតិទទួលបាននូវភាពរីកចម្រើនលើគ្រប់វិស័យ។ ការរៀបចំក្រុងទៀតសោត ចាំបាច់ត្រូវធ្វើឡើងដោយមាននូវការគិតគូរហ្មត់ចត់សព្វជ្រុងជ្រោយ ដូច្នេះហើយនៅក្នុងការកកើតនូវទីក្រុងមួយមិនមែនកើតឡើងដោយចៃដន្យនោះទេ តែវាកើតឡើងដោយសារមូលហេតុចម្បងៗដែលមានដូចជា៖ កំណើនប្រជាជន ភាពក្រីក្រ ស្តង់ដារនៃការរស់នៅ និងការដាក់សម្ពាធបរិស្ថាន។

### ១.១.២.១. កំណើនប្រជាជន

ជាទូទៅមាននូវសមាសភាពនៃកំណើនប្រជាជនក្នុងទីក្រុង៣សំខាន់រួមមាន៖ កំណើនប្រជាជននៅក្នុងទីក្រុងជាលក្ខណៈធម្មជាតិ កំណើនដោយសារមានចំណាកស្រុកពីទីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋាននៃក្រុងថ្មី ដែលពីមុនតំបន់នេះជាទីជនបទប៉ុណ្ណោះ។ កំណើនប្រជាជននៅក្នុងទីក្រុងជាលក្ខណៈធម្មជាតិបានធ្វើឱ្យមានកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន ចំណែកឯកំណើនដោយសារ

[11] បរិយាប័ន្នសង្គម(Social Inclusion) គឺជាការគិតគូពីបញ្ហាសង្គមបានគ្រប់ជ្រុងជ្រោយ នៅក្នុងការធ្វើសេចក្ដីសម្រេចចិត្តនានារបស់ថ្នាក់ដឹកនាំ ឬអ្នកធ្វើគោលនយោបាយនៅលើគ្រប់វិស័យទាំងអស់ដែលពាក់ព័ន្ធ។

[12] ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តភាពសម្រាប់រាជធានីក្រុងភ្នំពេញ ២០១៨-២០៣០ ទំព័រទី៥

មានចំណាកស្រុកពីទីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋានដីនៃទីក្រុងថ្មី ដែលពីមុនមកតំបន់នេះជាទីជនបទគ្រាន់តែជាធាតុចូលបន្ទាប់បន្សំតែប៉ុណ្ណោះ។

❖ **កំណើនប្រជាជននៅថ្ងៃអនាគត**

ចំនួនប្រជាជនពិភពលោក បានកើនឡើងដល់ចំនួន ៦,១ពាន់លាននាក់ ក្នុងពាក់កណ្ដាលឆ្នាំ២០០០ទៅហើយ ដោយឡែកបច្ចុប្បន្នកំពុងតែកើនឡើងជាមធ្យមចំនួន ៧,៧លាននាក់ក្នុងមួយឆ្នាំ។ នៅក្នុងឆ្នាំ២០២៥ ខាងមុខចំនួនប្រជាជននៅក្នុងពិភពលោកនឹងមានការកើនឡើងខ្លាំងចន្លោះពីចំនួន ៧,៩ ទៅ ១០,៩លាននាក់[13] និងកើនដល់ ៨,២៦៧លាននាក់ ក្នុងឆ្នាំ២០៥០នៃតំបន់ក្រុង។[14] បើទោះបីជាមាននូវប្រទេសមួយចំនួនដែលបានលេចចេញនូវអត្រិភាពនៃអត្រាមរណភាពខ្ពស់ដោយសារតែជម្ងឺអេដស៍ក៏ដោយ ក៏កំណើនប្រជាជននៅតែខ្ពស់ដដែល។ ជាមួយគ្នានេះផងដែរ ចំនួនប្រជាជននៅក្នុងប្រទេសអភិវឌ្ឍនាពេលបច្ចុប្បន្ននេះ គឺមិនត្រូវបានគេរំពឹងថានឹងកើនឡើងក្នុងរយៈពេល៥០ឆ្នាំខាងមុខ ដែលនេះជាហេតុផលគឺដោយសារតែកម្រិតនៃការមានកូនគឺត្រូវដាក់ឱ្យស្ថិតក្រោមកម្រិតកំណត់មួយជាក់លាក់។ ផ្ទុយទៅវិញចំនួនប្រជាជនក្នុងប្រទេសកំពុងអភិវឌ្ឍន៍ត្រូវបានព្យាករណ៍ថានឹងមានចំនួនកើនឡើងពី៤,៩ពាន់លាននាក់។ នៅក្នុងឆ្នាំ២០០០ ដែលនឹងមានការកើនឡើងដល់ ៨,២លាននាក់នៅក្នុងឆ្នាំ២០៥០។ កំណើនយ៉ាងឆាប់រហ័សនេះ ត្រូវបានគេរំពឹងថានឹងកើនឡើងក្នុងចំណោមក្រុមប្រទេសអភិវឌ្ឍន៍ចំនួន ៤៨ប្រទេស ដែលចំនួនប្រជាជនរបស់ពួកគេត្រូវបានរំពឹងថា នឹងមានការកើនឡើងជិតបីដងក្នុងរយៈពេល៥០ឆ្នាំខាងមុខនេះ។ ចំណែកឯរឿងដែលទាក់ទងនឹងអន្តោប្រវេសន៍អន្តរជាតិវិញក៏ត្រូវបានព្យាករណ៍ថាក៏នឹងមានកំណើនផងដែរ រួមទាំងដង់ស៊ីតេប្រជាជនខ្ពស់នៅក្នុងសតវត្សទី២១នេះផងដែរ។[15]

### ១.១.២.២. ភាពក្រីក្រ

ការកំណត់អំពីស្ថានភាពក្រីក្រ គឺមានការលំបាកនៅក្នុងការកំណត់ណាស់ ដែលជាទូទៅភាពក្រីក្រគឺសម្ដៅដល់តម្រូវការរបស់មនុស្សមិនត្រូវបានបំពេញគ្រប់គ្រាន់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ជារួមមានប្រទេសជាច្រើនបានកំណត់អំពីភាពក្រីក្រតាមរយៈប្រាក់ចំណូលទាប ដែលពួកគេមិនអាចចាយវាយបានគ្រប់គ្រាន់នៅក្នុងស្ថានភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ នៅក្នុងនោះផងដែរ មានតម្រូវការជាច្រើនសម្រាប់ពួកគេដូចជា តម្រូវការរូបកាយ ចំណីរអាហារ លំនៅឋាន ការងារ ធនធានទឹក អគ្គិសនី អនាម័យ សុខុមាលភាពនៃសង្គម គឺនៅ

[13] សៀវភៅ នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី៥-៦

[14] សៀវភៅការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទំព័រទី១៥

[15] សៀវភៅ នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី៥-៦

មានកង្វះខាតច្រើន។ លើសពីនេះទៅទៀត សិទ្ធិសេរីភាពផ្នែកស្មារតីនិយាយជារួម និងដោយឡែកសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅមានកម្រិតនៅឡើយ។

ការសម្គាល់ពីភាពក្រីក្រត្រូវបានសង្កត់ធ្ងន់ទៅលើចំណូលទាបរបស់បុគ្គលម្នាក់ៗពីព្រោះតែបញ្ហាផ្សេងៗ ដូចជា៖ ចំនួនករណីឧក្រិដ្ឋកម្ម អំពើហិង្សា ឬអាយុសង្ឃឹមរស់ជាមធ្យមមិនអាចយកមកជំនួសដោយការវាស់ស្ទង់តាមរយៈប្រាក់ចំណូលនេះឡើយ ដែលជាធម្មតាអ្នកទទួលបានប្រាក់ចំណូលក្រោមមធ្យមត្រូវបានគេសន្មត់ថាជាជនក្រីក្រ។ យ៉ាងហោចណាស់ជាង ២០ភាគរយនៃចំនួនប្រជាជនក្នុងពិភពលោករស់នៅក្នុងបន្ទាត់នៃភាពក្រីក្រ ហើយចំនួន ៩០ភាគរយ ក្នុងចំនួននោះស្ថិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

❖ **ភាពក្រីក្រនៅតាមជនបទ**

ស្ថិតនៅក្នុងបរិបទនៃបច្ចុប្បន្នភាព ស្ថានភាពក្រីក្រនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មានការកើនឡើងជាលំដាប់ ដែលកំណើននេះអាស្រ័យដោយស្ថានភាពសេដ្ឋកិច្ចសង្គម ប្រជាសាស្ត្រ ភូមិសាស្ត្រនយោបាយ គ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ និងកង្វះដីបង្កបង្កើនផលជាដើម។ ភាពក្រីក្រនៅតាមទីជនបទនាំឱ្យមានការចំណាកស្រុកទៅទីក្រុង ហើយចរន្តការនេះនឹងកើនឡើងនៅពេលស្ថានភាពនៅតំបន់ជនបទកាន់តែលំបាកទៅៗ។ ដូចនេះការបង្កើនសកម្មភាពសេដ្ឋកិច្ចនៅទីជនបទ គឺជាវិធីសាស្ត្រមួយដ៏មានប្រសិទ្ធភាពបំផុតដើម្បីគ្រប់គ្រង ក៏ដូចជាការកាត់បន្ថយចំណាកស្រុកពីទីជនបទទៅទីក្រុងផងដែរ។

❖ **ភាពក្រីក្ររបស់ទីក្រុង**

ជាទូទៅពុំមាននូវលក្ខណៈសមភាពទេកាលណាគេធ្វើការប្រៀបធៀបពីភាពក្រីក្រដោយដាក់បន្ទាត់មួយក្រិតឱ្យស្មើគ្នានោះ យើងអាចលើកជាឧទាហរណ៍ថា ការប្រើប្រាស់ថវិកាមួយដុល្លារសហរដ្ឋអាមេរិកដូចគ្នា តែបុគ្គលម្នាក់នៅទីជនបទ ចំណែកបុគ្គលម្នាក់ទៀតនៅទីក្រុងច្បាស់ណាស់ថាវាមិនស្មើគ្នា ជាចម្លើយគឺធម្មតាការចំណាយនៅទីក្រុងគឺខ្ពស់ជាងទីជនបទដាច់ស្រយាលឆ្ងាយណាស់។ ស្របពេលជាមួយគ្នានេះផងដែរ សម្រាប់អ្នកដែលរស់នៅតាមទីជនបទ អាចមានឱកាសស្វែងរកការងារដើម្បីចិញ្ចឹមជីវិតតាមរយៈការទទួលអំណោយពីភោគផលពីធម្មជាតិជាច្រើនជាងអ្នកនៅទីក្រុង។ តាមរូបភាពនេះផងដែរ អ្នកនៅទីក្រុងក្រជាងនិងមានស្ថានភាពលំបាកជាងអ្នកក្រនៅទីជនបទ។ ដោយឡែកការនិយាយបែបនេះក៏ពុំត្រឹមត្រូវទាំងស្រុងនោះដែរ ដោយហេតុថានៅទីក្រុងមានបរិយាកាសសង្គម អនាម័យសាធារណៈ ដែលអាចជួយឱ្យអ្នកស្ថិតនៅក្នុងស្ថានភាពក្រីក្រអាចមានឱកាសដើរចេញពីស្ថានភាពលំបាកនេះក្នុងកម្រិតខ្ពស់។[16]

[16] សៀវភៅ នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី៦-៧

### ១.១.២.៣. គុណភាពនៃការរស់នៅ

ភាពខុសគ្នានៃស្ថានភាពជីវភាព គឺជាកត្តាចម្បងដែលត្រូវបានគិតគូរនៅពេលមានការពិភាក្សាជុំវិញការជម្រុញឱ្យមានការរៀបចំក្រុង។ កម្រិតជីវភាព និងប្រាក់បៀវត្សន៍ខ្ពស់នៅទីក្រុងជាកត្តាទាក់ទាញមនុស្សឱ្យមករស់នៅទីក្រុងដរាបណាភាពខុសគ្នារវាងទីក្រុង និងទីជនបទដែលមានគម្លាតខ្ពស់ ប្រជាពលរដ្ឋនៅតាមទីជនបទនៅតែចង់ចូលមករស់នៅទីក្រុង។ ជាទូទៅកត្តាសេដ្ឋកិច្ច និងអត្រានិកម្មភាពខ្ពស់ជាងកត្តាជម្រុញចំណាកស្រុកមូលហេតុដោយសារតែពេលខ្លះការងារនៅទីជនបទនៅមានកម្រិត។ ដូច្នេះហើយ ទោះបីជាទទួលបានប្រាក់ខែទាបក៏ត្រូវតែបង្ខំចិត្តធ្វើចំណាកស្រុកមកកាន់ទីក្រុងដែរ។ លើសពីនេះទៅទៀត នៅទីក្រុងមានប្រមូលផ្តុំដោយកត្តាសង្គម នយោបាយល្អប្រសើរស្របជាមួយសេវាសុខាភិបាល និងសេវាអប់រំបែបរឹតតឹងជាមួយគុណភាពដោយផ្សំកត្តាផ្សេងៗ ដែលធ្វើឱ្យអ្នករស់នៅមានអារម្មណ៍ថាមានសុវត្ថិភាពជាងកន្លែងណាៗទាំងអស់នៅក្នុងទីក្រុង។[17]

### ១.១.២.៤. ការដាក់សម្ពាធបរិស្ថាន

សម្ពាធដ៏ធំបំផុតរបស់ប្រជាពលរដ្ឋនៅទីជនបទទាក់ទងនឹងវិស័យបរិស្ថាន គឺកង្វះដីក្នុងការបង្កបង្កើនផលដើម្បីធ្វើកសិកម្ម។ ហេតុការណ៍នេះកើតមានឡើងនៅករណីដែលដីរបស់ពួកគេដែលទទួលបានពីកេរ្តិ៍ដូនតាឪពុកម្តាយរបស់ខ្លួន ត្រូវបានពួកគេចែកឱ្យកូនៗអស់។ ចំណែកឯផ្ទៃដីដែលនៅសល់គឺមានទំហំតូច មិនសមល្មមសម្រាប់អំណោយផលដល់ដីធ្វើកសិកម្ម ឬការបង្កបង្កើនផលសម្រាប់ដំណាំផ្សេងៗបានឡើយ ហើយពេលខ្លះស្ថានភាពដីនោះមានលក្ខណៈខ្សោះ និងគ្មានជីវជាតិទៀតផង។ ប្រសិនបើយើងក្រឡេកទៅមើលមួយជ្រុងទៀតគឺ ចំពោះប្រជាពលរដ្ឋក្រីក្រនៅពេលដែលដីមានគ្រប់គ្រាន់ហើយ តែគាត់បែរជាកង្វះប្រព័ន្ធធារាសាស្ត្រសម្រាប់ធ្វើការស្រោចស្រព និងជីកសិកម្មសម្រាប់បង្កបង្កើនផលបានគ្រប់គ្រាន់ទៅវិញ ដែលករណីនេះច្រើនកើតមាននៅប្រទេសកំពុងអភិវឌ្ឍន៍ក្នុងតំបន់មេគង្គក្រោម។[18]

### ១.១.៣. ឥទ្ធិពលនៃការរៀបចំទីក្រុងរណបជ្រោយចង្វារ

ស្ថិតក្រោមការដឹកនាំប្រកបដោយការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលកម្ពុជា កន្លងមករហូតមកដល់បច្ចុប្បន្នយើងសង្កេតឃើញថា ប្រទេសកម្ពុជាមានរីកចម្រើនលើគ្រប់វិស័យដែលជាកត្តានាំឱ្យប្រទេសកម្ពុជាយើងមានមុខមាត់លើឆាកអន្តរជាតិ ក៏ដូចជាប្រទេសជាតិមានភាពលូតលាស់ទាំងផ្នែកសេដ្ឋកិច្ច និងសន្តិភាពផងដែរ។ ជាការពិតណាស់ស្ថិតនៅក្នុងបរិបទបែបនេះហើយ ទើបយើងឃើញថាវិស័យសំខាន់ៗជាច្រើនបានរីករាលដាលដុះដូចផ្សិត ដែលជាកត្តាបណ្តាលឱ្យមានភាពងាយស្រួលបម្រើដល់ការរស់នៅរបស់ប្រជាជននៅគ្រប់លំដាប់

[17] សៀវភៅ នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី៧

[18] សៀវភៅ នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី៧-៨

ថ្នាក់ឱ្យកាន់តែមានភាពល្អប្រសើរឡើងសម្រាប់ការរស់នៅរបស់ប្រជាជន រាប់បញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធ ប្រណីតភាព ទំនើបកម្ម និងគុណភាពនៃការរស់នៅ ជាមួយនឹងភាពងាយស្រួលផ្សេងៗដែលកើតចេញពីការអភិវឌ្ឍក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល។

**១.១.៣.១. គមនាគមន៍**

ការអភិវឌ្ឍមួយដែលច្បាស់លាស់ត្រូវបានធ្វើឡើងដោយធ្វើការពង្រីកទំហំទីក្រុង និងការរៀបចំប្រព័ន្ធគមនាគមន៍។[19] ជាមួយគ្នានេះ តំបន់ទីក្រុងរណបជ្រោយចង្វារនៃរាជធានីភ្នំពេញកំពុងមានការអភិវឌ្ឍក្នុងរាងជារង្វង់តាមបណ្តោយច្រាំងខាងស្តាំទន្លេសាប។ នៅច្រាំងខាងឆ្វេងទន្លេសាបភ្នំពេញត្រូវបានភ្ជាប់ជាមួយនឹងតំបន់ព្រែកលៀប ដែលកាន់តែមានភាពងាយស្រួលបន្ទាប់ពីមានការសាងសង់ស្ពានជ្រោយចង្វារបន្ថែមមួយទៀត។ ក៏ប៉ុន្តែពុំសូវមានសំណង់អគារច្រើននៅឡើយទេ ពីព្រោះពុំមានស្ពានឆ្លងកាត់ទន្លេមេគង្គ។ ការឆ្លងកាត់ដោយនាវាចម្លងដែលកាន់តែមានលក្ខណៈប្រសើរឡើង គឺបានជំរុញឱ្យអ្នករស់នៅក្នុងទីក្រុងសាងសង់ផ្ទះស្នាក់នៅ ឬក៏ផ្ទះសម្រាកកម្សាន្តនៅតំបន់អរិយក្សត្រ ក៏ប៉ុន្តែការអភិវឌ្ឍនៅតែមានឧបសគ្គទោះបីមានការកែលម្អបណ្តាញតភ្ជាប់ដោយសាឡាងក៏ដោយ។

ដើម្បីកាត់បន្ថយភាពកកស្ទះនៅក្នុងទីក្រុង សាលាក្រុងបានលើកទឹកចិត្តឱ្យវិស័យឯកជនធ្វើការអភិវឌ្ឍទីក្រុងរណប បុរី។ គំរូនៃការអភិវឌ្ឍដោយវិស័យឯកជន ដែលបង្កើតឱ្យមានសំណង់បុរី ឬខុនដូ ហ៊ុមព័ទ្ធដោយរបងបិទជិត និងកាត់បន្ថយនូវភាពលាយឡំគ្នានៃក្រុមសង្គម ប៉ុន្តែសំណង់ទាំងនោះត្រូវមានស្តង់ដាររៀបចំក្រុងស្របតាមកម្រិតជីវភាពធូរធារ និងមធ្យម។[20]

តំបន់ជ្រោយចង្វាររត់កាត់ដោយផ្លូវជាតិលេខ៦អា ដែលជាផ្លូវតភ្ជាប់ដ៏សំខាន់មួយនៅក្នុងតំបន់ និងរត់ត្រង់ទៅកាន់ខេត្តសំខាន់ៗមួយចំនួនដូចជា៖ ខេត្តសៀមរាប ខេត្តកំពង់ធំ និងខេត្តកំពង់ចាម។ ដោយស្ថិតនៅជាផ្នែកមួយនៃទីក្រុងភ្នំពេញ តំបន់ជ្រោយចង្វារគឺជាឈ្មោះនៃខណ្ឌមួយរបស់ទីក្រុងភ្នំពេញ និងជាឧបទ្វីបមួយស្ថិតនៅចន្លោះទន្លេសាប និងទន្លេមេគង្គប៉ែកខាងជើងឈាងខាងកើតនៃរាជធានីភ្នំពេញ។ តំបន់ជ្រោយចង្វារត្រូវបានពុះចែកពីតំបន់កណ្តាលរាជធានីភ្នំពេញដោយទន្លេ។ ប៉ុន្តែតំបន់នេះត្រូវបានភ្ជាប់ទៅកណ្តាលទីក្រុងដោយស្ពានមួយគូរ គឺស្ពានមិត្តភាពកម្ពុជា-ចិន និងស្ពានមិត្តភាពកម្ពុជា-ជប៉ុន ដែលស្ពានទាំងពីរជាផ្នែកមួយដ៏សំខាន់ដែលជួយជំរុញដល់ការអភិវឌ្ឍតំបន់នេះ។ ស្ពានមិត្តភាពកម្ពុជា-ជប៉ុន បានសាងសង់តាំងពីទសវត្សឆ្នាំ ១៩៦០ និងបានជួលជុលឡើងវិញម្តងទៀតកាលពីដើមឆ្នាំ២០១៩ ។[21]

[19] សៀវភៅ នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១០

[20] គេហទំព័រ https://www.kfa.com.kh/detailnews.php?id=180 ដកស្រង់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២០

[21] គេហទំព័រ https://www.realestate.com.kh/km/location-profiles/the-ultimate-guide-to-chroy-changvar/ ដកស្រង់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២០

ហើយសាលាខណ្ឌជ្រោយចង្វារ បានធ្វើការចាក់បេតុងផ្លូវសម្តេច ជា ស៊ីម ចាប់ពីស្ពានព្រែកតាសេក ដល់ផ្លូវជាតិលេខ៦ ហើយគម្រោងផ្លូវនេះ ជាប្រភេទផ្លូវបេតុងអារមេ មានប្រវែង ៩០០ម៉ែត្រ ទទឹង ១០ម៉ែត្រ ដែលមានកម្រាស់ ២០សង់ទីម៉ែត្រ ដោយប្រើថវិកាគម្រោងអភិវឌ្ឍន៍ខណ្ឌឆ្នាំ២០១៥។[22]

**១.១.៣.២. បរិស្ថាន**

គុណប្រយោជន៍បរិស្ថានក្នុងការរៀបចំទីក្រុង គឺមិនមានលក្ខណៈដោយផ្ទាល់នោះទេ ពីព្រោះវាមានទំនាក់ទំនងជាមួយនឹងការដឹកជញ្ជូនដែលមានផលប៉ះពាល់ដល់ការរៀបចំទីក្រុង បើទោះបីជាបរិស្ថានមានសារៈសំខាន់យ៉ាងណាក៏ដោយ។ ទំនាក់ទំនងនេះបានបង្ហាញយ៉ាងច្បាស់លាស់ នៅក្នុងរបាយការណ៍ថ្មីមួយដែល ផ្តល់បានជាភស្តុតាងដើម្បីឱ្យយល់ដឹងកាន់តែច្បាស់ ថាតើទំនាក់ទំនងនៃការដឹកជញ្ជូនបានបញ្ចេញឧស្ម័នកាបូនិចច្រើនប៉ុណ្ណា។ ការសិក្សាផ្សេងទៀតបានចង្អុលបង្ហាញថា ការអភិវឌ្ឍតិចតួចអាចធ្វើឱ្យមានប្រយោជន៍ដល់ បរិស្ថាន។ ការអភិវឌ្ឍតិចតួចអាចកាត់បន្ថយការរីកសាយនូវឧស្ម័នផ្ទះកញ្ចក់ និងការប្រើប្រាស់ថាមពល។ ម្យ៉ាងវិញទៀត ការចរាចរណ៍រថយន្តក៏មានការថយចុះដែរ ព្រោះការអភិវឌ្ឍតិចតួចបានធ្វើឱ្យមានភាពងាយស្រួល និងសន្សំសំចៃ និងការការពារចំពោះបរិស្ថាន។[23]

**១.១.៣.៣. គុណភាពការរស់នៅ**

ការរៀបចំទីក្រុងគឺមានសារៈសំខាន់ណាស់សម្រាប់គុណភាពនៃការរស់នៅ ផលប្រយោជន៍សេដ្ឋកិច្ច និងការគ្រប់គ្រងបរិស្ថាន ព្រោះការរៀបចំក្រុងជាវិធីសាស្ត្រដែលល្អបំផុតសម្រាប់បំពេញតម្រូវការនៃការរស់នៅរបស់ប្រជាជនឱ្យមានលក្ខណៈល្អប្រសើរ ក្នុងករណីដែលការរៀបចំក្រុងនោះមានលក្ខណៈស្តង់ដារ និងស្របតាមគោលការណ៍នៃសំណង់។

ជាមួយគ្នានេះផងដែរ ទាក់ទងនឹងការរស់នៅនៅក្នុងតំបន់ជ្រោយចង្វារនេះផងដែរ រដ្ឋាភិបាលបានធ្វើការអភិវឌ្ឍជាបន្តបន្ទាប់នៅក្នុងតំបន់ជ្រោយចង្វារ ដែលបានបង្កលក្ខណៈងាយស្រួលសម្រាប់ការរស់នៅរបស់ប្រជាជនគ្រប់លំដាប់ថ្នាក់។ ស្របពេលជាមួយគ្នានេះផងដែរ ការរស់នៅរបស់ប្រជាជននៅក្នុងតំបន់នោះ គឺសុទ្ធតែពោរពេញទៅដោយទំនើបកម្ម និងភាពទាន់សម័យ ពីព្រោះដោយហេតុថាតំបន់នោះបានទទួលនូវការអភិវឌ្ឍយ៉ាងច្រើនមិនថាហេដ្ឋារចនាសម្ព័ន្ធ ផ្លូវគមនាគមន៍ដែលបង្កឱ្យមានភាពងាយស្រួលសម្រាប់ការរស់នៅ។ បន្ថែមពីនោះទៅទៀត យើងឃើញថាសំណង់អគារជាច្រើនបានកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃគួរឱ្យកត់សម្គាល់តាមរយៈការវិនិយោគរបស់ក្រុមហ៊ុនធំៗជាច្រើនទាំងក្នុង និងក្រៅប្រទេស ដែលបានចូលមកបណ្តាក់ទុនរកស៊ីលើវិស័យអចលនទ្រព្យ និងវិស័យលំនៅឋានដែលបង្កជាភាពងាយស្រួលសម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋ។

---

[22] គេហទំព័រ សាលារាជធានីភ្នំពេញ http://phnompenh.gov.kh/ ដកស្រង់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២០

[23] សៀវភៅ នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១១

ជាមួយនឹងអំណោយផលនៃទីតាំងប្រកបដោយទេសភាពល្អ ពោលគឺទន្លេដែលមាននូវខ្យល់អាកាសបរិសុទ្ធ ជាមួយនឹងការអភិវឌ្ឍលើគ្រប់វិស័យ ដែលធ្វើឱ្យតំបន់នេះក្លាយជាតំបន់មួយដែលមានការរស់នៅប្រកបដោយភាពល្អប្រសើរ និងកាន់តែគួរឱ្យចង់រស់នៅជាទីបំផុត។

## ១.២. ការរៀបចំទីក្រុងទីក្រុងរណបជ្រោយចង្វារប្រកបទៅដោយស្តង់ដារ

បើយោងទៅតាមសៀវភៅរបស់លោកគ្រូសាស្ត្រាចារ្យបណ្ឌិត **អ៊ុន សកក្កដា** បានសរសេរថាក្នុងការរៀបចំក្រុងជាលក្ខណៈពិធីការមួយត្រូវបានឈរក្រោមគោលការណ៍សសរស្តម្ភចំនួន៥គឺ **ផលិតភាព និរន្តភាព ភាពដែលអាចរស់នៅបាន ភាពជាអ្នកដឹកនាំ និងរចនាដ៏ល្អប្រសើរ** ជារួមមានន័យថា ត្រូវធ្វើយ៉ាងណាបង្កើតកន្លែងមួយដែលមាន ផលិតភាព និរន្តភាព និងភាពដែលអាចរស់នៅបានតាមរយៈភាពជាអ្នកដឹកនាំ និងការរួមបញ្ចូលគ្នានៃរចនាបទទីក្រុងមួយដ៏ល្អប្រសើរ។[24] ដូចគ្នានេះផងដែរ ការរៀបចំក្រុងរណបជ្រោយចង្វារទៅជាទីក្រុងដែលប្រកបទៅដោយស្តង់ដារ គឺជាទីក្រុងមួយមានលក្ខណៈគ្រប់គ្រាន់នូវប្រព័ន្ធផ្សេងៗដែលអំណោយផលសម្រាប់ការរស់នៅរបស់ប្រជាជន បានន័យថាមិនថាហេដ្ឋារចនាសម្ព័ន្ធ សំណង់ សោភណ្ឌភាព បរិស្ថាន សន្តិសុខ សណ្តាប់ធ្នាប់គឺមានស្តង់ដារ និងរបៀបរៀបរយស្របតាមគោលនយោបាយនៃការអភិវឌ្ឍរបស់រាជរដ្ឋាភិបាល។ ជាមួយគ្នានេះផងដែរ ការរៀបចំទីក្រុងមួយដែលប្រកបទៅដោយស្តង់ដារ គឺជាទីក្រុងមានសកម្មភាពដែលស្របជាមួយការយកចិត្តទុកខ្ពស់នៅក្នុងការរៀបចំ និងថែរក្សាគុណភាពបរិស្ថានជាមួយនឹងការអភិវឌ្ឍ។

### ១.២.១. ទីក្រុងដែលមានសណ្តាប់ធ្នាប់

ជាគោលការណ៍ទីក្រុងមួយដែលមានសណ្តាប់ធ្នាប់ត្រូវឈរលើគោលការណ៍៣គឺ ៖

- សន្តិសុខ
- ភាពស្ងប់ស្ងៀម
- បរិស្ថាន (អនាម័យ)។[25]

#### ១.២.១.១. សន្តិសុខ

នៅក្នុងសន្តិសុខត្រូវបានកំណត់នៅក្នុងគោលការណ៍សំខាន់ៗ ៣រួមមាន៖ សុវត្ថិភាពបុគ្គល សុវត្ថិភាពសម្ភារៈ និងសុវត្ថិភាពចំណីអាហារ។[26]

---

[24] សៀវភៅ នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១៣

[25] សៀវភៅ នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១

[26] សៀវភៅ នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១

❖ **សុវត្ថិភាពបុគ្គល**

សុវត្ថិភាពបុគ្គល គឺសម្តៅដល់សុវត្ថិភាពរបស់បុគ្គលគ្រប់ៗរូប និងមានសេរីដែលគ្មានការបំពានពីសំណាក់បុគ្គលណាម្នាក់ ដែលនាំបង្កឱ្យមានបញ្ហា ពោលគឺមានសុវត្ថិភាព និងការការពារជូនដល់ប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់។ ជាមួយគ្នានេះផងដែរ គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពក៏បានចូលរួមយ៉ាងសកម្មក្នុងការការពារសុវត្ថិភាពបុគ្គល ហើយគោលនយោបាយនេះលក្ខណៈសម្បត្តិ ៩ យ៉ាង រួមមានៈ

១. គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ

២. គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់គ្រប់ប្រភេទ

៣. គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រីនិងកុមារ និងអំពើហិង្សាក្នុងគ្រួសារ

៤. គ្មានក្មេងទំនើង

៥. គ្មាននូវការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ គ្មានការប្រើប្រាស់អាវុធខុសច្បាប់ និងគ្មាននូវបទល្មើសគ្រប់ប្រភេទ

៦. គ្មានគ្រោះថ្នាក់ចរាចរណ៍

៧. គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

៨. មានវិធានការទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតប ចំពោះគ្រោះមហន្តរាយ ប្រកបដោយ ប្រសិទ្ធិភាព

៩. គ្មានការត្រួតពិនិត្យខុសច្បាប់ ។[27]

បន្ថែមជាមួយគ្នានេះផងដែរ បើតាមទិន្នន័យរបស់ក្រសួងមហាផ្ទៃក៏បានបន្ថែមផងដែរថា តាមលទ្ធផលប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ ឃុំ មានសុវត្ថិភាព» ប្រចាំឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃបានបង្ហាញឱ្យឃើញថាក្នុងចំណោម ឃុំ សង្កាត់ទាំង១២៧ របស់រដ្ឋបាលខេត្តកណ្តាល ទទួលបានចំណាត់ប្រភេទ១ បានចំនួន៥០/៥៧ឃុំ ប្រភេទ២ ទទួលបាន ៦៩/៦១ ឃុំ-សង្កាត់ ចំណាត់ថ្នាក់ប្រភេទ៣ ទទួលបាន ៨/៩ឃុំ និងគ្មានចំណាត់ថ្នាក់ មានចំនួន 0/0ឃុំ។

ទោះបីជាទទួលបានលទ្ធផលគួរជាទីមោទនៈក៏ពិតមែន ប៉ុន្តែការប្រព្រឹត្តទៅនៃចលនាអនុវត្តគោលនយោបាយ "ភូមិ-ឃុំមានសុវត្ថិភាព" នៅមានបញ្ហាប្រឈមជាច្រើនដែលពាក់ព័ន្ធដល់ការងារពង្រឹងតួនាទីដឹកនាំការផ្សព្វផ្សាយគោលនយោបាយ "ភូមិ-ឃុំមានសុវត្ថិភាព" ការកសាងកំលាំងប្រជាការពារ ការរៀបចំវេទិការសាធារណៈ ពិសេសការបំផុសចលនាប្រឡងប្រណាំងនៅមិនទាន់ស៊ីជំរៅ មានលក្ខណៈស្មុគស្មាញ និងបន្ទុក

[27] គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព

ការងារកាន់តែច្រើន។ ដូចនេះគណៈបញ្ជាការឯកភាពក្រុង-ស្រុក កងកម្លាំងមានសមត្ថកិច្ច ព្រមទាំងមាននូវអាជ្ញាធរពាក់ព័ន្ធត្រូវបន្តប្រកាន់ខ្ជាប់នូវទស្សនៈ «ភូមិ-ឃុំ មានសុវត្ថិភាព» ជាភារកិច្ចសំខាន់សម្រាប់កិច្ចការប្រចាំថ្ងៃរបស់ខ្លួន។ ត្រូវបង្កើនការប្រមូលផ្តុំដឹកនាំក្នុងមូលដ្ឋានឱ្យចូលរួមសកម្ម ក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ តាមរយៈការកសាងផែនការប្រើប្រាស់កម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ព្រមទាំងមានកម្មវិធីប្រជុំបូកសរុប ដកពិសោធន៍តាមដំណាក់កាលនីមួយៗ សំដៅកែលម្អបង្កើនប្រសិទ្ធភាពថែមទៀតសម្រាប់រដ្ឋបាលក្រុង-ស្រុករបស់ខ្លួន។ បង្កើនការរៀបចំនូវវេទិកាសាធារណៈឱ្យកាន់តែសកម្មបន្ថែមទៀត ដោយយកចិត្តទុកដាក់ខ្ពស់អំពីគុណភាពនៃការទទួលបានព័ត៌មាន អំពីទុក្ខកង្វល់របស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងបញ្ហាសន្តិសុខ ព្រមទាំងបានខិតខំដោះស្រាយនូវរាល់សំណូមពរ ដែលប្រជាពលរដ្ឋបានលើកឡើងឱ្យរួសរាន់ប្រកបដោយស្មារតីទទួលខុសត្រូវ គឺសំដៅដល់ការធ្វើឱ្យវេទិកាសាធារណៈមួយឱ្យទទួលបាននូវគុណប្រយោជន៍ពិតៗ ហើយគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ក្នុងខេត្ត ត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីឱ្យការអនុវត្តគោលនយោបាយ "ភូមិ-ឃុំមាសុវត្ថិភាព" ទទួលបានលទ្ធផលល្អ ធានាការពារសន្តិសុខ និងសណ្តាប់ធ្នាប់ជូនដល់ប្រជាពលរដ្ឋគ្រប់ទីកន្លែង ដើម្បីរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងកាត់បន្ថយភាពក្រីក្រ។[28]

- **សុវត្ថិភាពសម្ភារៈ**

សុវត្ថិភាពសម្ភារៈនៅពេលនេះ គឺចង់បានន័យថាមិនត្រឹមតែមិនមានការឆក់ប្លន់នោះទេ ពោលគឺមានសុវត្ថិភាពដល់សម្ភារៈដែលបម្រើដល់ការរស់នៅរបស់ប្រជាជនរួមមានដូចជា៖ មិនមាននូវការគាស់ផ្ទះ ផ្លោះរបង ឬការគាស់ទូរធនាគារ (ATM) ក្មេងពាល ល្បែងស៊ីសង ឬសកម្មភាពផ្សេងទៀតដែលបង្កឱ្យមានភាពអសន្តិសុខដែលធ្វើឱ្យមានភាពភ័យខ្លាច ដល់ការរស់នៅរបស់ប្រជាជននៅតាមតំបន់ផងដែរ។ ជាមួយគ្នានេះផងដែរ ក៏ត្រូវមានសន្តិសុខ សុវត្ថិភាពដោយមានយាមពីសំណាក់មន្ត្រីជំនាញ ឬមន្ត្រីដែលពាក់ព័ន្ធបន្ថែមសម្រាប់ភាពកក់ក្តៅរបស់ប្រជាពលរដ្ឋជាមួយនឹងការការពារដោយការយកចិត្តទុកដាក់ខ្ពស់ ជាមួយនឹងបញ្ហាសន្តិសុខ។ ការគិតគូរបែបនេះមិនត្រឹមតែធ្វើឱ្យប្រជាជនមានទំនុកចិត្តនោះទេ គឺថែមទាំងធ្វើឱ្យជនជាតិបរទេស ជាពិសេសជាមួយផ្នែកទេសចរណ៍ ដែលធ្វើឱ្យមានទំនុកចិត្តជាមួយដំណើរកំសាន្ត។ លើសពីនេះទៅទៀត កាលណាពួកគាត់មាននូវសុវត្ថិភាពពេលចូលមកដល់ប្រទេសកម្ពុជា នោះធ្វើឱ្យមានចំណាប់អារម្មណ៍កាន់តែខ្លាំងសម្រាប់ការងាររកស៊ីបណ្តាក់ទុន ព្រោះជាប្រទេសដែលមានសុវត្ថិភាព ដូច្នេះការរកស៊ីក៏មានសុវត្ថិភាព។ ស្ថិតក្នុងបរិបទបែបនេះ ការវិនិយោគកាន់តែកើនឡើង ជាហេតុបណ្តាលឱ្យសេដ្ឋកិច្ចជាតិកាន់តែមានការអភិវឌ្ឍ និងជួយបង្កើនឱកាសការងារដល់ប្រជាពលរដ្ឋផងដែរតាមរយៈទេសចរណ៍ ក៏ដូចជាការនិយោគផងដែរ។

[28] គេហទំព័រ ក្រសួងមហាផ្ទៃ https://www.interior.gov.kh/report/detail/2325 ដកស្រង់ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២០

❖ **សុវត្ថិភាពចំណីអាហារ**

បច្ចុប្បន្ននេះទាំងអាជ្ញាធរ រដ្ឋាភិបាល ក៏ដូចជាមន្ត្រីពាក់ព័ន្ធផ្សេងៗបានខិតខំព្យាយាមទប់ស្កាត់ និង ផាកពិន័យ រាល់ការនាំចូលនូវរបស់របរ បន្លែ និងចំណីអាហារដែលមិនមានគុណភាពនៅតាមព្រំដែន ក៏ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ តម្រូវការនៃការប្រើប្រាស់របស់ប្រជាពលរដ្ឋមានច្រើន។ ដូចនេះដើម្បីបំពេញតម្រូវឱ្យ គ្រប់នូវការប្រើប្រាស់នេះ ត្រូវទាមទារឱ្យមានចូលរួមពីប្រជាពលរដ្ឋក្នុងការដាំដំណាំ បន្លែ ផ្លែឈើ គ្មានសារជាតិ គីមីដោយខ្លួនឯង ទុកប្រើប្រាស់ផង និងដាក់លក់នៅលើទីផ្សារផង ដើម្បីផ្តល់សុវត្ថិភាពដល់ខ្លួនឯង ក្រុមគ្រួសារ និងសង្គមជាតិផងដែរ។

អ្នកផលិតម្ហូបអាហារ បន្លែ ត្រូវមានគុណធម៌ សច្ចធម៌ មានបច្ចេកទេសខ្ពស់ ដើម្បីជួយបំរើដល់សុខភាព របស់អ្នកប្រើប្រាស់ កុំដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួនធ្វើឱ្យប៉ះពាល់ ដល់សុខភាពរបស់អ្នកដទៃតាមរយៈការលក់ របស់ដែលមិនមានគុណភាពទៅឱ្យអតិថិជន។ ចំពោះអ្នកប្រើប្រាស់ក៏គួរគប្បីស្វែងយល់ឱ្យបានច្រើននូវរាល់ ផលិតផលណាដែលគួរប្រើប្រាស់ និងមិនគួរប្រើប្រាស់ដូចគ្នាផងដែរ។

សម្រាប់អ្នកប្រើប្រាស់ទាំងអស់ ដើម្បីទទួលបានសុវត្ថិភាពចំណីអាហារ បើអាចពិនិត្យលើគុណភាព ចំណីអាហារ ក៏គួរគប្បីមុននឹងទិញផលិតផលយកទៅប្រើប្រាស់ យ៉ាងហោចណាស់ក៏បានពិនិត្យមើលទៅលើ កាលបរិច្ឆេទផុតកំណត់ឱ្យបានមួយចំណុចមុនសិនដែរ ដើម្បីធានាឱ្យដឹងថាផលិតផលនោះនៅអាចប្រើប្រាស់ បាន ហើយបើកន្លែងបរិច្ឆេទផុតកំណត់មានការកោសលុប មានមិនជាន់គ្នានោះ យើងមិនត្រូវទិញយកទៅប្រើ ប្រាស់នោះឡើយ។[29]

ជារួមអាហារដែលមានសុវត្ថិភាព គឺយើងត្រូវពិនិត្យទៅលើបញ្ហាមួយចំនួនដែលជាកត្តាចាំបាច់ដូចជា៖ កាលបរិច្ឆេទនៃការផុតកំណត់ អនាម័យ ការវេចខ្ចប់ ការទទួលស្គាល់ជាលក្ខណៈស្តង់ដារ ជាពិសេសជាងនេះ ទៅទៀតស្ថាប័នដែលពាក់ព័ន្ធខាងគីមីចំណីរអាហារ គឺត្រូវបានដើរតួនាទីយ៉ាងសំខាន់ក្នុងថែរក្សាសុខភាពរបស់ ប្រជាជន និងអនុវត្តយ៉ាងតឹងរឹងតាមរយៈការចុះត្រួតពិនិត្យទំនិញខុសច្បាប់ និងដាក់ទោសជនដែលនាំចូល ឬលក់ផលិតផលចំណីអាហារដែលខូចគុណភាព ដែលនាំឱ្យមានផលប៉ះពាល់ដល់អ្នកប្រើប្រាស់។ ជាមួយគ្នា នេះផងដែរ ប្រជាពលរដ្ឋដែលលក់ចំណីអាហារក៏ត្រូវចូលរួមចំណែកដូចគ្នា ក្នុងការថែរក្សាអនាម័យចំណីអាហារ ដើម្បីសុខភាពអ្នកបរិភោគ។ បើយោងតាមរយៈសេចក្តីណែនាំលេខ១៨ អយក.សណន ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ចំណីអាហារនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ដែលត្រូវបានហាមឃាត់មាន៦ប្រភេទ ដូចខាងក្រោម៖

---

[29] គេហទំព័រ http://www.freshnewsasia.com/index.php/en/localnews/140598-2019-11-24-09-06-53.html ដកស្រង់ថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០២០

១. ចំណីអាហារគ្រប់ប្រភេទដែលហួសកំណត់កាលបរិច្ឆេទ

២. គ្រឿងស្រវឹង និងផលិតផលថ្នាំជក់គ្រប់ប្រភេទ

៣. ចំណីអាហារដែលមិនមានប្រភពច្បាស់លាស់

៤. ភេសជ្ជៈប៉ូវកម្លាំង ភេសជ្ជៈផ្អែមខ្លាំង កាហ្វេ កាម៉េម ទឹកស៊ីរ៉ូប៍គ្រប់ប្រភេទ

៥. ស្ករសូកូឡា ស្ករគ្រាប់ និងស្ករកៅស៊ូគ្រប់ប្រភេទ

៦. ចាហួយគ្រប់ប្រភេទ នំដូណាត់ នំផ្អែមខ្លាំង។[30]

### ១.២.១.២. ភាពស្ងប់ស្ងៀម

ភាពស្ងប់ស្ងៀម គឺសម្តៅទៅលើទីតាំងមួយដែលមិនមានការបំពុលដោយសម្លេង។[31] ស្ថិតក្នុងបរិបទបែបនេះការដែលមិនមានការបំពុលដោយសម្លេង គឺជាការរស់នៅដោយមានភាពស្ងប់ស្ងៀមដោយមិនមានការរំខានដោយសម្លេងផ្សេងៗ ដែលអាចបង្កជាការរំខានដល់ការរស់នៅប្រចាំថ្ងៃ ដែលចេញមកពីប្រភពផ្សេងៗជាច្រើនដូចជា៖ មិនមានសម្លេងចេញពីការដ្ឋាន រោចចក្រសហគ្រាស សម្លេងតាមរយៈការបំពងសម្លេង ឬចេញពីប្រភពណាមួយ រួមទាំងការរំខានដោយសម្លេងគ្រប់ប្រភេទគឺត្រូវបានហាមឃាត់ ឬមានវិធានការយ៉ាងតឹងរឹងចំពោះបញ្ហាទាំងអស់នេះ។ ម្យ៉ាងវិញទៀត ការធ្វើបែបនេះវាបានបង្កឱ្យការរស់នៅរបស់ប្រជាជននៅក្នុងតំបន់នោះទទួលបាននៅការរស់នៅដែលប្រកបទៅដោយភាពស្ងប់ស្ងៀម ព្រោះមិនមានការរំខានដល់អារម្មណ៍រាល់ការសម្រាករបស់ប្រជាជននៅក្នុងតំបន់នោះពីប្រភពផ្សេងៗ។ បន្ថែមពីនេះទៅទៀត ភាពស្ងប់ស្ងៀម គឺពិតជាមានសារៈសំខាន់សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅក្នុងតំបន់នោះ ព្រោះបើមានការរំខានដោយសម្លេងជាការបំពុលនោះការរស់នៅប្រចាំថ្ងៃប្រាកដ ជាមានការពិបាកនៅក្នុងការរស់នៅ ព្រោះវាបានយាយីដោយការរំខានជាខ្លាំងដល់សតិអារម្មណ៍ មិនទទួលបានអារម្មណ៍សម្រាកគ្រប់គ្រាន់។ ដូច្នេះស្ថាប័នដែលពាក់ព័ន្ធត្រូវបានមានវិធានការសម្រាប់ទប់ស្កាត់ ក៏ដូចជាមានវិធានការសម្រាប់ដាក់ចេញសម្រាប់ការគ្រប់គ្រងការបំពុលដោយសម្លេងជូនដល់ប្រជាពលរដ្ឋ ក្នុងគោលបំណងអាចធានាបានថាប្រជាពលរដ្ឋរស់នៅបានដោយភាពស្ងប់ស្ងៀម ដោយគ្មានការបំពុល ឬរំខានដោយសម្លេងចំពោះការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នោះ។

### ១.២.១.៣. ការថែរក្សាបរិស្ថាន

**បរិស្ថាន** គឺជាមជ្ឈដ្ឋានដែលនៅជុំវិញខ្លួនយើង ឬជារបស់របរវត្ថុដែលនៅលោមព័ទ្ធយើង ហើយមានឥទ្ធិពលដល់ជីវិត និងការលូតលាស់របស់បណ្តាភាវៈ។ បរិស្ថានចែកចេញជា៣ផ្នែកគឺ៖

---

[30] សេចក្តីណែនាំលេខ១៨ អយក.សណន ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ស្តីពី ចំណីអាហារនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន

[31] សៀវភៅ នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី២

- **បរិស្ថានធម្មជាតិ** រួមមានបរិស្ថានគ្មានជីវិត (ទឹក ដី ភ្លើង ខ្យល់ ភ្នំ ព្រៃឈើ) និងបរិស្ថានមានជីវិត (មនុស្សសត្វ និងរុក្ខជាតិ)
- **បរិស្ថានមនុស្ស** ជាសំណុំលក្ខខណ្ឌរូបសាស្ត្រ គីមី ជីវសាស្ត្រ រួមជាមួយកត្តាសង្គមនានាដែលកំណត់ការរស់នៅរបស់មនុស្សក្នុងពេលជាក់លាក់ណាមួយ
- **បរិស្ថានសង្គម** មានដូចជាសំណង់អគារ ហេដ្ឋារចនាសម្ព័ន្ធទីក្រុង ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រោងចក្រ សហគ្រាស សិប្បកម្ម សួនច្បារ វិមានរដ្ឋសភា វិមានរាជរដ្ឋាភិបាល និងសកម្មភាពសង្គមផ្សេងៗទៀត។[32]

នៅក្នុងបរិបទនេះផងដែរបរិស្ថាន គឺបានសំដៅដល់មជ្ឈដ្ឋានជុំវិញដែលយើងរស់នៅប្រកបទៅដោយភាពសុខដុម បានន័យថាបរិស្ថានដែលនៅជុំវិញខ្លួនយើងគឺមានភាពល្អប្រសើរសម្រាប់ការរស់នៅដូចជាៈ ទីធ្លា ទីតាំងនៃតំបន់កន្លែងលំហែកាយ អនាម័យ ព្រមទាំងទំនើបកម្មនៃការរស់នៅជាច្រើនដែលអាចបម្រើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ទីក្រុងរណបជ្រោយចង្វារកាន់តែទទួលបាននូវភាពល្អប្រសើរ។ ទន្ទឹមជាមួយគ្នានេះផងដែរ បរិស្ថាននៅតំបន់នេះគឺត្រូវតែមានការរៀបចំជាលក្ខណៈស្តង់ដារ ដែលអាចបម្រើដល់ការរស់នៅរបស់ប្រជាពលរដ្ឋទទួលបាននូវភាពល្អប្រសើរ និងទំនើបកម្មស្របតាមសម័យកាលទំនើបនៃការរស់នៅរបស់ប្រជាជនក្នុងតំបន់ឱ្យទទួលបាននូវគុណភាពពិតប្រាកដនៃការរស់នៅជាមួយនឹងបរិស្ថាន ដែលប្រកបទៅដោយការរៀបចំនៃបច្ចុប្បន្នភាព។

ដោយសារតែបរិស្ថានមានសារៈសំខាន់ខ្លាំងសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃ ហើយក៏មាននូវការទទួលរងផលប៉ះពាល់ពីសកម្មភាពរបស់មនុស្សផងដែរ ទើបមានការបង្កើតច្បាប់បរិស្ថានមានដែលមានគោលបំណងគឺផែនការបរិស្ថានជាតិ និងផែនការបរិស្ថានតំបន់ ការវាយតម្លៃប៉ះពាល់បរិស្ថានការគ្រប់គ្រងធម្មជាតិ កិច្ចការពារបរិស្ថាន កាត្រួតពិនិត្យ កំណត់ហេតុ និងអធិការកិច្ច ការចូលរួមរបស់សាធារណជន និងការស្រង់ព័ត៌មានមូលនិធិទាយជ្ជទានបរិស្ថាន ទោសបញ្ញតិ និងអនុសានុបញ្ញតិនៃច្បាប់នេះ។ អនុសញ្ញាអន្តរជាតិឆ្នាំ ១៩៩៨ នៃព្រះរាជាណាចក្រកម្ពុជាបានចូលជាសមាជិកនៃអនុសញ្ញាអន្តរជាតិស្តីពីវិស័យបរិស្ថានមានដូចជាៈ

- អនុសញ្ញាស្តីពី តំបន់ដីសើមអន្តរជាតិនៅថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៦
- អនុសញ្ញាស្តីពី ជីវៈចំរុះនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៩៥
- អនុសញ្ញាស្តីពី ការប្រែប្រួលអាកាសធាតុនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៥
- អនុសញ្ញាស្តីពី ការបំពុលសមុទ្រដោយនាវានៅខែវិច្ឆកា ឆ្នាំ១៩៩៤

[32] គេហទំព័រ https://www.khsearch.com/qna/16521 ដកស្រង់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២០

- អនុសញ្ញាស្តីពី ច្បាប់សមុទ្ររបស់អង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៦
- អនុសញ្ញាវីយ៉ែន និងពិធីសាម៉ុងរ៉េអាល់ស្តីពីធាតុបំពុលស្រទាប់អូសូន ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០១
- អនុសញ្ញាស្តីពី ការធ្វើពាណិជ្ជកម្មអន្តរជាតិសត្វព្រៃនិងរុក្ខជាតិ ថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៧
- អនុសញ្ញាស្តុកខូមស្តីពី សារធាតុពុលសរីរាង្គមិនបំបែកធាតុនថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០១
- អនុសញ្ញាស្តីពីការប្រឆាំងនឹងរហោរស្ថានកម្មនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣
- អនុសញ្ញាបេតិកភណ្ឌធម្មជាតិពិភពលោកមានដូចជា៖ ដែនជំរកសត្វព្រៃ ភ្នំសំកុល ឱរាល់ ភ្នំគូលែន ព្រហ្មទេព ឋបនីយជីវមណ្ឌលបឹងទន្លេសាប នៅថ្ងៃទី១០ខែមេសាឆ្នាំ២០០១។[33]

ទន្ទឹមនឹងនេះមានលិខិតបទដ្ឋានគតិយុត្តជាច្រើន ដែលបានចូលរួមដើម្បីការគាំទ្រការថែរក្សាបរិស្ថានយ៉ាងតឹងរឹង។ ជាមួយគ្នានេះផងដែរក៏មានស្ថាប័នជាច្រើនដែលបានរួមចំណែកយ៉ាងសំខាន់នៅក្នុងការចូលរួមថែរក្សាបរិស្ថានផងដែរ។

### ១.២.២. ទីក្រុងដែលមានសោភណ្ឌភាព

ទីក្រុងដែលមានសោភណ្ឌ ក៏ដូចជាសណ្តាប់ធ្នាប់ល្អ គឺជាទីក្រុងដែលមានការរៀបចំរាជធានី បុរី ដែលជាកន្លែងមួយមិនមានសកម្មភាព កសិកម្ម ឱ្យមានភាពល្អ មានសន្តិសុខ ភាពស្ងប់ស្ងៀម និងអនាម័យ។ ហើយសោភណ្ឌភាពត្រូវបានបង្កើតឡើងដោយមនុស្ស និងធម្មជាតិ ហើយសោភណ្ឌត្រូវបានចែកចេញជា២ទៀតគឺ៖

#### ១.២.២.១. សោភណ្ឌភាពពេលថ្ងៃ

**សោភណ្ឌភាពពេលថ្ងៃ** គឺសម្តៅលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរួមមាន៖ ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធលូចិញ្ចើមផ្លូវ សំណង់អគារតូចធំទាំងអស់របស់រដ្ឋ និងឯកជន សួនច្បារសាធារណៈ ផ្លូវក្រោមដី ព្រមទាំងប្រព័ន្ធសុវត្ថិភាពចរាចរណ៍រួមមាន ភ្លើងសញ្ញា ស្លាកសញ្ញា និងគំនូសសញ្ញាចារចរណ៍ រួមទាំងការធ្វើដំណើរតាមដងផ្លូវនៃយានយន្តគ្រប់ប្រភេទ រាប់បញ្ចូលទាំងថ្មើរជើង ដែលប្រកបទៅដោយសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយថែមទៀតផង។[34]

#### ១.២.២.២. សោភណ្ឌភាពពេលយប់

**សោភណ្ឌភាពពេលយប់** គឺសម្តៅដល់លើការបំពាក់ភ្លើងបំភ្លឺតាមអគារនានា និងតាមដងវិថីនានានៅក្នុងទីក្រុង ជាពិសេសការបំពាក់ភ្លើងបំភ្លឺចម្រុះពណ៌ពេលរាត្រីនៅតាមសួនសាធារណៈនានានៅក្នុងទីក្រុង។[35] ម្យ៉ាងវិញទៀត វាគឺជាការលម្អមួយដែលធ្វើឱ្យទីក្រុងកាន់តែមានសោភណ្ឌ ជាមួយនឹងការបំភ្លឺបែបនេះ។ ចំណែក

---

[33] គេហទំព័រ https://www.khsearch.com/qna/10254 ដកស្រង់ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០

[34] សៀវភៅ នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១

[35] សៀវភៅ នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១

ការធ្វើដំណើរទៀតសោត ជាពិសេសគឺតំបន់ជ្រោយចង្វារផ្ទាល់តែម្តង គឺបានបង្កជាភាពងាយស្រួលដល់ការធ្វើដំណើររបស់ប្រជាជនដែលធ្វើដំណើរឆ្លងកាត់ផងដែរ។

### ១.២.៣. ទីក្រុងដែលគ្មានការបំពុលទាំង៥

#### ១.២.៣.១. ការបំពុលទឹក និងវិធានការ

ការបំពុលទឹក អាចត្រូវបានគេឱ្យនិយមន័យច្រើនយ៉ាងផ្សេងៗពីគ្នា។ ជាទូទៅការបំពុលទឹក គឺជាការធ្វើឱ្យកង្វក់ដល់ទឹកនៅពេលដែលសារធាតុបំពុលនានាបានហូរចូលទៅក្នុងប្រភពទឹកដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តកម្ម (ដកយកសារធាតុបំពុលចេញ)។ ការបំពុលទឹកភាគច្រើន គឺបណ្តាលមកពីសំណល់ដែលចេញពីរោងចក្រឧស្សាហកម្ម កសិកម្ម និងតាមផ្ទះដែលផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពមនុស្ស និងសត្វក៏ដូចជាគុណភាពបរិស្ថាននៃប្រភពទឹកទាំងមូល។ ប្រភេទនៃការបំពុលទឹកមានពីរគឺ ប្រភេទបំពុលចំណុច និងប្រភពបំពុលរាយប៉ាយ។ ទឹកក្នុងដីត្រូវបានបំពុលដោយសារទឹកដែលនៅលើផ្ទៃដី ព្រោះទឹកក្នុងដីទទួលបានពីការស្រូបយកពីទឹកលើដី បើកាលណាទឹកលើដីរងការបំពុលដោយសារធាតុគីមីពុលផ្សេងៗ វានឹងជ្រាបមកពុលដល់ទឹកក្នុងដី ហើយទឹកក្នុងដីក៏អាចរងការបំពុលពីសណ្ឋានដីធម្មជាតិរបស់វាផងដែរ ហើយកាលណាទឹកក្រោមដីពុលវាពិបាកនឹងសម្គាល់ណាស់។[36] នៅក្នុងនោះផងដែរ យើងក៏មានមូលហេតុសំខាន់ៗដែលនាំឱ្យកង្វក់ទឹកផងដែរ ដែលកត្តាទាំងអស់នោះរួមមាន៖

**ការបំពុលដោយឧស្សាហកម្ម៖** ដោយសារតែឧស្សាហកម្ម ជាកន្លែងដែលបញ្ចេញថាមពលច្រើន និងមានផ្ទុកសារធាតុគីមី ការបំពុលដោយសំណល់ អាចបង្កគ្រោះថ្នាក់ដល់សតិបញ្ញារបស់កុមារ និងធ្វើឱ្យការលូតលាស់យឺតជាងធម្មតា។ ឧស្សាហកម្មដែលបំពុលច្រើនជាងគេ គឺឧស្សាហកម្មផលិតក្រដាស និងផលិតចំណីអាហារ។

**ការបំពុលដោយកសិកម្ម៖** ដើម្បីធ្វើស្រែចំការ ដាំដំណាំ បន្លែផ្លែឈើ ឱ្យទទួលបានផ្លែផ្កាល្អ កសិករត្រូវការប្រើថ្នាំគីមី សម្លាប់សត្វល្អិតចង្រៃដូចជាដង្កូវ និងសត្វល្អិតជាដើម។ ការប្រើជី និងថ្នាំសម្លាប់សត្វល្អិត ជាកត្តាដែលបំពុលបរិស្ថានយ៉ាងធ្ងន់ធ្ងរ។ កសិដ្ឋានចិញ្ចឹមសត្វជ្រូក បង្កើតឱ្យមានលាមក និងទឹកនោម ដែលបញ្ចេញនូវឧស្ម័នពុលទៅក្នុងខ្យល់ ហើយជ្រាបចូលក្នុងដី បំពុលទឹកផងដែរ។

**ការបំពុលដោយវិទ្យុសកម្ម៖** រោងចក្រនុយក្លេអ៊ែរ ដែលមានផ្ទុកសារធាតុអ៊ុយរ៉ាញ៉ូម ដើម្បីផលិតគ្រឿងអគ្គិសនី ដែលពួកយោធាប្រើនៅក្នុងនាវាមុជទឹក និងផលិតគ្រាប់បែក ដោយបន្សល់សំណល់ និងបញ្ចេញកាំរស្មីថាមពល ជាហេតុនាំឱ្យបង្កគ្រោះថ្នាក់ដល់សុខភាព បណ្តាលឱ្យស្លាប់ មានជំងឺមហារីក ធ្វើឱ្យគ្មានកូន ឬធ្វើឱ្យទារកមានកាយសម្បទាមិនគ្រប់គ្រាន់ជាដើម។

[36] គេហទំព័រ https://opendevelopmentcambodia.net/km/topics/water-pollution/ ដកស្រង់ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០

**ការបំពុលដោយសំណល់ផ្សេងៗ៖** ការបោះចោលសំណល់ដូចជា៖ ថង់ប្លាស្ទិក កាតុង ក្រដាស កែវ សំណល់សរីរាង្គ សំបកដប សំបកកង់ឡាន សំបកកង់ម៉ូតូ វត្ថុទាំងអស់នេះ មិនងាយរលាយទៅក្នុងធម្មជាតិទេ ទោះជារលាយ ក៏មានរយៈពេលយូរដែរ ធ្វើឱ្យបរិស្ថានមិនស្រស់ស្រាយ។ មិនតែប៉ុណ្ណោះ ការបោះចោលសំរាមពាសវាលពាសកាល នាំឱ្យស្ទះលូ និងត្រីងាប់ផងដែរ។[37]

❖ **វិធានការនៃការការពារការបំពុលទឹក**

ដើម្បីចូលរួមកាត់បន្ថយការបំពុលទឹក យើងទាំងអស់គ្នាត្រូវមានវិធានការដូចខាងក្រោម ៖

- ប្រើប្រាស់ទឹកក្នុងការសន្សំសំចៃខ្ពស់
- មិនត្រូវបោះចោលកាកសំណល់ ទាំងឡាយណាដែលបណ្តាលឱ្យមានការកង្វក់ទឹក
- មិនត្រូវប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត និងជីគីមីដែលមិនបានត្រួតពិនិត្យត្រឹមត្រូវ
- អប់រំប្រជាជនឱ្យបានយល់ច្បាស់ពីបញ្ហាបរិស្ថាន តម្លៃនៃការខូចខាត បញ្ចូលការអប់រំបរិស្ថានក្នុងកម្មវិធីសិក្សាតាំងពីកម្រិតទាបរហូតដល់កម្រិតខ្ពស់នៃប្រព័ន្ធអប់រំ
- ក្រសួងពាក់ព័ន្ធត្រូវមានវិធានការត្រឹមត្រូវក្នុងការថែរក្សាបរិស្ថាន ត្រូវចេះគ្រប់គ្រង និងតាមដានជាតិពុលទាំងឡាយដែលបណ្តាលឱ្យកង្វក់ទឹកហើយបណ្តុះបណ្តាលមន្ត្រីជំនាញក្នុងការត្រួតពិនិត្យ និងចេះប្រើប្រាស់ឧបករណ៍រកជាតិពុលក្នុងទឹកជាដើម
- ណែនាំអប់រំដល់ម្ចាស់រោងចក្រ សិប្បកម្ម សហគ្រាស រមណីដ្ឋាន ក៏ដូចជាភោជនីយដ្ឋានឱ្យធ្វើអាងសម្អាតកាកសំណល់ទាំងឡាយមុននឹងបង្ហូរចូលក្នុងទឹក
- បង្កើតក្រុមចុះត្រួតពិនិត្យ និងធ្វើការដាក់ពិន័យចំពោះអ្នកទាំងឡាយណាដែលធ្វើឱ្យមានកង្វក់ទឹក ។[38]

គួរបញ្ជាក់ផងដែរថា ការត្រួតពិនិត្យរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុលជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។[39] ទន្ទឹមជាមួយគ្នានេះផងដែរ គឺត្រូវបានហាមឃាត់ជាដាច់ខាតរាល់ការចាក់ចោល ក៏ដូចជាការបង្ហូរចេញសំណល់រាវពីប្រភពបំពុលណាមួយដែលមិនអនុវត្តតាមកំរិតស្តង់ដារនៃការបញ្ចេញសំណល់រាវ។[40]

### ១.២.៣.២. ការបំពុលខ្យល់ និងវិធានការ

ការបំពុលខ្យល់មានប្រភពចេញពីការដុតឥន្ធនៈ តួយ៉ាងប្រេងឥន្ធនៈ ប្រេងម៉ាស៊ូត និងធ្យូងសម្រាប់ការដឹកជញ្ជូន ការប្រើប្រាស់តាមផ្ទះ និងការប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម និងថាមពល។ ការដុតឥន្ធនៈទាំងនេះ

---

[37] គេហទំព័រ https://thmeythmey.com/?page=detail&id=58963 ដកស្រង់ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០

[38] គេហទំព័រ https://www.khsearch.com/qna/10411 ដកស្រង់ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០

[39] មាត្រា១៨ នៃអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩ ស្តីពី ការត្រួតពិនិត្យការបំពុលទឹក

[40] មាត្រា៦ នៃអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការត្រួតពិនិត្យការបំពុកទឹក

បានបញ្ចេញផ្សែងពុលចូលទៅក្នុងបរិយាកាសដែលបង្កឱ្យមានផលប៉ះពាល់ គួរឱ្យកត់សម្គាល់ទៅលើគុណភាពខ្យល់ និងសុខភាពរបស់មនុស្ស។[41]

- **មូលហេតុនាំឱ្យមានការបំពុលខ្យល់**

បើតាមទិន្នន័យអង្គការសុខភាពពិភពលោក (WHO) បានចាត់ទុកការបំពុលខ្យល់ និងការប្រែប្រួលអាកាសធាតុជាគ្រោះថ្នាក់ធំបំផុតសម្រាប់សុខភាពប្រជាជនក្នុងពិភពលោកឆ្នាំ ២០១៩។ កត្តាចម្បងបង្កើតការបំពុលខ្យល់គឺចេញពីឧស្សាហកម្ម ការដឹកជញ្ជូន ការដុតបញ្ឆេះប្រេងឥន្ធនៈ និងកសិកម្មផងដែរ។ ការបំពុលខ្យល់ស្ថិតក្នុងចំណោមបញ្ហាប្រឈមផ្នែកសុខភាពធំបំផុតសម្រាប់ប្រជាជនពិភពលោកសម្រាប់ឆ្នាំ ២០១៩។ នេះបើតាមការបញ្ជាក់របស់អង្គការសុខភាពពិភពលោក។ បើសិនជាគ្មានដំណោះស្រាយទេ ការស្លាប់របស់ប្រជាជននឹងបន្តកើនឡើងខ្លាំងនៅពេលអនាគត។

បើតាមអង្គការសុខភាពពិភពលោក ប្រជាជនពិភពលោករហូតដល់ ៩០ភាគរយដែលស្រូបយកខ្យល់កខ្វក់រៀងរាល់ថ្ងៃ ហើយក្នុងមួយឆ្នាំមនុស្សប្រហែលប្រាំពីរលាននាក់ឯណោះបានស្លាប់ដោយសារតែការបំពុលខ្យល់នេះ ក្នុងនោះមានកើតជំងឺមហារីក ជំងឺផ្លូវដង្ហើម បេះដូង និងសួតជាដើម។ អង្គការអន្តរជាតិដដែលនេះបានបន្ថែមថា កម្រិតបំពុលខ្យល់ខ្លាំងជាងគេកើតឡើងនៅតំបន់ភាគខាងកើតមេឌីទែរ៉ាណេ និងអាស៊ីអាគ្នេយ៍ ដោយកម្រិតបំពុលនោះកើនឡើងប្រាំដងលើកម្រិតស្តង់កំណត់របស់ខ្លួនឯណោះ។ ចំណែកអ្នកស្លាប់កើនរហូតដល់ ៩០ភាគរយ គឺស្ថិតនៅក្នុងប្រទេសដែលមានចំណូលទាប និងចំណូលមធ្យម ដែលរងការបំពុលដោយសារកំណើនឧស្សាហកម្ម ការដឹកជញ្ជូន កសិកម្ម និងការដុតប្រេងឥន្ធនៈនៅតាមលំនៅឋាននានាផងដែរ។

- **វិធានការការពារពីការបំពុលខ្យល់**

នាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ និងសំឡេងមានតួនាទី និងភារកិច្ចយ៉ាងសំខាន់ដូចជា រៀបចំនូវសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងការការពារគុណភាពខ្យល់ ស្តង់ដារគុណភាពខ្យល់បរិយាកាស និងខ្យល់ក្នុងអគារ ស្តង់ដារនៃការបញ្ចេញផ្សែង ចំហាយឧស្ម័ន ភាគល្អិតនិចល់ សំឡេង រំញ័រ ពីប្រភពចល័ត និងប្រភពអចល័ត និងស្តង់ដារសារធាតុបំពុល បរិស្ថានដែលមានផ្ទុកនៅក្នុងសារធាតុឥន្ធនៈហ្វូស៊ីល ក៏ដូចជាត្រួតពិនិត្យមធ្យោបាយគ្រប់គ្រង ឬបរិក្ខាប្រព្រឹត្តកម្មផ្សែងចំហាយឧស្ម័ន ភាគល្អិតនិចល់ សំឡេង រំញ័រនៅតាមទីតាំង ឬសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្មផ្សេងៗ។[42] ភ្ជាប់ជាមួយគ្នានេះផងដែរការត្រួតពិនិត្យនូវបរិមាណជាតិពុលក្នុងសារធាតុឆេះ ការបញ្ចេញសារធាតុ

[41] គេហទំព័រ https://opendevelopmentcambodia.net/km/topics/air-pollution/ ដកស្រង់ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២០

[42] គេហទំព័រក្រសួងបរិស្ថាន https://www.moe.gov.kh/ ដកស្រង់ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២០

បំពុលខ្យល់ និងសម្លេងពីប្រភពអចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។[43] ចំណែកឯការត្រួតពិនិត្យនូវការបញ្ចេញឧស្ម័នពីប្រភពចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដោយមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យត្រូវកំណត់ដោយប្រកាសរួមរបស់អន្តរក្រសួង។[44]

### ១.២.៣.៣. ការបំពុលដី និងវិធានការ

- **មូលហេតុនាំឱ្យមានការបំពុលដី**

ការបំពុលដី គឺត្រូវបានកំណត់ថាជាការសឹករិចរិល ឬការបំផ្លាញផ្ទៃដី និងដីដែលជាលទ្ធផលនៃសកម្មភាពរបស់មនុស្ស។ ការបំពុលដី គឺជាបញ្ហាធំមួយនៅជុំវិញពិភពលោកហើយបណ្តាលមកពីកត្តាផ្សេងៗគ្នា និងបុព្វហេតុចំបងមួយចំនួនដូចជា៖

**សកម្មភាពធ្វើកសិកម្ម** ជាការពិតណាស់ ការធ្វើកសិកម្មត្រូវបានគេរកឃើញថាជាមូលហេតុផ្ទាល់ប្រសិនបើការកាប់បំផ្លាញព្រៃឈើ ៨០ ភាគរយនៅទូទាំងពិភពលោក ។ ភាគច្រើននៃផ្ទៃដីកសិកម្មនេះត្រូវបានទាមទារដើម្បីដាំដំណាំសម្រាប់ចំណីសត្វ ជាពិសេសគោ ក្របីសម្រាប់ឧស្សាហកម្មសាច់ ។ ម្យ៉ាងវិញទៀតការកើនឡើងនៃកំណើនប្រជាជនក្នុងពិភពលោក គឺជាកើនឡើងនូវតម្រូវការសម្រាប់ការផ្គត់ផ្គង់ស្បៀងអាហារ ដែលជាមូលហេតុកំពុងបណ្តាលឱ្យព្រៃឈើ និងវាលស្មៅត្រូវបានប្តូរទៅជាដីស្រែចំការ ហើយដើម្បីធ្វើស្រែចំការ ការដាំដំណាំ បន្លែផ្លែឈើ ឱ្យទទួលបានផ្លែផ្កាល្អ កសិករត្រូវការប្រើថ្នាំគីមី សម្លាប់សត្វល្អិតចង្រៃដូចជាដង្កូវ និងសត្វល្អិតជាដើម ។ ការប្រើជី និងថ្នាំសម្លាប់សត្វល្អិត ជាកត្តាដែលបំពុលបរិស្ថានយ៉ាងធ្ងន់ធ្ងរ ។ ជាងនេះទៅទៀតកសិដ្ឋានចិញ្ចឹមសត្វជ្រូកបង្កើតឱ្យមានលាមក និងទឹកនោម ដែលបញ្ចេញនូវឧស្ម័នពុលទៅក្នុងខ្យល់ ហើយជ្រាបចូលក្នុងដី បំពុលទឹកផងដែរ ។

**ការចាក់សំរាម** ការរំលោភបំពានបរិស្ថានធំបំផុតប្រកបទៅដោយកាកសំណល់ពុលដែលបណ្តាលឱ្យរលូតកូន ជំងឺសរសៃប្រសាទ ជម្ងឺមហារីក និងចំនួននៃការខូចទ្រង់ទ្រាយពីកំណើត និងការខូចទ្រង់ទ្រាយរបស់មនុស្សមុនពេលត្រូវបានគេរកឃើញ។ ហើយចំពោះអង្គធាតុរាវដែលចេញពីសំរាម គឺជាទឹករំអិលរាវដែលមានសារធាតុពុលខ្ពស់ផ្ទុកទៅដោយសារធាតុគីមីជាច្រើន ហើយក៏នាំឱ្យប៉ះពាល់ដែលបានជះឥទ្ធិពលអាក្រក់ដល់បរិស្ថានជាមួយនឹងភាវរស់គ្រប់ប្រភេទ។

**សកម្មភាពធ្វើឧស្សាហកម្ម** សកម្មភាពឧស្សាហកម្មឧស្សាហ៍បញ្ចេញកាកសំណល់ពុលនិងវត្ថុធាតុដើមទៅលើដី ឬបរិយាកាសដែលពួកគេតាំងនៅលើដី។ ខណៈពេលដែលប្រទេសអភិវឌ្ឍន៍ភាគច្រើនគ្រប់គ្រងការ

[43] មាត្រា ១៧ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង

[44] មាត្រា ១៨ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង

ចាក់សំរាម និងការបំភាយដី បទបញ្ញត្តិធ្វើឱ្យមានតុល្យភាពថ្លៃដើមសម្រាប់ឧស្សាហកម្មហើយមិនចាំបាច់ការពារបានត្រឹមត្រូវនូវភាពសុចរិតនៃជីវមណ្ឌលរបស់យើង ជាពិសេសសុខភាពមនុស្សទេ ។

❖ **វិធានការការបំពុលដី**

- បញ្ឈប់រាល់សកម្មភាពនៃការបោះចោលសំណល់រឹងទៅលើដី
- ត្រូវធ្វើការរៀបចំ គ្រប់គ្រង និងត្រួតពិនិត្យនូវរាល់សំណល់រឹងទាំងអស់ឱ្យបានល្អ
- ធ្វើការរៀបចំកន្លែង និងបច្ចេកទេសនៃការបំផ្លាញចោលនូវកាកសំណល់ប្រកបដោយប្រសិទ្ធភាព និងមិនប៉ះពាល់ដល់បរិស្ថាន
- ការកំណត់ប្រភេទ ឬកម្រាស់ ឬទំហំនៃថង់ប្លាស្ទិក។ អនុក្រឹត្យស្តីពី ការគ្រប់គ្រងថង់ប្លាស្ទិចបានកំណត់ហាមឃាត់ការនាំចូល ការផលិតក្នុងស្រុក ការប្រើប្រាស់ និងចែកចាយនូវថង់ប្លាស្ទិចស្តើងមានដៃយួរគ្រប់ប្រភេទ លើកលែងតែថង់ផ្លាស្ទិចនោះមានកម្រាស់ចាប់ពី ០,០៣ មីលីម៉ែត្រឡើងទៅ និងមានវង្វាស់ទទឹងផ្នែកបាតខាងក្រោមចាប់ពី ២៥ សង់ទីម៉ែត្រ ឬ១០ អ៊ីងឡើងទៅ
- ធ្វើការផ្សព្វផ្សាយ និងលើកទឹកចិត្តឱ្យសាធារណៈជនចូលរួមក្នុងសកម្មភាពកិច្ចការពារបរិស្ថាននានា
- រាល់លំនៅឋាន ផ្សារទំនើប កន្លែងកំសាន្ត និងស្ថាប័នទាំងអស់ មានកាតព្វកិច្ចទុកដាក់ និងរៀបចំបែងចែកសំណល់រឹង ដាច់ដោយឡែកពីសំណល់ផ្សេងៗទៀត តាមគោលការណ៍របស់ក្រសួងបរិស្ថាន
- រាល់ការប្រមូល ស្តុកទុក ដោះបំបែក ធ្វើប្រតិកម្ម ឬបោះបង់ចោល សំណល់រឹង ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន
- ហាមដាច់ខាតរាល់ការដុត ឬវាយបំបែកសំណល់ដែលបង្កឱ្យមានប៉ះពាល់ ឬគ្រោះថ្នាក់ដល់សុខភាពសាធារណៈ និងបរិស្ថាន។ **ឧទាហរណ៍៖** សំណល់អាគុយ សំណល់ថ្មពិល ឬសំណល់បរិក្ខាអគ្គិសនី និងអេឡិចត្រូនិច ។[45]

**១.២.៣.៤.ការបំពុលដោយសម្លេង និងវិធានការ**

បើយោងតាមអនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង ការបំពុលដោយសម្លេងមានប្រភពពីរគឺ៖

- **ប្រភពចល័ត** គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មាន៖ យន្តហោះនាវាដឹកជញ្ជូនគ្រឿងយន្ត និងគ្រឿងបំពងសម្លេងគ្រប់ប្រភេទ។

[45] មាត្រា ១៤ នៃអនុក្រឹត្យស្តីពី ការគ្រប់គ្រងថង់ប្លាស្ទិច ឆ្នាំ ២០១៧

- **ប្រភពដោយអចល័ត** គឺជាប្រភពដែលស្ថិតនៅទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មាន៖ រោងចក្រ សហគ្រាស ឃ្លាំងស្តុកសម្ភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសម្លេង សិប្បកម្ម និង កសិដ្ឋានគ្រប់ប្រទភេទ។[46]

❖ **វិធានការចំពោះបំពុលដោយសម្លេង**

បើយោងទៅតាមអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេងបានកំណត់ អំពីការត្រួតពិនិត្យនូវសម្លេងរំខានពីប្រភពអចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន[47]។ ចំពោះត្រួតពិនិត្យនូវការ រំខានដោយសម្លេងពីប្រភពចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យត្រូវកំណត់ដោយប្រកាសរួមរបស់អន្តរក្រសួង។[48]

### ១.២.៣.៥. ការបំពុលដោយកាកសំណល់រឹង រាវ និងវិធានការ

សំណល់រឹង សំដៅលើសារធាតុ ឬរបស់រឹងដែលលែងប្រើប្រាស់ហើយត្រូវបានបញ្ចេញចោលពីប្រភព បំពុល ។ ចំណែកឯ សំណល់រាវវិញគឺសំដៅទៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុលចូលទៅក្នុងតំបន់ទឹក សាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ទោះបានធ្វើប្រតិកម្ម ឬមិនបានធ្វើប្រតិកម្មក្តី។ ទន្ទឹមជាមួយ គ្នានេះផងដែរ ប្រភពបំពុលសំណល់ទាំងអស់នេះគឺមានប្រភពមកពីលំនៅឋាន អគាររដ្ឋបាលសាធារណៈ ទីបរិវេន មធ្យោបាយដឹកជញ្ជូន និងតំបន់អាជីវកម្ម ឬសេវាកម្ម ដែលបញ្ចេញសំណល់រឹង រាវ សារធាតុបំពុល ឬសារធាតុដែលបង្កឱ្យមានគ្រោះថ្នាក់ ដោយផ្ទាល់ក្តី ឬមិនផ្ទាល់ក្តីចូលទៅក្នុងតំបន់សាធារណៈ។[49]

❖ **វិធានការសម្រាប់ការគ្រប់គ្រងកាកសំណល់រឹង រាវ**

តាមប្រកាសអន្តរក្រសួងលេខ៨០ រវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាននៅក្នុងឆ្នាំ២០០៣ ស្តីពីការ គ្រប់គ្រងសំរាម និងកាកសំណល់រឹងនៅថ្នាក់ខេត្ត ក្រុង មានវិសាលភាពគ្រប់គ្រងសំណល់រឹងទាំងឡាយ ដោយ រាប់បញ្ចូលទាំងការប្រមូល ការសម្អាត ការស្តុកទុកបណ្តោះអាសន្ន ការដឹកជញ្ជូន ការកែច្នៃ និងការបោះចោល សំរាមសំណល់រឹងគ្រប់ប្រភេទ ដែលមានគោលបំណងលើកកម្ពស់ការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន និង សមត្ថកិច្ចដែលពាក់ព័ន្ធនានា ក្នុងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងនៅថ្នាក់ រាជធានីខេត្ត ក្រុង ប្រកបដោយប្រសិទ្ធិភាពទូទាំងប្រទេស។ ប្រកាសអន្តរក្រសួងលេខ៨០ ផ្តល់ទៅឱ្យអាជ្ញាធរដែនដី និងសមត្ថកិច្ច ពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖

[46] មាត្រា៣ នៃអនុក្រឹត្យ លេខ ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង

[47] មាត្រា ១៧ នៃអុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង

[48] មាត្រា ១៨ នៃអុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង

[49] មាត្រា៣ នៃអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការត្រួតពិនិត្យការបំពុកទឹក

- ការដាក់ធុងសំរាមឱ្យបានគ្រប់គ្រាន់ ដើម្បីធានានូវសោភណ្ឌភាព និងបរិស្ថាន
- ដាក់ស្លាកហាមឃាត់ចោលសំរាម និងអប់រំឱ្យមានការទុកដាក់សំរាម សំណល់រឹងឱ្យបានត្រឹមត្រូវ
- រៀបចំ និងកំណត់ទីលានចាក់សំរាម សំណល់រឹងបណ្តោះអាសន្នឱ្យបានសមរម្យ ដោយគ្មានការរំខានដល់ចរាចរណ៍ សុខភាពសាធារណៈ សោភណ្ឌភាព និងសណ្តាប់ធ្នាប់សង្គម
- ប្រមូលសំរាម និងដឹកជញ្ជូនសំរាម សំណល់រឹងទៅបោះចោលឱ្យបានទៀងទាត់ នៅទីលានចាក់សំរាមដែលបានកំណត់ដោយអាជ្ញាធរដែនដី និងសមត្ថកិច្ចដែលពាក់ព័ន្ធ
- ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានការសហការជាមួយស្ថាប័ន ឬអង្គភាពដែលពាក់ព័ន្ធនានា ត្រូវអប់រំ និងផ្សព្វផ្សាយព័ត៌មានទៅដល់សាធារណៈជន អំពីការទុកដាក់សំរាម សំណល់រឹង តាមរយៈវិធីសាស្ត្រប្រកបដោយអនាម័យ និងសុវត្ថិភាពបរិស្ថាន។ ដើម្បីកាត់បន្ថយសំរាម សំណល់រឹង ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវតែជម្រុញ និងលើកទឹកចិត្តឱ្យមានសកម្មភាពកែច្នៃសំរាម ឬដំណើរការកែច្នៃសំរាមនៅក្នុងមូលដ្ឋានរបស់ខ្លួន
- មន្ទីរបរិស្ថានខេត្ត/ក្រុង និងការិយាល័យបរិស្ថានស្រុកខណ្ឌ ត្រូវដើរតួនាទីជាសេនាធិការឱ្យអាជ្ញាធរមូលដ្ឋាន ក្នុងការរៀបចំផែនការគ្រប់គ្រង និងចូលរួមបង្កើតផែនការសកម្មភាពក្នុងការប្រមូល ការស្តុកសំរាមបណ្តោះអាសន្ន ការដឹកជញ្ជូន និងការចាក់សំរាមក្នុងទីលានចាក់សំរាម ដោយត្រូវសហការ និងតាមដានការអនុវត្តផែនការទាំងនោះផងដែរ។ រាយការណ៍អំពីការអនុវត្តផែនការសកម្មភាពរបស់ខ្លួនអំពីការប្រមូល ការស្តុកទុកបណ្តោះអាសន្ន ការដឹកជញ្ជូន និងការចាក់សំរាមក្នុងទីលានចាក់សំរាម ដោយត្រូវផ្ញើរបាយការណ៍នេះទៅកាន់ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន ព្រមទាំងក្រសួងដែលមានការពាក់ព័ន្ធនានាទៀតផង។[50]

យោងតាមអនុក្រឹត្យលេខ១១៣ ដែលទទួលបានការអនុម័តកាលពីខែសីហា ឆ្នាំ២០១៥ បានកំណត់អាណត្តិកាន់តែច្បាស់លាស់ និងមានភាពប្រសើរដល់រដ្ឋបាលក្រុង ស្រុក ក្នុងការគ្រប់គ្រងសំរាម សំណល់រឹង។ ដោយអនុក្រឹត្យលេខ១១៣ នេះមានគោលបំណងដូចខាងក្រោម៖

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា លើការគ្រប់គ្រងសំរាម សំណល់រឹងតាមទីប្រជុំជន
- ប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងតាមទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី ក្រុង និងស្រុក និងធ្វើប្រតិភូកម្មមុខងារនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ

[50] ប្រកាសអន្តរក្រសួងលេខ៨០ រវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាននៅក្នុងឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសំរាម និងកាកសំណល់រឹងនៅថ្នាក់ខេត្ត ក្រុង

- កំណត់វិធានការចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងសំរាម សម្រាប់សំណល់រឹងទីប្រជុំជន
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។[51]

[51] មាត្រា២ នៃអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

# ជំពូកទី២

# ការអភិវឌ្ឍទីក្រុងរណប

# ក្រោយចទ្វារទៅជាទីក្រុងឆ្លាតវៃ

# ជំពូកទី២
# ការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារទៅជាទីក្រុងឆ្លាតវៃ

ការអភិវឌ្ឍទីក្រុងនាសតវត្សរ៍ទី២១នេះកាន់តែមានការគិតគូរយ៉ាងខ្លាំងពីនិរន្តរភាពបរិស្ថាន ការកាត់បន្ថយការបំពុលខ្យល់ និងសម្លេងយានយន្ត ដើម្បីធ្វើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋកាន់តែមានភាពសុខដុម។ ទីក្រុងចំនួន ៣ របស់ប្រទេសកម្ពុជារួមមាន រាជធានីភ្នំពេញ សៀមរាប និងខេត្តបាត់ដំបងត្រូវបានជ្រើសរើសជាបណ្តាញទីក្រុងឆ្លាតវៃអាស៊ាន (Smart City) បន្ទាប់ពីមេដឹកនាំទាំងអស់នៃប្រទេសជាសមាជិកបានឯកភាពលើគំនិតផ្តួចផ្តើមឱ្យមានទីក្រុងឆ្លាតវៃ ដែលស្នើដោយនាយករដ្ឋមន្ត្រីសិង្ហបុរី នៅក្នុងអំឡុងពេលកិច្ចប្រជុំកំពូលអាស៊ានលើកទី ៣២ ដែលបានប្រារព្ធធ្វើឡើងនៅប្រទេសសិង្ហបុរីកាលពីខែមេសាកន្លងទៅ។ ទោះបីជាយ៉ាងណាក៏ដោយនៅខេត្តសៀមរាប និងបាត់ដំបង គេមិនទាន់ឃើញមានគម្រោងជាក់លាក់ណាមួយត្រូវបានស្នើរឡើងដើម្បីអភិវឌ្ឍន៍ទៅជាទីក្រុងឆ្លាតវៃនោះទេ ប៉ុន្តែសម្រាប់រាជធានីភ្នំពេញអ្នកទទួលខុសត្រូវរៀបចំគម្រោងអភិវឌ្ឍន៍ក្រុងរណបជ្រោយចង្វារបានបញ្ជាក់ថាគម្រោងនេះ ត្រូវបានបង្កើតឡើងដោយផ្អែកលើគោលគំនិតទីក្រុងឆ្លាតវៃជាចម្បង។ បណ្តាញនៃទីក្រុងឆ្លាតវៃមានបំណងបង្កើនការតភ្ជាប់ក្នុងតំបន់នឹងត្រូវបានបង្កើតឡើងដោយមានទីក្រុងចំនួន២៦។ បើយោងតាមកំណត់ត្រាគំនិតផ្តួចផ្តើមនៃបណ្តាញទីក្រុងឆ្លាតវៃអាស៊ាន គឺបណ្តាញទីក្រុងឆ្លាតវៃអាស៊ានត្រូវបានគេមើលឃើញថាជាវេទិការួមគ្នាមួយដែលទីក្រុងចំនួន ៣ ពីរដ្ឋជាសមាជិកអាស៊ានទាំងអស់រួមគ្នាធ្វើការឆ្ពោះទៅរកគោលដៅរួមនៃការអភិវឌ្ឍទីក្រុងជ្រោយចង្វារប្រកបដោយភាពវៃឆ្លាត និងមាននិរន្តរភាពដោយយកនូវបច្ចេកវិទ្យាជាចម្បង។ នៅក្នុងបណ្តាប្រទេសនៅក្នុងតំបន់អាស៊ានបានទទួលស្គាល់ថាបច្ចេកវិទ្យាព្រមទាំងឌីជីថលអាចត្រូវបានប្រើប្រាស់ ដើម្បីដោះស្រាយបាននូវផលប៉ះពាល់នៃការធ្វើនគរូបនីយកម្មបានយ៉ាងឆាប់រហ័សដូចជា៖ ការកកស្ទះក្នុងទីក្រុង គុណភាពទឹក និងខ្យល់ ការបែងចែកទីក្រុង និងជនបទ សន្តិសុខ និងសុវត្ថិភាពរបស់ប្រជាជន។[52]

## ២.១. ជំហាននៃការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារ

ដើម្បីអភិវឌ្ឍន៍ទីក្រុងរណបជ្រោយចង្វារក្លាយជាទីក្រុងឆ្លាតវៃនាពេលបច្ចុប្បន្ននិងអនាគត យើងត្រូវសិក្សាតាមជំហាននៃការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារ ដែលជំហាននៃការអភិវឌ្ឍក្រុងរណបជ្រោយចង្វារគឺជាគំនិតថ្មីមួយនៃទីក្រុងដែលផ្តល់ការរីកចម្រើនប្រកបទៅដោយនិរន្តរភាព នឹងត្រូវបានរចនាឡើង ដើម្បីលើកកម្ពស់សកម្មភាពសេដ្ឋកិច្ចដែលមានសុខភាពល្អ និងអាចកាត់បន្ថយនូវការបំពុលបរិស្ថាន ជាពិសេសជួយកែលម្អគុណភាពនៃជីវិតរបស់ប្រជាជនទៀតផង។ ទីក្រុងឆ្លាតវៃអាចកើតឡើងបានលុះត្រាតែមានមេដឹកនាំពូកែដែលធ្វើ

[52] គេហទំព័រព័ត៌មាន http://news.khbmedia.asia ដកស្រង់ថ្ងៃទី ៨ ខែមិថុនា ឆ្នាំ២០២០

ការលើផែនការមេដ៏ទូលំទូលាយក្នុងការអភិវឌ្ឍទីក្រុង ពោលគឺមានផែនការមេតាមផ្លូវច្បាប់ច្បាស់លាស់ដែលគ្រប់គ្រងលើការប្រើប្រាស់ដី សំណុំបែបបទ ការរចនា ក៏ដូចជាការប៉ុនប៉ងគ្រប់គ្រងលើការអភិវឌ្ឍទីក្រុង។ ទន្ទឹមនឹងនេះ តំបន់នីមួយៗត្រូវតែកំណត់ឱ្យបានច្បាស់ថាជាតំបន់សម្រាប់លំនៅឋាន ពាណិជ្ជកម្ម ឬតំបន់ឧស្សាហកម្មដែលនឹងអាចពង្រីកឱកាសនៅក្នុងការអភិវឌ្ឍទីក្រុង និងអាចជួយដល់ការរស់នៅឱ្យកាន់តែមានភាពប្រសើរឡើង។ ការរៀបចំផែនការមេរាជធានីភ្នំពេញ ជាពិសេសផែនការមេរបស់ទីក្រុងរណបជ្រោយចង្វារត្រូវការអ្នកបច្ចេកទេសដែលមានសមត្ថភាពខ្ពស់ដើម្បីធ្វើផែនការមេនេះបាន ហើយផែនការមេនេះត្រូវតែមានផែនការរយៈពេលខ្លី និងរយៈពេលវែង រួមទាំងផែនការសកម្មភាពក្នុងនោះផងដែរ។ ឧទាហរណ៍៖ បើយើងចង់បង្កើតតំបន់ជាយក្រុងណាមួយឱ្យទៅជាតំបន់ឧស្សាហកម្ម ឬជាតំបន់ពាណិជ្ជកម្ម ប៉ុន្តែយើងមិនមាននូវហេដ្ឋារចនាសម្ព័ន្ធដើម្បីគាំទ្រតំបន់នោះ ក្នុងករណីនេះយើងមិនហៅវាថាជាផែនការមេនោះទេ។ ជំហាននៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងទីក្រុងរណបជ្រោយចង្វារទៅជាទីក្រុងឆ្លាតវៃមានដូចជា៖ ភ្លើងបំភ្លឺនៅតាមផ្លូវគ្រប់គ្រងដោយកុំព្យូទ័រ ប្រព័ន្ធភ្លើងLEDដែលមានប្រសិទ្ធភាព និងភាពសន្សំសំចៃ ប្រព័ន្ធកាមេរ៉ា ដាក់នៅគ្រប់ជ្រុងសម្រាប់សុវត្ថិភាពអ្នកដំណើរ ប្រព័ន្ធលូ និងអគ្គិសនីក្រោមដី ហើយគេហដ្ឋាន និងអគារទាំងអស់ត្រូវបានបំពាក់ដោយប្រព័ន្ធការពារធម្មជាតិ។ ទីក្រុងឆ្លាតវៃតម្រូវឱ្យមានផែនការមេធំទូលាយសម្រាប់ទីក្រុងទាំងមូលមិនមែនត្រឹមទីក្រុងរណបនោះទេ។ លើសពីនេះទៅទៀត ទីក្រុងឆ្លាតវៃគួរតែមានចន្លោះតំបន់បៃតង ដូចជាសួនច្បារដែលព័ទ្ធជុំវិញអគារសាធារណៈដើម្បីឱ្យមនុស្សអាចសម្រាក និងទទួលបានខ្យល់អាកាសបរិសុទ្ធ។[53]

### ២.១.១. ប្លង់គោល

ការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារដែលស្របទៅតាមប្លង់គោលរបស់រាជធានីភ្នំពេញ គឺជាការអភិវឌ្ឍប្រកបដោយភាពត្រឹមត្រូវ លើសពីនេះអាចទាក់ទាញអ្នកវិនិយោគឱ្យចាប់អារម្មណ៍ជាមួយគម្រោងនេះជាពិសេសអាចចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការបែងចែកតំបន់នៅក្នុងការរស់នៅ ក៏ដូចជាការប្រកបអាជីវកម្មរបស់ប្រជាពលរដ្ឋយ៉ាងល្អប្រសើរ។ ផ្ទុយទៅវិញ ប្រសិនបើគម្រោងនៃការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារដែលមិនស្របទៅតាមប្លង់គោល វាអាចនឹងបង្កើតជាបញ្ហានៅពេលអនាគត ជាពិសេសធ្វើឱ្យគម្រោងអភិវឌ្ឍទាំងមូលជួបភាពខាតបង់ទៀតផង។ ដើម្បីបញ្ចៀសបញ្ហាប្រឈមនៅថ្ងៃអនាគត រដ្ឋាភិបាលនិងស្ថាប័នដែលពាក់ព័ន្ធនានាត្រូវតែមានផែនការមេឱ្យបានច្បាស់លាស់ ទាំងការអភិវឌ្ឍនៅពេលបច្ចុប្បន្ន ក៏ដូចជាបន្តទៅថ្ងៃអនាគតក្នុងរយៈពេលវែង ដែលក្រៅពីគិតទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធ ត្រូវគិតទៅលើការបង្កើត និងថែរក្សាតំបន់បៃតងឱ្យបានកាន់តែច្រើន ដែលជាចំណែកមួយយ៉ាងសំខាន់នៅក្នុងការរស់នៅរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ។ កត្តាដែលនាំឱ្យមានការរៀបចំប្លង់គោលរាជធានីភ្នំពេញ ជាពិសេសប្លង់គោលទីក្រុងរណបជ្រោយចង្វារ គឺដើម្បី

[53] គេហទំព័រព័ត៌មាន http://news.khbmedia.asia ដកស្រង់ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០

បង្កបានជាលក្ខណៈងាយស្រួលនៅក្នុងការអភិវឌ្ឍសម្រាប់តំបន់ទីក្រុងរណបជ្រោយចង្វារ ដែលប្រកបទៅដោយប្រសិទ្ធភាពខ្ពស់ ដែលស្របទៅនឹងបរិបទនៃការរស់នៅដូចជា តំបន់លំនៅឋាន តំបន់សេដ្ឋកិច្ច ក៏ដូចជាតំបន់សេដ្ឋកិច្ចឧស្សាហកម្មជាដើម។[54]

### ២.១.១.១.សញ្ញាណទូទៅនៃប្លង់គោល

❖ **ប្រវត្តិនៃការបង្កើតប្លង់គោល**

ដោយយោងតាមការស្រាវជ្រាវប្លង់គោលបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៥០ ដែលបានអនុម័តជាផ្លូវការដោយក្រសួងនៅខែមេសា ឆ្នាំ១៩៥០ ដែលបានធ្វើឡើងដោយការិយាល័យសិក្សាគម្រោង។ ប្លង់គោលនៅពេលនោះ ជាប្លង់គោលតម្រង់ទិសអភិវឌ្ឍន៍តំបន់ធំៗដូចជា៖ ពហុកីឡាដ្ឋានអូឡាំពិច តំបន់ទួលគោក តំបន់បុរីកីឡា និងតំបន់សកលវិទ្យាល័យភ្នំពេញ។ នៅក្នុងឆ្នាំ ១៩៧០ មានការិយាល័យនគរូបនីយកម្មដែលដឹកនាំដោយលោក លុយ បានហាប់ ក៏មានបំណងរៀបចំទីក្រុងភ្នំពេញបន្ថែមទៀតតែមិនបានសម្រេច។ នៅឆ្នាំ ១៩៩៣ មានការសិក្សាជាឯកសារគោលសំខាន់របស់លោក Guy Lemarchand ដែលស្តីអំពីគម្រោងប្លង់គោល Greater Phnom Penh និងឆ្នាំ២០០២ ដល់ឆ្នាំ២០០៥ ទៅលើគម្រោងប្លង់គោលរាជធានីភ្នំពេញក្រោមកម្មវិធីរបស់សាធារណៈរដ្ឋបារាំង។[55]

❖ **និយមន័យ**

ប្លង់គោល គឺជាឯកសារ ឬគម្រោងដែលមានលក្ខណៈជាយុត្តិសាស្ត្រសម្រាប់ការអភិវឌ្ឍរាជធានីភ្នំពេញដល់ឆ្នាំ២០២០។ ម្យ៉ាងវិញទៀត ប្លង់គោលគឺជាប្លង់គ្រឹះសម្រាប់រៀបចំដែនដីនៃក្រុងនីមួយៗ ពីព្រោះថាប្លង់គោលជាអ្នកតម្រង់ទិសក្នុងការរៀបចំ និងបែងចែក ឬកំណត់ផ្ទៃដីសម្រាប់តំបន់សំណង់ តំបន់ទេសចរណ៍ តំបន់ឧស្សាហកម្ម តំបន់សណ្ឋាគារ កន្លែងសួនសាធារណៈ តំបន់សម្រាប់ចាក់សំរាម តំបន់សាលារៀន តំបន់ដែលត្រូវការពារ និងតំបន់ដែលត្រូវអភិវឌ្ឍន៍។ ប្លង់គោលជាទូទៅ គឺគេចែងអំពីទស្សនៈវិស័យនៃការអភិវឌ្ឍដីធ្លីនៅក្នុងតំបន់ ខេត្ត ក្រុងតែប៉ុណ្ណោះ។ នៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ពុំទាន់ឃើញមានការឱ្យនិយមន័យណាមួយជាក់លាក់ទៅលើប្លង់គោលនោះទេ ប៉ុន្តែប្លង់គោលនេះក៏ត្រូវបានយកមកប្រើប្រាស់ផងដែរនៅក្នុងច្បាប់ស្តីពីការរៀបចំនគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ នៅត្រង់មាត្រា៥ ដែលបានចែងថា គណៈកម្មាធិការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ ឬអនុគណៈកម្មាធិការរៀបចំទឹកដី និងសំណង់ ខេត្ត ក្រុង នីមួយៗត្រូវគូសប្លង់គោលដើម្បីធ្វើការរៀបចំ និងអភិវឌ្ឍន៍ខេត្ត ក្រុងរបស់ខ្លួន ហើយការរៀបចំប្លង់គោលនេះទៀតសោត ត្រូវមានការយល់ព្រមពីគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងត្រូវបាន

[54] គេហទំព័រព័ត៌មាន https://www.propertyarea.asia/ ដកស្រង់ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០

[55] សៀវភៅ នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១២៨

កំណត់ដោយអនុក្រឹត្យ។ គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់មានភារៈកិច្ចរៀបចំប្លង់គោលសម្រាប់តំបន់ពិសេសណាដាក់ជូនគណៈរដ្ឋមន្ត្រី ដើម្បីការពាររក្សានូវបេតិកភណ្ឌ ការពារបរិស្ថាន និងដើម្បីជានាការអភិវឌ្ឍសេដ្ឋកិច្ច។ ចំពោះរាជធានីភ្នំពេញ ការរៀបចំត្រូវបានបង្កើតដោយគណៈកម្មាធិការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សំរាប់ក្រុងភ្នំពេញ ហើយគណៈកម្មាធិការនេះត្រូវដឹកនាំដោយប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ប្រតិរាជរដ្ឋាភិបាលប្រចាំក្រុងភ្នំពេញ ឬអភិបាលអភិបាលរង ព្រមទាំងអង្គភាពបច្ចេកទេស ដែលមានសមត្ថកិច្ចចូលជាសមាជិក។ ជាទូទៅប្លង់គោលនេះមិនត្រូវបានប្រជាពលរដ្ឋយកមកធ្វើជាកម្មវត្ថុនៃបណ្តឹងតាមផ្លូវច្បាប់បានឡើយ ពីព្រោះប្លង់គោលចែងតែអំពីទស្សនៈវិស័យនៃការអភិវឌ្ឍដីធ្លីនៅក្នុងតំបន់ដែលត្រូវរៀបចំតែប៉ុណ្ណោះ។ ដូច្នេះភ្នាក់ងាររដ្ឋបាលដែលមានសមត្ថកិច្ចត្រូវធ្វើការពិនិត្យទៅលើអត្ថន័យនៃប្លង់គោលជាមុនសិនមុននឹងធ្វើការរៀបចំប្លង់ប្រើប្រាស់ដីធ្លី និងសំណង់តំបន់ណាមួយ។[56]

**២.១.១.២. អត្ថប្រយោជន៍ប្លង់គោល**

ការរៀបចំបង្កើតជាប្លង់គោលបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ការអភិវឌ្ឍទីក្រុងដែលមានដូចជាៈ

១. ធ្វើឱ្យការសាងសង់មានបទដ្ឋានតាមការកំណត់របស់ប្លង់គោល

២. រាល់ឧទ្យានសួនច្បារ រមណីយដ្ឋាន មហោស្រព ទីធ្លាកំសាន្ត ត្រូវបានសាងសង់ដោយមានសណ្តាប់ធ្នាប់

៣. ទីក្រុងមានសោភណ្ឌស្រស់បំព្រង គ្មានសំណង់អនាធិបតេយ្យ មានអនាម័យ គ្មានភក់ ជ្រាំចម្លងមេរោគ

៤. គ្មានភាពច្របូកច្របល់សួនច្បារក្លាយជាស្ថានីយបូមប្រេង ឆ្នេរទន្លេដែលជាទីលានយកខ្យល់អាកាសសំរាប់បំរើឱ្យអ្នកទេសចរណ៍ ប្រែក្លាយទៅជាផ្ទះស្លឹក ផ្ទះឈើភូមិជរាអនាធិបតេយ្យនៅក្នុងក្រុង

៥. ប្លង់គោលជាប្លង់ដែលបង្ហាញពីសោភណ្ឌភាពតំបន់សណ្តាប់ធ្នាប់ មានបណ្តាញផ្គត់ផ្គង់ទឹក បណ្តាញលូរបង្ហូរទឹកភ្លៀង និងទឹកស្អុយ មានបណ្តាញអគ្គិសនី មានទីកំសាន្ត មានសាលារៀន ដីសំរាប់កីឡាដ្ឋាន ដីសំរាប់រដ្ឋបាល ទីធ្លាសំរាប់ផ្សារ គ្រឹះស្ថានពាណិជ្ជកម្ម និងវប្បធម៌។ ប្លង់គោលមានបំណងធ្វើយ៉ាងណាឱ្យអនាគតនៃទីក្រុងទំនើបនឹងលេចឡើងទៅតាមលំនាំនៃប្លង់គោលដើម្បីឱ្យការអភិវឌ្ឍរីកចម្រើន និងធ្វើការលុបបំបាត់សំណង់អនាធិបតេយ្យ ព្រោះសំណង់លំនៅឋានគេបានកំណត់ក្នុងប្លង់គោលហើយតំបន់ទឹកស្អាតក៏គ្មានឧបសគ្គដែរព្រោះគេបានកំណត់ហាមឃាត់រួចទៅហើយ។[57]

[56] សៀវភៅ នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១២៨-១២៩

[57] សៀវភៅ នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១២៩

### ២.១.១.៣. ច្បាប់រដ្ឋធម្មនុញ្ញ និងលិខិតបទដ្ឋាន

❖ **ច្បាប់រដ្ឋធម្មនុញ្ញ**

រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ជំពូកទី៥ និងជំពូកទី៦មានមាត្រាជាច្រើនដែលបានចែងពីតួនាទីរបស់រដ្ឋដូចជា មាត្រា ៥៨ រដ្ឋទទួលបន្ទុកការងារ «ការពារបរិស្ថាន និងសមតានៃធម្មជាតិ និងធ្វើគំរោងការគ្រប់គ្រងដី ទឹក លំហអាកាស ខ្យល់ ប្រព័ន្ធអេកូឡូស៊ី ថាមពល ប្រេង ហ្គាស ថ្ម ខ្សាច់ ត្រី និងធនធានក្នុងទឹក»។ មាត្រា ៦៩ បាន ចែងថា រដ្ឋមាន «កាតព្វកិច្ចក្នុងការថែរក្សា និងការពារបូជនីយដ្ឋានបុរាណនានា វត្ថុសិល្បៈបុរាណ និងរៀបចំកែ លម្អតំបន់ប្រវត្តិសាស្ត្រនានា»។ មាត្រា ៦១ នៃរដ្ឋធម្មនុញ្ញបានចែងថា «រដ្ឋលើកទឹកចិត្តដល់ការអភិវឌ្ឍសេដ្ឋកិច្ច លើគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ដោយយកចិត្តទុកដាក់ដល់គោលនយោបាយ ធារាសាស្ត្រ អគ្គិសនី ការដឹកជញ្ជូន បច្ចេកទេសទំនើប និងប្រព័ន្ធឥណទាន» និងមាត្រា ៤៤ ចែងថា «ការដក សិទ្ធិនេះពីបុគ្គលម្នាក់អាចធ្វើបានតែក្នុងករណីហេតុផលនៃប្រយោជន៍សាធារណៈ ដែលមានចែងនៅក្នុងច្បាប់ តែប៉ុណ្ណោះ ហើយលុះណាតែមានការផាត់សងសមស្របណាមួយផ្តល់ឱ្យជាមុនទៀត។ ដូចនេះ តួនាទីរបស់រដ្ឋគឺ សម្រួលដំណើរការនៃទីផ្សារដោយដាក់ឱ្យអនុវត្តនូវគោលនយោបាយ ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខាចាំបាច់ ទាំងឡាយដើម្បីពង្រឹងសមត្ថភាពការអភិវឌ្ឍសេដ្ឋកិច្ច។

❖ **លិខិតបទដ្ឋាននានា**

អត្ថបទច្បាប់ និងលិខិតបទដ្ឋាននានាដែលទាក់ទងនឹងប្លង់គោលៈ

- ច្បាប់ស្តីពី ការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ឆ្នាំ១៩៩៤
- សារាចរណែនាំស្តីពីការរៀបចំគម្រោងប្លង់គោលនៅតាមខេត្ត-ក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជា និងសារាចរលេខ០២សរ ១៥ មករា ១៩៩៦
- អនុក្រឹត្យស្តីពី លិខិតអនុញ្ញាតការសាងសង់ លេខ៨៦អនក្រ/បក ១៩ ធ្នូ ១៩៩៧
- ច្បាប់ភូមិបាល ឆ្នាំ២០០១
- អនុក្រឹត្យលេខ ៤៦ អនក្រ.បក ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឆ្នាំ២០០២
- អនុក្រឹត្យលេខ ៤៧ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៅគណៈកម្មការ សុរិយោដី ឆ្នាំ២០០២
- អនុក្រឹត្យលេខ ៤៨ អនក្រ.បក ស្តីពី ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ឆ្នាំ២០០២
- ច្បាប់ស្តីពី ការរៀបចំខេត្តក្រុងនានាឆ្នាំ១៩៩៤
- ច្បាប់ស្តីពី កិច្ចការពារបេតិកភណ្ឌវប្បធម៌ ឆ្នាំ១៩៩៦

- ច្បាប់ស្តីពី ការពិនិត្យឡើងវិញនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៩
- ច្បាប់ស្តី ពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ នសរ/រកម/០៣០១/០០៥ ឆ្នាំ២០០១
- ច្បាប់ស្តីពី ការបង្កើតក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់, នស/រកម/ ០៦៩៩/០៩/២៣ មិថុនា ១៩៩៩
- ច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ
- អនុក្រឹត្យស្តីពី ការត្រួតពិនិត្យការបំពុលបរិយាកាស និងការបំពុលដោយការរំខានដោយសំលេង ឆ្នាំ២០០០
- ប្រកាសស្តីពី ការបំរុងទុកនូវទីតាំងនានាសំរាប់ផ្លូវថ្នល់ និងផ្លូវដែក
- សារាចរលេខ ០២ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ របស់ខុទ្ទកាល័យនៃទីស្តីការគណៈរដ្ឋមន្ត្រី
- អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី១៨ ធ្នូ ១៩៩៧
- អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២០ កក្កដា ១៩៩៩។[58]

## ២.១.២. ការរៀបចំផែនការសម្រាប់ទីក្រុងរណបជ្រោយចង្វារនៅរាជធានីភ្នំពេញ

ការរៀបចំផែនការអភិវឌ្ឍទីក្រុងនិរន្តភាពសម្រាប់ទីក្រុងរណបជ្រោយចង្វារ គឺជាផែនទីបង្ហាញផ្លូវមួយសម្រាប់អ្នករៀបចំគោលនយោបាយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍ទាំងជាតិ និងអន្តរជាតិនានា ដើម្បីបន្តការអភិវឌ្ឍទីក្រុងប្រកបដោយនិរន្តរភាពក្នុងគោលដៅប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុនៅក្នុងដំណើរការអភិវឌ្ឍកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងពង្រឹងបរិយាប័ន្នសង្គម[59]។ ដូច្នេះ ផែនការនេះមានសារៈប្រយោជន៍សម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់រាជធានី វិស័យឯកជន ដៃគូអភិវឌ្ឍន៍អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងស្ថាប័នសិក្សាស្រាវជ្រាវនៅក្នុងការអភិវឌ្ឍរាជធានីភ្នំពេញ។ ទន្ទឹមនឹងនេះផងដែរ ផែនការនៃការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារមានភ្ជាប់មកជាមួយនូវវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រទីក្រុង ដែលជាគោលការណ៍ណែនាំជាជំហានៗសម្រាប់មន្ត្រីពាក់ព័ន្ធនានាទាំងនៅថ្នាក់ រាជធានី ក្រុង/ស្រុក ឃុំ/សង្កាត់ ព្រមទាំងភាគីដែលពាក់ព័ន្ធ ដែលកំពុងបន្តអនុវត្តដំណើរការអភិវឌ្ឍទីក្រុងសំដៅឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនឹងនេះផងដែរ រាជរដ្ឋាភិបាល

[58] សៀវភៅ នីតិរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០១៩ ទំព័រទី១៣០

[59] បរិយាប័ន្នសង្គម(Social Inclusion) គឺជាការគិតគូពីបញ្ហាសង្គមបានគ្រប់ជ្រុងជ្រោយ នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនានារបស់ថ្នាក់ដឹកនាំ ឬអ្នកធ្វើគោលនយោបាយនៅលើគ្រប់វិស័យទាំងអស់ដែលពាក់ព័ន្ធ។

កម្ពុជាមានចក្ខុវិស័យធ្វើឱ្យរាជធានីភ្នំពេញ ជាពិសេសគឺទីក្រុងរណបជ្រោយចង្វារឱ្យក្លាយទៅជាទីក្រុងឆ្លាតវៃ ទីក្រុងបៃតង ដែលមានបរិស្ថានស្អាត មានផលប៉ះពាល់កម្រិតទាប ជាមជ្ឈមណ្ឌលពាណិជ្ជកម្ម សេដ្ឋកិច្ច វប្បធម៌ ជាពិសេសមានលក្ខណៈប្រកួតប្រជែងជាមួយនឹងការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌ ដែលស្ថិតនៅក្រោមផែនការមេនៃការប្រើប្រាស់ដីធ្លីរបស់រាជធានីភ្នំពេញឆ្នាំ២០៣៥។[60]

ដើម្បីធ្វើការរៀបចំផែនការសម្រាប់ការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារទៅជាទីក្រុងឆ្លាតវៃ យើងត្រូវធ្វើការរៀបចំផែនការទាំងនោះឱ្យបានច្បាស់លាស់ និងត្រូវគិតគូឱ្យបានហ្មត់ចត់សព្វគ្រប់ជ្រុងជ្រោយ ដែលផែនការសំខាន់ៗទាំងនេះត្រូវផ្តោតទៅលើ ចរាចរណ៍ឆ្លាតវៃ ចំណតឆ្លាតវៃ ភ្លើងបំភ្លឺផ្លូវឆ្លាតវៃ ការគ្រប់គ្រងកាកសំណល់ឆ្លាតវៃ និងប្រព័ន្ធកាមេរ៉ាសុវត្ថិភាពឆ្លាតវៃ។

### ២.១.២.១. ចរាចរណ៍ឆ្លាតវៃ

ចរាចរណ៍ឆ្លាតវៃគឺសម្តៅទៅលើការគ្រប់គ្រងការធ្វើដំណើរនៅតាមដងផ្លូវរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានភាពងាយស្រួល និងចំណាយពេលវេលាតិចនៅក្នុងការធ្វើដំណើរនៅក្នុងទីក្រុងប្រកបដោយប្រសិទ្ធិភាព ពីព្រោះថាចរាចរណ៍ឆ្លាតវៃបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការគ្រប់គ្រងចរាចរណ៍ឱ្យមានភាពល្អប្រសើរ និងបញ្ចៀសនូវការកកស្ទះចរាចរណ៍នៅក្នុងទីក្រុងផងដែរ។ ទន្ទឹមនឹងនេះផងដែរ ចរាចរណ៍ឆ្លាតវៃបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើន ជាពិសេសបានជួយសម្រួលការងាររបស់សមត្ថកិច្ចដែលពាក់ព័ន្ធនៅក្នុងការអភិវឌ្ឍទីក្រុងមួយទៅជាទីក្រុងឆ្លាតវៃ។ ដើម្បីធ្វើឱ្យទីក្រុងមួយមានចរាចរណ៍ឆ្លាតវៃ យើងត្រូវធ្វើការរៀបចំទៅលើគំនូសសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ និងរៀបចំទៅលើហេដ្ឋារចនាសម្ព័ន្ធនានា។

- **គំនូសសញ្ញាចរាចរណ៍**

គំនូសសញ្ញាចរាចរណ៍ គឺសម្តៅទៅលើការបែងចែកគំនូសផ្លូវដើម្បីឱ្យប្រជាពលរដ្ឋមានភាពងាយស្រួលនៅក្នុងការធ្វើដំណើរ ដែលការបែងចែកគំនូសផ្លូវនេះមានដូចជា៖ គំនូសផ្លូវសំរាប់ទោចក្រយានយន្ត គំនូសផ្លូវសំរាប់ត្រីចក្រយានយន្ត គំនូសផ្លូវសំរាប់អ្នកថ្មើរជើង និងគំនូសផ្លូវសំរាប់ជនពិការ។ ការបែងចែកគំនូសសញ្ញាចរាចរណ៍ គឺបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ ជាពិសេសជួយសម្រួលដល់ការគ្រប់គ្រងចរាចរណ៍ឱ្យមានភាពល្អប្រសើរ ដើម្បីឱ្យទីក្រុងនោះឆ្ពោះរកការអភិវឌ្ឍប្រកបដោយចីរភាព។

- **ភ្លើងសញ្ញាចរាចរណ៍**

ភ្លើងសញ្ញាចរាចរណ៍ គឺបានសម្តៅទៅលើភ្លើងស្តុបដែលបានធ្វើការបញ្ជាទៅលើការធ្វើដំណើររបស់ប្រជាពលរដ្ឋ តាមរយៈការកំណត់រយៈពេលការធ្វើដំណើរ ដោយកាមេរ៉ាសុវត្ថិភាពដែលបានបំពាក់នៅតាមដងផ្លូវ មានន័យថា នៅពេលផ្លូវណាមួយមានទំហំចរាចរណ៍កកស្ទះច្រើន នោះកាមេរ៉ាសុវត្ថិភាពនឹងធ្វើការចាប់យក

[60] ផែនការអភិវឌ្ឍទីក្រុងនិរន្តភាពសម្រាប់រាជធានីភ្នំពេញ២០១៨-២០៣០ ទំព័រទី១

រូបភាពទាំងនោះ រួចបញ្ជូនសញ្ញាមកភ្លើងសញ្ញាចរាចរណ៍ឱ្យកំណត់រយៈពេលវែង ដើម្បីឱ្យផ្លូវដែលមានការកកស្ទះខ្លាំងអាចធ្វើដំណើរទៅមុខទៀតបាន ពោលគឺការកំណត់រយៈពេលរបស់ភ្លើងសញ្ញាចរាចរណ៍គឺអាស្រ័យទៅលើទំហំចរាចរណ៍ដែលប្រព័ន្ធកាមេរ៉ាសុវត្ថិភាពបានផ្ដល់សញ្ញាមក។ ប្រព័ន្ធភ្លើងសញ្ញាចរាចរណ៍ពិតជាមានតួនាទីសំខាន់ណាស់ នៅក្នុងការគ្រប់គ្រងទៅលើការធ្វើដំណើររបស់ប្រជាពលរដ្ឋ ជាពិសេសបានបញ្ចៀសនូវការកកស្ទះចរាចរណ៍ដែលបានកើតមានឡើងនៅក្នុងទីក្រុងប្រកបដោយប្រសិទ្ធិខ្ពស់។ លើសពីនេះទៅទៀតនោះគឺភ្លើងសញ្ញាចរាចរណ៍ក៏បានជួយសម្រួលដល់ការធ្វើដំណើរនៅតាមដងផ្លូវរបស់អ្នកថ្មើរជើង ជាពិសេសជនពិការផងដែរ ដោយមានបំពាក់នូវភ្លើងសញ្ញាចរាចរណ៍ដែលអាចបញ្ជាឱ្យយានយន្តទាំងអស់ឈប់ ដើម្បីឱ្យអ្នកថ្មើរជើង និងជនពិការអាចធ្វើដំណើរឆ្លងកាត់ផ្លូវបានផងដែរ។

❖ **ហេដ្ឋារចនាសម្ព័ន្ធនានា**

ហេដ្ឋារចនាសម្ព័ន្ធនានាគឺសម្ដៅទៅលើផ្លូវថ្នល់ ស្ពានអាកាស ផ្លូវក្រោមដី ផ្លូវរថភ្លើង ដែលបានរួមចំណែកនៅក្នុងការជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ នៅក្នុងទីក្រុងដើម្បីកុំឱ្យមាននូវការកកស្ទះចរាចរណ៍។ លើសពីនេះទៅទៀត នៅពេលដែលនៅក្នុងទីក្រុងមានហេដ្ឋារចនាសម្ព័ន្ធល្អ នោះនឹងធ្វើឱ្យមានការទាក់ទាញដល់ភ្ញៀវទេសចរណ៍ចូលមកទស្សនា ជាពិសេសធ្វើឱ្យទីក្រុងមានសោភណ្ឌភាពល្អ និងមានភាពទាក់ទាញដល់អ្នកវិនិយោគឱ្យចូលមកធ្វើការវិនិយោគផងដែរ។[61]

### ២.១.២.២. ចំណតឆ្លាតវៃ

ចំណតឆ្លាតវៃ គឺសម្ដៅទៅលើកន្លែងសំរាប់ចតរថយន្តដែលគ្រប់គ្រងដោយប្រព័ន្ធសេនស័រ ដែលប្រព័ន្ធនេះនឹងធ្វើការផ្ដល់ព័ត៌មានដល់យើងដោយប្រាប់ពីកន្លែងណាដែលមានចំណតសំរាប់ចត ឬមិនមានចំណត។ លើសពីនេះទៅទៀត ចំណតឆ្លាតវៃបានបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋដែលបានធ្វើដំណើរនៅក្នុងទីក្រុងដោយប្រជាពលរដ្ឋមិនចាំបាច់ចំណាយពេលវេលាច្រើននៅក្នុងការស្វែងរកកន្លែងចតរថយន្ត ជាពិសេសចំណតឆ្លាតវៃ គឺអាចធ្វើការផ្ដល់ព័ត៌មានអំពីពេលវេលាដែលអាចរកចំណតសម្រាប់ចតរថយន្តបានតាមរយៈកម្មវិធីនៅក្នុងទូរស័ព្ទ ឬតាមរយៈប្រព័ន្ធសេនស័រ។[62]

### ២.១.២.៣. ភ្លើងបំភ្លឺផ្លូវឆ្លាតវៃ

ភ្លើងបំភ្លឺផ្លូវឆ្លាតវៃ គឺសម្ដៅទៅលើភ្លើងបំភ្លឺនៅតាមដងផ្លូវនានា ដែលត្រូវបានគ្រប់គ្រងដោយប្រព័ន្ធសេនស័រ ដែលប្រព័ន្ធនេះបានផ្ដល់នូវការសន្សំសំចៃថាមពលអគ្គិសនីចំពោះអ្នកប្រើប្រាស់ មានន័យថានៅពេលយើងចូលទៅក្បែរ ឬដើរកាត់ភ្លើងបំភ្លឺផ្លូវ ពេលនោះប្រព័ន្ធសេនស័រនឹងធ្វើការចាប់យករូបភាពរបស់យើង បន្ទាប់

---

[61] គេហទំព័រ Smart-City-Plan-2018-2035 ដកស្រង់ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២០

[62] គេហទំព័រ Smart-City-Plan-2018-2035 ដកស្រង់ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២០

មកវាបញ្ជូនសញ្ញាទៅឱ្យភ្លើងដើម្បីបំភ្លឺភ្លើងឡើង ហើយនៅពេលដែលយើងដើរឆ្លងកាត់រួច ភ្លើងនោះនឹងបិទដោយខ្លួនវា។ លើសពីនេះទៅទៀត ភ្លើងបំភ្លឺផ្លូវឆ្លាតវៃបានជួយកាត់បន្ថយការប្រើប្រាស់ថាមពល តម្លៃ និងការថែទាំប្រព័ន្ធភ្លើងបំភ្លឺនៅក្នុងទីក្រុង។[63]

### ២.១.២.៤. ការគ្រប់គ្រងកាកសំណល់ឆ្លាតវៃ

ការគ្រប់គ្រងកាកសំណល់ឆ្លាតវៃ គឺសម្តៅទៅលើការបែងចែកប្រភេទកាកសំណល់ទៅតាមប្រភេទផ្សេងៗ ហើយត្រូវបានគ្រប់គ្រងដោយប្រព័ន្ធសេនស័រ មានន័យថានៅពេលប្រភេទកាកសំណល់ណាមួយពេញនោះប្រព័ន្ធសេនស័រនឹងផ្តល់ព័ត៌មានទៅដល់ក្រុមហ៊ុនប្រមូលសំរាម ដើម្បីឱ្យមកយកសំរាមបានទាន់ពេលវេលាដើម្បីចៀសវាងការចោលសំរាមនៅក្រៅធុង ដែលអាចបង្កឱ្យមានក្លិនមិនល្អដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុង។ ការគ្រប់គ្រងកាកសំណល់ឆ្លាតវៃបង្កើតឡើងក្នុងគោលបំណង ដើម្បីជួយសម្រួលដល់ការងាររបស់អ្នករៀបចំទីក្រុង ជាពិសេសដើម្បីផ្តល់នូវភាពងាយស្រួលដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុងផងដែរ។[64]

### ២.១.២.៥. ប្រព័ន្ធកាមេរ៉ាសុវត្ថិភាពឆ្លាតវៃ

ប្រព័ន្ធកាមេរ៉ាសុវត្ថិភាពឆ្លាតវៃគឺសម្តៅទៅលើការគ្រប់គ្រងទិន្នន័យ និងរក្សាទុករូបភាពការធ្វើដំណើររបស់ប្រជាពលរដ្ឋរស់នៅក្នុងទីក្រុង ដើម្បីងាយស្រួលនៅក្នុងការតាមដានរាល់ការធ្វើដំណើរនៅតាមដងផ្លូវ។ ប្រសិនបើមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង ឬបញ្ហាផ្សេងៗកើតឡើងនៅក្នុងទីក្រុង នោះប្រព័ន្ធកាមេរ៉ាសុវត្ថិភាពឆ្លាតវៃនឹងធ្វើការផ្តល់ព័ត៌មានដល់អាជ្ញាធរដែលពាក់ព័ន្ធ ដើម្បីឱ្យចុះមកធ្វើការអន្តរាគមន៍បានទាន់ពេលវេលា។ លើសពីនេះទៅទៀតនោះគឺ ប្រព័ន្ធកាមេរ៉ាសុវត្ថិភាពឆ្លាតវៃគឺពិតជាផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនដល់តំបន់ទីក្រុងជាពិសេសជួយជំរុញឱ្យទីក្រុងនោះមានការអភិវឌ្ឍប្រកបដោយប្រសិទ្ធិខ្ពស់។[65]

- **លក្ខណៈសម្បត្តិរបស់ទីក្រុងឆ្លាតវៃ**

ដើម្បីធ្វើការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារទៅជាទីក្រុងឆ្លាតវៃ សម្រាប់ពេលបច្ចុប្បន្នទៅថ្ងៃអនាគតពោលគឺទីក្រុងរណបជ្រោយចង្វារត្រូវមាននូវលក្ខណៈសម្បត្តិដូចជា៖

**មធ្យោបាយធ្វើដំណើរឆ្លាតវៃ** គឺសម្តៅទៅលើការធ្វើចរាចរណ៍លើដងផ្លូវដែលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឆ្លាតវៃដើម្បីតភ្ជាប់នូវទំនាក់ទំនងរវាងអ្នកបើកបរ និងបានកំណត់នូវចំនួនយានជំនិះនៅលើដងផ្លូវបានយ៉ាងច្បាស់លាស់។ មួយវិញទៀតការប្រើប្រាស់យានជំនិះរួមដែលយើងហៅថា រថយន្តក្រុងសាធារណៈអាចជួយកាត់បន្ថយបាននូវការកកស្ទះចរាចរណ៍ ដែលរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាប្រសិទ្ធភាពនៃសេដ្ឋកិច្ចជាតិ។

---

[63] គេហទំព័រ Smart-City-Plan-2018-2035 ដកស្រង់ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២០

[64] គេហទំព័រ Smart-City-Plan-2018-2035 ដកស្រង់ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២០

[65] គេហទំព័រ Smart-City-Plan-2018-2035 ដកស្រង់ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២០

**ហេដ្ឋារចនាសម្ព័ន្ធឆ្លាតវៃ** គឺសម្តៅទៅលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានភ្ជាប់មកជាមួយការគិតគូរអំពីបរិស្ថាន និងគំនិតនវានុវត្តន៍ជានិច្ច។ ជាឧទាហរណ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឆ្លាតវៃ ត្រូវបានធ្វើឡើងតាមរយៈការបំពាក់ប្រព័ន្ធស្រូបថាមពលពីព្រះអាទិត្យនៅតាមទីសាធារណៈ ព្រមទាំងលំនៅឋានឯកជនក៏ដូចជាការសាងសួនបៃតងលើដំបូលអគារជាដើម។ ហើយបច្ចុប្បន្ន សូម្បីតែរថយន្តក្រុង ក៏មានបំពាក់ដោយសួនបៃតងលើដំបូលផងដែរ។

**សុវត្ថិភាពឆ្លាតវៃ** គឺសម្តៅទៅលើទីក្រុងមួយដែលមានសុវត្ថិភាពខ្ពស់នៅតាមដងផ្លូវ និងទីសាធារណៈ ពោលគឺមានប្រព័ន្ធកាមេរ៉ាសុវត្ថិភាពជាច្រើននៅក្នុងទីក្រុង ដើម្បីរង់ចាំអង្កេតគ្រប់សកម្មភាពល្មើសច្បាប់ និងការចោលសំរាមគ្មានសណ្តាប់ធ្នាប់ជាដើម។

**សេវាកម្មថែទាំសុខភាព** គឺសម្តៅទៅលើប្រព័ន្ធសុខាភិបាលដែលត្រូវបានគេទទួលស្គាល់ជាសកលដោយសារតែការប្រើប្រាស់បច្ចេកវិទ្យាទំនើបៗ។ បច្ចុប្បន្ននេះសេវាថែទាំសុខភាពបាននឹងកំពុងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងបញ្ញាសិប្បនិម្មិតក្នុងការពិនិត្យ និងព្យាបាលជំងឺ។

**ប្រព័ន្ធរដ្ឋបាលសាធារណៈឆ្លាតវៃ** គឺសម្តៅទៅលើប្រព័ន្ធរដ្ឋបាលដែលបានផ្តល់ភាពងាយស្រួលជាច្រើនដល់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរណ៍ដែលមកទស្សនានៅក្នុងទីក្រុង ដែលប្រព័ន្ធរដ្ឋបាលសាធារណៈឆ្លាតវៃទាំងនោះ មានដូចជា៖ ការចុះឈ្មោះធ្វើអត្តសញ្ញាណប័ណ្ណ ការចុះបញ្ជីអចលនទ្រព្យ និងការបង់ពន្ធតាមរយៈប្រព័ន្ធអេឡិចត្រូនិចជាដើម។ [66]

❖ **លក្ខណៈសម្គាល់របស់ទីក្រុងឆ្លាតវៃ**

ដើម្បីធ្វើការសម្គាល់ទីក្រុងណាបជ្រោយចង្វារជាទីក្រុងឆ្លាតវៃ គឺយើងអាចធ្វើការកត់សម្គាល់នូវលក្ខណៈមួយចំនួនរបស់វាដូចខាងក្រោម៖

**ថាមពលឆ្លាតវៃ** សម្តៅទៅលើអគារ លំនៅឋាន និងអគារពាណិជ្ជកម្មដែលមានប្រសិទ្ធភាពនៅក្នុងការប្រើប្រាស់ថាមពលតិច ហើយថាមពលដែលបានប្រើត្រូវបានវិភាគដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធ។ បណ្តាញឆ្លាតវៃ និងអំពូលLED តាមផ្លូវឆ្លាតវៃត្រូវបានយកមកប្រើប្រាស់នៅក្នុងទីក្រុងដើម្បីរួមចំណែកដល់ការគ្រប់គ្រងបណ្តាញឱ្យកាន់តែប្រសើរ បង្កើនប្រសិទ្ធភាពផលិតកម្ម និងចែកចាយថាមពល។ នៅក្នុងការគ្រប់គ្រងបណ្តាញឆ្លាតវៃមានការរកឃើញនៃការបរាជ័យនៃការប្រមូលទិន្នន័យ ការស្តារគ្រោះមហន្តរាយប្រតិបត្តិការនៅតាមមូលដ្ឋាន និងបច្ចេកទេស ដើម្បីធ្វើឱ្យការគ្រប់គ្រងបណ្តាញឆ្លាតវៃមានលក្ខណៈប្រសើរឡើង។

[66] គេហទំព័រព័ត៌មាន https://news.khbmedia.asia/32191 ដកស្រង់ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០

**ទិន្នន័យឆ្លាតវៃ** ទីក្រុងឆ្លាតវៃបានប្រមូលទិន្នន័យយ៉ាងច្រើន ដែលបានធ្វើការវិភាគយ៉ាងឆាប់រហ័សដើម្បីផ្តល់ព័ត៌មានដែលមានប្រយោជន៍ដល់ប្រជាពលរដ្ឋ តាមរយៈការផ្សព្វផ្សាយនូវទិន្នន័យនៅក្នុងទីក្រុងតាមរយៈប្រព័ន្ធអ៊ិនធើណេតដែលអាចប្រើសម្រាប់ការវិភាគព្យាករណ៍ ដើម្បីកំណត់បាននូវស្ថានភាពដែលកើតឡើងនាពេលអនាគត។

**ការដឹកជញ្ជូនឆ្លាតវៃ** គឺសម្តៅទៅលើទីក្រុងដែលបានកាត់បន្ថយចរាចរណ៍ យានយន្តតាមរយៈការជួយសម្រួលដល់ការដឹកជញ្ជូនទំនិញ ព្រមទាំងមនុស្សតាមរយៈមធ្យោបាយសាធារណៈ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍។ លើសពីនេះទៀត ការដឹកជញ្ជូនឆ្លាតវៃបានកាត់បន្ថយកម្រិតនៃការបំពុលបរិស្ថានផងដែរ ដើម្បីលើកកម្ពស់នូវការរស់នៅរបស់ប្រជាពលរដ្ឋអោយមានសុខភាពល្អ។

**ហេដ្ឋារចនាសម្ព័ន្ធឆ្លាតវៃ** គឺសម្តៅទៅលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានភ្ជាប់មកជាមួយការគិតគូរអំពីបរិស្ថាន និងគំនិតនវានុវត្តន៍ជានិច្ច។ ហេដ្ឋារចនាសម្ព័ន្ធឆ្លាតវៃតម្រូវឱ្យមានការរួមបញ្ចូលបច្ចេកវិទ្យាមួយចំនួនដូចជា អាយអូធី ទិន្នន័យធំដែលបានប្រមូល។

**ឧបករណ៍ភ្ជាប់ឆ្លាតវៃ** គឺសម្តៅទៅលើឧបករណ៍អាយអូធីដែលជាធាតុសំខាន់នៃទីក្រុង។ ឧបករណ៍អាយអូធី គឺជាឧបករណ៍សម្រាប់ចាប់សញ្ញារួមបញ្ចូលគ្នា ដើម្បីប្រមូលទិន្នន័យមានប្រយោជន៍ដែលអាចត្រូវបានវិភាគដើម្បីទទួលបានព័ត៌មានពាក់ព័ន្ធ។ ការផ្លាស់ប្តូរព័ត៌មានរបស់ប្រព័ន្ធទីក្រុងឆ្លាតវៃនឹងត្រូវគ្រប់គ្រងតាមពេលវេលាជាក់ស្តែង ជាពិសេសមានការរួមបញ្ចូលនៃការវិភាគទិន្នន័យដើម្បីកាត់បន្ថយគ្រោះថ្នាក់ និងផលវិបាកដែលអាចនឹងកើតមានឡើងនាពេលអនាគត។[67]

- **លក្ខណៈពិសេសរបស់ទីក្រុងឆ្លាតវៃ**

លក្ខណៈពិសេសរបស់ទីក្រុងឆ្លាតវៃនៃទីក្រុងរណបជ្រោយចង្វារ មានលក្ខណៈពិសេសដូចខាងក្រោម៖

- ទីក្រុងឆ្លាតវៃមានការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងមានការគ្រប់គ្រងទិន្នន័យ ដើម្បីពង្រឹងការផ្តល់នូវសេវាកម្មសាធារណៈដល់ប្រជាពលរដ្ឋ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធនានា។ លើសពីនេះទៅទៀត ទីក្រុងឆ្លាតវៃផ្តល់នូវការអប់រំ សេវាកម្មសុខភាពត្រឹមត្រូវ និងបង្កើនការភ្ជាប់បច្ចេកព័ត៌មានវិទ្យា។
- សេវាកម្មសាធារណៈរបស់រដ្ឋាភិបាលត្រូវធ្វើឱ្យប្រជាជនកាន់តែមានភាពងាយស្រួល ដែលផ្តល់ជូនតាមរយៈប្រព័ន្ធអ៊ិនធើណេត ជាពិសេសផ្តល់នូវគណនេយ្យភាព តម្លាភាព ព្រមទាំងការចូលរួមរបស់

[67] គេហទំព័រ https://ecmapping.com/2017/03/31/top-6-characteristics-to-understand-the-concept-of-smart-city/ ដកស្រង់ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០

សាធារណៈជនកាន់តែច្រើន។ ការបង្កើតក្រុមអេឡិចត្រូនិកនឹងអនុញ្ញាតឱ្យប្រជាជនបញ្ចេញមតិរបស់ពួកគេ ទទួលបានមតិយោបល់ល្អៗ ជំនួយពីការក្រុមអេឡិចត្រូនិកតាមរយៈប្រព័ន្ធអ៊ីនធើណេត។

- ការកើនឡើងនៃការទទួលបានមធ្យោបាយធ្វើដំណើរសាធារណៈ និងដំណោះស្រាយដូចជា៖ ចំណតរថយន្តឆ្លាតវៃ ការគ្រប់គ្រងឆ្លាតវៃ និងការដឹកជញ្ជូនតាមបែបរួមបញ្ចូលគ្នា។
- ទីក្រុងឆ្លាតវៃនឹងអភិវឌ្ឍន៍ដោយមានផែនការគ្រោងទុក និងផែនការច្បាស់លាស់ ដើម្បីធ្វើឱ្យទីក្រុងមានសុវត្ថិភាព សោភណ្ឌភាព និងមិនសូវមានគ្រោះមហន្តរាយធម្មជាតិកើតឡើង។ លើសពីនេះទីក្រុងឆ្លាតវៃមានការប្រើប្រាស់ការឃ្លាំមើលវីដេអូសកម្មភាពនានាដើម្បីធ្វើការតាមដាន ហើយចំពោះវិធានការណ៍សន្តិសុខត្រូវបានធ្វើឡើងដើម្បីការពារស្ត្រី កុមារ និងប្រជាជនវ័យចំណាស់។
- ទីក្រុងឆ្លាតវៃមានការបង្កើតសួនច្បារសាធារណៈ និងថែរក្សាឧទ្យានសួនកុមារ និងកន្លែងកំសាន្តនានាជាច្រើន។ ជាពិសេស កន្លែងរស់នៅរបស់ប្រជាពលរដ្ឋត្រូវបានធ្វើឡើងដើម្បីឆ្លើយតបទៅនឹងកំណើនប្រជាជន និងបង្កើនកម្រិតជីវភាពរបស់ប្រជាពលរដ្ឋផងដែរ។
- ទីក្រុងឆ្លាតវៃមានការបង្កើតហេដ្ឋារចនាសម្ព័ន្ធប្រកបដោយនិរន្តរភាព និងមានបរិស្ថានល្អ ដោយកាត់បន្ថយបរិមាណកាកសំណល់ដែលបានបង្កើតឡើងតាមរយៈការប្រើប្រាស់នូវ ធនធានធម្មជាតិដោយយកចិត្តទុកដាក់។[68]

## ២.១.៣. មាត្រដ្ឋានស្តង់ដារនៃសំណង់

### ២.១.៣.១. ទំនើបកម្មនៃសំណង់

វិស័យសំណង់កម្ពុជាទទួលបានកំណើនវិនិយោគកើនឡើងជាប់ៗគ្នានាប៉ុន្មានឆ្នាំចុងក្រោយនេះ ពោលគឺតាមរយៈការសាងសង់គម្រោងមានសក្តានុពលធំៗចំនួន ១២ប្រភេទ ដែលធ្វើឱ្យវិស័យនេះបន្តរីកចម្រើនទៅមុខជាបន្តបន្ទាប់។ បើយោងតាមរបាយការណ៍ដែលស្តីពីវឌ្ឍនភាពវិស័យសំណង់របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បញ្ជាក់ថាការវិនិយោគរយៈពេល៣ឆ្នាំចុងក្រោយនេះ ទាំងគម្រោង និងទុនវិនិយោគនៅក្នុងវិស័យសំណង់គឺបានបន្តកើនឡើងជាលំដាប់។ កំណើនដែលវិស័យសំណង់ទទួលបានកន្លងមកនេះភាគច្រើនគឺមកពីគម្រោងសំណង់ធំៗដូចជា៖ អគារពាណិជ្ជកម្ម សណ្ឋាគារ រមណីយដ្ឋាន ផ្សារទំនើប អគារខ្ពស់ៗ ទីក្រុងរណប បុរី លំនៅឋាន រោងចក្រផលិតគ្រឿង អេឡិចត្រូនិក រោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង រោងចក្រកិនស្រូវ និងតំបន់សេដ្ឋកិច្ចពិសេស ។[69]

[68] គេហទំព័រ Smart-City-Plan-2018-2035 ដកស្រង់ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២០

[69] គេហទំព័រ អប្សរាសង់ត្រាល់ http://apsaracentral.com/article/1150 ដកស្រង់ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០

យ៉ាងណាមិញ បើទោះជាកម្ពុជាកំពុងតែស្ថិតនៅក្នុងភាពប្រឈមនៃការរាតត្បាតជំងឺ Covid-19 ប៉ុន្តែសម្រាប់វិស័យសំណង់នៅក្នុងប្រទេសកម្ពុជានៅតែបន្តកើនឡើងគួរឱ្យកត់សម្គាល់រហូតដល់ចំនួន៥២៣គម្រោង កើនឡើងជិត៥០ភាគរយ បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំកន្លងទៅ។ អ្នកនាំពាក្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានមានប្រសាសន៍ក្នុងសន្និសីទសារព័ត៌មានស្តីពី "វឌ្ឍនភាពការងាររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងលើកទិសដៅបន្តថា បច្ចុប្បន្ននេះ គម្រោងសាងសង់សំណង់ជាច្រើន នៅតែមានសកម្មភាពក្នុងការអភិវឌ្ឍដដែល ដោយចំនួនសរុបមានរហូតដល់៥២៣គម្រោង គិតត្រឹមចុងខែកុម្ភៈ ឆ្នាំ២០២០ ខណៈដែលក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំ២០១៩ មានចំនួនត្រឹមជាង៣០០គម្រោងតែប៉ុណ្ណោះ។ គួរបញ្ជាក់ថា "ជាមួយនឹងការកើនឡើងនូវចំនួនគម្រោងអភិវឌ្ឍន៍ក្នុងវិស័យសំណង់នេះ បានជំរុញឱ្យទុនវិនិយោគកើនឡើងស្ទើរទ្វេដង ហើយវានឹងនៅតែបន្តកើនឡើងទៀត ប្រសិនបើបញ្ហានៃជំងឺCovid-19 ត្រូវបានទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពក្នុងពេលដ៏ខ្លីខាងមុខនេះ"។

នៅពេលបច្ចុប្បន្ននេះ សំណង់អគារខ្ពស់ៗនៅកម្ពុជាមានចំនួនជិត២០០០អគារ ដែលក្នុងនោះអគារបម្រើវិស័យសណ្ឋាគារមានចំនួនជាង ១០០០អគារ ហើយខុនដូមានចំនួន២៣,០០០យូនីត។ ដោយឡែកសម្រាប់គម្រោងអភិវឌ្ឍន៍លើវិស័យលំនៅឋានមានចំនួន៣២៧ទីតាំង រួមមានទាំងគម្រោងអភិវឌ្ឍន៍បែបបុរី និងគម្រោងអភិវឌ្ឍន៍លំនៅឋានដែលមានលក្ខណៈបែបបុរី។ ក្រុមហ៊ុនអន្តរជាតិដែលចូលមកវិនិយោគនៅក្នុងវិស័យសំណង់នៅកម្ពុជាសរុបមានចំនួន១៨ប្រទេស ដែលក្នុងនោះការវិនិយោគមកពីប្រទេសចិន ឈរនៅលំដាប់ទី១ ប្រទេសកូរ៉េស្ថិតនៅតំដាប់ទី២ ហើយប្រទេសជប៉ុនស្ថិតនៅលំដាប់ទី៣។[70] ដែលតំបន់ដែលត្រូវបានវិនិយោគនៃសំណង់ទាំងនោះមានជាច្រើនកន្លែងនៅក្នុងរាជធានីភ្នំពេញ ក្នុងនោះផងដែរតំបន់ទីក្រុងរណបជ្រោយចង្វារ គឺជាគោលដៅសំខាន់សម្រាប់ទំនើបកម្មនៃសំណង់ដែលទទួលបានលើការវិនិយោគនោះ។ ទោះបីជាសំណង់នៅប្រទេសកម្ពុជាបានកសាងឡើងជាមួយលក្ខណៈពិសេសនៃទំនើបកម្មនៃសំណង់ក៏ដោយ ក៏ប៉ុន្តែលក្ខណៈនៃសំណង់ទាំងអស់នោះ គឺត្រូវគោរពតាមគោលការណ៍នៃច្បាប់ដែលបានកំណត់មក ជាពិសេសគឺចំពោះអ្នកមានវិជ្ជាជីវៈក្នុងវិស័យសំណង់ គឺត្រូវពិនិត្យកត្តាសំខាន់លើការប្រើប្រាស់សម្ភារៈសំណង់ បរិក្ខាសំណង់ ព្រមទាំងមន្ទីរពិសោធន៍សំណង់ដើម្បីទទួលបានគុណភាពនៃសំណង់យ៉ាងពិតប្រាកដ។ ជាមួយគ្នានេះផងដែរសម្ភារៈសំណង់ បរិក្ខាសំណង់ និងផលិតផលសំណង់ដែលចាំបាច់សម្រាប់ធានានូវគុណភាពសម្រាប់សំណង់ និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ត្រូវមានការបញ្ជាក់អំពីការទទួលស្គាល់ ឬការបញ្ជាក់អនុលោមដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមបញ្ញាបច្ចេកទេសសំណង់ ឬតាមស្តង់ដារកម្ពុជាដែលបាន

[70] គេហទំព័រ https://www.propertyarea.asia/ គម្រោងអភិវឌ្ឍន៍វិស័យសំណង់ ដកស្រង់ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០

អនុម័តដោយក្រុមប្រឹក្សាស្តង់ដារអន្តរជាតិ ដោយត្រូវមានបិទពុម្ពសញ្ញាស្តង់ដារកម្ពុជា និងមានអាជ្ញាប័ណ្ណប្រើប្រាស់ស្តង់ដារកម្ពុជា។ ចំពោះបែបបទនិងនីតិវិធីនៃការបញ្ជាក់ទទួលស្គាល់ ឬការបញ្ជាក់អនុលោម និងប្រភេទនៃសំណង់ បរិក្ខាសំណង់ ឬសំណង់ដែលចាំបាច់សម្រាប់ធានាគុណភាពសំណង់ និងសុវត្ថិភាពត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។[71] បន្ថែមពីនេះទៅទៀតរាល់ការសាងសង់ត្រូវមានការអនុញ្ញាតជាមុនដោយអាជ្ញាធរមានសមត្ថកិច្ច។[72]

ទាក់ទិនទៅនឹងរាល់គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការសាងសង់ ឬរុះរើត្រូវចុះហត្ថលេខាទទួលខុសត្រូវដោយ អ្នកសិក្សាលើគម្រោងប្លង់ដែលមានអាជ្ញាប័ណ្ណឬការអនុញ្ញាតដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់។[73] បានន័យថា គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការសាងសង់ ឬត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស និងសំណង់ជាមួយនឹងបទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម។ គម្រោងប្លង់ដែលប្រើប្រាស់គម្រោងការងារសាងសង់សំណង់គ្រប់ប្រភេទត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធ គ្រឿងបរិក្ខាព្រមទាំងសេវាសម្រាប់ជនមានពិការភាព ផ្លូវជម្រាលសម្រាប់ផ្លាស់ទី ឧបករណ៍ផ្ទាក់ដៃ ជណ្តើរយន្ត បន្ទប់ទឹកអនាម័យ ចំណតយានយន្ត ពិសេសសម្រាប់ជនពិការ និងផ្លាកសញ្ញានានា។[74] ជាពិសេសជាងនេះទៅទៀតរាល់ការសាងសង់ត្រូវអនុវត្តស្របតាមគម្រោងប្លង់បទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀតដែលមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាតសាងសង់។[75]

### ២.១.៣.២. ប្រណីតភាពនៃហេដ្ឋារចនាសម្ព័ន្ធ

ទាក់ទងនឹងការវិនិយោគយើងឃើញថា ការរស់នៅមានភាពកាន់តែប្រសើរឡើងព្រោះដោយហេតុថាមានការវិនិយោគជាច្រើន ជាពិសេសក្រុមហ៊ុនសំណង់ធំជាងគេនៅកម្ពុជា OCIC បានប្រកាសបោះទុនវិនិយោគក្នុងទឹកប្រាក់ជាង ៣ ០០០លានដុល្លារអាមេរិក ដើម្បីបង្កើតទីក្រុងរណបជ្រោយចង្វារ ដែលជាទីក្រុងដែលមានពាណិជ្ជកម្ម និងជាទីក្រុង Smart City មុនគេនាពេលអនាគតឆាប់ៗខាងមុខ។ ទីក្រុងរណបជ្រោយចង្វារនឹងរៀបចំឡើងតាមបែប Smart City ដោយប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធត្រូវបានរៀបចំជាពិសេស ដូចជាខ្សែភ្លើងនឹងត្រូវកប់នៅក្រោមដីទាំងអស់ អំពូលភ្លើងនឹងប្រើប្រាស់ប្រភេទអំពូល LED មានការបំពាក់កាមេរ៉ាសុវត្ថិភាព និងប្រព័ន្ធទឹកកខ្វក់ទាំងអស់ដែលចេញពីទីក្រុងនេះ គឺនឹងត្រូវឆ្លងកាត់ការចម្រោះឱ្យស្អាតទាំងអស់មុននឹងបង្ហូរចេញចូល ។ ចំពោះការវិនិយោគទីក្រុងបែបស្មាតស៊ីធី (Smart City) នេះគឺត្រូវចំណាយប្រាក់ជាច្រើន ប៉ុន្តែដើម្បី

[71] មាត្រា២២ នៃច្បាប់ស្តីពីសំណង់

[72] មាត្រា២៦ នៃច្បាប់ស្តីពីសំណង់

[73] មាត្រា៣២ នៃច្បាប់ស្តីពីសំណង់

[74] មាត្រា៣៣ នៃច្បាប់ស្តីពីសំណង់

[75] មាត្រា៣៧ នៃច្បាប់ស្តីពីសំណង់

និរន្តរភាពរក្សាបាននូវបរិស្ថាន និងភាពសុខសាន្ត ក៏ដូចជាផាសុកភាពរបស់ប្រជាពលរដ្ឋគឺជាអ្វីដែលក្រុមហ៊ុន OCIC ត្រូវបានយកចិត្តទុកដាក់ និងផ្តោតសំខាន់ជាពិសេស។

អគ្គលេខាធិការរងនៃគណៈស្ថាបត្យករកម្ពុជា និងជាស្ថាបត្យករអាស៊ាន បាននិយាយថាទីក្រុងឆ្លាតវៃតម្រូវឱ្យមានផែនការធំទូលាយសម្រាប់ទីក្រុងទាំងមូល មិនមែនត្រឹមតែជាទីក្រុងរណបនោះទេ។ ទីក្រុងឆ្លាតវៃគួរតែមានចន្លោះបៃតង ដូចជាសួនច្បារដែលព័ទ្ធជុំវិញអគារសាធារណៈ ដើម្បីឱ្យមនុស្សអាចសម្រាក និងទទួលបានខ្យល់អាកាសបរិសុទ្ធ។ លោកបានបន្ថែមថា ទីក្រុងឆ្លាតវៃអាចកើតឡើងបាន លុះត្រាតែមានមេដឹកនាំពូកែដែលធ្វើការលើផែនការមេដ៏ទូលំទូលាយក្នុងការអភិវឌ្ឍទីក្រុងពោល គឺមានផែនការមេតាមផ្លូវច្បាប់ច្បាស់លាស់ដែលគ្រប់គ្រងលើការប្រើប្រាស់ដី សំណុំបែបបទ ការរចនា ឬការគ្រប់គ្រងលើការអភិវឌ្ឍទីក្រុងជាដើម។ តំបន់នីមួយៗត្រូវតែកំណត់ឱ្យបានច្បាស់ថា តំបន់ណាមួយជាតំបន់លំនៅឋាន ពាណិជ្ជកម្ម ឬឧស្សាហកម្មដែលនឹងអាចពង្រីកឱកាសនៅក្នុងការអភិវឌ្ឍទីក្រុង និងអាចជួយសម្រួលដល់ការរស់នៅរបស់ប្រជាជននៅក្នុងទីក្រុងកាន់តែប្រសើរឡើង។

តាមការព្យាករណ៍របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក៏បានឱ្យដឹងថា បើគិតត្រឹមឆ្នាំ២០៣០ ខាងមុខប្រជាជនជិត ៨លាននាក់ត្រូវគេរំពឹងថានឹងរស់នៅក្នុងទីក្រុង ហើយភាគច្រើននៃពួកគេនឹងមករស់នៅក្នុងទីក្រុងភ្នំពេញ។ រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានប្រសាសន៍ពន្យល់ថាការសាងសង់អគារធំៗ និងការគិតគូរពីបញ្ហាបរិស្ថានជាការងាររបស់យើង ដែលត្រូវផ្តោតការយកចិត្តទុកដាក់លើអ្វីដែលគេឱ្យឈ្មោះថា Smart City ព្រោះទីក្រុងបែបឆ្លាតវៃនេះទាមទារការគិតគូរច្រើនណាស់ ដើម្បីសម្រេចបាននូវស្តង់ដារទីក្រុងមួយដែលមានភាពទាក់ទាញ និងផ្តល់ភាពសុខសាន្តដល់ប្រជាពលរដ្ឋ។

ការសាងសង់អគារត្រូវតែធ្វើឡើងដោយមានទីធ្លាបៃតង កន្លែងលេងកម្សាន្ត ការទាញយកថាមពលពន្លឺព្រះអាទិត្យមកប្រើជំនួស ឬកាត់បន្ថយការប្រើប្រាស់ថាមពលអគ្គិសនី ការដាំដើមឈើក្នុងអគារ និងប្រព័ន្ធចម្រោះទឹកកខ្វក់ជាដើម។ ទាំងអស់នេះសុទ្ធតែជារឿងចាំបាច់ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍ ដោយត្រូវគោរពនូវពាក្យស្លោកដែលថា ការអភិវឌ្ឍត្រូវដើរទន្ទឹមគ្នានឹងការអភិរក្ស។[76] ស្ថិតនៅបរិបទបែបនេះហើយ ទើបបង្កឱ្យការរស់នៅរបស់ប្រជាជន ជាពិសេសគឺតំបន់ជ្រោយចង្វារកាន់តែប្រកបទៅដោយទំនើបកម្ម និងប្រណីតភាពនៃការរស់នៅ។

### ២.១.៣.៣. ប្រណីតភាពនៃទំនើបកម្មសម្រាប់ការរស់នៅ

ប្រណីតភាពនៃទំនើបកម្មសម្រាប់ការរស់នៅ គឺសម្តៅទៅលើទីក្រុងដែលមានការអភិវឌ្ឍលើគ្រប់វិស័យដែលផ្តល់នូវភាពងាយស្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋ។ ជាក់ស្តែងនៅក្នុងទីក្រុងរណបជ្រោយចង្វារមាន

---

[76] គេហទំព័រ https://www.lareine.com.kh/news/eco-bussiness/29764/ ដកស្រង់ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០

ការអភិវឌ្ឍន្ទនូវគម្រោងធំៗជាច្រើន ជាពិសេសមានគម្រោងអភិវឌ្ឍន៍លំនៅឋានលំដាប់ខ្ពស់ជាច្រើននៅក្នុងតំបន់នេះផងដែរ ដែលក្នុងគម្រោងទាំងនោះបានរួមបញ្ចូលទាំងផ្សារទំនើប មជ្ឈមណ្ឌលតាំងពិព័រណ៍ បរិក្ខាកីឡា អគាររបស់រដ្ឋាភិបាល និងសាលារៀនជាដើម ដែលបានបង្កជាភាពងាយស្រួលក្នុងការរស់នៅរបស់ប្រជាពលរដ្ឋ។ លើសពីនេះទៅទៀត រាល់ការសាងសង់អគារធំៗ និងលំនៅឋានប្រណីតមានការយកចិត្តទុកដាក់លើទីក្រុងបៃតងឆ្លាតវៃ ដែលទាមទារឱ្យមានការគិតគូរច្រើនណាស់ ដើម្បីសម្រេចបាននូវស្តង់ដារទីក្រុងដែលមានភាពទាក់ទាញ និងផ្តល់ភាពសុខសាន្តដល់ប្រជាពលរដ្ឋ។ ចំពោះការសាងសង់អគារ និងលំនៅឋានប្រណីតត្រូវធ្វើឡើងដោយរក្សាទីធ្លាបៃតង កន្លែងលេងកម្សាន្ត ការទាញយកពន្លឺព្រះអាទិត្យមកប្រើជំនួស ឬកាត់បន្ថយការប្រើប្រាស់ថាមពលអគ្គិសនី ការដាំដើមឈើក្នុងអគារ និងប្រព័ន្ធចម្រោះទឹកកខ្វក់ជាដើម។ ទាំងអស់នេះសុទ្ធតែជារឿងចាំបាច់ ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍ ដោយត្រូវគោរពនូវពាក្យស្លោកដែលថា ការអភិវឌ្ឍត្រូវដើរទន្ទឹមគ្នានឹងការអភិរក្ស។ ស្ថិតនៅបរិបទបែបនេះហើយ ទើបធ្វើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងទីក្រុងរណបជ្រោយចង្វារ កាន់តែប្រកបទៅដោយប្រណីតភាពនៃទំនើបកម្មសម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋ។ គម្រោងទាំងនេះសុទ្ធតែមានប្រជាប្រិយភាព និងមានអតិថិជនច្រើនដែលទិញសំរាប់ស្នាក់នៅ ដើម្បីធ្វើការប្រកបអាជីវកម្ម ចំណែកឯតម្លៃផ្ទះនៅតាមបណ្តោយផ្លូវនៃតំបន់ជ្រោយចង្វារនោះទៀតសោត មានតម្លៃសមរម្យជាមួយនឹងគុណភាពនៃសំណង់ ក៏ដូចជាប្រណីតភាពនៃការរៀបចំលំនៅឋាននីមួយៗ ដែលអាចបង្កបាននូវភាពងាយស្រួលដល់ការរស់នៅរបស់ប្រជាជននៅក្នុងតំបន់នោះ។[77]

## ២.២. សកម្មភាពអាទិភាពនៃការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារ

ដើម្បីរៀបចំផែនការក្នុងការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារ ឱ្យក្លាយជាទីក្រុងមួយដែលមានការអភិវឌ្ឍស្ថាប័នដែលពាក់ព័ន្ធត្រូវពិនិត្យ និងធ្វើការរៀបចំតាមផែនការសកម្មភាពអាទិភាពដោយគោរពទៅតាមមាត្រដ្ឋានស្តង់ដារនៃការរៀបចំ ដែលស្របតាមគោលនយោបាយក្រោមការរៀបចំគ្រោងទុកផែនការរបស់រាជរដ្ឋាភិបាលកម្ពុជាដែលស្របតាមផែនការសកម្មភាពអាទិភាពនៃការអភិវឌ្ឍទីក្រុងដូចខាងក្រោម៖

### ២.២.១. សកម្មភាពអាទិភាពក្នុងវិស័យរៀបចំផែនការអភិវឌ្ឍទីក្រុង

- ផ្សព្វផ្សាយផែនការមេប្លង់គោលស្តីពីការប្រើប្រាស់ដីធ្លីឆ្នាំ ២០៣៥ ដើម្បីបង្ហាញពីហេដ្ឋារចនាសម្ព័ន្ធតំបន់សម្រាប់ពេលអនាគតនៃទីក្រុងប្រជុំជនក្នុងទីក្រុង និងទីតាំងមុខងារនៃការកំណត់តំបន់ដង់ស៊ីតេ បរិស្ថានសំណង់ដែលនឹងត្រូវបានបង្កើតទិសដៅនៃការលូតលាស់ និងការបែងចែកតំបន់ជុំវិញរាជធានី

[77] គេហទំព័រ https://www.lareine.com.kh/news/eco-bussiness/29764/ ដកស្រង់ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០

- កំណត់តំបន់អភិរក្សធនធានធម្មជាតិទីធ្លាសាធារណៈបេតិកភណ្ឌវប្បធម៌ និងភោជនីយដ្ឋានដែលត្រូវបានការពារអភិរក្សដែលមិនអនុញ្ញាតឱ្យមានសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ឬអគារណាមួយចូលធ្វើបានឡើយ
- កំណត់ទិសដៅនៃការពង្រីកទីប្រជុំជន ដើម្បីបញ្ចៀសហានិភ័យធម្មជាតិអាកាសធាតុដូចជា ការជន់លិច ឬការបាក់ច្រាំងទន្លេ
- រៀបចំផែនការសម្រាប់អភិវឌ្ឍន៍ទីក្រុងដែលបញ្ចេញកាបូនទាប បង្កើនដង់ស៊ីតេប្រជាជនខ្ពស់ និងសម្រាប់ប្រើប្រាស់ជាអតិបរមានូវហេដ្ឋារចនាសម្ព័ន្ធទីក្រុង
- ជៀសវាងការប្រើតែមធ្យោបាយដឹកជញ្ជូនដោយចំណាយច្រើនគ្មានប្រសិទ្ធភាពថាមពល និងមានការបំពុលបរិយាកាសដល់ដីតំបន់លំនៅឋានសម្រាប់គ្រួសារមានប្រាក់ចំណូលទាប និងកំណត់តំបន់ប្រមូលផ្តុំរោងចក្រឱ្យឆ្ងាយពីលំនៅឋាន
- កែលម្អការប្រមូល និងការគ្រប់គ្រងទិន្នន័យមូលដ្ឋានសម្រាប់ធ្វើគោលនយោបាយ
- អភិវឌ្ឍន៍ទីក្រុងប្រកបដោយភាពជឿជាក់ និងមានការវិភាគត្រឹមត្រូវ
- ពង្រឹងកិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងតម្លាភាពនៃដំណើររៀបចំផែនការ ដោយមានការចូលរួមពីសំណាក់គូរភាគីដែលពាក់ព័ន្ធ
- អនុវត្តយុទ្ធនាការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ តាមរយៈអាជ្ញាធរមូលដ្ឋានអំពីដំណើរការរៀបចំការអភិវឌ្ឍទីក្រុង
- កែលម្អអភិបាលកិច្ចមូលដ្ឋាន និងអនុវត្តបទប្បញ្ញត្តិនានាដែលទាក់ទងសណ្តាប់ធ្នាប់ ការថែរក្សាអនាម័យពីគ្រប់ភាគីទាំងអស់។[78]

### ២.២.២. សកម្មភាពអាទិភាពក្នុងវិស័យភាពធាយរងគ្រោះរបស់ទីក្រុង

នៅក្នុងសកម្មភាពនេះ ការការពារទីក្រុងក៏ដូចជាការប្រើប្រាស់នូវធនធានដែលមានពីមុនក្រោមការអភិវឌ្ឍយើងក៏ត្រូវគោរពទៅតាមច្បាប់ការពារបរិស្ថាន និងច្បាប់នគរូបនីយកម្ម និងសំណង់ដែលយើងគួរផ្តោតសំខាន់លើសកម្មភាពដូចខាងក្រោម៖

- ការពារបឹងធម្មជាតិ ស្ទឹង ប្រឡាយ និងតំបន់ដីសើមក្នុងទីក្រុង និងមិនត្រូវអនុញ្ញាតឱ្យមានការប្រើប្រាស់សំរាប់ការវិនិយោគពាណិជ្ជកម្មថែមទៀតឡើយ
- ស្តារឡើងវិញនូវច្រករបៀងបៃតងនៅក្នុងទីក្រុង និងបង្កើននូវទីធ្លាបៃតង
- ស្តារឡើងវិញនូវប្រព័ន្ធជលវិទ្យា ដើម្បីប្រើប្រាស់មុខងារក្នុងវិស័យចម្រុះ (នេសាទ វារីវប្បកម្ម កំសាន្ត...)

[78] ផែនការអភិវឌ្ឍទីក្រុងនិរន្តភាពសម្រាប់រាជធានីភ្នំពេញ២០១៨-២០៣០ ទំព័រទី៣៩

- ធ្វើឱ្យកាន់តែរឹងមាំនូវប្រព័ន្ធលូ ដើម្បីការពារទឹកជំនន់ជាមួយនឹងការទុកដាក់សំរាមឱ្យបានត្រឹមត្រូវ
- ធ្វើប្រព្រឹត្តិកម្ម (ចម្រោះ) ទឹកកខ្វក់ដែលមាននៅក្នុងតំបន់ផ្សេងៗ ព្រមទាំងបង្កើតប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់នៅតាមគ្រប់តំបន់។[79]

### ២.២.៣. សកម្មភាពអាទិភាពក្នុងវិស័យដឹកជញ្ជូន

នៅក្នុងវិស័យដឹកជញ្ជូនពិតជាមានសារៈណាស់នៅក្នុងការរស់នៅប្រចាំថ្ងៃសំរាប់បំពេញនូវ កិច្ចការងារផ្សេងៗ ប៉ុន្តែវាក៏បានបង្កជាផលប៉ះពាល់ដូចជា គ្រោះថ្នាក់ចរាចរណ៍ ការកកស្ទះចរាចរណ៍ ជាពិសេសការបំពុលបរិស្ថាន ដូច្នេះដើម្បីជួយសម្រួលឱ្យវិស័យដឹកជញ្ជូននេះមានលក្ខណៈប្រសើរស្របតាមគោលការណ៍នៅការអភិវឌ្ឍទីក្រុង ស្ថាប័នដែលពាក់ព័ន្ធត្រូវមានវិធានការដូចខាងក្រោមៈ

- បង្កើតប្រព័ន្ធគ្រប់គ្រងចរាចរណ៍ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ មានប្រសិទ្ធិភាពធនធាន និងមានបុគ្គលិកគ្រប់គ្រាន់នៅក្នុងការអនុវត្ត
- អនុវត្តបទប្បញ្ញត្តិដែលទាក់ទងនឹងការគ្រប់គ្រងចំណត
- បង្កើតប្រព័ន្ធតាមដានគុណភាពខ្យល់ប្រចាំថ្ងៃនៅក្នុងទីក្រុងដោយស្ថាប័នដែលពាក់ព័ន្ធ
- កាត់បន្ថយការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដោយប្រើម៉ាស៊ីន ដោយការលើកទឹកចិត្តឱ្យប្រើប្រាស់ទោចក្រយានយន្ត (កង់) ឬថ្មើរជើង ដោយរួមបញ្ចូលទាំងការរៀបចំផ្លូវសំរាប់អ្នកថ្មើរជើង និងអ្នកជិះកង់
- ប្រើប្រាស់មធ្យោបាយសាធារណៈ ដើម្បីកាត់បន្ថយការបំពុលបរិស្ថាន ការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍ជាដើម។[80]

### ២.២.៤. សកម្មភាពអាទិភាពក្នុងវិស័យបរិស្ថានសំណង់

ទាក់ទងទៅនឹងវិស័យសំណង់ការសាងសង់ត្រូវតែគោរពតាមគោលការណ៍នៃការការពារបរិស្ថាន បានន័យថារាល់សំណង់ទាំងអស់នៅពេលដែលធ្វើការសាងសង់ គឺត្រូវយកចិត្តទុកដាក់អំពីគុណភាពនៃសំណង់ជាពិសេសត្រូវគិតគូដល់បញ្ហាបរិស្ថានជាចម្បង។ លើសពីនេះទៅទៀត គម្រោងដែលសាងសង់ធំៗនិងថ្មីៗត្រូវតែបែងចែកទីធ្លាឱ្យបានគ្រប់គ្រាន់សំរាប់បៀងបៃតង និងត្រូវប្រកាន់ភ្ជាប់នូវបទដ្ឋានសំណង់អគារនៃបរិស្ថានបៃតង ព្រមទាំងជម្រុញសំណង់លំនៅឋានទីក្រុងដែលរួមបញ្ចូលពីរចនាបទស្ថាបត្យកម្មទំនើប និងបុរាណលាយគ្នាដើម្បីរក្សា អត្តសញ្ញាណរបស់ទីក្រុង។ ជាមួយគ្នានេះផងដែរ ត្រូវអនុវត្តច្បាប់ស្តីអំពីនគរូបនីយកម្មនិងសំណង់ក៏ដូចជាច្បាប់ដែលពាក់ព័ន្ធនឹងការបែងចែកទីធ្លាគ្រប់គ្រាន់នៅលើដីឡូត៍សាងសង់ សំរាប់បរិស្ថានបៃតង។[81]

---

[79] ផែនការអភិវឌ្ឍទីក្រុងនិរន្តភាពសម្រាប់រាជធានីភ្នំពេញ២០១៨-២០៣០ ទំព័រទី៣៩-៤០

[80] ផែនការអភិវឌ្ឍទីក្រុងនិរន្តភាពសម្រាប់រាជធានីភ្នំពេញ២០១៨-២០៣០ ទំព័រទី៤០

[81] ផែនការអភិវឌ្ឍទីក្រុងនិរន្តភាពសម្រាប់រាជធានីភ្នំពេញ២០១៨-២០៣០ ទំព័រទី៤១

### ២.២.៥. សកម្មភាពអាទិភាពនៅក្នុងវិស័យអភិវឌ្ឍន៍ទីធ្លាសាធារណៈ និងបេតិកភណ្ឌវប្បធម៌

នៅក្នុងវិស័យសំណង់ការរៀបចំសាងសង់ គឺត្រូវគិតគូរយ៉ាងយកចិត្តទុកដាក់ចំពោះទីធ្លាសាធារណៈ ព្រោះដោយហេតុថា ទីធ្លាសាធារណៈគឺជាទីលម្អដែលមានសារៈសំខាន់នៃសំណង់ និងសម្រាប់បំពេញតម្រូវការនៃការរស់នៅផងដែរ។ ជាមួយគ្នានេះផងដែរ ការសាងសង់សំណង់អគារផ្សេងៗត្រូវតែស្របតាមបទដ្ឋាននៃសំណង់ជាមួយនឹងការថែរក្សានូវទម្រង់នៃវប្បធម៌នៃសំណង់ដែរ ហើយទាក់ទងទៅនឹងទីធ្លាសាធារណៈ ក៏ដូចជាបេតិកភណ្ឌវប្បធម៌ ការសាងសង់សំណង់អគារក៏ត្រូវ៖

- ពង្រីកបន្ថែមឧទ្យាន សួនច្បារ និងរបៀងបៃតងសារធារណៈ ឬសាងសង់ និងរចនាឡើងវិញនូវតំបន់សាធារណៈដែលមានស្រាប់មួយចំនួន ដើម្បីឱ្យមានសោភណ្ឌភាពបន្ថែមពីនេះទៀត
- បង្កើតតំបន់បៃតងបន្ថែមទៀត ដើម្បីកាត់បន្ថយតំបន់ក្តៅនៅក្នុងទីក្រុង
- អភិវឌ្ឍន៍តំបន់កម្សាន្តពហុមុខងារបន្ថែមទៀត ដើម្បីគាំទ្រដល់អ្នកហាត់ប្រាណ សកម្មភាពកីឡា និងការរាប់អានគ្នានៅក្នុងសង្គម
- អភិរក្ស ជួសជុល និងកែលម្អតំបន់អគារបេតិកភណ្ឌប្រវត្តិសាស្ត្រផ្សេងៗ
- យុទ្ធនាការផ្សព្វផ្សាយលើវិស័យទេសចរណ៍ ដើម្បីជាការបង្កើនការយល់ដឹងពីតំបន់ផ្សេងៗនៅទីក្រុងជាពិសេសគឺតំបន់ក្រុងរណបជ្រោយចង្វារផ្ទាល់តែម្តង។[82]

[82] ផែនការអភិវឌ្ឍទីក្រុងនិរន្តភាពសម្រាប់រាជធានីភ្នំពេញ២០១៨-២០៣០ ទំព័រទី៤២

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ជាការពិតណាស់ការរៀបចំទីក្រុងរណបជ្រោយចង្វារឱ្យក្លាយជាទីក្រុងឆ្លាតវៃគឺ មានកត្តារួមផ្សំយ៉ាងច្រើន ដែលលក្ខខណ្ឌទាំងនោះមានជាច្រើនដូចជាការរៀបចំក្រុងឱ្យមានសណ្ដាប់ធ្នាប់ សោភណ្ឌភាព ជាពិសេសមាន ការបង្កើតនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជាមួយនឹងទំនើបកម្មនៃសំណង់ និងការថែរក្សាបរិស្ថាន ដោយមិនមានការ បំពុលផ្សេងៗនៃបរិស្ថានសង្គមនៃការរស់នៅ ដែលស្របគោលការណ៍នៃការសាងសង់ដូចជា ការរៀបចំនៃការ អភិវឌ្ឍទាំងនោះត្រូវគោរពតាមគោលការណ៍របស់ច្បាប់ស្ដីពីបរិស្ថាន ក៏ដូចជាច្បាប់ស្ដីពីសំណង់ និងប្លង់គោល ជាមួយនឹងបច្ចេកទេស ដើម្បីឱ្យការរៀបចំទីក្រុងរណបជ្រោយចង្វារក្លាយទៅជាទីក្រុងឆ្លាតវៃ។ ជាមួយគ្នានេះផង ដែរ សាលាខណ្ឌជ្រោយចង្វារ ជាពិសេសរាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការអភិវឌ្ឍ ទីក្រុងរណបមួយនេះ ដែលផ្ដោតសំខាន់ទៅលើការរៀបចំក៏ដូចជាការអភិវឌ្ឍទីក្រុងនេះប្រកបដោយទំនើបកម្ម ជាមួយនឹងសន្តិសុខនៃការអភិវឌ្ឍ ដោយអមជាមួយនឹងការថែរក្សាបរិស្ថានឱ្យបានល្អប្រសើរ និងការដែលមិនធ្វើ ឱ្យមានផលប៉ះពាល់ដល់បរិស្ថាននៃសំណង់។

លើសពីនេះទៅទៀតកត្តាដែលជំរុញឱ្យមានការអភិវឌ្ឍទីក្រុងរណបជ្រោយចង្វារទៅជាទីក្រុងឆ្លាតវៃក៏បាន ចូលរួមយ៉ាងសំខាន់អំពីសំណាក់ស្ថាប័នដែលពាក់ព័ន្ធក៏ដូចជាការវិនិយោគផ្សេងៗដែលស្របតាមគោលការណ៍ របស់រាជរដ្ឋាភិបាល ទន្ទឹមជាមួយនឹងច្បាប់ដែលកំណត់អំពីការអភិវឌ្ឍផ្សេងៗផងដែរ។ នាពេលបច្ចុប្បន្នស្ថាប័ន ដែលពាក់ព័ន្ធជាពិសេសស្ថាប័នដែលគ្រប់គ្រងផ្ទាល់នៅតំបន់ជ្រោយចង្វារ គឺបានខិតខំបំពេញតម្រូវការនៃការ វិនិយោគដើម្បីធ្វើឱ្យទីក្រុងនេះក្លាយទៅជាទីក្រុងរណបដែលមានសក្ដានុពលមិនថាវិស័យសំណង់ មិនថាវិស័យ ហេដ្ឋារចនាសម្ព័ន្ធ ជាមួយនឹងប្រព័ន្ធគ្រប់គ្រងតាមបែបបច្ចេកវិទ្យាថ្មីនៃភាពឆ្លាតវៃរបស់ទីក្រុងរណបជ្រោយចង្វារ ព្រមទាំងការកំសាន្ត និងទេសចរណ៍ រួមផ្សំជាមួយនឹងទំនើបកម្មនៃសំណង់ ប្រណីតភាពការរស់នៅ និងការ ថែរក្សាបរិស្ថាន។

សរុបសេចក្ដីមកយើងអាចសន្និដ្ឋានបានថាការរៀបចំទីក្រុងរណបជ្រោយចង្វារឱ្យទៅជាទីក្រុងឆ្លាតវៃ គឺពិត ជាមានសារៈសំខាន់ណាស់ពីព្រោះការរៀបចំទីក្រុងរណបនេះ គឺបានផ្ដល់សារៈសំខាន់សម្រាប់សេដ្ឋកិច្ចសម្រាប់ ប្រទេសកម្ពុជាតាមរយៈការវិនិយោគ ក៏ដូចជាសំណង់ទំនើបៗ ដែលអាចបង្កជាលក្ខណៈងាយស្រួលរស់នៅ សម្រាប់ប្រជាជនគ្រប់លំដាប់ថ្នាក់ ទៅតាមការបំពេញតម្រូវការយ៉ាងពេញចិត្តជាមួយនឹងការរស់នៅជាមួយ នឹងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងតម្រូវការយ៉ាងសម្បូរបែបដែលកើតចេញពីទីក្រុងដែលមានការរៀបចំយ៉ាងល្អ ប្រសើរលើគ្រប់វិស័យជាមួយនឹងការថែរក្សាបរិស្ថានប្រកបទៅដោយគុណភាព។ មិនត្រឹមតែប៉ុណ្ណោះការអភិវឌ្ឍ មួយនេះបានធ្វើឱ្យទីក្រុងនេះកាន់តែមានសោភណ្ឌភាព ក៏ដូចជាភាពទាក់ទាញសម្រាប់ការរស់នៅរបស់ប្រជា ជនដ៏ល្អប្រសើរនាពេលបច្ចុប្បន្ននិងអនាគត។

# អនុសាសន៍

# អនុសាសន៍

យោងតាមការពិនិត្យមើលអំពីស្ថានភាពជាក់ស្តែងនៃការអភិវឌ្ឍទីក្រុងរណបខណ្ឌជ្រោយចង្វារ យើងឃើញថាគឺពិតជាមានការអភិវឌ្ឍក៏ដូចជាការរីកចម្រើនគួរឱ្យកត់សម្គាល់ដោយក្នុងនោះផងដែរការអភិវឌ្ឍផ្សេងៗជាច្រើនមិនថាវិស័យសំណង់ហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាទំនើបកម្មនៃសំណង់រួមផ្សំជាមួយនឹងសោភណ្ឌភាពនៃបរិស្ថានសណ្តាប់ធ្នាប់និងសំណង់សំខាន់ៗជាច្រើន ដែលជាកត្តាបម្រើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋកាន់តែមានភាពល្អប្រសើរ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយទោះបីជាមានការអភិវឌ្ឍខ្លាំងប៉ុន្តែនៅតែមានបញ្ហាតិចតួចដែលអាចបង្កជាផលលំបាកខ្លះសម្រាប់ការអភិវឌ្ឍ ប៉ុន្តែទោះជាយ៉ាងនេះក្តីបញ្ហាទាំងអស់នោះត្រូវបានរដ្ឋបាលខណ្ឌជ្រោយចង្វារដូចជា ថ្នាក់ដឹកនាំរបស់រដ្ឋាភិបាលបានយកចិត្តទុកដាក់ធ្វើយ៉ាងណាឱ្យការអភិវឌ្ឍដំណើរការយ៉ាងរលូនជាមួយនឹងការខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍតំបន់នោះផងដែរ។

ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះយើងខ្ញុំសូមសេចក្តីអនុញ្ញាតបញ្ចេញនូវមតិដូចតទៅ៖

- ស្នើសុំដល់ថ្នាក់ដឹកនាំនៃរដ្ឋបាលខណ្ឌជ្រោយចង្វាសូមមេត្តាពង្រឹងច្បាប់ អនុវត្តនូវគោលនយោបាយភូមិឃុំមានសុវត្ថិភាពឱ្យបានរឹងមាំ ដើម្បីធានាដល់សុវត្ថិភាពរស់នៅរបស់ប្រជាជនពលរដ្ឋ
- សូមស្នើសុំឱ្យថ្នាក់ដឹកនាំ អាជ្ញាធរមានសមត្ថកិច្ចដែលសហការជាមួយស្ថាប័នឯកជន ឬស្ថាប័នដែលពាក់ព័ន្ធធ្វើយ៉ាងណាអនុវត្តនូវការសាងសង់ដែលប្រកបទៅដោយប្រសិទ្ធភាព និងគុណភាព
- ទន្ទឹមនឹងមានការអភិវឌ្ឍនេះផងដែរ សូមឱ្យប្រជាពលរដ្ឋទាំងអស់បានចូលរួមនូវសកម្មភាពថែរក្សាបរិស្ថានអនាម័យ ដើម្បីឱ្យតំបន់នោះក្លាយជាតំបន់ដែលទទួលបានការវិនិយោគជាមួយនឹងបរិស្ថានល្អប្រសើរ ដើម្បីការរស់នៅដែលប្រកបទៅដោយសុខភាព អនាម័យ និងបរិស្ថានបៃតង
- រាល់ច្បាប់នៃការសាងសង់ ឬវិនិយោគផ្សេងៗ ត្រូវគោរពតាមគោលការណ៍ស្តង់ដារនៃច្បាប់ដែលរាជរដ្ឋាភិបាលបានកំណត់ដើម្បីឱ្យទទួលបាននូវគុណភាពពិតនៃការសាងសង់សម្រាប់បម្រើដល់ការរស់នៅរបស់ប្រជាពលរដ្ឋ
- សូមស្នើសុំដល់និស្សិត និងអ្នកដែលបានអានលើប្រធានបទសារណារបស់យើងខ្ញុំបាទសូមមេត្តាចូលរួមចំណែកចែករំលែកនូវចំណេះដឹងលើបញ្ហានេះនឹងចូលរួមជម្រុញ ក៏ដូចជាចូលរួមចំណែកតាមលទ្ធភាពក្នុងការចូលរួមជួយថែរក្សា អភិវឌ្ឍនូវសមិទ្ធផលផ្សេងៗ និងថ្មីៗបន្ថែមទៀត។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧
- ច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងគ្រប់គ្រងធម្មជាតិ, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦
- ច្បាប់ស្តីពីសំណង់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៩
- អនុក្រឹត្យលេខ ៥៧៧ អនក្រ.បក ស្តីពី ការបង្កើតខណ្ឌជ្រោយចង្វារនៃរាជធានីភ្នំពេញ
- អនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ
- អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតខណ្ឌកំបូល នៃរាជធានីភ្នំពេញ
- អនុក្រឹត្យស្តីពី ការគ្រប់គ្រងថង់ប្លាស្ទិច ឆ្នាំ ២០១៧
- អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង
- អនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩  ស្តីពី ការត្រួតពិនិត្យការបំពុលទឹក
- អនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩  ស្តីពី ការគ្រប់គ្រងសំណល់រឹង
- អនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ប្រកាសអន្តរក្រសួងលេខ៨០ រវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាននៅក្នុងឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសំរាម និងកាកសំណល់រឹងនៅថ្នាក់ខេត្ត ក្រុង
- សេចក្តីណែនាំលេខ១៨ អយក.សណន ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ស្តីពី ចំណីអាហារនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន
- ផែនការណែនាំលេខ ០២០ ផក, ស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព
- សេចក្តីណែនាំ ស្តីពី ការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ, លេខ ០១៣/១៨ សណន ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៨
- ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា
- ផែនការអភិវឌ្ឍទីក្រុងនិរន្តភាពសម្រាប់រាជធានីភ្នំពេញ២០១៨-២០៣០

## ២. សៀវភៅឯកសារនិពន្ធ

- សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា
- វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត

## ៣. គេហទំព័រ

- គេហទំព័រ ក្រសួងបរិស្ថាន https://www.moe.gov.kh/
- គេហទំព័រ ក្រសួងមហាផ្ទៃ https://www.interior.gov.kh/report/detail/2325
- គេហទំព័រព័ត៌មាន http://news.khbmedia.asia
- គេហទំព័រព័ត៌មាន https://www.propertyarea.asia/
- គេហទំព័រ https://www.khsearch.com/qna/16521
- គេហទំព័រ https://thmeythmey.com/?page=detail&id=58963
- គេហទំព័រ អប្សរាសង់ត្រាល់ http://apsaracentral.com/article/1150
- គេហទំព័រ https://www.postkhmer.com
- គេហទំព័រ Smart-City-Plan-2018-2035.
- គេហទំព័រព័ត៌មាន https://www.lareine.com.kh/news/eco-bussiness/29764/
- គេហទំព័រ https://www.lareine.com.kh/news/eco-bussiness/29764/
- គេហទំព័រ https://opendevelopmentcambodia.net/km/topics/air-pollution/
- គេហទំព័រ https://opendevelopmentcambodia.net/km/topics/water-pollution/
- គេហៈទំព័រ http://www.freshnewsasia.com/index.php/en/localnews/140598-2019-11-24-09-06-53.html
- គេហទំព័រ https://www.realestate.com.kh/km/location-profiles/the-ultimate-guide-to-chroy-changvar/

# ឧបសម្ព័ន្ធ

# មាតិកាឧបសម្ព័ន្ធ

**១. ឧបសម្ព័ន្ធរូបភាព**

ឧបសម្ព័ន្ធទី១៖ ផែនទីរដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខណ្ឌជ្រោយចង្វារ

ឧបសម្ព័ន្ធទី២៖ ទីតាំងសំខាន់ៗនៅក្នុងខណ្ឌជ្រោយចង្វារ និងសោភណ្ឌភាពរបស់ខណ្ឌជ្រោយចង្វារ

ឧបសម្ព័ន្ធទី៣៖ សកម្មភាពរបស់រដ្ឋបាលខណ្ឌជ្រោយចង្វារ

ឧបសម្ព័ន្ធទី៤៖ តំបន់ពហុកីឡដ្ឋានមរតកតេជោ

**២. ឧបសម្ព័ន្ធគតិយុត្តិ**

ឧបសម្ព័ន្ធទី១៖ ប្លង់គោលប្រើប្រាស់ដី រាជធានីភ្នំពេញ ២០៣៥

ឧបសម្ព័ន្ធទី២៖ ច្បាប់ស្តីពីសំណង់

ឧបសម្ព័ន្ធទី៣៖ អនុក្រឹត្យលេខ ៥៧៧ អនក្រ.បក ស្តីពី ការបង្កើតខណ្ឌជ្រោយចង្វារ នៃរាជធានីភ្នំពេញ

ឧបសម្ព័ន្ធទី៤៖ អនុក្រឹត្យលេខ ០៣ អនក្រ.បក ស្តីពីការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ

ឧបសម្ព័ន្ធទី៥៖ អនុក្រឹត្យលេខ ០៤ អនក្រ.បក ស្តីពី ការបង្កើតខណ្ឌកំបូលនៃរាជធានីភ្នំពេញ

ឧបសម្ព័ន្ធទី៦៖ អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង

ឧបសម្ព័ន្ធទី៧៖ អនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការត្រួតពិនិត្យការបំពុលទឹក

ឧបសម្ព័ន្ធទី៨៖ អនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការគ្រប់គ្រងសំណល់រឹង

ឧបសម្ព័ន្ធទី៩៖ អនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

ឧបសម្ព័ន្ធទី១០៖ ផែនការណែនាំលេខ ០២០ ជក, ស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព

ឧបសម្ព័ន្ធទី១១៖ សេចក្តីណែនាំ ស្តីពី ការដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ, លេខ ០១៣/១៨ សណន ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៨

# ឧបសម្ព័ន្ធរូបភាព

# ឧបសម្ព័ន្ធទី១៖ ផែនទីរដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខណ្ឌជ្រោយចង្វារ




ផែនទីរដ្ឋបាលរាជធានីភ្នំពេញ




ផែនទីរដ្ឋបាលខណ្ឌជ្រោយចង្វារ

# ឧបសម្ព័ន្ធទី២៖ ទីតាំងសំខាន់ៗនៅក្នុងខណ្ឌជ្រោយចង្វារ និងសោភណ្ឌភាពរបស់ខណ្ឌជ្រោយចង្វារ




ទីតាំង៖ សាលាខណ្ឌជ្រោយចង្វារ



ទីតាំង៖ រង្វង់មូលតាព្រហ្មមុខបួន




ទីតាំង៖ ស្ពានបាឡេ



ទីតាំង៖ សណ្ឋាគារសុខា



ទីតាំង៖ វិមានឈ្នះ ឈ្នះ


ទីក្រុងរថយន្ត
វិមានអាហារ
អគារអេស៊ីអាយស៊ី
សួនដាយណូស័រ


ស្ពានបាឡេ
អគារសាលពិពណ៌
រង្វង់មូលនាងទេពមច្ឆា


ផ្លូវឆ្ពោះទៅកាន់ផ្លូវជាតិលេខ 5
ផ្លូវឆ្ពោះទៅកាន់ផ្លូវជាតិលេខ 6A

# ឧបសម្ព័ន្ធទី៣៖ សកម្មភាពរបស់រដ្ឋបាលខណ្ឌជ្រោយចង្វារ





សកម្មភាព៖ ការប្រមូលសំរាម និងការលាងសំអាតផ្លូវនៅក្នុងខណ្ឌជ្រោយចង្វារ





សកម្មភាព៖ ការរៀបចំប្រព័ន្ធកែលម្អបំពុងលូថ្មី





សកម្មភាព៖ ការជួសជុលកែលម្អផ្លូវមួយចំនួន





សកម្មភាព៖ ការចុះរៀបចំសណ្តាប់ធ្នាប់តាមចំណីផ្លូវក្នុងខណ្ឌជ្រោយចង្វារ





សកម្មភាព៖ រដ្ឋបាលខណ្ឌជ្រោយចង្វារចុះណែនាំ និងរៀបចំសណ្តាប់ធ្នាប់លើផ្លូវជាតិលេខ ៦A

# ឧបសម្ព័ន្ធទី៤៖ តំបន់ពហុកីឡដ្ឋានមរតកតេជោ



ពហុកីឡដ្ឋានមរតកតេជោ

# ឧបសម្ព័ន្ធគតិយុត្ត

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មរាជធានីភ្នំពេញ

# ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ២០៣៥
## Land Use Master Plan of Phnom Penh City 2035

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ








មាត្រដ្ឋានផែនទី
មាត្រដ្ឋាន ១:៥០០០០
0 1,500 3,000 6,000 Meters
មួយសង់ទីម៉ែត្រស្មើនឹង៥០០ម៉ែត្រ
1centimetre equal 500meters

សន្លឹកលេខ: ០១

សិក្សាដោយ : គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មរាជធានីភ្នំពេញ
ជំនួយបច្ចេកទេសដោយ : ទីចាត់ការរៀបចំក្រុង សាលារាជធានីភ្នំពេញ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ

ប៉ា សុជាតិវង្ស

អ៊ឹម ឈុនលឹម

# ព្រះរាជក្រម

នស/រកម/១១១៩/ ០១៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីសំណង់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# សំណង់

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ចំនួនទឹកប្រាក់អប្បបរមាដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២០ .-**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈនិងអាជ្ញាបណ្ណឬការអនុញ្ញាតផ្សេងទៀតឱ្យប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២១ .-**

ការស្នើសុំអាជ្ញាបណ្ណឬការអនុញ្ញាតផ្សេងទៀតដើម្បីប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវបង់កម្រៃសេវា។

កម្រៃសេវាអាជ្ញាបណ្ណនិងការអនុញ្ញាតផ្សេងទៀតដើម្បីប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

កម្រៃសេវាអាជ្ញាបណ្ណនិងការអនុញ្ញាតផ្សេងទៀតដើម្បីប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវបានជាប្រយោជន៍ដល់ថវិកាជាតិនិងថវិកាថ្នាក់ក្រោមជាតិ។

## ជំពូកទី៧

## ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ និងមន្ទីរពិសោធន៍សំណង់

**មាត្រា២២ .-**

សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលចាំបាច់សម្រាប់ធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ត្រូវមានការបញ្ជាក់ទទួលស្គាល់ឬការបញ្ជាក់អនុលោមភាពដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬតាមស្តង់ដាកម្ពុជាដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដាជាតិ ដោយត្រូវមានបិទឬបោះពុម្ពសញ្ញាស្តង់ដាកម្ពុជានិងត្រូវមានអាជ្ញាបណ្ណប្រើសញ្ញាស្តង់ដាកម្ពុជា។

បែបបទនិងនីតិវិធីនៃការបញ្ជាក់ទទួលស្គាល់ឬការបញ្ជាក់អនុលោមភាពនិងប្រភេទនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលចាំបាច់សម្រាប់ធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៣ .-**

ការផលិត ការចែកចាយ ការនាំចូល ការដាក់លក់ ការផ្គត់ផ្គង់ ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ដែលគ្មានបិទសញ្ញាស្តង់ដាកម្ពុជា ឬគ្មានការបញ្ជាក់ទទួលស្គាល់ ឬគ្មានការបញ្ជាក់អនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវហាមឃាត់ក្នុងករណីសម្ភារៈសំណង់ បរិក្ខារសំណង់

ឬផលិតផលសំណង់នោះ តម្រូវឱ្យមានបិទសញ្ញាស្តង់ដាកម្ពុជា ឬការបញ្ជាក់ទទួលស្គាល់ ឬការបញ្ជាក់ពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវហាមឃាត់។

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យអនុលោមភាពនៃការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៤ ..**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវរៀបចំឱ្យមានមន្ទីរពិសោធន៍ជាតិសំណង់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៥ ..**

មន្ទីរពិសោធន៍សំណង់ក្នុងគោលដៅអាជីវកម្មត្រូវមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ការបង្កើតមន្ទីរពិសោធន៍សំណង់ក្នុងគោលដៅសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាលត្រូវមានលិខិតអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតលិខិតអនុញ្ញាតបង្កើតមន្ទីរពិសោធន៍សំណង់ក្នុងគោលដៅសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាល ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៨

## លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ

**មាត្រា២៦ ..**

រាល់ការងារសាងសង់ឬរុះរើត្រូវមានការអនុញ្ញាតជាមុនដោយអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា២៧ ..**

ការងារសាងសង់ឬរុះរើក្នុងស្ថានភាពអាសន្នឬគ្រោះមហន្តរាយដើម្បីជួយសង្គ្រោះឬការពារអាយុជីវិតឬបង្ការ មិនឱ្យមានការប៉ះពាល់ឬខូចខាតធ្ងន់ធ្ងរដល់សុខភាពឬទ្រព្យសម្បត្តិក្នុងភាពអាសន្ន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតជាមុនឡើយ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលត្រូវបានសាងសង់ក្នុងស្ថានភាពអាសន្នត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់តាមលក្ខខណ្ឌនិងនីតិវិធីជាធរមាន។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលបានរុះរើក្នុងភាពអាសន្នត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា២៨ .-**

រាល់ការងារសាងសង់ឬរុះរើដែលមិនតម្រូវឱ្យមានការអនុញ្ញាតមានដូចខាងក្រោម៖

- សំណង់ទំហំតូចដែលមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ
- លំនៅឋានធ្វើពីឈើ ផ្ទះថ្មក្រោមឈើលើ ផ្ទះតៀមធ្វើពីឈើឬថ្មនៅទីជនបទឬស្រែចម្ការ ដែលមិនប៉ះពាល់ដល់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌ តំបន់អភិរក្ស ឬតំបន់ការពារ
- សំណង់បម្រើដល់សន្តិសុខជាតិនិងការពារជាតិ។

ប្រភេទនិងទំហំនៃការងារសាងសង់ឬរុះរើដែលមិនតម្រូវឱ្យមានការអនុញ្ញាត ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៩ .-**

រាល់ការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់មិនតម្រូវឱ្យមានការអនុញ្ញាតឡើយ ក្នុងករណីដែលការងារនោះមិនប៉ះពាល់ដល់រចនាសម្ព័ន្ធទ្រទម្ងន់ សោភណភាពខាងក្រៅ ឬមុខងារប្រើប្រាស់ទាំងមូលឬផ្នែកណាមួយនៃសំណង់ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។ ក្នុងករណីនេះ ម្ចាស់សំណង់ត្រូវជូនដំណឹងជាមុនទៅអាជ្ញាធរមានសមត្ថកិច្ច។

ប្រភេទនិងទំហំការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់ដែលមិនតម្រូវឱ្យមានការអនុញ្ញាតត្រូវកំណត់ដោយអនុក្រឹត្យ។

បែបបទនិងនីតិវិធីនៃការជូនដំណឹងជាមុនអំពីការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់ដែលមិនតម្រូវឱ្យមានការអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣០ .-**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣១ .-**

លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើមិននាំឱ្យបុគ្គលដែលទទួលបានលិខិតអនុញ្ញាតនោះរួចផុតពីកាតព្វកិច្ចនិងការទទួលខុសត្រូវ តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀតឡើយ។

ការអនុវត្តការងារសាងសង់ឬរុះរើចំពោះសំណង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតមិននាំឱ្យម្ចាស់សំណង់រួចផុតពីកាតព្វកិច្ចនិងការទទួលខុសត្រូវតាមច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតឡើយ។

## ជំពូកទី៩
## ការគ្រប់គ្រងគម្រោងប្លង់

**មាត្រា៣២ .-**

រាល់គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើត្រូវចុះហត្ថលេខាទទួលខុសត្រូវដោយអ្នកសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៣ .-**

រាល់គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម។

គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើសំណង់គ្រប់ប្រភេទ លើកលែងតែសំណង់សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារ និងសេវាសម្រាប់ជនមានពិការភាព ជាអាទិ៍ ផ្លូវនិងជម្រាលសម្រាប់ផ្លាស់ទី ឧបករណ៍ធ្នាក់ដៃ ជណ្តើរយន្ត បន្ទប់អនាម័យ ចំណតយានយន្តពិសេសសម្រាប់ជនពិការ និងផ្លាកសញ្ញានានា។

អនុលោមភាពនៃគម្រោងប្លង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម ត្រូវបញ្ជាក់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

គម្រោងប្លង់សាងសង់ឬរុះរើសំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានការបញ្ជាក់ពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៤ .-**

ម្ចាស់សំណង់ត្រូវធានាថាការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវបានអនុវត្តត្រឹមត្រូវតាមគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។

មុនការអនុវត្តការងារសាងសង់ឬរុះរើ អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឱ្យកែសម្រួលគម្រោងប្លង់ដែលបានទទួលការយល់ព្រមរួចហើយ។

ការអនុញ្ញាតកែសម្រួលគម្រោងប្លង់ត្រូវធ្វើឡើងតាមរយៈលិខិតអនុញ្ញាតកែសម្រួលគម្រោងប្លង់។

លក្ខខណ្ឌនិងនីតិវិធីនៃការអនុញ្ញាតកែសម្រួលគម្រោងប្លង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៥ .-**

រាល់ស្នាដៃរបស់អ្នកសិក្សាគម្រោងប្លង់ដែលមានលក្ខណៈដើមទាំងមូលឬដោយផ្នែកដែលបានទទួលការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាតសាងសង់ ត្រូវបានការពារពីការលួចចម្លងស្របតាមបទប្បញ្ញត្តិជាធរមាន។

គម្រោងប្លង់មួយមិនអាចយកទៅអនុវត្តនៅទីតាំងផ្សេងទៀតដោយគ្មានការអនុញ្ញាតពីអ្នកសិក្សាដែលបានចុះហត្ថលេខាលើគម្រោងប្លង់នោះនិងម្ចាស់សំណង់បានឡើយ។

រាល់ការអនុវត្តគម្រោងប្លង់ដែលមានតម្លៃពិសេសផ្នែកស្ថាបត្យកម្មនៅទីតាំងផ្សេងទៀតត្រូវបានហាមឃាត់។ គម្រោងប្លង់ដែលមានតម្លៃពិសេសផ្នែកស្ថាបត្យកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី១០

## ការគ្រប់គ្រងការងារសាងសង់ឬរុះរើ

**មាត្រា៣៦ .-**

រាល់ការងារសាងសង់ឬរុះរើត្រូវអនុវត្តដោយអ្នកសាងសង់ដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋបាលរាជធានី ខេត្ត។

អ្នកសាងសង់មិនតម្រូវឱ្យមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋបាលរាជធានី ខេត្ត លុះត្រាតែអ្នកសាងសង់នោះបានបំពេញគ្រប់លក្ខខណ្ឌដូចខាងក្រោម៖

- ជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់
- សាងសង់ឬរុះរើសំណង់ដែលជាលំនៅឋានផ្ទាល់ខ្លួន និង
- សាងសង់ឬរុះរើសំណង់តាមជំនាញវិជ្ជាជីវៈរបស់ខ្លួន។

**មាត្រា៣៧ .-**

រាល់ការងារសាងសង់ឬរុះរើត្រូវអនុវត្តស្របតាម៖

- គម្រោងប្លង់
- បទប្បញ្ញត្តិបច្ចេកទេសសំណង់
- បទប្បញ្ញត្តិជាធរមានដទៃទៀត។

រាល់ការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាត ត្រូវអនុវត្តតាមគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។

**មាត្រា៣៨ .-**

រាល់ការងារសាងសង់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ជាមុន។

លក្ខខណ្ឌនិងនីតិវិធីនៃការចេញលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៩ .-**

អ្នកសាងសង់ត្រូវធានាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាននៅការដ្ឋានសំណង់របស់ខ្លួន។

## ជំពូកទី២២

## អវសានបញ្ញត្តិ

**មាត្រា១១០ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

**មាត្រា១១១ ..**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ៦កើត ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៩

នស/រកម.១១១៩.០៥៦

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៧៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតខណ្ឌជ្រោយចង្វារ នៃរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើត**ខណ្ឌជ្រោយចង្វារ** នៃរាជធានីភ្នំពេញ ដោយកាត់យកសង្កាត់ចំនួន **០៥** ពីខណ្ឌឫស្សីកែវ នៃរាជធានីភ្នំពេញគឺ សង្កាត់ជ្រោយចង្វារ សង្កាត់ព្រែកលៀប សង្កាត់ព្រែកតាសេក សង្កាត់កោះដាច់ និងសង្កាត់បាក់ខែង។

ព្រំប្រទល់រដ្ឋបាល**ខណ្ឌជ្រោយចង្វារ** ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ទីតាំងសាលា**ខណ្ឌជ្រោយចង្វារ** ត្រូវស្ថិតនៅក្នុងសង្កាត់ព្រែកលៀប។

**មាត្រា ៣.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល**ខណ្ឌជ្រោយចង្វារ** ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានីភ្នំពេញ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សាខណ្ឌឫស្សីកែវ អភិបាលខណ្ឌឫស្សីកែវ និងក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...០៣....អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១៣ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ ដោយកាត់យកសង្កាត់ចំនួន០៧ ពីខណ្ឌចំការមន នៃរាជធានីភ្នំពេញគឺ សង្កាត់បឹងកេងកងទី១ សង្កាត់បឹងកេងកងទី២ សង្កាត់បឹងកេងកងទី៣ សង្កាត់អូឡាំពិច សង្កាត់ទំនប់ទឹក សង្កាត់ទួលស្វាយព្រៃទី១ និងសង្កាត់ទួលស្វាយព្រៃទី២។

ព្រំប្រទល់រដ្ឋបាលខណ្ឌបឹងកេងកង ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានផ្ទេរទីតាំងសាលាខណ្ឌចំការមនដែលស្ថិតក្នុងសង្កាត់បឹងកេងកងទី៣ ទៅឲ្យសាលាខណ្ឌបឹងកេងកង។

ទីតាំងសាលាខណ្ឌចំការមន ត្រូវស្ថិតនៅក្នុងសង្កាត់ទន្លេបាសាក់។

**មាត្រា ៣.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលខណ្ឌបឹងកេងកង ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានីភ្នំពេញ គណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សាខណ្ឌចំការមន គណៈអភិបាលខណ្ឌចំការមន ក្រុមប្រឹក្សាខណ្ឌបឹងកេងកង គណៈអភិបាលខណ្ឌបឹងកេងកង និងក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ៍៣ កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមករា ឆ្នាំ២០១៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...០៤...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតខណ្ឌកំបូល នៃរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១៣ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតខណ្ឌកំបូល នៃរាជធានីភ្នំពេញ ដោយកាត់យកសង្កាត់ចំនួន០៦ ពីខណ្ឌពោធិ៍សែនជ័យ នៃរាជធានីភ្នំពេញគឺ សង្កាត់កំបូល សង្កាត់កន្ទោក សង្កាត់ឪឡោក សង្កាត់ស្នោរ សង្កាត់ភ្លើងឆេះរទេះ សង្កាត់បឹងធំ និងកាត់យកសង្កាត់ចំនួន០១ ពីខណ្ឌដង្កោ នៃរាជធានីភ្នំពេញគឺ សង្កាត់ប្រទះឡាង។

ព្រំប្រទល់រដ្ឋបាលខណ្ឌកំបូល ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ខណ្ឌកំបូល មានសង្កាត់ចំនួន០៧ គឺ សង្កាត់កំបូល សង្កាត់កន្ទោក សង្កាត់ឪឡោក សង្កាត់ស្នោរ សង្កាត់ភ្លើងឆេះរទេះ សង្កាត់បឹងធំ និងសង្កាត់ប្រទះឡាង។

ទីតាំងសាលាខណ្ឌកំបូល ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។

**មាត្រា ៣.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលខណ្ឌកំបូល ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានីភ្នំពេញ គណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ គណៈអភិបាលខណ្ឌពោធិ៍សែនជ័យ ក្រុមប្រឹក្សាខណ្ឌដង្កោ គណៈអភិបាលខណ្ឌដង្កោ ក្រុមប្រឹក្សាខណ្ឌកំបូល គណៈអភិបាលខណ្ឌកំបូល និងក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៣ កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០១៩

ប.ហ.ត នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលខ្យល់

# និងការរំខានដោយសំលេង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤២ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលខ្យល់

# និងការរំខានដោយសំលេង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០០។

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសំលេងក្នុងបរិយាកាសសំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័តនិងអចល័តទាំងឡាយដែលបង្កអោយមានការបំពុលខ្យល់ និងការរំខានដោយសំលេងនៅក្នុងបរិយាកាស ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក -"ប្រភពបំពុល" ចែកចេញជាពីរគឺ :

-ប្រភពចល័ត : គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មាន : យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសំលេងគ្រប់ភេទ ។

-ប្រភពអចល័ត : គឺជាប្រភពដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មាន : រោងចក្រ សហគ្រាស ឃ្លាំងស្តុកសំភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំលេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ ។

ខ-"សារធាតុបំពុល" គឺសំដៅទៅលើផ្សែង លំអងផ្សែង ធូលី ផេះ ភាគល្អិតនៃសំណង់ ឧស្ម័ន ចំហាយទឹកអ័ព្ទ ក្លិន និងសារធាតុវិទ្យុសកម្ម ។

គ-"សារធាតុឆេះ" គឺសំដៅទៅលើប្រេងឥន្ធនៈ ធ្យូងថ្ម ឧស្ម័នធម្មជាតិ អុស ធ្យូង ឬសារធាតុគីមីផ្សេងៗទៀត ដែលមានប្រតិកម្មចំហេះ

ឃ-"កំរិតកំណត់ស្តង់ដារ" គឺជាកំរិតកំណត់កំហាប់អតិបរមានៃសាធារបំពុល ដែលអាចអនុញ្ញាតអោយមាននៅក្នុងមជ្ឈដ្ឋានបរិស្ថាន ឬដែលអាចអនុញ្ញាតអោយបញ្ចេញពីប្រភពបំពុលចូលទៅក្នុងបរិស្ថាន ។

## ជំពូកទី ២

## បញ្ញត្តិលើការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេង

**មាត្រា ៤.-**

កំរិតកំណត់ស្តង់ដារគុណភាពខ្យល់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ១ និងកំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់មានចែងនៅក្នុងឧបសម្ព័ន្ធ ២ ។

**មាត្រា ៥.–**

ក៏រិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញពីប្រភពអចល័តចូលទៅក្នុងបរិយាកាស មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និងក៏រិតកំណត់ស្តង់ដារនៃការបញ្ចេញឧស្ម័នពីប្រភពអចល័ត មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ ។

**មាត្រា ៦.–**

ក្នុងករណីចាំបាច់ ក៏រិតកំណត់ស្តង់ដារដូចមានចែងក្នុងមាត្រា៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះ នឹងត្រូវពិនិត្យកែសំរួលរៀងរាល់ប្រាំឆ្នាំម្តងតាមសំណើរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៧.–**

ក៏រិតកំណត់ស្តង់ដារបញ្ចេញសំលេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងក៏រិតកំណត់ស្តង់ដារសំលេងអតិបរមាសំរាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ៦ និងឧបសម្ព័ន្ធ ៧ ។

**មាត្រា ៨.–**

ហាមឃាត់ដាច់ខាតនូវការបញ្ចេញសារធាតុពុលទៅក្នុងបរិយាកាស ដែលមិនឆ្លើយតបទៅនឹងក៏រិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និងឧបសម្ព័ន្ធ ៤ ។

**មាត្រា ៩.–**

ហាមឃាត់ដាច់ខាតនូវការបង្កអោយមានសំលេង ដែលមិនឆ្លើយតបទៅនឹងក៏រិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ ៦ និងឧបសម្ព័ន្ធ ៧ ។

**មាត្រា ១០.–**

ការនាំចូល និងផលិតនូវសារធាតុឆេះ ដែលមានជាតិស្ពាន់ធ័រ សំណ បង់សែន និងសារធាតុអ៊ីដ្រូកាប៊ួប្រហើរ ត្រូវឆ្លើយតបទៅនឹងក៏រិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងឧសម្ព័ន្ធ ៨ ។

**មាត្រា ១១.–**

ហាមឃាត់ដាច់ខាតការនាំចូល ប្រើប្រាស់ ផលិតយានយន្ត និងគ្រឿងយន្តគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ដែលយានយន្ត និងគ្រឿងយន្តទាំងនោះបានបញ្ចេញសារធាតុបំពុល និងសំលេងមិនឆ្លើយតបទៅនឹងក៏រិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ និងឧបសម្ព័ន្ធ ៥ ។

**មាត្រា ១២.–**

ហាមដាច់ខាតការបង្ហូរ ឬការធ្វើអោយលេចធ្លាយសារធាតុឆេះ ប្រេងឥន្ធនៈ ធាតុវិទ្យុសកម្ម ឬសារធាតុគីមីផ្សេងៗទៀតចូលក្នុងបរិយាកាស ទឹក និងដី ។

## ជំពូកទី ៣
## ការសុំអនុញ្ញាត

**មាត្រា ១៣.-**

ការបញ្ចេញសារធាតុបំពុល និងសំលេងចូលទៅក្នុងបរិយាកាសពីប្រភពអចល័ត ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថាន និងត្រូវផ្ញើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ១៤.-**

ការសុំអនុញ្ញាតនាំចូលសារធាតុឆេះ ត្រូវមានភ្ជាប់នូវលទ្ធផលវិភាគ ដែលបញ្ជាក់ពីបរិមាណជាតិពុលស្ពាន់ធ័រ សំណបង់សែន ឬអ៊ីដ្រូកាបួប្រហើរពីប្រភពដើមនៃការនាំចូល ឬការផលិត ។

**មាត្រា ១៥.-**

ការសុំអនុញ្ញាតលើការបញ្ចេញសារធាតុបំពុល និងសំលេងដូចមានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុលទាំងគំរោងថ្មី និងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ លើកលែងតែគំរោងដែលមានរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរួចហើយ ។

**មាត្រា ១៦.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលដូចមានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន :

- អោយបានមុន ៤០ថ្ងៃ នៃការចាប់ផ្តើមដំនើរការ សំរាប់គំរោងនៅភ្នំពេញ
- អោយបានមុន ៦០ថ្ងៃ នៃការចាប់ផ្តើមដំនើរការ សំរាប់គំរោងនៅតាមខេត្ត ក្រុង ។

## ជំពូកទី ៤
## ការត្រួតពិនិត្យប្រភពបំពុល

**មាត្រា ១៧.-**

ការត្រួតពិនិត្យនូវបរិមាណជាតិពុលក្នុងសារធាតុឆេះ ការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេងពីប្រភពអចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

**មាត្រា ១៨.-**

ការត្រួតពិនិត្យនូវការបញ្ចេញឧស្ម័ន និងសំលេងពីប្រភពចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដោយមានកិច្ចសហការពីក្រសួងស្ថាប័នពាក់ព័ន្ធ ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យនេះត្រូវកំណត់ដោយប្រកាសរួមរបស់អន្តរក្រសួង ។

**មាត្រា ១៩.-**

ក្រសួងបរិស្ថានត្រូវរៀបចំគោលការណ៍ណែនាំបច្ចេកទេស ស្តីពីវិធីសាស្ត្រត្រួតពិនិត្យប្រភពបំពុល វិធីសាស្ត្រកំណត់ទីតាំងយកគំរូតាង និងវិធីសាស្ត្រវិភាគគុណភាពខ្យល់ និងសំលេង ។

**មាត្រា ២០.-**

ក្រសួងបរិស្ថានត្រូវចុះយកគំរូតាងនៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល ។ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាងដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២១.-**

នៅពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីបរិស្ថានអាចធ្វើការវិភាគគំរូតាងនៅនឹងកន្លែង ឬយកមកធ្វើនៅមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

**មាត្រា ២២.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវបង់ថ្លៃសំរាប់វិភាគតាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំនត់ជាមុនដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំណូលនេះត្រូវបញ្ចូលទៅក្នុងថវិកាជាតិដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

**មាត្រា ២៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសារធាតុបំពុលរបស់ខ្លួននៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តវិធីសាស្ត្រវិភាគដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ។

**មាត្រា ២៤.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលទាំងអស់ត្រូវ :

- ទទួលខុសត្រូវក្នុងការដំឡើង ឬបំពាក់ឧបករណ៍ច្រោះសំអាតសារធាតុបំពុល និងឧបករណ៍សំរាប់កាត់បន្ថយសំលេង ដើម្បីឱ្យឆ្លើយតបទៅនឹងកំណត់កំរិតស្តង់ដារ
- ទទួលខុសត្រូវក្នុងការដំឡើងគ្រឿងបរិក្ខារវាស់ស្ទង់សារធាតុបំពុលដែលបញ្ចេញពីប្រភពបំពុលរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជាឯកសារ ហើយត្រូវផ្ញើរបាយការណ៍មកក្រសួងបរិស្ថានរៀងរាល់ ៣ខែ ម្តង ។
-ជ្រើសរើសអ្នកជំនាញបរិស្ថានចំនួនមួយរូប ជាអ្នកទទួលខុសត្រូវក្នុងកិច្ចសំរបសំរួលការងារបរិស្ថាន និងរៀបចំផែនការការពារបរិស្ថានក្នុងមូលដ្ឋានរបស់ខ្លួន ដែលក្រសួងបរិស្ថានអាចផ្តល់ការបណ្តុះបណ្តាលតាមសំណូមពររបស់ម្ចាស់កម្មសិទ្ធិ ។

**មាត្រា ២៥.-**

ក្នុងករណីដែលរកឃើញថាការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេងពីប្រភពណាមួយពុំបានឆ្លើយតបទៅ និងកំរិតកំណត់ស្តង់ដារដូចមានចែងក្នុងមាត្រា ៥ មាត្រា ៧ នៃអនុក្រឹត្យនេះក្រសួងបរិស្ថានត្រូវ :

ក-ចេញបញ្ជាជាលាយលក្ខណ៍អក្សរតំរូវអោយម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ក្នុងរយៈពេលជាក់លាក់មួយ

ខ-ចេញបញ្ជាជាលាយលក្ខណ៍អក្សរតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះផ្អាកសកម្មភាពរបស់ខ្លួនជាបណ្តោះអាសន្នរហូតដល់បទល្មើសនោះត្រូវបានកែប្រែ ប្រសិនបើសកម្មភាពល្មើសបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពសាធារណៈ ឬប៉ះពាល់ដល់គុណភាពបរិស្ថាន ។

## ជំពូកទី ៥

## ការត្រួតពិនិត្យគុណភាពខ្យល់

### មាត្រា ២៦.-

ក្រសួងបរិស្ថានត្រូវធ្វើការត្រួតពិនិត្យតាមដានជាប្រចាំពីស្ថានភាព និងគុណភាពខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជាដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់បានទាន់ពេលវេលា ។

### មាត្រា ២៧.-

ក្រសួងបរិស្ថានត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពខ្យល់ និងវាយតំលៃពីស្ថានភាពគុណភាពខ្យល់ ព្រមទាំងធ្វើការផ្សព្វផ្សាយជាសាធារណៈពីស្ថានភាពគុណភាព និងការបំពុលខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ២៨.-

ក្នុងករណីរកឃើញថា តំបន់ណាមួយត្រូវទទួលរងការបំពុលខ្យល់ ដែលបង្កអោយមានការគំរាមកំហែងដល់អាយុជីវិតសាធារណៈ ឬគុណភាពបរិស្ថាន ក្រសួងបរិស្ថានត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់ និងត្រូវស៊ើបអង្កេតរកប្រភពដែលបង្កអោយមានការបំពុល ព្រមទាំងចាត់វិធានការទប់ស្កាត់ប្រភពបំពុលទាំងនោះ ដើម្បីស្តារនូវគុណភាពខ្យល់អោយបានប្រសើរឡើងវិញ ។

## ជំពូកទី ៦

## នីតិវិធីនៃការធ្វើអធិការកិច្ច

### មាត្រា ២៩.-

នៅពេលចុះធ្វើអធិការកិច្ចតាមប្រភពបំពុល មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថានត្រូវអនុវត្តតាមនីតិវិធីដូចមានចែងខាង ក្រោម :

ក-បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មរបស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬកន្លែងប្រភពបំពុលដើម្បីធ្វើអធិការកិច្ចយកគំរូតាង ឬពិនិត្យកំណត់ត្រា ។

ខ-កំណត់ហេតុ និងរបាយការណ៍ដំបូងនៃការត្រួតពិនិត្យ ឬយកគំរូតាង ត្រូវធ្វើនៅនឹងកន្លែងដែលធ្វើអធិការកិច្ចដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់ ។

គ-មន្ត្រីអធិការកិច្ចអាចសាកសួរ និងតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលផ្តល់ពត៌មាន ឬឯកសារនានាដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ និងកំណត់ហេតុសំរាប់ប្រើជាវត្ថុតាង ។

ឃ-របាយការណ៍ ឬកំណត់ហេតុត្រូវផ្តល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល មួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន ។

**មាត្រា ៣០.-**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា ប្រភពបំពុលណាមួយបានបញ្ចេញសារធាតុបំពុលខ្យល់ ឬសំលេង ឬរំញ័របង្កអោយមានគ្រោះថ្នាក់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិធ្វើអធិការកិច្ចនៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ ។

**មាត្រា ៣១.-**

ក្នុងករណីមានឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយនៃការបំពុលខ្យល់ ឬការរំខានដោយសំលេង ក្រសួងបរិស្ថានត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ និងត្រូវជូនពតិមានទៅស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

**មាត្រា ៣២.-**

ក្នុងករណីបទល្មើសជាក់ស្តែងដែលបង្កអោយមានការបំពុលខ្យល់ ឬការរំខានដោយសំលេង មន្ត្រីអធិការកិច្ចក្រសួងបរិស្ថានត្រូវ :

ក-ធ្វើកំណត់ហេតុ ប្រមូលឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ប្រសិនបើបទល្មើសនោះមិនបង្កអោយមានការបំពុលធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន ។

ខ-ប្រមូល និងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះដើម្បីធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿងទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កអោយមានការបំពុលធ្ងន់ធ្ងរ ឬប៉ះពាល់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ៣៣.-**

ការរំលោភល្មើសទៅ និងអនុក្រឹត្យនេះនឹងត្រូវទទួលពិន័យ និងផ្តន្ទាទោសដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៥ ជំពូក ទី ៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ៣៤.-**

កំណត់ហេតុចោទប្រកាន់បទល្មើសចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថានត្រូវអនុវត្តវិធានការច្បាប់ចំពោះបទល្មើសទាំង

ឡាយនៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣៥.-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែសខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលដល់អ្នកប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់ពីបទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៦.-**

បទញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធត្រូវសហការជាមួយក្រសួងបរិស្ថានហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៨.-**

អនុក្រឹត្យនេះចូលជាធរមានគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ១

# កំរិតកំណត់ស្តង់ដារគុណភាពខ្យល់

| ល.រ | ប៉ារ៉ាម៉ែត្រ | រយៈពេល១ម៉ោង ជាមធ្យម mg/m3 | រយៈពេល៨ម៉ោង ជាមធ្យម $mg/m^3$ | រយៈពេល២៤ម៉ោង ជាមធ្យម $mg/m^3$ | រយៈពេល ១ឆ្នាំ ជាមធ្យម$mg/m^3$ |
|---|---|---|---|---|---|
| 1 | កាបូនឌីអុកស៊ីត CO | 40 | 20 | | |
| 2 | អាសូតឌីអុកស៊ីត$NO_2$ | 0,3 | | 0,10 | |
| 3 | ស្ពាន់ធ័រឌីអុកស៊ីត$SO_2$ | 0,5 | | 0,30 | 0,10 |
| 4 | អូសូន $0_3$ | 0,2 | | | |
| 5 | សំណ Pb | | | 0,005 | |
| 6 | សារធាតុរឹងអណ្តែតក្នុងខ្យល់ TSP | | | 0,33 | 0,10 |

## កំណត់សំគាល់

-កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ធ្វើការវាយតំលៃគុណភាពខ្យល់ទូទៅ និងអង្កេតតាមដានស្ថានភាពនៃការបំពុលខ្យល់ ។

-វិធីសាស្ត្រនៃការវិភាគគុណភាពខ្យល់នឹងត្រូវកំណត់តាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន

-TSP Total Suspended Particulate

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ២

## កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់

| ល.រ | ឈ្មោះសារធាតុគីមី | រូបមន្តគីមី | កំរិតអតិបរមា (mg/m$^3$) |
|---|---|---|---|
| 1 | អានីលីន | $C_6H_5NH_2$ | 0,03 |
| 2 | អាម៉ូញាក់ | $NH_3$ | 0,2 |
| 3 | អាស៊ីត អាសេទិច | $CH_3COOH$ | 0,2 |
| 4 | អាស៊ីតស៊ុលផួរិច | $H_2SO_4$ | 0,3 |
| 5 | អាស៊ីតនីទ្រិច | $HNO_3$ | 0,4 |
| 6 | បង់សែន | $C_6H_6$ | 1 |
| 7 | បង់ស៊ីឌីន | $NH_2C_6H_4C_6H_4NH_2$ | គ្មាន |
| 8 | កាបូនឌីស៊ុលហ្វីត | $CS_2$ | 0,02 |
| 9 | ក្លរ៉ូហ្វម | $CHCL_3$ | 0,01 |
| 10 | កាបូនតេត្រាក្លរិត | $CCL_4$ | 3 |
| 11 | ភាគល្អិតដែលមាន asbestor | | គ្មាន |
| 12 | ដេ ដេ តេ | $C_8H_{11}CL$ | 0,5 |
| 13 | ហ្វម៉ល់ដេអ៊ីត | HCOH | 0,012 |
| 14 | អ៊ីដ្រូសែន អាសេនិច | $AsH_3$ | 0,002 |
| 15 | អ៊ីដ្រូសែន ស៊ីអានីត | HCN | 0,01 |
| 16 | អ៊ីដ្រូសែន ភ្លុយអរិច | HF | 0,002 |
| 17 | អ៊ីដ្រូសែនស៊ុលហ្វីត | $H_2S$ | 0,001 |
| 18 | ផេណុល | $C_6H_5OH$ | 0,01 |
| 19 | ស៊ីរេន | $C_6H_5CHCH_2$ | 0,003 |
| 20 | តេត្រាក្លរូអេទីឡែន | $C_2Cl_4$ | 0,1 |
| 21 | សំណតេត្រាអេទិល | $Pb(C_2H_5)_4$ | 0,005 |
| 22 | ទ្រីក្លរួអេទីឡែន | $CLCHCCL_2$ | 0,2 |
| 23 | តូលុយអេន | $C_9H_5CH_3$ | 0,4 |
| 24 | វិនិក្លរួ | $CLCHCH_2$ | 0,05 |

| | | | |
|---|---|---|---|
| 25 | អាសេទិច (សមាសធាតុអសរីរាង្គ) | As | 0,00001 |
| 26 | កាត់មូម(សមាសធាតុលោហៈ និងអុកស៊ីត) | Cd | 0,003 |
| 27 | ក្រូម(លោហៈ និងសមាសធាតុ) | Cr | 0,0015 |
| 28 | នីកែល (លោហៈ និងសមាសធាតុ) | Ni | 0,0001 |
| 29 | បារត(លោហៈ និងសមាសធាតុ) | Hg | 0,0001 |
| 30 | ប្រេងសាំង | | 5 |

**កំណត់សំគាល់**

ក៏រិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់ ។

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ៣

## កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញ ពីប្រភពអចលត៍ ចូលទៅក្នុងបរិយាកាស

| ល.រ | ប៉ារ៉ាម៉ែត | កំរិតអតិបរមានៃការបញ្ចេញ |
|---|---|---|
| 1 | ភាគល្អិតនៅក្នុងផ្សែង បញ្ចេញពីប្រភព : | |
| | -ឡដុត | 400 mg/$m^3$ |
| | -រោងចក្រផលិតលោហធាតុ | 400 mg/$m^3$ |
| | -រោងចក្រស៊ីម៉ង់ត៍ កំបោរ និងថ្មស្អុយ | 400 mg/$m^3$ |
| | -រោងចក្របេតុងអាស្ពាល់ | 500 mg/$m^3$ |
| 2 | ធូលី ដែលមានភ្ជាប់ : | |
| | -សារធាតុ ស៊ីលីកាត $Si0_2$ | 100 mg/$m^3$ |
| | -សារធាតុ Asbetos | 27 µg/$m_3$ |
| | -សារធាតុគីមីអសរីរាង្គ : | |
| 3 | អាលុយមីញ៉ូម AL | (ធូលី) ៣០០ mg/$m^3$ .˙(Al) 50 mg/$m^3$ |
| 4 | អាម៉ូញាក់ $NH_3$ | 100 mg/$m^3$ |
| 5 | អាង់ទីម៉ូន Sb | 25 mg/$m^3$ |
| 6 | អាសេទិច As | 20 mg/$m_3$ |
| 7 | បេរីល្យ៉ូម Be | 10 µg/$m_3$ |
| 8 | ក្លរ CL | 20 mg/$m_3$ |
| 9 | អ៊ីដ្រូសែនក្លរីត HCL | 200 mg/$m_3$ |
| 10 | អ៊ីដ្រូសែនភ្លុយអរីត HF | 10 mg/$m_3$ |
| 11 | អ៊ីដ្រូសែនស៊ុលភីត $H_2F$ | 2 mg/$m_3$ |
| 12 | កាត់ម្ញ៉ូម Cd | 1 mg/$m_3$ |
| 13 | ទង់ដែង Cu | (ធូលី) ៣០០mg/$m_3$ (Cu) 20 mg/$m_3$ |
| 14 | សំណ Pb | (ធូលី) ១០០ mg/$m_3$ (Pb) 30 mg/$m_3$ |
| 15 | ស័ង្កសី Zn | 30 mg/$m_3$ |
| 16 | បារត Hg | 0,1 mg/$m_3$ |
| 17 | កាបូនម៉ូណូអុកស៊ីត Co | 1000 mg/$m_3$ |

| | | |
|---|---|---|
| 18 | ស្ពាន់ធ័រឌីអុកស៊ីត $SO_2$ | 500 $mg/m^3$ |
| 19 | អាសូតអុកស៊ីត( គ្រប់ប្រភេទ) NOx | 1000 $mg/m^3$ |
| 20 | អាសូតអុកស៊ីត( ចេញពីការផលិតអាស៊ីត)NOx | 2000 $mg/m^3$ |
| 21 | អាស៊ីតស៊ុលផួរិច $H_2SO_4$ | 35 $mg/m^3$ |
| 22 | អាស៊ីតនីទ្រិច $HNO_3$ | 70 $mg/m^3$ |
| 23 | ស្ពាន់ធ័រទ្រីអុកស៊ីត ($SO_3$) | 35 $mg/m^3$ |
| 24 | អាស៊ីតផូស្វរិច ($H_3PO_4$) | 3 $mg/m^3$ |
| | សារធាតុគីមីសរីរាង្គ : | |
| 25 | អាសេទីឡែនតេត្រាប្រូមីត $CHBr_2CHBr_2$ | 14 $mg/m^3$ |
| 26 | អាក្រូឡេអ៊ិន $CH_2CHCHO$ | 1,2 $mg/m^3$ |
| 27 | អានីលីន $C_6H_5NH_2$ | 19 $mg/m^3$ |
| 28 | បង់ស៊ីឌីន $NH_2C_6H_4C_6H_4NH_2$ | None |
| 29 | បង់សែន $C_6H_6$ | 80 $mg/m^3$ |
| 30 | ក្លរូបង់ស៊ីល $C_6H_5CH_2Cl$ | 5 $mg/m^3$ |
| 31 | ប៊ុយទីលឡាមីន $CH_3(CH_2)_2CH_2NH_2$ | 15 $mg/m^3$ |
| 32 | ក្រេសូល (O-,m-,P-) $CH_3C_6H_4OH$ | 22 $mg/m^3$ |
| 33 | ក្លរូបង់សែន $C_6H_5Cl$ | 350 $mg/m^3$ |
| 34 | ក្លរូហ្វម $CHCl_3$ | 240 $mg/m^3$ |
| 35 | ក្លរូពិគ្រីន $CCl_3NO_2$ | 0,7 $mg/m^3$ |
| 36 | O-ឌីក្លរូបង់សែន $C_6H_4Cl_2$ | 300 $mg/m^3$ |
| 37 | 1.1-ឌីក្លរូអេតាន $CHCl_2CH_3$ | 400 $mg/m^3$ |
| 38 | ឌីមេទីលស៊ុលហ្វាត $(CH_3)_2SO_4$ | 0,5 $mg/m^3$ |
| 39 | ឌីមេទីលអ៊ីដ្រាហ្ស៊ីន $(NH_3)_2NNH_2$ | 1 $mg/m^3$ |
| 40 | ឌីនីត្រូបង់សែន (O-,m-,P-) $C_6H_4(NO_2)_2$ | 1 $mg/m^3$ |
| 41 | អេទីឡែនឌីអាមីន $NH_2CH_2$-$CH_2NH_2$ | 30 $mg/m^3$ |
| 42 | អេទីឡែន ក្លរូអ៊ីឌ្រីន $CH_2ClCH_2OH$ | 16 $mg/m^3$ |
| 43 | អេទីឡែន អុកស៊ីត $CH_2OCH_2$ | 20 $mg/m^3$ |
| 44 | ហ្វ័រម៉ាល់ដេអ៊ីដ HCHO | 6 $mg/m^3$ |
| 45 | មេទីលអាគ្រីឡាត $CH_2CHCOOCH_3$ | 35 $mg/m^3$ |
| 46 | មេតាណុល $CH_3OH$ | 260 $mg/m^3$ |
| 47 | មេទីលប្រូមីត $CH_3Br$ | 80 $mg/m^3$ |

| | | |
|---|---|---|
| 48 | ម៉ូណូមេទីលអានីលីន $C_6H_5NHCH_3$ | 9 mg/m$^3$ |
| 49 | នីត្រូបង់សែន $C_6H_5NO_2$ | 5 mg/m$^3$ |
| 50 | នីត្រូគ្លីសេរីន $C_3H_5(NO_2)_3$ | 5 mg/m$^3$ |
| 51 | នីត្រូតូលូអែន $NO_2C_6H_4CH_3$ | 30 mg/m$^3$ |
| 52 | ផេណុល $C_6H_5OH$ | 19 mg/m$^3$ |
| 53 | ផេនីលអ៊ីដ្រាហ្សីន $C_6H_5NHNH_2$ | 22 mg/m$^3$ |
| 54 | ពីរីនឌីន $C_5H_5N$ | 30 mg/m$^3$ |
| 55 | ពីរែន $C_{16}H_{10}$ | 15 mg/m$^3$ |
| 56 | គ្វីណូន $C_6H_4O_2$ | 0,4 mg/m$^3$ |
| 57 | ស្ទីរែន $C_6H_5CHCH_2$ | 420 mg/m$^3$ |
| 58 | 1,1,2,2-តេត្រាក្លរូអេតាន $Cl_2HCCHCl_2$ | 35 mg/m$^3$ |
| 59 | តេត្រាក្លរូមេតាន $CCl_4$ | 65 mg/m$^3$ |
| 60 | តូលូអែន $C_6H_5CH_3$ | 750 mg/m$^3$ |
| 61 | តេត្រានីត្រូមេតាន $C(NO_2)_4$ | 8 mg/m$^3$ |
| 62 | តូលូអ៊ីឌីន $CH_3C_6H_4NH_2$ | 22 mg/m$^3$ |
| 63 | តូលូអែន 2.4- ឌីអ៊ីសូស៊ីអាណាត $CH_3C_6H_3(NCO)_2$ | 0,7 mg/m$^3$ |
| 64 | ទ្រីក្លរូអេទីឡែន $ClCHCCl_2$ | 110 mg/m$^3$ |
| 65 | ស៊ីលីឌីន $(CH_3)_2C_6H_3NH_2$ | 50 mg/m$^3$ |
| 66 | វីនីលក្លរីត $CH_2CHCl$ | 150 mg/m$^3$ |

**កំណត់សំគាល់**

ករិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលពីប្រភពអចល័តចូលទៅក្នុងបរិយាកាស ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក
ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៤

## កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញឧស្ម័នពីប្រភពអចល័ត

| ល.រ | ប្រភេទយានយន្ត | ប្រភេទប្រេងឥន្ធនៈ | កំរិតនៃការបញ្ចេញ | | | | |
|---|---|---|---|---|---|---|---|
| | | | CO (%) | | HC(ppm) | | ផ្សែងខ្មៅ % |
| | | | ក | ខ | ក | ខ | |
| 1 | ទោចក្រយានយន្តដែលមានចំហេះ២វគ្គ | ប្រេងសាំង | 4,5 | 4 | 10.000 | 3000 | |
| 2 | ទោចក្រយានយន្តដែលមានចំហេះ៤វគ្គ | ប្រេងសាំង | 4,5 | 4 | 10.000 | 2400 | |
| 3 | យានយន្តគ្រប់ប្រភេទ | ប្រេងសាំង | 4,5 | 4 | 1200 | 800 | |
| 4 | យានយន្តគ្រប់ប្រភេទ | ប្រេងម៉ាស៊ូត | | | | | ៥០ |

### កំណត់សំគាល់

កំរិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យការបញ្ចេញឧស្ម័នពីប្រភពអចល័តចូលទៅក្នុងបរិយាកាស ។

ក-គឺសំដៅលើយានយន្តគ្រប់ប្រភេទដែលប្រើប្រាស់ហួសរយៈពេល ៥ឆ្នាំ គិតពីឆ្នាំដែលផលិត ។

ខ-គឺសំដៅទៅលើយានយន្តគ្រប់ប្រភេទដែលបាននាំចូលថ្មីក្នុងរយៈពេល ប្រាំឆ្នាំដំបូងគិតចាប់ពីឆ្នាំដែលផលិត ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៥

## កំរិតកំណត់ស្តង់ដារអតិបរមា ដែលអនុញ្ញាតបញ្ចេញសំលេងនៅ លើផ្លូវសាធារណៈ ពីប្រភពយានយន្ត

| ល.រ | **ប្រភេទយានយន្ត** | កំរិតអតិបរមា (dB (A)) |
|---|---|---|
| 1 | ទោចក្រយានយន្តចំណុះស៊ីឡាំង (cc)< 125 Cm$^3$ | 85 |
| 2 | ទោចក្រយានយន្តចំណុះស៊ីឡាំង (cc)≥ 125 Cm$^3$ | 90 |
| 3 | **ត្រីចក្រយានយន្ត** | 90 |
| 4 | រថយន្តធុនតូច រថយន្តដឹកអ្នកដំណើរ ១២ នាក់ | 80 |
| 5 | រថយន្តដឹកអ្នកដំណើរ ≥ ១២ នាក់ | 85 |
| 6 | រថយន្តដឹកទំនិញដែលផ្ទុកទំនិញ < 3,5 តោន | 85 |
| 7 | រថយន្តដឹកទំនិញដែលផ្ទុកទំនិញ > 3,5 តោន | 88 |
| 8 | រថយន្តដឹកទំនិញដែលមានកំលាំង ≥ 150 kw | 89 |
| 9 | គ្រឿងយន្តផ្សេងៗទៀតដែលមិនបានរៀបរាប់ខាងលើ | 91 |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតបញ្ចេញសំលេងពីប្រភពយានយន្តគ្រប់ប្រភេទ ដែលកំពុងធ្វើចរាចរលើផ្លូវសាធារណៈ ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ៦

## កំរិតកំណត់ស្តង់ដារសំលេងអតិបរមា ដែលអនុញ្ញាតនៅតំបន់ សាធារណៈ និងតំបន់លំនៅដ្ឋាន (dB(A))

| ល.រ | **ទីតាំង** | **អំឡុងពេល** | | |
|---|---|---|---|---|
| | | ពីម៉ោង ៦ព្រឹកដល់ ម៉ោង ១៨ល្ងាច | ពីម៉ោង ១៨ល្ងាចដល់ ម៉ោង ២២យប់ | ពីម៉ោង២២យប់ ដល់ម៉ោង ៦ព្រឹក |
| 1 | តំបន់ស្ងប់ស្ងៀម<br>-មន្ទីរពេទ្យ<br>-បណ្ណាល័យ<br>សាលារៀន<br>មតេយ្យសាលា | 45 | 40 | 35 |
| 2 | តំបន់លំនៅដ្ឋាន<br>-សណ្ឋាគារ ទីកន្លែង រដ្ឋបាល<br>-ភូមិគ្រឹះ ផ្ទះល្វែង | 60 | 50 | 45 |
| 3 | តំបន់ពាណិជ្ជកម្ម សេវាកម្ម និងចំរុះ | 70 | 65 | 50 |
| 4 | ឧស្សាហកម្មធន់ស្រាល លាយចំរុះ នៅក្នុងតំបន់លំនៅដ្ឋាន | 75 | 70 | 50 |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតសំលេងពីប្រភព ឬសកម្មភាពណាមួយ ដែលបញ្ចេញសំលេងចូលក្នុងតំបន់សាធារណៈ និងតំបន់លំនៅដ្ឋាន ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៧

## កំរិតកំណត់ស្តង់ដារសំរាប់ត្រួតពិនិត្យសំលេង

## ក្នុងទីតាំង រោងជាង រោងចក្រឧស្សាហកម្ម

| កំរិតសំលេង (dB(A)) | រយៈពេលអតិបរមា (ម៉ោង) | កំណត់បង្ហាញ |
|---|---|---|
| 75 | 32 | ត្រូវផ្តល់ឧបករណ៍ការពារត្រចៀកដល់អ្នកបំរើការដែលធ្វើការនៅកន្លែងមានសំលេងលើសពី 80dB (A) |
| 80 | 16 | |
| 85 | 8 | |
| 90 | 4 | |
| 95 | 2 | |
| 100 | 1 | |
| 105 | 0,5 | |
| 110 | 0,25 | |
| 115 | 0,125 | |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតសំលេងនៅក្នុងទីតាំងរោងជាង រោងចក្រឧស្សាហកម្ម ។

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៧

## កំរិតកំណត់ស្តង់ដារ ជាតិស្ពាន់ធ័រ សំណ បង់សែន

## និងអ៊ីដ្រូកាបួប្រហើរ ដែលអនុញ្ញាតឱ្យមាននៅក្នុងប្រេងឥន្ធនៈ និងធ្យូងថ្ម

| ល.រ | សារធាតុចំហេះ | ស្ពាន់ធ័រ(S) | សណ(Pb) | បង់សែន | អ៊ីដ្រូកាប៊ួប្រហើរ |
|---|---|---|---|---|---|
| 1 | ប្រេងខ្មៅ | 1,0% | | | |
| 2 | ប្រេងម៉ាស៊ូត | 0,2% | | | |
| 3 | ប្រេងសាំង | | 0,15ក្រាម/លីត្រ | 3,5% | 50% |
| 4 | ធ្យូងថ្ម | 1,5% | | | |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ត្រួតពិនិត្យជាតិស្ពាន់ធ័រ សំណ បង់សែន និងអ៊ីដ្រូកាប៊ូប្រហើរ ដែលអនុញ្ញាតអោយមាននៅក្នុងប្រេងឥន្ធនៈ និងធ្យូងថ្ម ។

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលទឹក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

**លេខ** : ២៧ អ.ន.ក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលទឹក

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ និងការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៩៩ ។

## សំរេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅ កំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយដែលបង្កឱ្យមានការបំពុលទឹកនៅតាមតំបន់សាធារណៈ ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក-"**តំបន់ទឹកសាធារណៈ**" គឺសំដៅទៅលើតំបន់ទឹកសំរាប់ប្រើប្រាស់ជាសាធារណៈ ដូចជា : ទន្លេ ស្ទឹង ជ្រោះ អូរ ព្រែក បឹង ស្រះ អណ្តូង ត្រពាំង ថ្លុក សមុទ្រ ពាម ដោយរាប់បញ្ចូលទាំងប្រព័ន្ធប្រឡាយធារាសាស្ត្រ និងផ្លូវទឹកដទៃទៀតដែលសំរាប់ប្រើប្រាស់ជាសាធារណៈ និងទឹកក្រោមដី ។

ខ-"**ប្រភពបំពុល**" គឺសំដៅទៅលើទីតាំងអាគារទាំងឡាយណា រួមទាំងលំនៅស្ថាន និងអាគាររដ្ឋបាលសាធារណៈ ទីបរិវេណ មធ្យោបាយដឹកជញ្ជូន និងតំបន់អាជីវកម្ម ឬសេវាកម្ម ដែលបញ្ចេញសំណល់រាវ សារធាតុពុល ឬសារធាតុដែលបង្កអោយមានគ្រោះថ្នាក់ ដោយផ្ទាល់ក្តី ឬមិនផ្ទាល់ក្តី ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ

គ-"**សំណល់រាវ**" គឺសំដៅទៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបានធ្វើប្រព្រឹត្តកម្មក្តី ។

ឃ-"**ទឹកលូ**" គឺសំដៅទៅលើទឹកកខ្វក់ ដែលបញ្ចេញពីលំនៅស្ថាន និងអាគារសាធារណៈ ។

ង-"**សំណល់រឹង**" គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ហើយត្រូវបានបញ្ចេញចោលពីប្រភពបំពុល ។

ច-"**សំរាម**" គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ ហើយត្រូវបានបញ្ចេញចោលពីលំនៅស្ថាន និងអាគារសាធារណៈ ។

ឆ-"**សារធាតុបំពុល**" គឺសំដៅទៅលើសារធាតុរឹង រាវ ឬឧស្ម័ន ឬសំណល់គ្រប់ប្រភេទដែលធ្វើឱ្យមានការប្រែប្រួលនូវធាតុផ្សំ ឬលក្ខណៈរបស់ទឹក ដូចជា ធ្វើឱ្យប្រែប្រួលនូវ លក្ខណៈរូប លក្ខណៈគីមី ឬលក្ខណៈជីវសាស្ត្ររបស់ទឹក នៅពេលបញ្ចេញ ឬចាក់វាចោលចូលទៅក្នុងទឹកដោយចេតនាក្តី ឬអចេតនាក្តី ។

ជ-"**បរិមាណសារធាតុបំពុល**" គឺសំដៅទៅលើបន្ទុក ឬចំណុះសារធាតុបំពុល រួមទាំងកំដៅដែលមាននៅក្នុងសំណល់រាវ ដែលត្រូវបានបញ្ចេញចោលពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹក សាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ឈ-"**សារធាតុប្រកបដោយគ្រោះថ្នាក់**" គឺសំដៅទៅសារធាតុ ដែលបណ្តាលអោយមានគ្រោះថ្នាក់ទៅដល់សរីរាង្គមានជីវិត ឬធ្វើអោយខូច ឬបាក់បែកវត្ថុសំភារៈ អាគារ ឬបណ្តាលអោយប៉ះពាល់ ឬមហន្តរាយដល់បរិស្ថាន ។ ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ២
## បញ្ញត្តិលើការបញ្ចេញសំណល់
## និងសារធាតុប្រកបដោយគ្រោះថ្នាក់

**មាត្រា ៤.-**

កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវពីប្រភពបំពុលទាំងឡាយ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

**មាត្រា ៥.-**

ក្នុងករណីចាំបាច់ និងតំរូវការទៅតាមតំបន់នីមួយៗ ក្នុងការការពារសុខភាពមនុស្ស និងការអភិរក្សជីវចំរុះ ក្រសួងបរិស្ថាន ត្រូវរៀបចំកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក សំរាប់អនុវត្តលើប្រភពបំពុល ដែលតាំងនៅជុំវិញតំបន់ទឹកសាធារណៈនោះ ។

កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ មាត្រា ៥ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៦.-**

ហាមឃាត់ជាដាច់ខាតនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុលណាមួយដែលមិនអនុវត្តតាមកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា៥ នៃអនុក្រឹត្យនេះ ។

**មាត្រា ៧.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំកំរិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុលនៅក្នុងសំណល់រាវ ដែលអាចអនុញ្ញាតឱ្យបញ្ចេញពីប្រភពបំពុលនានា ចូលទៅក្នុងតំបន់ទឹកសាធារណៈដែលត្រូវការពារ ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស និង ការអភិរក្សជីវៈចំរុះ ។

កំរិតស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា៧ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៨.-**

ហាមឃាត់ជាដាច់ខាតនូវការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ទៅក្នុងតំបន់ទឹក

សាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ហាមឃាត់ជាដាច់ខាតនូវការទុកដាក់ ឬការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលនាំឱ្យមានការបំពុលទឹកតំបន់ទឹកសាធារណៈ ។

**មាត្រា ៩.-**

ហាមឃាត់ជាដាច់ខាតនូវការបង្ហូរទឹកលូចេញពីលំនៅស្ថាន ឬពីអាគារសាធារណៈ ចូលទៅក្នុងតំបន់ទឹកសាធារណៈ ដោយពុំឆ្លងកាត់ប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធច្រោះសំអាតនានា ។

## ជំពូកទី ៣

## ការសុំអនុញ្ញាតបញ្ចេញសំណល់រាវ

**មាត្រា ១០.-**

ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពីប្រភពបំពុលទៅកន្លែងដទៃ ក្នុងគោលបំណងណាមួយ ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន និងត្រូវផ្ញើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ១១.-**

ប្រភេទនៃប្រភពបំពុល ដែលតំរូវអោយសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ ដូចមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៣ នៃអនុក្រឹត្យនេះ ហើយដែលចែកចេញជាពីរប្រភេទ ដូចតទៅ :

ក-ប្រភពបំពុលប្រភេទថ្នាក់ទី១ តំរូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណសំណល់រាវរបស់ប្រភពបំពុលនោះមានចំនួនច្រើនជាង ១០ ម៉ែត្រគូបក្នុងមួយថ្ងៃដោយពុំគិតបញ្ចូលនូវបរិមាណទឹកដែលប្រើប្រាស់សំរាប់ប្រព័ន្ធត្រជាក់គ្រឿងចក្រ ។

ខ-ប្រភពបំពុលប្រភេទថ្នាក់ទី២ ចាំបាច់តំរូវអោយមានការសុំការអនុញ្ញាតពីក្រសួងបរិស្ថាន ។

**មាត្រា ១២.-**

ការសុំអនុញ្ញាតលើការបញ្ចេញចោល ឬការដឹកសំណល់រាវចេញពីប្រភពបំពុលទៅកន្លែងដទៃដូចមានចែងក្នុងមាត្រា១០ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុល ទាំងគំរោងថ្មី និងទាំងគំរោងកំពុងដំណើរការ លើកលែងតែគំរោងប្រភពបំពុលថ្មី ដែលរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គំរោងនោះត្រូវបានអនុម័ត នឹងត្រូវបានរួចផុតពីការតំរូវឱ្យសុំការអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ ។

**មាត្រា ១៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះដែលមានបំណងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកាន់កន្លែងដទៃ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន :

-អោយបានមុន ៤០ថ្ងៃសំរាប់គំរោងនៅភ្នំពេញ និង ៦០ថ្ងៃ សំរាប់គំរោងនៅតាមខេត្ត ក្រុងនៃការចាប់ផ្តើម

ដំណើរការ សំរាប់ប្រភពបំពុលដែលជាគំរោងថ្មី ។

-អោយបានក្នុងរយៈពេល ៣០ថ្ងៃ សំរាប់ប្រភពបំពុលនៅភ្នំពេញ និង ៥០ថ្ងៃសំរាប់ប្រភពបំពុលនៅតាមខេត្ត ក្រុង ក្រោយពេលទទួលបានការណែនាំពីក្រសួងបរិស្ថាន សំរាប់ប្រភពបំពុលដែលកំពុងដំណើរការ ។

**មាត្រា ១៤.-**

លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុលទៅកាន់កន្លែងដទៃ នឹងត្រូវបានផ្តល់ជូន ប្រសិនបើបែបបទនៃការសុំអនុញ្ញាតនោះត្រូវបានបំពេញទៅតាមគោលការណ៍ណែនាំបច្ចេកទេស ដែលកំនត់ដោយក្រសួង បរិស្ថាន ។

**មាត្រា ១៥.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដែលទទួលបានការអនុញ្ញាតពីក្រសួងបរិស្ថានអោយបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅទីដទៃ ហើយមានបំណងចង់ធ្វើការផ្លាស់ប្តូរប្រព័ន្ធបញ្ចេញសំណល់រាវរបស់ខ្លួន ត្រូវដាក់ពាក្យ សុំការអនុញ្ញាតជាថ្មី ទៅក្រសួងបរិស្ថានអោយបានមុន ៣០ថ្ងៃ នៃការចាប់ផ្តើមដំណើរការផ្លាស់ប្តូរ ។

**មាត្រា ១៦.-**

បុគ្គលដែលជួល ឬអ្នកកាន់កាប់បន្តប្រភពបំពុលពីម្ចាស់កម្មសិទ្ធិដើម ឬអ្នកទទួលខុសត្រូវដើមដែលបានទទួលការ អនុញ្ញាតពីក្រសួងបរិស្ថានឱ្យបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅទីដទៃត្រូវអនុវត្តបន្តអោយបានត្រឹមត្រូវនូវចំនុច ដែលបានកំណត់នៅក្នុងពាក្យសុំការអនុញ្ញាត ដែលម្ចាស់កម្មសិទ្ធិដើម ឬអ្នកទទួលខុសត្រូវដើម បានដាក់ជូនទៅក្រសួង បរិស្ថាន ។

ម្ចាស់កម្មសិទ្ធិថ្មី ឬអ្នកទទួលខុសត្រូវថ្មីនៃប្រភពបំពុល ត្រូវផ្តល់សេចក្តីជូនដំណឹងពីការជួល ឬការកាន់កាប់បន្ត របស់ខ្លួនទៅក្រសួងបរិស្ថាន ក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរ ក្រោយពីមានការជួល ឬកាន់កាប់បន្តនោះ ។

**មាត្រា ១៧.-**

លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុលទៅកន្លែងដទៃ ដែលបានផ្តល់ជូនទៅឱ្យ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល នឹងត្រូវបានដកហូតជាបណ្តោះអាសន្ន ឬជាស្ថាពរ បន្ទាប់ពីមានការពិគ្រោះ យោបល់ជាមុនជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ប្រសិនបើម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះប្រព្រឹត្ត ល្មើសធ្ងន់ធ្ងរ និងមាត្រាណាមួយនៃមាត្រា ១៤ មាត្រា ១៥ ឬមាត្រា ១៦ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៤

## ការត្រួតពិនិត្យប្រភពបំពុល

**មាត្រា ១៨.-**

ការត្រួតពិនិត្យនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុល ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន

**មាត្រា ១៩.-**

ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងសំណល់រាវ នៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២០.-**

ការវិភាគគំរូតាងសំណល់រាវ ដែលយកបានមកពីប្រភពបំពុលក្នុងពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ច ត្រូវធ្វើនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

**មាត្រា ២១.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវបង់ថ្លៃវិភាគសំណល់រាវរបស់ខ្លួន តាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំណត់ជាមុន ដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំនូលនេះត្រូវបញ្ចូលទៅក្នុងថវិកាជាតិ ដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

**មាត្រា ២២.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសំណល់រាវរបស់ខ្លួននៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តវិធីសាស្ត្រវិភាគដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

**មាត្រា ២៣.-**

ចំពោះប្រភពបំពុល ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវ :

ក-ទទួលខុសត្រូវក្នុងការកំណត់យកនូវវិធីសាស្ត្រធ្វើប្រព្រឹត្តកម្មសំអាតនិងបញ្ចេញសំណល់រាវរបស់ខ្លួន ដើម្បីឱ្យឆ្លើយតបទៅ និងកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះ និងកំរិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ។

ខ-មានសំភារៈ និងមធ្យោបាយគ្រប់គ្រាន់សំរាប់រារាំង ឬទប់ស្កាត់ការបំពុលតំបន់ទឹកសាធារណៈនៅពេលដែលមានគ្រោះថ្នាក់ដោយចៃដន្យបង្កឡើងពីប្រភពបំពុលរបស់ខ្លួន ។

គ-ទទួលខុសត្រូវក្នុងការដំឡើងឧបករណ៍ សំរាប់ធ្វើការវាស់នូវចរន្តហូរ កំហាប់ និងបរិមាណសារធាតុបំពុលដែលមាននៅក្នុងសំណល់រាវរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជាឯកសារ ។ លទ្ធផលនៃការវាស់ស្ទង់ ត្រូវផ្ញើជារបាយការណ៍មកកាន់ក្រសួងបរិស្ថានរៀងរាល់ ៣ខែម្តង ។

**មាត្រា ២៤.-**

ក្នុងករណីដែលរកឃើញថា ការបញ្ចេញសំណល់រាវពីប្រភពបំពុលណាមួយ ពុំបានឆ្លើយតបទៅ និងកំរិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ ឬពុំឆ្លើយតបទៅ និងកំរិតស្តង់ដារបរិមាណសារធាតុ

បំពុល ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ក្រសួងបរិស្ថានត្រូវ :

ក-ចេញបញ្ជាជាលាយលក្ខណ៏អក្សរ តម្រូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ក្នុងរយៈពេលជាក់លាក់ណាមួយ ប្រសិនបើសកម្មភាពល្មើសនោះមិនទាន់បង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬប៉ះពាល់ដល់គុណភាពទឹក ។

ខ-ចេញបញ្ជាជាលាយលក្ខណ៏អក្សរ តម្រូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះផ្អាកសកម្មភាពរបស់ខ្លួនជាបណ្តោះអាសន្ន រហូតដល់បទល្មើសនោះត្រូវបានកែប្រែ ប្រសិនបើសកម្មភាពល្មើសបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬប៉ះពាល់ដល់គុណភាពទឹក ។

## ជំពូកទី ៥
## ការត្រួតពិនិត្យការបំពុលទឹក
## នៅតាមតំបន់ទឹកសាធារណៈ

### មាត្រា ២៥.-

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹកមានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៤ នៃអនុក្រឹត្យនេះ ។

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹសាធារណៈ សំរាប់ការពារសុខភាពសាធារណៈមានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៥ នៃអនុក្រឹត្យនេះ ។

### មាត្រា ២៦.-

ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យ តាមដានជាប្រចាំពីស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ ។

### មាត្រា ២៧.-

ក្រសួងបរិស្ថាន ត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពទឹក និងវាយតំលៃពីស្ថានភាពគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ២៨.-

ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ពីស្ថានភាពគុណភាពទឹក និងស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ២៩.-

ក្នុងករណីរកឃើញថា តំបន់ទឹកសាធារណៈត្រូវទទួលរងការបំពុល ដែលបង្កអោយមានការគំរាមកំហែងដល់ជីវិតមនុស្ស ឬជីវៈចំរុះ ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់នេះ និងត្រូវចាត់

វិធានការទប់ស្កាត់ការបំពុលទឹក និងស្តារនូវគុណភាពទឹកតំបន់ទឹកសាធារណៈនោះ ។

## ជំពូកទី ៦

## នីតិវិធីនៃការធ្វើអធិការកិច្ច

**មាត្រា ៣០.-**

នៅពេលចុះធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថាន ត្រូវអនុវត្តន៍តាមនីតិវិធីដូចចែងខាងក្រោម :

ក-បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកម្មរបស់ខ្លួន នៅពេលចូលក្នុងបរិវេណ ឬទីកន្លែងប្រភពបំពុលដើម្បីអធិការកិច្ច យកគំរូតាង ឬពិនិត្យកត់ត្រា

ខ-កំណត់ហេតុ និងរបាយការណ៍តំបូងនៃការត្រួតពិនិត្យ ឬការយកគំរូតាង ត្រូវធ្វើនៅនឹងកន្លែងដែលធ្វើអធិការកិច្ច ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់

គ-មន្ត្រីអធិការកិច្ចអាចសាកសួរ និងតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលផ្តល់នូវពត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ និងកំណត់ហេតុ សំរាប់ប្រើប្រាស់ជាវត្ថុតាង

ឃ-របាយការណ៍ ឬកំណត់ហេតុត្រូវផ្តល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល មួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន ។

**មាត្រា ៣១.-**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា ប្រភពបំពុលណាមួយបានបង្ហូរបញ្ចេញនូវសំណល់រាវ ដែលមានផ្ទុកសារធាតុពុល បង្កឱ្យមានគ្រោះថ្នាក់សុខភាពមនុស្សសត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្កអោយមានការបំពុលតំបន់ទឹកសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិចូលធ្វើអធិការកិច្ច នៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ ។

**មាត្រា ៣២.-**

ក្នុងករណីមានឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយ នៃការបំពុលទឹកនៅតំបន់ទឹកសាធារណៈ ក្រសួងបរិស្ថានត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ និងត្រូវជូនពត៌មានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

**មាត្រា ៣៣.-**

ក្នុងករណីបទល្មើសជាក់ស្តែងដែលបង្កឱ្យមានការបំពុលទឹក មន្ត្រីអធិការកិច្ចក្រសួងបរិស្ថានត្រូវ :

ក-ធ្វើកំណត់ហេតុ ប្រមូល ឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ប្រសិនបើបទល្មើសនោះមិនទាន់បង្កអោយមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ ឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ ។

ខ-ប្រមូល និងឃាត់ទុកភស្តុតាងនៃបទល្មើសនោះ ដើម្បីធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿងទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កអោយមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាពមនុស្សសត្វ ឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ ។

## ជំពូកទី ៧

## ទោសបញ្ញត្តិ

### មាត្រា ៣៤.-

ការរំលោភល្មើសទៅ និងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោស ដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៥ ជំពូកទី ៩ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

### មាត្រា ៣៥.-

កំណត់ហេតុចោទប្រកាន់បទល្មើស ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តន៍តាមមាត្រាណាមួយនៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថានត្រូវអនុវត្តវិធានការច្បាប់ចំពោះបទល្មើសទាំងឡាយនៅក្នុងអនុក្រឹត្យនេះ ។

### មាត្រា ៣៦.-

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណាដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិត និងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។

# ជំពូកទី ៨
# អវសានបញ្ញត្តិ

**មាត្រា ៣៧.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៩.-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**កន្លែងទទួល**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣៨

-កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

# តារាងឧបសម្ព័ន្ធ ១

## ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់

១-សមាសធាតុសរីរាង្គអាឡូសែន និងសារធាតុដែលអាចបង្កើតបានជាសមាសធាតុសរីរាង្គអាឡូសែនទាំងនោះនៅក្នុងបរិស្ថានទឹក

២-សមាសធាតុសរីរាង្គផូស្វរ

៣-សមាសធាតុសរីរាង្គទីន

៤-សារធាតុដែលបង្កអោយមានជំងឺមហារីក

៥-បារត និងសមាសធាតុរបស់វា

៦-កាត់មូម និងសមាសធាតុរបស់វា

៧-សមាសធាតុប្រេងអសរីរាង្គដែលមិនបំបែកធាតុ និងពពួកអ៊ីដ្រូកាបូនៃសមាសធាតុប្រេងឆៅ

៨-សមាសធាតុសំយោគដែលមិនបំបែកធាតុ ដែលអាចអណ្តែតនៅលើផ្ទៃទឹក រឺលិចក្នុងទឹកហើយដែលអាចជ្រាបចូលទៅក្នុងការប្រើប្រាស់ទឹក

៩-សារធាតុវិទ្យុសកម្ម

១០-លោហៈ និងសមាធាតុ របស់វាដូចជា :

| | | | |
|---|---|---|---|
| សង្កសី (Zn) | សេលីនីយ៉ូម (Se) | សំណប៉ាហាំង (Sn) | វ៉ាណាដ្យូម (V) |
| ទង់ដែង (Cu) | អាសេនិច (As) | បារីយ៉ូម (Ba) | កូបាល់ (Co) |
| នីកែល (Ni) | អង់ទីម៉ូនី (Sb) | បេរីលីយ៉ូម(Be) | តាល់យ៉ូម (Tl) |
| ក្រូម (Cr) | ម៉ូលីបដែន (Mo) | បរ (B) | តេលុយរិយ៉ូម (Te) |
| សំណ (Pb) | ទីតានីយ៉ូម (Ti) | អ៊ុយរ៉ាញ៉ូម (U) | ប្រាក់ (Ag) |

១១-សមាសធាតុសរីរាង្គពុលមិនបំបែកធាតុស៊ីលីស្យូម

១២-សមាសធាតុអសរីរាង្គផូស្វរ

១៣-សមាសធាតុប្រេងជាអសរីរាង្គបំបែកធាតុ និងពពួកអ៊ីដ្រូកាបូនៃសមាសធាតុប្រេងឆៅ

១៤-សមាសធាតុស៊ីអានីត និងភ្លុយអរ

១៥-សារធាតុដែលមានឥទ្ធិពលលើអុកស៊ីសែន ដូចជា អាម៉ូញ៉ាក់ នីទ្រីត ។ល។

# តារាងឧបសម្ព័ន្ធ ២

កំរិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវ ពីប្រភពបំពុលចូលទៅ

ក្នុងតំបន់ទឹកសាធារណៈ ឬទៅក្នុងប្រព័ន្ធបណ្តាញលូ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | បរិមាណសារធាតុបំពុលដែលអាចអនុញ្ញាតឱ្យបញ្ចេញ | |
|---|---|---|---|---|
| | | | តំបន់ទឹកសាធារណៈដែលត្រូវបានការពារ | តំបន់ទឹកសាធារណៈនិងលូ |
| 1 | សីតុណ្ហភាព | $^0C$ | <45 | <45 |
| 2 | pH | | 6-9 | 5-9 |
| 3 | $BOD_5$ | mg/l | <30 | <80 |
| 4 | COD | mg/l | <50 | <100 |
| 5 | សារធាតុរឹងអណ្តែតក្នុងទឹក | mg/l | <60 | <120 |
| 6 | សារធាតុរឹងដែលរលាយក្នុងទឹក | mg/l | <1000 | <2000 |
| 7 | ប្រេង ឬខ្លាញ់ | mg/l | <5.0 | <15 |
| 8 | សាប៊ូ | mg/l | <5.0 | <15 |
| 9 | ផេណុល | mg/l | <0.1 | <1.2 |
| 10 | នីត្រាត | mg/l | <10 | <20 |
| 11 | ក្លរក្នុងទំរង់សេរី | mg/l | <1.0 | <2.0 |
| 12 | ក្លរជាអ៊ីយ៉ុង | mg/l | <500 | <700 |
| 13 | ស៊ុលផាត | mg/l | <300 | <500 |
| 14 | ស៊ុលហ្វីត | mg/l | <0.2 | <1.0 |
| 15 | ផូស្វាត | mg/l | <0.3 | <6.0 |
| 16 | ស៊ីអានីត ($CN^{-1}$) | mg/l | <0.2 | <1.5 |
| 17 | បារ្យ៉ូម (Ba) | mg/l | <4.0 | <7.0 |
| 18 | អាសេនិច (As) | mg/l | <0.10 | <1.0 |
| 19 | សំណប៉ាហាំង(Sn) | mg/l | <2.0 | <8.0 |
| 20 | ដែក (Fe) | mg/l | <1.0 | <20 |
| 21 | បរ(B) | mg/l | <1.0 | <5.0 |
| 22 | ម៉ង់កាណែស(Mn) | mg/l | <1.0 | <5.0 |
| 23 | កាត់ម្ញ៉ូម(Cd) | mg/l | <0.1 | <0.5 |

| | | | | |
|---|---|---|---|---|
| 24 | ក្រូម(Cr)$^{+3}$ | mg/l | <0.2 | <1.0 |
| 25 | ក្រូម(Cr)$^{+6}$ | mg/l | <0.05 | <0.5 |
| 26 | ទង់ដែង(Cu) | mg/l | <0.2 | <1.0 |
| 27 | សំណ(Pb) | mg/l | <0.1 | <1.0 |
| 28 | បារត(Hg) | mg/l | <0.002 | <0.05 |
| 29 | នីកែល(Ni) | mg/l | <0.2 | <1.0 |
| 30 | សេលេញ៉ូម(Se) | mg/l | <0.05 | <0.5 |
| 31 | ប្រាក់(Ag) | mg/l | <0.1 | <0.5 |
| 32 | ស័ង្កសី(Zn) | mg/l | <1.0 | <3.0 |
| 33 | ប៉ូលីបដែន(Mo) | mg/l | <0.1 | <1.0 |
| 34 | អាម៉ូញាក់($NH_3$) | mg/l | <5.0 | <7.0 |
| 35 | អុកស៊ីសែនដែលរលាយក្នុងទឹក | mg/l | >2.0 | >.1.0 |
| 36 | ប៉ូលីក្លរ៉ូ បីផេនីល(PCB) | mg/l | <0.003 | <0.003 |
| 37 | កាល់ស្យូម(Ca) | mg/l | <150 | <200 |
| 38 | ម៉ាញ៉េស្យូម(Mg) | mg/l | <150 | <200 |
| 39 | កាបូនតេត្រាក្លរួ | mg/l | <3 | <3 |
| 40 | អ៊ិចសាក្លរបង់សែន | mg/l | <2 | <2 |
| 41 | ដេដេតេ | mg/l | <1,3 | <1,3 |
| 42 | អង់ឌ្រីន | mg/l | <0,01 | <0,01 |
| 43 | ឌីអលឌ្រីន | mg/l | <0,01 | <0,01 |
| 44 | អេនឌ្រីន | mg/l | <0,01 | <0,01 |
| 45 | អ៊ីសូឌ្រីន | mg/l | <0,01 | <0,01 |
| 46 | ពែក្លរអេទីឡែន | mg/l | <2,5 | <2,5 |
| 47 | អ៊ិចសាក្លរប៊ុយតាឌីអែន | mg/l | <3 | <3 |
| 48 | ក្លរហ្វម | mg/l | <1 | <1 |
| 49 | 1,2 ឌីក្លរអេទីឡែន | mg/l | <2,5 | <2,5 |
| 50 | ទ្រីក្លរអេទីឡែន | mg/l | <1 | <1 |
| 51 | ទ្រីក្លរបង់សែន | mg/l | <2 | <2 |
| 52 | អ៊ិចសាក្លរស៊ីក្លូអ៊ិចសែន | mg/l | <2 | <2 |

***កំណត់សំគាល់*** : ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការរៀបចំក៏រិតកំណត់ស្តង់ដារថ្នាំពុលកសិកម្ម ដែលបញ្ចេញពីប្រភពបំពុល ។

## តារាងឧបសម្ព័ន្ធ ៣

ប្រភេទនៃប្រភពបំពុល ដែលតំរូវអោយមានការសុំអនុញ្ញាតិពីក្រសួងបរិស្ថាន

មុននឹងបញ្ចេញចោលនូវសំណល់រាវរបស់ខ្លួន ឬដឹកទៅទីដទៃ

| ល.រ | ប្រភេទប្រភពបំពុល | កំរិតថ្នាក់ប្រភេទ |
|---|---|---|
| 1 | -ទីតាំងផលិតអាហារ និងសាច់កំប៉ុង | ទី១ |
| 2 | -ទីតាំងផលិតបន្លែ និងផ្លែឈើកំប៉ុង | ទី១ |
| 3 | -ទីតាំងកែច្នៃផលនេសាទ | ទី១ |
| 4 | -ទីតាំងក្លាសេ និងបង្កក | ទី១ |
| 5 | -ទីតាំងផលិតម្សៅមី | ទី១ |
| 6 | -ទីតាំងផលិតស្ករស | ទី១ |
| 7 | -ទីតាំងផលិតទឹកស្អាត | ទី១ |
| 8 | -ទីតាំងផលិតស្នូនរបស់ប្រើប្រាស់ពីដី | ទី១ |
| 9 | -ទីតាំងផលិតភេសជ្ជៈ និងស្រាបៀរ | ទី១ |
| 10 | -ទីតាំងផលិតអាល់កុល និងស្រា | ទី១ |
| 11 | -ទីតាំងផលិតចំណីសត្វ | ទី១ |
| 12 | -ទីតាំងផលិតប្រេង និងខ្លាញ់ | ទី១ |
| 13 | -ទីតាំងផលិតដំបែ និងមេស្រា | ទី១ |
| 14 | -ទីតាំងផលិតនំ និងស្ករគ្រាប់ | ទី១ |
| 15 | -ទីតាំងផលិតបារី | ទី១ |
| 16 | -ទីតាំងកាត់ដេរគ្មានក្រឡុកបោក | ទី១ |
| 17 | -សណ្ឋាគារ | ទី១ |
| 18 | -ភោជនីយដ្ឋាន | ទី១ |
| 19 | -ទីតាំងកសិដ្ឋានចិញ្ចឹមសត្វ | ទី១ |
| 20 | -ទីតាំងសត្តឃាត | ទី១ |
| 21 | -ទីតាំងយានដ្ឋាន និងកន្លែងលាងរថយន្ត | ទី១ |
| 22 | -ទីតាំងមជ្ឈមណ្ឌលលក់ដុំ និងទីផ្សារ | ទី១ |
| 23 | -ទីតាំងមន្ទីរពេទ្យ និងសម្ភព | ទី១ |
| 24 | -ទីតាំងផលិតរបស់ប្លាស្ទិក-កៅស៊ូកង់ | ទី១ |
| 25 | -ទីតាំងប្រព្រឹត្តកម្មសំអាតសំណល់រាវលំនៅស្ថាន | ទី១ |
| 26 | -ទីតាំងផលិតជ័រការ | ទី១ |
| 27 | -ទីតាំងបង្កក និងកែច្នៃជ័រក្រែប | ទី១ |

| | | |
|---|---|---|
| 28 | -ទីតាំងផលិតកែវ-ដប | ទី១ |
| 29 | -ទីតាំងផលិតស៊ីម៉ងត៍ | ទី១ |
| 30 | -ការដ្ឋានយកថ្ម | ទី១ |
| 31 | -ការដ្ឋានយកគ្រួស | ទី១ |
| 32 | -ទីតាំងផលិតក្តារបន្ទះ | ទី១ |
| 33 | -ទីតាំងផលិត ឬកែច្នៃជីគីមីកសិកម្ម | ទី១ |
| 34 | -ទីតាំងលាយបេតុង និងផលិតសំភារៈសំណង់ជាបេតុង | ទី១ |
| 35 | -នាំវាំដឹកសារធាតុពុល | ទី២ |
| 36 | -ទីតាំងផលិតអាសេទីឡែន | ទី២ |
| 37 | -ទីតាំងសំលាប់ស្បែក | ទី២ |
| 38 | -ទីតាំងផលិតសាប៊ូ និងផលិតមេសាប៊ូ | ទី២ |
| 39 | -ទីតាំងស្ថានីយ៍ និងឃ្លាំងស្តុកប្រេងឥន្ធនៈ | ទី២ |
| 40 | -ទីតាំងកប់ ឬចាក់ចោលសំណល់រឹង | ទី២ |
| 41 | -ទីតាំងតំបាញ ឬជ្រលក់ពណ៌ | ទី២ |
| 42 | -ទីតាំងកាត់ដេរមានក្រឡុកបោក | ទី២ |
| 43 | -ទីតាំងផលិតក្រដាស និងម្សៅក្រដាស | ទី២ |
| 44 | -ទីតាំងបោះពុម្ពទស្សនាវដ្តី និងឯកសារផ្សេងៗ | ទី២ |
| 45 | -ទីតាំងលាងសំអាតត្បូងថ្ម និងរ៉ែ | ទី២ |
| 46 | -ទីតាំងផលិតថ្មពិល —អាគុយ | ទី២ |
| 47 | -ទីតាំងផលិតថ្នាំពណ៌អសរីរាង្គ | ទី២ |
| 48 | -ទីតាំងផលិត និងតំឡើងគ្រឿងអេឡិចត្រូនិច | ទី២ |
| 49 | -ទីតាំងផលិតជ័រក្រាលថ្ម | ទី២ |
| 50 | -ទីតាំងផលិតហ្វីលថត និងថ្នាំលាងហ្វីល | ទី២ |
| 51 | -ទីតាំងផលិតសារធាតុគីមីសរីរាង្គ | ទី២ |
| 52 | -ទីតាំងផលិតឱសថ | ទី២ |
| 53 | -ទីតាំងផលិតសារធាតុសរីរាង្គប្រើសំរាប់លាង | ទី២ |
| 54 | -ទីតាំងផលិត និងលាយថ្នាំពុលកសិកម្ម | ទី២ |
| 55 | -ទីតាំងផលិត ចំរាញ់ប្រេងកាត | ទី២ |
| 56 | -ទីតាំងផលិតដែក និងដែកថែប | ទី២ |
| 57 | -ទីតាំងផលិតលោហៈធាតុដែលមិនមែនដែក | ទី២ |
| 58 | -ទីតាំងផលិតរបស់របរលោហៈ | ទី២ |

| | | |
|---|---|---|
| 59 | -ទីតាំងក្រូមេ៉របស់លោហៈធាតុដែលមិនមែនដែក | ទី២ |
| 60 | -ទីតាំងដុត រឺកែច្នៃសំណល់រឹង | ទី២ |
| 61 | -ទីតាំងប្រព្រឹត្តកម្មសំអាតដី | ទី២ |
| 62 | -ទីតាំងកែច្នៃសំណល់ប្រេង | ទី២ |
| 63 | -ទីតាំងប្រព្រឹត្តកម្មសំអាតសំណល់រាវឧស្សាហកម្ម | ទី២ |
| 64 | -មន្ទីរពិសោធន៏ និងមជ្ឈមណ្ឌលស្រាវជ្រាវ | ទី២ |
| 65 | -រោងចក្រអគ្គិសនី | ទី២ |
| 66 | -ទីតាំងកែច្នៃឈើ | ទី២ |
| 67 | -ការដ្ឋានស្រែបង្គា | ទី២ |

# តារាងឧបសម្ព័ន្ធ ៤

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ

សំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹក

## ១.សំរាប់ទន្លេ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 6,5-8,5 |
| 2 | $BOD_5$ | mg/l | 1-10 |
| 3 | សារធាតុរឹងអណ្តែតលើទឹក(SS) | mg/l | 25-100 |
| 4 | កំរិតរលាយអុកស៊ីសែន(DO) | mg/l | 7,5-2,0 |
| 5 | កូលីហ្វម(Coliform) | MPN/100ml | <5000 |

## ២.សំរាប់បឹង និងអាងស្តុកទឹក

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 6,5-8,5 |
| 2 | COD | mg/l | 1-8 |
| 3 | សារធាតុរឹងអណ្តែតលើទឹក(SS) | mg/l | 1-15 |
| 4 | កំរិតរលាយអុកស៊ីសែន(DO) | mg/l | 7,5-2,0 |
| 5 | កូលីហ្វម(Coliform) | MPN/100ml | <1000 |
| 6 | អាសូតសរុប(Total Nitrogen) | mg/l | 0,1-0,6 |
| 7 | ផូស្វរសរុប(Total Phosphorus) | mg/l | 0,005-0,05 |

## ៣.សំរាប់ទឹកសមុទ្រ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 7,0-8,3 |
| 2 | COD | mg/l | 2-8 |
| 3 | កំរិតរលាយអុកស៊ីសែន(DO) | mg/l | 7,5-2,0 |
| 4 | កូលីហ្វម(Coliform) | MPN/100ml | <1000 |
| 5 | សមាសធាតុប្រេង(Oil content) | mg/l | 0 |
| 6 | អាសូតសរុប (Total Nitrogen) | mg/l | 0,2-1,0 |
| 7 | ផូស្វរសរុប (Total Phosphorus) | mg/l | 0,02-0,09 |

# តារាងឧបសម្ព័ន្ធ ៥

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ

សំរាប់ការពារសុខភាពសាធារណៈ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | កាបូនតេត្រាក្លរួ | µg/l | <12 |
| 2 | អ៊ិចសាក្លរបង់សែន | µg/l | <0,03 |
| 3 | ដេដេតេ | µg/l | <10 |
| 4 | អង់ឌ្រីន | µg/l | <0,01 |
| 5 | ឌីអលឌ្រីន | µg/l | <0,01 |
| 6 | អេនឌ្រីន | µg/l | <0,005 |
| 7 | អ៊ីសូឌ្រីន | µg/l | <0,005 |
| 8 | ពែក្លរួអេទីឡែន | µg/l | <10 |
| 9 | អ៊ិចសាក្លរប៊ុយតាឌីអែន | µg/l | <0,1 |
| 10 | ក្លរហ្វម | µg/l | <12 |
| 11 | 1,2ឌីក្លរអេទីឡែន | µg/l | <10 |
| 12 | ទ្រីក្លរអេទីឡែន | µg/l | <10 |
| 13 | ទ្រីក្លរបង់សែន | µg/l | <0,4 |
| 14 | អ៊ិចសាក្លរស៊ីក្លូអ៊ិចសែន | µg/l | <0,05 |
| 15 | បង់សែន | µg/l | <10 |
| 16 | តេត្រាក្លរអេទីឡែន | µg/l | <10 |
| 17 | កាត់ម្ញូម | µg/l | <1 |
| 18 | បារតសរុប | µg/l | <0,5 |
| 19 | បារតសរីរាង្គ | µg/l | 0 |
| 20 | សំណ | µg/l | <10 |
| 21 | ក្រូមវ៉ាឡង់ ៦ | µg/l | <50 |
| 22 | អាសេទិច | µg/l | <10 |
| 23 | សេលេញ៉ូម | µg/l | <10 |
| 24 | ប៉ូលីក្លរ៉ូ ប៊ីផេនីល(PCB) | µg/l | 0 |
| 25 | ស៊ីអានីត ($CN^{+}$) | µg/l | <0,005 |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

**លេខ** : ៣៦ អ.ន.ក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការគ្រប់គ្រងសំណល់រឹង

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩៩ ។

## សំរេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំនត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត ចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចោញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានបកស្រាយដូចតទៅ :

ក-"**សំណល់រឹង**" គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់កំទេចកំទីដែលលែងត្រូវការប្រើប្រាស់ ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោល ឬតំរូវឱ្យបោះបង់ចោល ។

ខ-"**សំរាម**" គឺជាផ្នែកមួយនៃសំណល់រឹង ដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ ហើយត្រូវបញ្ចោញពីលំនៅស្ថាន អាគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកំសាន្ត ។ល។

គ-"**សំណល់ប្រកបដោយគ្រោះថ្នាក់**" គឺសំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កអោយមានជំងឺមហារីក ចំលងជំងឺ ធ្វើអោយរលាក ធ្វើអោយច្រេះ ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីដទៃទៀត ដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន ។ សំណល់ប្រកបដោយគ្រោះថ្នាក់អាចមានប្រភពពីលំនៅស្ថាន រោងចក្រឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និងសេវាកម្មអាជីវកម្មរ៉ែ ។ល។ ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូកទី ២

## ការគ្រប់គ្រងសំរាម

**មាត្រា ៤.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពី គោលការណ៍ណែនាំលើការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណសំរាម និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ដើម្បីធានាបាននូវការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ។

អាជ្ញាធរខេត្ត-ក្រុង ត្រូវរៀបចំផែនការគ្រប់គ្រងសំរាមនៅក្នុងខេត្ត-ក្រុង របស់ខ្លួន សំរាប់រយៈពេលខ្លី រយៈពេល

មធ្យម និងរយៈពេលវែង ។

**មាត្រា ៥.-**

ការអនុវត្តន៍ក្នុងការប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តន៍វាក្យខ័ណ្ឌទី ១ នៃមាត្រា៥ នេះត្រូវអនុលោមទៅតាមគោលការណ៍ណែនាំលើការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ដែលមានចែងក្នុងប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៦.-**

ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យលើការអនុវត្តន៍ក្នុងការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ។

**មាត្រា ៧.-**

ហាមឃាត់ជាដាច់ខាត ការបោះចោលសំរាមនៅតាមទីសាធារណៈ ឬការចាក់ចោលសំរាមខុសទីកន្លែង ដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា ៨.-**

ការវិនិយោគក្នុងស្រុកលើការសាងសង់កន្លែងចាក់ចោល ដុត ស្តុក ឬកែច្នៃសំរាម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន ជាមុនសិន ។

**មាត្រា ៩.-**

ការនាំចេញសំរាមពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបានល្គឹកណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្មព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាមីប្រទេស ជាមុនសិន ។

**មាត្រា ១០.-**

ហាមឃាត់ជាដាច់ខាត ការនាំសំរាមពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣

## ការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

**មាត្រា ១១.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពីគោលការណ៍ណែនាំ លើការគ្រប់គ្រងសំណល់ ប្រកបដោយគ្រោះថ្នាក់ ដើម្បីធានាបាននូវការគ្រប់គ្រងប្រកបដោយសុវត្ថិភាព ។

**មាត្រា ១២.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពី កំរិតស្តង់ដារបរិមាណជាតិពុល ឬសារធាតុគ្រោះថ្នាក់ នៅក្នុងសំណល់ប្រ

កបដោយគ្រោះថ្នាក់ ដែលអាចអនុញ្ញាតអោយបោះបង់ចោល ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស ការការពារគុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ១៣.-**

ម្ចាស់សំណល់ ត្រូវទទួលខុសត្រូវក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ននូវសំណល់ប្រកបដោយគ្រោះថ្នាក់របស់ខ្លួន តាមលក្ខណៈបច្ចេកទេសសមស្របនឹងមានសុវត្ថិភាព ។

**មាត្រា ១៤.-**

ម្ចាស់សំណល់ ត្រូវធ្វើ និងផ្ញើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទង និងសំណល់ប្រកបដោយគ្រោះថ្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួន រួមមាន :

ក-ប្រភេទ និងបរិមាណសំណល់

ខ-វិធីសាស្ត្រក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ន

គ-វិធីសាស្ត្រក្នុងការសំអាតសំណល់ ឬបំបាត់សំណល់ ។

**មាត្រា ១៥.-**

ការទុកដាក់ ស្តុក ដឹកជញ្ជូន និងការបោះចោល ឬចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុវត្តដាច់ដោយឡែកពីសំរាមធម្មតា ដែលនឹងមានចែងនៅក្នុងប្រកាសរបស់ក្រសួងបរិស្ថាន ។

ហាមឃាត់ជាដាច់ខាត ការបោះចោល ឬការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់នៅតាមទីសាធារណៈ ប្រព័ន្ធលូសាធារណៈ ប្រភព ឬបណ្តាញផ្លូវទឹក តំបន់ជនបទ និងតំបន់ព្រៃភ្នំ ។

**មាត្រា ១៦.-**

ការប្រមូល ដឹកជញ្ជូន ស្តុក និងការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់ តាមលំនៅស្ថាន ទីផ្សារ គ្លីនិក សម្ភព មន្ទីរពេទ្យ សណ្ឋាគារ ភោជនីយដ្ឋាន និងអាគារសាធារណៈ គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តន៍វាក្យខ័ណ្ឌទី១ នៃមាត្រា១៦ នេះ ត្រូវអនុលោមទៅតាមប្រកាសរបស់ក្រសួងបរិស្ថាន ស្តីពី គោលការណ៍ណែនាំលើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

**មាត្រា ១៧.-**

ការដឹកជញ្ជូន ឬសាងសង់ទីកន្លែងចាក់ ឬទីកន្លែងស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ដែលមានប្រភពពីរោងចក្រសហគ្រាស និងមូលដ្ឋានផលិតកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន ជាមុនសិន ។

**មាត្រា ១៨.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែងចាក់ ឬស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ត្រូវធ្វើ និងផ្ញើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទងទៅនឹងសំណល់ ដែលបានដឹកយកមកចាក់ចោល ឬស្តុកនៅកន្លែងរបស់ខ្លួន រួមមាន :

ក-ប្រភេទ និងបរិមាណសំណល់

ខ-ប្រភពដើមរបស់សំណល់

គ-ការដឹកជញ្ជូនរបស់សំណល់ និងមធ្យោបាយវេចខ្ចប់

ឃ-ដំណើរការ និងការគ្រប់គ្រងសំណល់នៅក្នុងទីកន្លែងរបស់ខ្លួន ។

**មាត្រា ១៩.-**

ការវិនិយោគលើការធ្វើប្រព្រឹត្តកម្មសំអាត ឬដុតសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវមានការឯកភាពពីក្រសួងបរិស្ថាន ជាមុនសិន ។

**មាត្រា ២០.-**

ការនាំចេញនូវសំណល់ប្រកបដោយគ្រោះថ្នាក់ ពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបាន លុះត្រាណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាមីប្រទេស ជាមុនសិន ។

ការនាំចេញនូវសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុលោមតាមបទប្បញ្ញត្តិ និងគោលការណ៍នៃអនុសញ្ញាអន្តរជាតិបាសែល ស្តីពីការត្រួតពិនិត្យការដឹកជញ្ជូនអន្តរជាតិ និងការបោះបង់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ឆ្នាំ ១៩៨៩ ដែលចូលជាធរមាននៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩២ ។

**មាត្រា ២១.-**

ហាមឃាត់ជាដាច់ខាត ការនាំចូលសំណល់ប្រកបដោយគ្រោះថ្នាក់ពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៤
## ការត្រួតពិនិត្យ និងការធ្វើអធិការកិច្ច
## លើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

**មាត្រា ២២.-**

ការត្រួតពិនិត្យលើការវេចខ្ចប់ ទុកដាក់ ស្តុក ដឹកជញ្ជូន កែច្នៃ ដុត ធ្វើប្រព្រឹត្តកម្មសំអាតជាតិពុល និងការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

**មាត្រា ២៣.-**

ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងសំណល់ប្រកបដោយគ្រោះថ្នាក់ នៅគ្រប់គោលដៅដែលមានចែងក្នុងមាត្រា២២ នៃអនុក្រឹត្យនេះ ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រា២៣ នេះត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២៤.-**

ការវិភាគគំរូតាងសំណល់ប្រកបដោយគ្រោះថ្នាក់ ក្នុងពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចត្រូវយកទៅធ្វើនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ មាត្រា២៣ នៃអនុក្រឹត្យនេះ អាចសុំធ្វើការវិភាគគំរូតាងសំណល់របស់ខ្លួន នៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តនូវវិធីសាស្ត្រវិភាគ ដូចដែលបានអនុវត្តក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ មាត្រា២៣ នៃអនុក្រឹត្យនេះ ត្រូវបង់ថ្លៃវិភាគសំណល់របស់ខ្លួន តាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំណត់ជាមុន ដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំណូលនេះ ត្រូវបញ្ចូលទៅក្នុងថវិកាជាតិ ដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

**មាត្រា ២៥.-**

ក្នុងករណីដែលរកឃើញថា មានការលួចចាក់ចោល ឬបោះចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ដោយគ្មានការអនុញ្ញាតិពីស្ថាប័នមានសមត្ថកិច្ច ក្រសួងបរិស្ថាន សហការជាមួយស្ថាប័នពាក់ព័ន្ធ ត្រូវចុះធ្វើអធិការកិច្ចដល់ទីកន្លែងនោះ ដោយអនុវត្តន៍តាមនីតិវិធី ដែលមានចែងខាងក្រោម :

ក-បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកម្មរបស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬទីកន្លែងនោះ ដើម្បីធ្វើអធិការកិច្ច និងយកគំរូតាង ។

ខ-ត្រូវធ្វើនៅនឹងកន្លែង នូវកំណត់ហេតុ និងរបាយការណ៍តំបូងនៃការត្រួតពិនិត្យ ឬការយកគំរូតាង ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់ ។

គ-ត្រូវសាកសួរ និងតំរូវអោយម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ផ្តល់នូវពត៌មាន ឬឯកសារនានាដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ ឬកំណត់ហេតុ និងសំរាប់ជាវត្ថុតាង ។

ឃ-ប្រមូល និងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះ ។

**មាត្រា ២៦.-**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា មានស្តុកទុក ឬការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់បណ្តាលអោយប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្កអោយមានការបំពុលបរិស្ថាន ក្រសួងបរិស្ថាន ត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់ ហើយត្រូវជូនពតិមានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**មាត្រា ២៧.-**

ការរំលោភល្មើសទៅនឹងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោសដោយយោងទៅតាម មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា២៥ ជំពូកទី ៩ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ២៨.-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមសមគំនិត នឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តបទល្មើសនោះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។

**មាត្រា ២៩.-**

កំណត់ហេតុ និងការធ្វើបណ្តឹង ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ គឺជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។

## ជំពូកទី ៦

## អវសានបញ្ញត្តិ

**មាត្រា ៣០.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង។ខ្លួន។

**មាត្រា ៣២.-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ.ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**កន្លែងទទួល**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣១

-កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

# តារាងឧបសម្ព័ន្ធ

## ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់

១-សំណល់សរសៃអំបោះ និងកំទេចក្រណាត់ដែលមានពណ៌ (ក្នុងករណីយកទៅដុត) ។

២-សំណល់កំទេចក្រដាស ដែលសល់ពីការផលិតម្សៅក្រដាស ។

៣-សំណល់ភក់ ដែលបង្កើតឡើងដោយរោងចក្រប្រព្រឹត្តកម្មសំអាតសំណល់រាវ និងទឹកល្ង ។

៤-សំណល់ដែលសល់ពីការឆេះមិនអស់នៅក្នុងឡឧស្សាហកម្ម ។

៥-សំណល់ប្លាស្ទិច "ប៉ូលីវីនីក្លរួ" ។

៦-សំណល់សារធាតុជ័រប៉ូលីក្លរីណេតទីតប៊ីផេនីល (PCB) នៃម៉ាស៊ីនត្រជាក់ ទូរទស្សន៍ វិទ្យុ ម៉ាញ៉េ ។ល ។

៧-សំណល់ជ័រ និងកៅស៊ូដែលមានសារធាតុប៉ូលីម៉ែប៊ុយទីលីន

៨-សំណល់ប្រេងឥន្ធនៈ និងប្រេងម៉ាស៊ីន

៩-សំណល់ដែលមានផ្ទុកជាតិអាស៊ីត

១០-សំណល់ដែលមានផ្ទុកជាតិបាស

១១-សំណល់លោហៈ និងសមាសធាតុរបស់វារួមមាន :

| | | | |
|---|---|---|---|
| សង្កសី (Zn) | សេលីនីយ៉ូម (Se) | សំណប៉ាហាំង (Sn) | វ៉ាណាដ្យូម (V) |
| ទង់ដែង (Cu) | អាសេនិច (As) | បារីយ៉ូម (Ba) | កូបាល់ (Co) |
| នីកែល (Ni) | អង់ទីម៉ូនី (Sb) | បេរីលីយ៉ូម(Be) | តាល់យ៉ូម (Tl) |
| ក្រូម (Cr) | ម៉ូលីបដែន (Mo) | បរ (B) | តេលុយរិយ៉ូម (Te) |
| សំណ (Pb) | ទីតានីយ៉ូម (Ti) | អ៊ុយរ៉ាញ៉ូម (U) | ប្រាក់ (Ag) |
| បារត (Hg) | កាត់ម្យូម (Cd) | ដែក (Fe) | |

១២-លំអងផ្សែង និងធូលីដែលកើតមានក្នុងករណីសំអាតផ្សែងបញ្ចេញពីមូលដ្ឋានផលិតកម្ម

១៣-សំណល់អំពូលអគ្គិសនី និងបន្ទះប្រព័ន្ធគ្រឿងអេឡិចត្រូនិចអគ្គិសនី

១៤-សំណល់អាគុយ និងថ្មពិល

១៥-សំណល់ថ្នាំលាប និងថ្នាំជ្រលក់ពណ៌ និងសំភារៈវេចខ្ចប់ថ្នាំពណ៌

១៦-សំណល់បានមកពីការផលិត និងការប្រើប្រាស់ទឹកខ្មៅបោះពុម្ព

១៧-សំណល់គ្រឿងផ្ទុះ

១៨-សំណល់ដែលនាំអោយមានការចំលងមេរោគ ឬជំងឺ

១៩-សំណល់ដែលសល់ពីការផលិតថ្នាំពុលកសិកម្ម និងសំភារៈវេចខ្ចប់

២០-សំណល់ផេះនៃឡដុតសំរាម សំណល់រឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់

២១-ផលិតផលដែលមិនឆ្លើយតបទៅនឹងបទដ្ឋាននានា និងហួសកំណត់

២២-សំណល់ហ្វីល ដូចជាហ្វីលភាពយន្ត វីដេអូ ហ្វីលកាសែតចំរៀង ហ្វីលថតរូប និងហ្វីលថតសរីរាង្គមនុស្សតាមមន្ទីរពេទ្យ

២៣-សំណល់ដែលបានពីក្រោយពេលធ្វើប្រព្រឹត្តកម្មសំអាតដីកខ្វក់ ឬដីខូចគុណភាព

២៤-សំណល់ដែលបានមកពីការផលិតឱសថ និងឱសថដែលខូចគុណភាព

២៥-សំណល់ដែលជាសមាសធាតុសរីរាង្គក្លយអរីន

២៦-សំណល់ដែលជាសមាសធាតុស៊ីអានីត

២៧-សំណល់ដែលជាសមាសធាតុអាសបេតូស

២៨-សំណល់ដែលជាសមាសធាតុផេណុល ($C_6H_5OH$)

២៩-សំណល់ដែលជាសមាសធាតុអេទែ ($R\text{-}COO\text{-}R_1$)

៣០-សំណល់ដែលជាសារធាតុសរីរាង្គរំលាយដែលមានអាឡូសែន និងគ្មានអាឡូសែន

៣១-សំណល់ដែលជាសមាសធាតុឌីអុកស៊ីន និងហ្វូរ៉ាន

៣២-សំណល់ធាតុវិទ្យុសកម្ម

៣៣-សារធាតុដែលជាផលិតផលបានមកពីការធ្វើប្រព្រឹត្តកម្មសំអាតសំណល់ ដែលមានចែងពីចំនុចទី១ ដល់ទី៣២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

# សម្រេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាពសាធារណៈ និងបរិស្ថាន។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី ក្រុងនិងស្រុក និងធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ
- កំណត់វិធានការចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើការញែក ការទុកដាក់ ការសម្អាត ការប្រមូល ការដឹកជញ្ជូន ការកែច្នៃ និងការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះពុំមានវិសាលភាពអនុវត្តលើការងារគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម និងសំណល់គ្រោះថ្នាក់ឡើយ។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

## ជំពូកទី២

## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥ .-**

ក្រសួងបរិស្ថាន មានតួនាទីដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ
- ផ្តល់ការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ដឹកនាំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន ឬសាធារណៈ ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារ គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការអប់រំក្នុងនិងក្រៅប្រព័ន្ធ និងការផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ (3R: Reduce, Reuse, Recycle) និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៦.-**

ក្រសួងមហាផ្ទៃ មានតួនាទីជំរុញដល់កិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- គាំទ្រនិងសហការជាមួយក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធន៍អំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងកៀរគរការគាំទ្រនានាទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ផ្តល់អន្តរាគមន៍ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៧.-**

រដ្ឋបាលខេត្តត្រូវផ្តល់ការគាំទ្រ និងការសម្របសម្រួល ព្រមទាំងជំរុញកិច្ចប្រតិបត្តិការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលអនុវត្តដោយរដ្ឋបាលក្រុង ស្រុក និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានចាំបាច់នានាសម្រាប់ណែនាំនិងជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ណែនាំដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកា

ប្រចាំឆ្នាំសម្រាប់គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ជំរុញ និងគាំទ្រការបង្កើតសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន
- កៀរគរធនធាន មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលក្រុង ស្រុកលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងជំរុញការអប់រំ និងការផ្សព្វផ្សាយតាមគ្រប់រូបភាពដល់សាធារណជនអំពីសារប្រយោជន៍នៃការញែកសំរាម សំណល់រឹងទីប្រជុំជន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន
- សម្របសម្រួលដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំនិងប្រើប្រាស់រួមគ្នានូវសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តរបស់រដ្ឋបាលក្រុង ស្រុកក្នុងការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៨.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្តលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីអនាម័យបរិស្ថានតាមរយៈការអប់រំ និងធ្វើការផ្សព្វផ្សាយអំពីការទុកដាក់ ការសម្អាត ការញែក ការកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការចូលរួមប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួមរៀបចំផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើសំណើ ឬគម្រោងសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងដំណើរការសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងសកម្មភាពកែច្នៃសំរាម សំណល់រឹងប្រជុំជន
- ជំរុញការអនុវត្តវិធានការច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងចូលរួមការអនុវត្តវិធានការពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន និង
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីស្ថានភាព និងដំណើរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកមានតួនាទីក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំ និងអនុវត្តនូវវិធានការសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមរយៈការដាក់ចេញជាដីកា ឬលិខិតបទដ្ឋាននានា
- បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធ្វើការណែនាំដល់ប្រជាពលរដ្ឋអំពីការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលបានរៀបចំនៅក្នុងមូលដ្ឋាន និង
- អប់រំនិងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកនីមួយៗអាចស្នើសុំបង្កើតអង្គភាព ឬការិយាល័យដាក់លាក់ចំណុះរដ្ឋបាលរបស់ខ្លួនសម្រាប់ទទួលខុសត្រូវលើកិច្ចការនេះ ស្របតាមគោលការណ៍ និងនីតិវិធីជាធរមាន ដើម្បីធានាដល់ប្រសិទ្ធភាព និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១១.-**

រដ្ឋបាលរាជធានីត្រូវផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឬ/និងរដ្ឋបាលសង្កាត់។

រដ្ឋបាលក្រុង ស្រុកអាចធ្វើប្រតិភូកម្មមុខងារមួយផ្នែកក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១២.-**

រដ្ឋបាលខណ្ឌត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួល និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងរាជធានី និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តមុខងារដែលបានទទួលក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួម និងសហការអនុវត្តនូវកម្មវិធីនានានៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូលនិងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១៣.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួលប្រតិភូកម្ម និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមការធ្វើប្រតិភូកម្ម
- ចូលរួមអប់រំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការប្រើប្រាស់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ច
- ចូលរួមផ្តល់យោបល់លើការរៀបចំកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការងារសេវាសម្អាតប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង
- ចូលរួមសហការពង្រឹងការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១៤.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចដាក់ចេញលិខិតបទដ្ឋានសម្រាប់ណែនាំដល់ការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

## ជំពូកទី៣
## ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា១៥.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវអនុវត្តការញែក និងការវេចខ្ចប់សំរាម សំណល់រឹងដែលអាចប្រើប្រាស់ឡើងវិញ ឬកែច្នៃបានដាច់ដោយឡែកពីសំរាម សំណល់រឹងដែលត្រូវបោះចោលទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៦.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការវេចខ្ចប់ដោយថង់ ឬការដាក់នៅក្នុងធុងសំរាមផ្ទាល់ខ្លួននូវសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងលក្ខណៈហ្មត់ចត់ មិនឱ្យលេចធ្លាយ មិនឱ្យលេចជ្រាបទឹកស្អុយ ឬមិនឱ្យមានភាយក្លិនស្អុយក្នុងរយៈពេលនៃការទុកដាក់រង់ចាំការបញ្ចេញទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៧.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការរក្សាទុកនូវកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬបរិវេណនៃលំនៅឋាន អគារ ឬទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមពេលម៉ោងដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការត្រួតពិនិត្យឱ្យបានម៉ឹងម៉ាត់លើការអនុវត្តការបញ្ចេញកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជនទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈរង់ចាំការប្រមូល និងដឹកជញ្ជូនទៅតាមពេលម៉ោងដែលបានកំណត់។

**មាត្រា១៨.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំដីកា ឬលិខិតបទដ្ឋាននានា ដើម្បីណែនាំអនុវត្តការសម្អាត ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃទីប្រជុំជននីមួយៗ និងត្រូវធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងលើកកម្ពស់សោភ័ណភាព អនាម័យ និងបរិស្ថាននៅតាមទីប្រជុំជន ។

ដីកា ឬលិខិតបទដ្ឋានខាងលើនេះ ត្រូវរៀបចំឡើងដោយអនុលោមតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសជាធរមាន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវផ្សព្វផ្សាយដីកា ឬលិខិតបទដ្ឋាននានា ដូចមានចែងក្នុងកថាខណ្ឌខាងលើឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាឱ្យមានការចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវ។

## ជំពូកទី៤
## វិធានការទូទៅលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា២០.-**

ត្រូវបានហាមឃាត់ជាដាច់ខាតនូវការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល តាមប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការទប់ស្កាត់ការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល ប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

**មាត្រា២១.-**

រូបវន្តបុគ្គល និងនីតិបុគ្គលដែលប្រើប្រាស់ទីសាធារណៈសម្រាប់ការប្រារព្ធ ឬដំណើរការកម្មវិធីរបស់ខ្លួន ត្រូវទទួលខុសត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងពិធីទៅឱ្យអ្នកផ្ដល់សេវាប្រមូលក្នុងមូលដ្ឋាន ទៅតាមតម្លៃដែលបានកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២២.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់ចែងឱ្យមានធុងសំរាមសាធារណៈ និងត្រូវរៀបចំឱ្យមានសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតពីការលក់ដូរនៅតាមដងផ្លូវ និងទីសាធារណៈ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ម្ចាស់ ឬអ្នកគ្រប់គ្រងផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាសសិប្បកម្ម មណ្ឌលកំសាន្តត្រូវរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណ សម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន។

**មាត្រា២៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកម៉ៅការការដ្ឋានវាយកម្ទេច ជួសជុល ឬសាងសង់លំនៅឋាន ឬអគារត្រូវទទួលខុសត្រូវលើសំរាម សំណល់រឹងដែលចេញពីការដ្ឋានរបស់ខ្លួន ដូចខាងក្រោម៖

- ទុកដាក់ឱ្យបានត្រឹមត្រូវ មិនបង្កការប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ និងបរិស្ថាន និង
- សម្អាត ប្រមូល និងដឹកជញ្ជូនដោយខ្លួនឯងទៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ឬប្រើប្រាស់សេវា សម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានក្នុងមូលដ្ឋាន និងត្រូវបង់ថ្លៃតាមការកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់កន្លែងសមស្របសម្រាប់ស្តុកសំរាម សំណល់រឹងទីប្រជុំជនបណ្ដោះអាសន្នតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពក្នុងការប្រមូល និងដឹកជញ្ជូន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់ពេលវេលាដែលអាចអនុញ្ញាតឱ្យបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនយកទៅដាក់នៅកន្លែងស្តុកសំរាមបណ្ដោះអាសន្ន និងត្រូវចាត់វិធានការរារាំងការយកសំរាម សំណល់រឹងទៅបញ្ចេញនៅកន្លែងស្តុកសំរាមបណ្ដោះអាសន្នខុសពេលវេលាដែលបានកំណត់។

**មាត្រា២៥.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងនានា និងបុរីលំនៅឋាន ត្រូវរៀបចំកន្លែងសមស្របសម្រាប់ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងបរិវេណគ្រប់គ្រងរបស់ខ្លួនរង់ចាំការដឹកចេញដែលមិនបង្កផលប៉ះពាល់ដល់សោភ័ណភាព សណ្ដាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងសុខភាពសាធារណៈ។

**មាត្រា២៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការបន្ទាន់ចំពោះករណីមានការកកស្ទះសំរាម សំណល់រឹងទីប្រជុំជនដែលបណ្ដាលមកពីភាពអសកម្មនៃអ្នកផ្ដល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនដោយប្រើប្រាស់គ្រប់មធ្យោបាយតាមដែលអាចធ្វើបានក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដើម្បីដោះស្រាយភាពកកស្ទះ។

ចំពោះការចំណាយក្នុងប្រតិបត្តិការខាងលើ គឺជាបន្ទុកផ្ទាល់របស់អ្នកផ្ដល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅក្នុងទីប្រជុំជននោះ។

**ប្រការ២៧.-**

ការធ្វើអាជីវកម្មបូម ដឹកជញ្ជូន និងការបោះចោលសំណល់ភក់ពីអាងស៊ិបទិក ត្រូវមានការអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌបន្ទាប់ពីបានទទួលយោបល់បច្ចេកទេសពីមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា២៨.-**

ក្រសួងបរិស្ថានត្រូវផ្ដល់ការណែនាំអំពីបច្ចេកទេសគ្រប់គ្រងដោយឡែក សម្រាប់ប្រភេទសំណល់គ្រោះថ្នាក់ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

បញ្ជីសំណល់គ្រោះថ្នាក់ដែលបង្កើតតាមលំនៅឋាន ស្ថាប័នឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍មានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា២៩.-**

សំណល់រឹងឧស្សាហកម្មនិងសំណល់គ្រោះថ្នាក់ដែលបង្កើតចេញពីសកម្មភាពផលិតកម្មនៃរោងចក្រ អាជីវកម្មរ៉ែ និងពីប្រភពដទៃទៀតក្រៅពីទីតាំង ឬប្រភពដែលមានចែងក្នុងមាត្រា២៨នៃអនុក្រឹត្យនេះ ត្រូវគ្រប់គ្រងដោយក្រសួងបរិស្ថាន ដែលកំណត់ដោយបទបញ្ញត្តិដោយឡែក។

## ជំពូកទី៥
## សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវលើការងារគ្រប់គ្រងសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងមានសុវត្ថិភាពបរិស្ថាន។

**មាត្រា៣១.-**

ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រដ្ឋបាលរាជធានី ក្រុង ស្រុកអាចៈ

ក. រៀបចំ និងប្រតិបត្តិការដោយរដ្ឋបាលរបស់ខ្លួនផ្ទាល់នូវមុខងារមួយផ្នែក ឬទាំងស្រុងនៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ខ. ធ្វើកិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ដែលមានព្រំប្រទល់រដ្ឋបាលជាប់គ្នាក្នុងការផ្តល់សេវារួមជាមួយគ្នា។

គ. ផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូន ឬ/និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនទៅឱ្យផ្នែកឯកជន ជាអ្នកទទួលបន្ទុកអនុវត្ត។

ឃ. ផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ឬផ្តល់សិទ្ធិទៅឱ្យសហគមន៍អនុវត្តនូវមុខងារណាមួយ ឬមួយចំនួននៃមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន។

**មាត្រា៣២.-**

ការផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនត្រូវមានរយៈពេលមិនលើសពី១០ឆ្នាំក្នុងកិច្ចសន្យាមួយលើក និងត្រូវអនុវត្តទៅតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មជាធរមាន។

**មាត្រា៣៣.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយផ្អែកលើកម្រៃសេវាអតិបរមា ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់កម្រៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនសម្រាប់អនុវត្តនៅក្នុងមូលដ្ឋានរបស់ខ្លួន ដោយគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធានាប្រសិទ្ធភាព និងគុណភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- កំណត់កម្រៃសេវាផ្អែកតាមប្រភេទអាជីវកម្ម ទីតាំង កម្រិតប្រាក់ចំណូល បរិមាណសំរាម សំណល់រឹងទីប្រជុំជន ដែលត្រូវបញ្ចេញ និង
- ត្រូវមានការពិនិត្យ និងអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា៣៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវកំណត់អំពីវិធានការ និងនីតិវិធីសមស្រប មានតម្លាភាព និងមានប្រសិទ្ធភាពសម្រាប់ការប្រមូល ការគ្រប់គ្រង និងការទូទាត់កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ស្ថាប័ន និងអ្នកពាក់ព័ន្ធ។

ចំណូលដែលប្រមូលបានពីសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជាចំណូលផ្ទាល់របស់

រដ្ឋបាលរាជធានី ក្រុង ស្រុកសាមី។

រដ្ឋបាលរាជធានី ក្រុង ស្រុកអាចប្រើប្រាស់ថវិកាបរបស់ខ្លួន ឬថវិកាពីប្រភពផ្សេងទៀត សម្រាប់គាំទ្របន្ថែមលើការចំណាយសម្រាប់ការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៣៥.-**

ក្នុងករណីមានសំណើពីសហគមន៍ អង្គការ ឬប្រជាពលរដ្ឋសុំការអនុញ្ញាតប្រមូលយកសំរាម សំណល់រឹងទីប្រជុំជនមកប្រើប្រាស់ក្នុងប្រយោជន៍ណាមួយ រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយមានការពិគ្រោះយោបល់ជាមួយមន្ទីរបរិស្ថានរាជធានី ខេត្តអាច ៖

ក. ពិនិត្យផ្តល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនសម្រាប់យកទៅធ្វើការកែច្នៃធ្វើជីកំប៉ុស្តិ៍ ផលិតឧស្ម័ន ប្រសិនបើសកម្មភាពប្រមូលយកសំរាមសំណល់រឹងនោះ មិនធ្វើឱ្យប៉ះពាល់ដល់ផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផលប៉ះពាល់ជាអវិជ្ជមានដល់ការរស់នៅនៃមជ្ឈដ្ឋានជុំវិញ និងបរិស្ថាន។

ខ. ផ្តល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់កម្ទេចកម្ទីថ្ម និងដីចេញពីសកម្មភាពការដ្ឋានផ្លូវថ្នល់ សំណង់អគារ ឬលំនៅឋាន ដែលមិនមានលាយឡំសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផ្ទុកឬលាយឡំជាមួយសំណល់គ្រោះថ្នាក់ ដើម្បីយកទៅចាក់បំពេញរណ្តៅដីកម្មសិទ្ធិសហគមន៍ អង្គការ ឬជឹងកជន។

## ជំពូកទី៦
## វិធានការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវធ្វើការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនឱ្យស្របតាមទីតាំងស្ថានភាពភូមិសាស្ត្រជាក់ស្តែងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ចំពោះរដ្ឋបាលក្រុង ស្រុក ការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាមសំណល់រឹងទីប្រជុំជន ត្រូវមានការឯកភាពពីរដ្ឋបាលខេត្ត។

រាល់គម្រោងស្នើសុំបង្កើតទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនត្រូវស្នើសុំការពិនិត្យ សម្រេចពីក្រសួងបរិស្ថានលើបច្ចេកទេសរៀបចំទីលាន វិធានការការពារបរិស្ថានក្នុងពេលដំណើរការ និងពេលបិទបញ្ចប់ការប្រើប្រាស់ទីលាន និងរយៈពេលនៃការប្រើប្រាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣៧.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ត្រូវដំណើរការទីលានរបស់ខ្លួនតាមលក្ខខណ្ឌបច្ចេកទេស និងវិធានការការពារបរិស្ថាន តាមការកំណត់របស់ក្រសួងបរិស្ថាន។

ក្នុងករណីកើតមានហេតុការណ៍បំពុលបរិស្ថានបង្កដោយដំណើរការនៃទីលាន ម្ចាស់ ឬអ្នកគ្រប់

គ្រងទីលានត្រូវចាត់វិធានទប់ស្កាត់ជាបន្ទាន់ និងត្រូវផ្តល់ព័ត៌មានជាបន្ទាន់ទៅរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ និងមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា៣៨.-**

ក្រសួងបរិស្ថាន និងរដ្ឋបាលរាជធានី ខេត្តត្រូវចុះធ្វើការតាមដានត្រួតពិនិត្យជាប្រចាំលើការអនុវត្ត របស់ម្ចាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន នូវវិធានការទប់ស្កាត់និងកាត់បន្ថយផលប៉ះពាល់ បរិស្ថានពីដំណើរការគ្រប់គ្រងទីលាន។

## ជំពូកទី៧
## ទោសបញ្ញត្តិ

**មាត្រា៣៩.-**

ការមិនអនុវត្តតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌក្នុងការញែក និងការវេចខ្ចប់ ដោយឡែកនូវសំរាម សំណល់រឹងទីប្រជុំជនដែលអាចប្រើប្រាស់ឡើងវិញឬកែច្នៃបាន ដូចមានចែងក្នុង មាត្រា១៥នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ១០.០០០ (មួយម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១០០.០០០ (មួយសែន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ២០០.០០០ (ពីរសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ លើកមុន។

**មាត្រា៤០.-**

បុគ្គលដែលនាំយកកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជន ទៅដាក់នៅតាមដងផ្លូវ ឬទី សាធារណៈខុសពេលម៉ោងអនុញ្ញាតឱ្យធ្វើការបញ្ចេញ ដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៧នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំង សិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ លើកមុន។

**មាត្រា៤១.-**

បុគ្គលដែលបានប្រើប្រាស់សេវាគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន ហើយមិនព្រមបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន ឬសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលរៀបចំ ឬកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៨ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃតម្លៃសេវាសំរាម សំណល់រឹងដែលត្រូវបង់ក្នុងមួយខែ។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤២.-**

បុគ្គលដែលបោះចោលសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌហាមឃាត់ការបោះចោលសំរាម សំណល់រឹងទីប្រជុំជន ដូចមានចែងក្នុងមាត្រា២០ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូល សំអាតយកទៅដាក់ធុងសំរាមសាធារណៈ
- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមផ្ទះ ភោជនីយដ្ឋាន ទីកំសាន្ត និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៣.-**

បុគ្គលដែលដុតសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានីឬខណ្ឌ ក្រុង ស្រុកហាមឃាត់ ដូចមានចែងក្នុងមាត្រា២០នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូលសំអាត
- ចំនួន ១០០.០០០ (មួយសែន) រៀល ចំពោះម្ចាស់លំនៅឋាន អ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលសំអាត

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ ភោជនីយដ្ឋាន ទីកំសាន្ត អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៤.-**

បុគ្គលដែលគេចវេសមិនទទួលខុសត្រូវលើសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតនៅក្នុងពិធីនានារបស់ខ្លួនដែលប្រារព្ធនៅលើដងផ្លូវ ឬនៅលើទីសាធារណៈ ដូចមានចែងក្នុងមាត្រា២១នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់បន្ថែមទៅលើតម្លៃសេវាសំអាត ប្រមូលនិងដឹកជញ្ជូនដូចខាងក្រោម៖

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះពិធីមង្គលការ សម្ពោធហាង និងបុណ្យ លើកលែងពិធីបុណ្យសព
- ចំនួន ៦០០.០០០ (ប្រាំមួយសែន) រៀល ចំពោះពិធីប្រជុំ មិទ្ទិញ
- ចំនួន ២.០០០.០០០ (ពីរលាន) រៀល ចំពោះការប្រគុំតន្ត្រីសាធារណៈ

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៥.-**

បុគ្គលម្ចាស់ ឬអ្នកគ្រប់គ្រងទីផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម មណ្ឌលកំសាន្ត ដែលមិនបានរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណសម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន ដូចមានចែងក្នុងវាក្យខណ្ឌ២ មាត្រា២២នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួន៤០០.០០០(បួនសែន) រៀល។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៦.-**

បុគ្គលម្ចាស់ការដ្ឋានសំណង់អគារដែលធ្វើការទុកដាក់សំរាម សំណល់រឹងទីប្រជុំជនពីការងារសំណង់ ឬសម្ភារៈសំណង់មិនបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬការទុកដាក់បង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព ឬបរិស្ថាន ដូចមានចែងក្នុងមាត្រា២៣នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះការដ្ឋានសំណង់លំនៅឋាន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន

- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល ចំពោះការដ្ឋានសំណង់អគារធំៗ បុរីលំនៅឋាន និង ត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៧.-**

បុគ្គលដែលធ្វើអាជីវកម្មបូមសំណល់កក់ពីប្រព័ន្ធលូ ឬពីអាងស៊ិបទិក ដោយមិនមានលិខិតអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬដឹកយកទៅបញ្ចេញចោលខុសទីកន្លែងដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ដូចមានចែងក្នុងមាត្រា២៧នៃអនុក្រឹត្យនេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះអាជីវកម្មជាលក្ខណៈគ្រួសារ
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះអាជីវកម្មជាលក្ខណៈក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៨.-**

បុគ្គលដែលធ្វើការទុកដាក់ វេចខ្ចប់ ឬប្រមូលនិងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន លាយឡំជាមួយសំណល់រឹងឧស្សាហកម្ម សំណល់វេជ្ជសាស្ត្រ ឬសំណល់គ្រោះថ្នាក់ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ៥០០.០០០ (ប្រាំសែន) រៀល សម្រាប់អាជីវកម្ម សិប្បកម្ម មន្ទីរពេទ្យ សម្ភព
- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល សម្រាប់ក្រុមហ៊ុនសេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៩.-**

បុគ្គលដែលមិនបានបង់ប្រាក់ពិន័យអន្តរការណ៍នេះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃដែលបានទទួលបង្កាន់ដៃបង់ប្រាក់ពិន័យ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាពីរដង បើលើសពី៦០(ហុកសិប)ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាបីដង។ បើផុតរយៈពេល៩០(កៅសិប)ថ្ងៃ រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំសំណុំឯកសារប្តឹងទៅសាលាដំបូងរាជធានី ខេត្ត។

**មាត្រា៥០.-**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចផាកពិន័យអន្តរការណ៍របស់មន្ត្រីមានសមត្ថកិច្ចរបស់រាជធានី ក្រុង ស្រុក ខណ្ឌ មានសិទ្ធិប្តឹងតវ៉ាទៅអភិបាលរាជធានី ក្រុង ស្រុក ខណ្ឌសាមី។

អភិបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ យ៉ាងយូរគិតពីថ្ងៃទទួលពាក្យបណ្តឹង។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រាជធានី ក្រុង ស្រុក ខណ្ឌមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន។

**មាត្រា៥១.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវក្នុងការរៀបចំយន្តការសម្រាប់អនុវត្តវិធានការពិន័យអន្តរការណ៍ឱ្យមានប្រសិទ្ធភាព។

នីតិវិធីនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ចំណូលពីការពិន័យអន្តរការណ៍នេះនឹងត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ។

## ជំពូកទី៨
## អន្តរបញ្ញត្តិ

**មាត្រា៥២.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវពិនិត្យការអនុវត្តកិច្ចសន្យាកន្លងមក និងធ្វើការពិភាក្សាពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវា ព្រមទាំងអ្នកពាក់ព័ន្ធនានាដើម្បីពិនិត្យ និងកែសម្រួលនូវកិច្ចសន្យាផ្តល់សេវាសំរាម សំណល់រឹងដែលកំពុងអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងរយៈពេល១២(ដប់ពីរ)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា ៥៣.-**

ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបង្កើតក្រុមការងារអន្តរក្រសួងមួយ ដើម្បីពិភាក្សា និងសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ទេរការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងប្រតិភូកម្មការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ។

## ជំពូកទី៩
## អវសានបញ្ញត្តិ

**មាត្រា៥៤.-**

បទបញ្ញតិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្តេចក្រឡាហោម ស ខេង**

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សាយ សំអាល់**

**<u>កន្លែងទទួល</u>** ÷

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥៥*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ឧបសម្ព័ន្ធទី១
# សន្ទានុក្រម

១- **សំរាម** សំដៅដល់របស់របរប្រើប្រាស់ សម្ភារ ផលិតផលដែលបានបន្សល់ ឬបង្កើតពីសកម្មភាព និងជីវភាពផ្ទាល់របស់មនុស្សប្រចាំថ្ងៃ ដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

២- **សំណល់រឹងទីប្រជុំជន** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាពអាជីវកម្ម ឬសេវាកម្មដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

៣- **សំណល់រឹងឧស្សាហកម្ម** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាពផលិតកម្មនៃរោងចក្រ ឬសហគ្រាសដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

៤- **សំណល់គ្រោះថ្នាក់** សំដៅដល់វត្ថុធាតុរឹង រាវ ឧស្ម័ន សារធាតុវិទ្យុសកម្ម សារធាតុផ្ទុះ សារធាតុឆេះ សារធាតុចំលងជំងឺ ឬធ្វើឱ្យលោក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម បង្កការពុល បង្កឱ្យមានជំងឺមហារីក ឬសារធាតុគីមីពុលដទៃទៀត ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។ ប្រភពសំណល់គ្រោះថ្នាក់អាចមានប្រភពមកពីលំនៅដ្ឋាន ទីផ្សារ ផ្សារទំនើប ទីកន្លែងកំសាន្ត អគារសាធារណៈ គ្រឹះស្ថានសិក្សា សកម្មភាពអាជីវកម្ម សេវាកម្ម សិប្បកម្ម រោងចក្រ សកម្មភាពកសិកម្ម និងអាជីវកម្មរ៉ែ។

៥- **ការទាញយកធនធាន** សំដៅដល់សកម្មភាពជម្រើស ឬប្រើប្រាស់សំរាម សំណល់រឹងធ្វើជាជីកំប៉ុស្ត៍ កែច្នៃ ទាញយកថាមពល ឬសារប្រយោជន៍នានា។

៦- **ការកែច្នៃ** សំដៅដល់សកម្មភាព ឬដំណើរការបំបែក ឬបំលែងសំរាម សំណល់រឹងទៅជាវត្ថុធាតុដើមសម្រាប់បម្រើការផលិតឡើងវិញ។

៧- **ការប្រើប្រាស់ឡើងវិញ** សំដៅដល់ការជម្រើសសំរាម សំណល់រឹងដែលអាចប្រើប្រាស់សារជាថ្មីឡើងវិញដោយគ្រាន់តែឆ្លងកាត់ការលាងសម្អាត ឬការជួសជុលដោយនៅរក្សាទ្រង់ទ្រាយដើម។

៨- **ការញែក** សំដៅដល់ការបែងចែកទៅតាមប្រភេទនៃសំរាម សំណល់រឹងនៅនឹងប្រភពបង្កើតសម្រាប់គោលបំណងការទាញយកធនធាន ឬដើម្បីសុវត្ថិភាពក្នុងការយកទៅចាក់នៅទីលាន។

៩- **ទីលាន** សំដៅដល់ទីកន្លែងដែលអាជ្ញាធរបានកំណត់ ឬរៀបចំតាមវិធានសុវត្ថិភាពបរិស្ថានសម្រាប់ការចាក់សំរាម សំណល់រឹងទីប្រជុំជន។

១០-**ការធ្វើប្រព្រឹត្តកម្ម** សំដៅដល់សកម្មភាព ឬវិធានការនៅក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលរួមមាន៖

ក). ការបន្ថយទំហំ ឬបរិមាណសំរាម សំណល់រឹងមុនការយកទៅចាក់នៅទីលាន ដូចជា ការដោះបំបែក ការកិនកម្ទេច ការរំលាយ ឬការដុតនៅក្នុងឡ។

ខ). ការដកយក ឬកម្ទេចចោលជាតិពុល សារធាតុគ្រោះថ្នាក់ ឬភ្នាក់ងារចម្លងជម្ងឺ ដែលមាននៅក្នុងសំរាម សំណល់រឹងមុនការយកទៅចាក់នៅទីលាន។

**១១- ទីប្រជុំជន** សំដៅដល់ទីរួមក្រុង ទីរួមស្រុក ទីប្រជុំជនផ្សារ និងលំនៅដ្ឋាន រួមទាំងរមណីយដ្ឋាន មណ្ឌលកំសាន្ត តំបន់ទេសចរណ៍។

**១២- ទីតាំង** សំដៅដល់កន្លែងផលិតកម្ម អាជីវកម្ម សេវាកម្ម អគាររដ្ឋបាលសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម។

**១៣- អាងស៊ុបទិក** សំដៅដល់អាងស្តុកសំណល់បង្គន់អនាម័យបឋម។

**១៤- ពិន័យអន្តរការណ៍** សំដៅដល់ការតម្រូវជនប្រព្រឹត្តល្មើលទៅនឹងប្បញ្ញត្តិ ដែលមានចែងក្នុងអនុក្រឹត្យនេះ បង់ប្រាក់ពិន័យតាមកម្រិតទណ្ឌកម្មដែលបានប្រព្រឹត្តល្មើស។

**១៥- សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន** សំដៅដល់សេវាប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

## ឧបសម្ព័ន្ធទី២

## សំណល់គ្រោះថ្នាក់ ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអាគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍

សំណល់គ្រោះថ្នាក់ដែលបង្កើតឡើងនៅតាមលំនៅឋាន ស្ថាប័ន ឬអាគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍រួមមាន៖

១- សំណល់អាគុយ និងថ្មពិល ឬថ្មសាកគ្រប់ប្រភេទ។

២- សំណល់គ្រឿងបរិក្ខារអគ្គិសនី និងអេឡិចត្រូនិក។

៣- សំណល់សំបកដប ឬកំប៉ុងដែលមានប្រឡាក់សារធាតុគីមី ឬថ្នាំពុលកសិកម្ម។

៤- សំណល់សំបកកង់យានយន្តគ្រប់ប្រភេទ។

៥- សំណល់ប្រេងម៉ាស៊ីន។

៦- សំណល់ថ្នាំលាបថ្នាំជ្រលក់ពណ៌ និងសម្ភារវេចខ្ចប់។

៧- សំណល់ទឹកខ្មៅបោះពុម្ព។

៨- សំណល់ដែលជាសមាសធាតុអាបេស្តូស។

ក្រសួងមហាផ្ទៃ

# ផែនការណែនាំស្តីពី

# ការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ ឃុំ មានសុវត្ថិភាព"

**លក្ខណៈសម្បត្តិភូមិ ឃុំ មានសុវត្ថិភាពរួមមាន៖**

១. គ្មានសកម្មភាព លួច ឆក់ ប្លន់ គ្រប់ប្រភេទ

២. គ្មានការផលិត ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់

៣. គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ

៤. គ្មានក្មេងទំនើង

៥. គ្មានការលេងល្បែងស៊ីសងគ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ

**រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ៖ ០២០ ផ.ក

# ផែនការណែនាំ
## ស្តីពី
## ការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ, ឃុំមានសុវត្ថិភាព"

សន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះដល់ដំណើរការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងទៀតមានការរីកចំរើនស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា ។ ទោះបីយើងមានសន្តិភាព ស្ថេរភាពយ៉ាងរឹងមាំ ប៉ុន្តែសន្តិសុខសណ្តាប់ធ្នាប់សាធារណៈជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ជាប្រចាំ ដើម្បីធានាឲ្យប្រជាពលរដ្ឋគ្រប់រូប និងសង្គមទាំងមូលមានសុវត្ថិភាពយ៉ាងល្អប្រសើរ ។

នាឱកាសមិទ្ទីញរំលឹកខួបអនុស្សាវរីយ៍លើកទី៦៥ ថ្ងៃបង្កើតកងកម្លាំងនគរបាលជាតិកម្ពុជា នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ជាច្រើន ដែលក្នុងនោះបានកំណត់យកគោលការណ៍កសាងភូមិ, **ឃុំមានសុវត្ថិភាព** ដើម្បីលើកកំពស់ និងជំរុញចលនាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៅគ្រប់ពេល និងគ្រប់ច្រកល្ហក ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ផ្អែកតាមអនុសាសន៍ដ៏ថ្លៃថ្លានេះ ក្រសួងមហាផ្ទៃបានកំណត់យកភូមិ, **ឃុំមានសុវត្ថិភាព** ធ្វើជាគោលនយោបាយអាទិភាពមួយសំរាប់កម្លាំងអនុវត្តច្បាប់ អាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់ សមាសភាពផ្សេងៗទាំងក្នុងជួររដ្ឋាភិបាល គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋទាំងមូល រួមគ្នាពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈឲ្យបានគង់មង់ល្អនៅគ្រប់ភូមិ, ឃុំទូទាំងប្រទេស ។

ដើម្បីអនុវត្តឲ្យបានជោគជ័យគោលនយោបាយខាងលើ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំចាត់តាំងអនុវត្ត ដែលមានខ្លឹមសារសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

### I-<u>គោលបំណង និងសំណូមពរ ៖</u>

១-បន្តកសាង និងពង្រឹងសេចក្តីសុខសុវត្ថិភាព ជូនប្រជាពលរដ្ឋនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាតាមរយៈការតស៊ូលុបបំបាត់បទល្មើសគ្រប់ប្រភេទក្នុងមូលដ្ឋាន ភូមិ, ឃុំ, សង្កាត់ ទូទាំង

ព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច នៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿនកាត់បន្ថយភាពក្រីក្រឲ្យកាន់តែបានល្អប្រសើរថែមទៀត ។

២-បំផុសឱ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ច ពីគ្រប់សមាសភាពផ្សេងៗទាំងក្នុងជួររដ្ឋាភិបាល គណៈបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់រូប ដើម្បីកសាងបានជាកម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ក្នុងការអនុវត្ត **គោលនយោបាយភូមិ, ឃុំមានសុវត្ថិភាព** ។

**II-<u>លក្ខណៈសម្បត្តិ ភូមិ, ឃុំមានសុវត្ថិភាព</u>**

***ភូមិ, ឃុំមានសុវត្ថិភាព គឺភូមិ, ឃុំដែលមានលក្ខណៈសម្បត្តិ ៥យ៉ាង ដូចខាងក្រោម៖***

១-គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ

២-គ្មានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់

៣-គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ

៤-គ្មានក្មេងទំនើង

៥-គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ ។

**III-<u>វិធានការ និងផែនការសកម្មភាព</u>**

**ក-<u>វិធានការ៖</u>**

១-ចាត់វិធានការលុបបំបាត់ឲ្យបានបទល្មើសលួច ឆក់ ប្លន់គ្រប់ប្រភេទ ដែលតែងតែកើតមានឡើងនៅតាមភូមិ ឃុំ សង្កាត់ តាមវិធានការជំនាញ វិធានការច្បាប់ វិធានការរដ្ឋបាល និងវិធានការមហាជន ។

២-ចាត់វិធានការកាត់ផ្តាច់ និងលុបបំបាត់ឲ្យបានការផលិត ការចែកចាយ ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅតាមភូមិ, ឃុំ, សង្កាត់ ដោយអនុវត្តតាមផែនការណែនាំលេខ ០៥២ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីការអនុវត្តប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន និងជាពិសេសតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-ចាត់វិធានការលុបបំបាត់រាល់អំពើអនាចារ្យ ការជួញដូរស្ត្រី និងកុមារ អំពើហិង្សាក្នុងគ្រួសារ ដើម្បីការពារសន្តិសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងកុមារ ឲ្យរួចផុតពីការជួញដូរ អំពើរត់ពន្ធ ការធ្វើអាជីវកម្មលើកម្លាំងពលកម្ម ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សា (<u>ឯកសារយោង ផែនការសកម្មភាពលេខ ០២៣ ផ.ក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៥ របស់ក្រសួងមហាផ្ទៃ ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរ ការរត់ពន្ធមនុស្ស ការធ្វើអាជីវកម្មលើមនុស្ស និង</u>

ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ) ដោយអនុវត្តតាមច្បាប់ដែលមានជាធរមានឲ្យបានម៉ឺងម៉ាត់ ។

៤-ចាត់វិធានការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើងឲ្យបានទាន់ពេល និងមានប្រសិទ្ធភាព ដើម្បីធានារក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព ភូមិ ឃុំ សង្កាត់ល្អប្រសើរ (ឯកសារយោង សារាចរលេខ ០៤ស.រ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល សេចក្តីណែនាំលេខ ០២១ស.ណ.ន ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ និងផែនការសកម្មភាពលេខ ០៥០ផ.ក ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០៩ របស់អគ្គស្នងការដ្ឋាននគរបាលជាតិស្តីពីការចាត់តាំងអនុវត្តវិធានការបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើង) ។

៥-ចាត់វិធានការលុបបំបាត់ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធ និងលាក់អាវុធខុសច្បាប់ ព្រមទាំងបទល្មើសផ្សេងៗទៀតក្នុងភូមិ ឃុំ សង្កាត់ ដោយអនុវត្តទៅតាមច្បាប់ពាក់ព័ន្ធនានាជាធរមាន ។

**ខ-ផែនការសកម្មភាព៖**

១-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ត្រូវអនុវត្តអោយបាននូវរបបប្រជុំជាប្រចាំ ដើម្បីត្រួតពិនិត្យសភាពការណ៍ ដាក់ចេញផែនការ និងវិធានការដាក់ស្តែងក្នុងការអនុវត្តគោលនយោបាយ**ភូមិ, ឃុំមានសុវត្ថិភាព** ក្នុងវង្វង់សមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន (ឯកសារយោង សេចក្តីណែនាំ លេខ០០៩ ស.ណ.រ ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ) ។

គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ត្រូវមានសេនាធិការរបស់ខ្លួន ដែលមានសមាសភាពមកពីមន្ទីរអង្គភាពពាក់ព័ន្ធនានា ជាពិសេសនគរបាលជាតិ កងរាជអាវុធហត្ថ នាយក ឬនាយករងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ។

២-នគរបាលប៉ុស្តិ៍រដ្ឋបាល មានតួនាទីយ៉ាងសំខាន់ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ក្នុងការកសាង និងពង្រឹងកងកម្លាំងនេះ ដើម្បីក្លាយទៅជាកំលាំងស្នូលពិតប្រាកដ នៃចលនាការពារ "**ភូមិ, ឃុំ មានសុវត្ថិភាព**" និងក្លាយជាសេវាសាធារណៈដែលនៅជាប់ជាមួយប្រជាពលរដ្ឋដោយ ៖

-ត្រូវរៀបចំឲ្យមានក្របខ័ណ្ឌគ្រប់ចំនួនតាមការកំណត់ស្របតាមលក្ខណៈភូមិសាស្ត្រ និងប្រជាសាស្ត្រ

-ត្រូវធ្វើការបណ្តុះបណ្តាលបំពាក់បំប៉នអំពីតួនាទីភារកិច្ច របៀបរបបធ្វើការ និងសិទ្ធិអំណាច ព្រមទាំងសមត្ថភាពជំនាញរបស់នគរបាលប៉ុស្តិ៍រដ្ឋបាល (ឯកសារយោង មេរៀនដកស្រង់ពីក្រុមការងារ ការអនុវត្តសាកល្បងការពង្រឹងប៉ុស្តិ៍នគរបាលរដ្ឋបាលដើម្បីសហគមន៍)

-ត្រូវរៀបចំឲ្យមានទីកន្លែងធ្វើការ មធ្យោបាយ ឧបករណ៍សំភារៈសំរាប់បំរើការងារ និងរៀបចំឲ្យមានប្រអប់សំបុត្រ និង

-ត្រូវមានកម្លាំងប្តូរវេនប្រចាំការជាអចិន្ត្រៃយ៍នៅស្នាក់ការនគរបាលប៉ុស្តិ៍រដ្ឋបាលដើម្បីទំនាក់ទំនងជួប និងទទួលព័ត៌មានពីគ្រប់ប្រភព ។ ក្នុងករណីមានសភាពការណ៍បទល្មើស ឬឧប្បត្តិហេតុផ្សេងៗកើតឡើង ចាំបាច់ត្រូវកោះហៅប្រមូលផ្តុំកម្លាំងដើម្បីប្រតិបត្តិការណ៍ដោះស្រាយ ។

-ត្រូវមានកិច្ចសហការទំនាក់ទំនងជាមួយកងកម្លាំងមានសមត្ថកិច្ចនានា ដែលបោះទីតាំងនៅក្នុងឃុំ សង្កាត់របស់ខ្លួន ដើម្បីបង្កើតឲ្យមានយន្តការសហការផ្តល់ព័ត៌មាន និងកិច្ចសហការគាំទ្រគ្នាទៅវិញទៅមកក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានាក្នុងឃុំ សង្កាត់ ភូមិ និង

-ត្រូវមានទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ភូមិ ដោយមិនត្រូវប្រកាន់និន្នាការនយោបាយ ជំនឿសាសនា ភេទ ឬស្ថានភាពសង្គមនៃប្រជាពលរដ្ឋម្នាក់ៗ ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់ៗរូបស្រឡាញ់ជឿទុកចិត្ត ជួយឧបត្ថម្ភគាំទ្រ សហការ ចូលរួមឲ្យបានទូលំទូលាយប្រកបដោយទឹកចិត្តស្មោះសរជាមួយនគរបាល និងកងកម្លាំងមានសមត្ថកិច្ចនានាក្នុងចលនាភូមិ, **ឃុំមានសុវត្ថិភាព** ។

**៣-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ត្រូវ៖**

-ដឹកនាំអង្គភាពនគរបាលតាមថ្នាក់របស់ខ្លួន និងតាមតួនាទីនៃនគរបាលថ្នាក់នីមួយៗ ដើម្បីដឹកនាំ ត្រួតពិនិត្យ វាយតម្លៃប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ, សង្កាត់ជាប្រចាំ ។ ជាមួយនេះ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ត្រូវបញ្ជាអោយអង្គភាពនគរបាលជាតិ និងកងរាជអាវុធហត្ថគ្រប់ថ្នាក់ ដើម្បីត្រៀមកម្លាំងអន្តរាគមន៍ជួយដល់នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ, សង្កាត់ នៅពេលមានបទល្មើសកើតឡើង ឬនៅពេលមានសំណូមពរចាំបាច់ ។

-មានកម្មវិធីការងារឲ្យបានច្បាស់លាស់ និងទៀងទាត់ចុះតាមមូលដ្ឋាន ដោយត្រូវយកភូមិធ្វើជាគោលដៅ ដើម្បីបំផុសចលនាប្រជាពលរដ្ឋចូលរួមការពារសន្តិសុខ សណ្តាប់ធ្នាប់នៅមូលដ្ឋាន ក្នុងន័យទាក់ទាញឲ្យបានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីបង្កើតបានជាកម្លាំងចលករមួយក្នុងការប្រយុទ្ធប្រឆាំងបទល្មើស រក្សា**សុវត្ថិភាពភូមិ, ឃុំ** ។

៤-ក្រោមការសំរបសំរួលរបស់រដ្ឋបាលឃុំ, សង្កាត់ ដោយមានការចូលរួមពីប្រជាពលរដ្ឋនៅនឹងកន្លែង និងអ្នកពាក់ព័ន្ធផ្សេងទៀត នៅតាមភូមិនិមួយៗ ឬកម្រងភូមិត្រូវរៀបចំឲ្យមានវេទិកាសាធារណៈ **ស្តីពីសុវត្ថិភាពភូមិ, ឃុំ** ។ វេទិការនេះធ្វើឡើងយ៉ាងតិច ១ដង ក្នុង ១ត្រីមាស (ឯកសារយោងផែនការណែនាំបន្ថែមអំពីការចាត់តាំងចលនាការពារសន្តិសុខមាតុភូមិ "**ចលនាប្រជាការពារ**" លេខ ០៣៨៨ក ចុះថ្ងៃទី០៣ ខែវិច្ឆកា ឆ្នាំ២០០៥ របស់ក្រសួងមហាផ្ទៃ) ។ ក្នុងវេទិការនេះត្រូវធ្វើការដោះស្រាយសំណើ សំណូមពរនានារបស់ប្រជាពលរដ្ឋដែលលើកឡើង ។ ក្នុងករណីដោះស្រាយ

មិនបាន ត្រូវរាយការណ៍ជូនគណៈបញ្ជាការឯកភាពរដ្ឋបាលថ្នាក់លើដោះស្រាយ និងត្រូវផ្តល់ព័ត៌មានត្រឡប់ឲ្យបានសមស្របជូនប្រជាពលរដ្ឋវិញ ។

៥-ក្រសួងមហាផ្ទៃសូមអំពាវនាវៈ

-ដល់គ្រប់ក្រសួង ស្ថាប័នរដ្ឋគ្រប់ថ្នាក់ ដោយផ្អែកទៅតាមតួនាទី ភារកិច្ចរបស់ខ្លួន ចេញនូវការណែនាំដល់មន្ត្រី អង្គភាព ក្រោមឱវាទរបស់ខ្លួន ដើម្បីសហការ លើកទឹកចិត្ត ឧបត្ថម្ភ គាំទ្រ ចូលរួមជាមួយក្រសួងមហាផ្ទៃ គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ និងសមត្ថកិច្ចអនុវត្តច្បាប់ក្នុងការអនុវត្តគោលនយោបាយ **ភូមិ, ឃុំមានសុវត្ថិភាព** ។

-ដល់គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន ... ផ្អែកតាមតួនាទី ភារកិច្ច និងលទ្ធភាពរបស់ខ្លួន ដើម្បីចូលរួមឧបត្ថម្ភ គាំទ្រ លើកទឹកចិត្តតាមគ្រប់រូបភាព ចូលរួមក្នុងការអនុវត្តគោលនយោបាយ **ភូមិ, ឃុំមានសុវត្ថិភាព** ។

៦-ត្រូវចាត់តាំងឲ្យមានចលនាប្រឡងប្រណាំង បង្កើតស្នាដៃអបអរសាទរសំរាប់ខួបអនុស្សាវរីយ៍ថ្ងៃបង្កើតកងកម្លាំងនគរបាលជាតិកម្ពុជាប្រចាំឆ្នាំនិមួយៗ សំដៅស្វែងរកអង្គភាព និងបុគ្គលដែលខិតខំព្យាយាមពុះពារបំពេញភារកិច្ច ហើយបង្កើតបានជាស្នាដៃធំធេងធ្វើជាគំរូក្នុងការអនុវត្តគោលនយោបាយ "**ភូមិ ឃុំ មានសុវត្ថិភាព**" (<u>ឯកសារយោង សារាចរណែនាំលេខ ០០១ ស.រ ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការបំផុសចលនាប្រឡងប្រណាំងការពារសន្តិសុខសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម បង្កើតស្នាដៃអបអរសាទរមិទ្ធិញខួបអនុស្សាវរីយ៍ថ្ងៃកំណើតនគរបាលជាតិកម្ពុជា១៦ ឧសភា ១៩៤៥</u>) ។

**IV-<u>ការចាត់តាំងអនុវត្តៈ</u>**

១-ក្រសួងមហាផ្ទៃរៀបចំលេខាធិការដ្ឋាន និងក្រុមការងារថ្នាក់ជាតិ ដើម្បី សហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ ដឹកនាំ និងចាត់តាំងអនុវត្តគោលនយោបាយ**ភូមិ, ឃុំ មានសុវត្ថិភាព**នេះ ។ (ភ្ជាប់ជាមួយឧបសម្ព័ន្ធ) ។

២-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ក្រៅពីសេនាធិការរបស់ខ្លួន ត្រូវរៀបចំអោយមានក្រុមការងារចុះតាមមូលដ្ឋានឃុំ សង្កាត់ ដោយយក**ភូមិ**ជាគោលដៅ ដើម្បីសហការអនុវត្តគោលនយោបាយ**ភូមិ, ឃុំ មានសុវត្ថិភាព** ។

៣-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ត្រូវចាត់តាំងបូកសរុបលទ្ធផលអនុវត្តគោលនយោបាយ "**ភូមិ, ឃុំ មានសុវត្ថិភាព**" ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្ញើរមកលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ តាមតារាងទិន្នន័យដែលភ្ជាប់ជាឧបសម្ព័ន្ធនៃផែនការណែនាំនេះ ដើម្បីមានមូលដ្ឋានវាយតម្លៃលទ្ធផល និងស្នាដៃតាមឃុំ សង្កាត់ និមួយៗ ។

*៤-គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ត្រូវចាត់តាំងប្រជុំបូកសរុប ដកពិសោធន៍ និងលើកទិសដៅបន្តក្នុងរយៈពេល ០១ត្រីមាសម្តង ។ សមាសភាពចូលរួមក្នុងអង្គប្រជុំនេះ គឺអ្នកពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលរបស់ខ្លួន និងអាស្រ័យដោយប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលសំរេច ។*

*៥-ដើម្បីទទួលបានបទពិសោធន៍ឈានទៅកែលំអរផែនការចាត់តាំងអនុវត្តគោលនយោបាយភូមិ, ឃុំមានសុវត្ថិភាពនេះ ឲ្យកាន់តែល្អប្រសើរថែមទៀត គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់អាចជ្រើសរើសមូលដ្ឋានមួយ ឬពីរ ដើម្បីអនុវត្តសាកល្បង បន្ទាប់មកទើបធ្វើការផ្សព្វផ្សាយ និងចាត់តាំងអនុវត្តជាទូទៅ ។*

*៦-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានក្រុមប្រឹក្សាប្រឡងប្រណាំង ដើម្បីបំផុសចលនាប្រឡងប្រណាំង និងពិនិត្យបូកសរុប វាយតម្លៃលក្ខណៈសម្បត្តិរបស់ភូមិ,* ***ឃុំ មានសុវត្ថិភាព*** *។ តាមរយៈនេះត្រូវរកឲ្យឃើញអង្គភាព និងបុគ្គលដែលមានស្នាដៃល្អ ដើម្បីផ្តល់រង្វាន់លើកទឹកចិត្ត ។*

*៧-អគ្គនាយកដ្ឋានកស្តុភារ និងហិរញ្ញវត្ថុ ត្រូវធ្វើគំរោងថវិកា មធ្យោបាយ សំភារៈ បំរើដល់ការចាត់តាំងអនុវត្តគោលនយោបាយភូមិ, ឃុំមានសុវត្ថិភាពនេះ ។*

*ទទួលបានផែនការណែនាំស្តីពីការអនុវត្តគោលនយោបាយភូមិ,* ***ឃុំមានសុវត្ថិភាព****នេះ ក្រសួងមហាផ្ទៃសង្ឃឹមថា គ្រប់ក្រសួង ស្ថាប័ន គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់រូប នឹងចូលរួមអនុវត្ត និងឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាង តាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីទទួលបានជោគជ័យក្នុងការកសាងសេចក្តីសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋយើង ។*

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១០*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ
លេខ : ០០៧/១៧ សណន.ច

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០១៧

## សេចក្តីណែនាំ
## ស្តីពី
## ការដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

ក្នុងរយៈពេលកន្លងមកនេះ រដ្ឋបាលរាជធានីភ្នំពេញពិនិត្យឃើញថា បងប្អូនប្រជាពលរដ្ឋមួយចំនួនដែលជាម្ចាស់លំនៅដ្ឋាន ម្ចាស់សហគ្រាស ម្ចាស់ហាង ម្ចាស់អាជីវកម្ម មន្ទីរពេទ្យ សាលារៀន ស្ថាប័នរដ្ឋ និងគ្រឹះស្ថានឯកជនផ្សេងទៀត បាននឹងកំពុងប្រើប្រាស់ទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងជាយផ្លូវមិនទាន់បានសមស្របទាំងស្រុង ឬដោយបំពានលើបទប្បញ្ញត្តិច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន ជាពិសេសបំពានលើបទប្បញ្ញត្តិមួយចំនួននៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ និងបទដ្ឋានគតិយុត្តដែលអនុវត្តក្នុងវិស័យនគរូបនីយកម្ម និងសំណង់។ អំពើរំលោភបំពានទាំងនោះមានជាអាទិ៍ ការយកទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងជាយផ្លូវធ្វើជាចំណតយានជំនិះ ការតសំយ៉ាប ការហ៊ុំព័ទ្ធយកចិញ្ចើមផ្លូវ ការយកផ្លូវថ្មើរជើង ឬចិញ្ចើមផ្លូវធ្វើទីតាំងការដ្ឋានទុកដាក់សម្ភារៈ ឬដាក់តាំងបង្ហាញទំនិញ ឬប្រកបអាជីវកម្ម ផ្សេងៗជាលក្ខណៈឯកជន ដែលបង្កឱ្យមានការកកស្ទះចរាចរណ៍ និងជះឥទ្ធិពលអវិជ្ជមានដល់សណ្តាប់ធ្នាប់សាធារណៈ និងសោភណភាពរាជធានីភ្នំពេញ។

អនុវត្តតាមស្មារតីនៃកិច្ចប្រជុំគណៈបញ្ជាការឯកភាពកាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧ រដ្ឋបាលរាជធានីភ្នំពេញសម្រេចជ្រើសយកផ្លូវសំខាន់ៗចំនួន ១១ខ្សែ ធ្វើជាអាទិភាពគំរូ សម្រាប់អនុវត្តវិធានការដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់សាធារណៈ មុននឹងបន្តអនុវត្តចំពោះបណ្តាទីតាំងផ្សេងៗទៀតក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។ ផ្លូវអាទិភាពគំរូទាំងនោះរួមមាន៖ ១- មហាវិថីសហព័ន្ធរុស្ស៊ី, ២- មហាវិថីព្រះមុនីវង្ស, ៣- មហាវិថីកម្ពុជាក្រោម, ៤- មហាវិថីម៉ៅសេងទុង, ៥- មហាវិថីព្រះសីហនុ និងមហាវិថីនេរុហ៍, ៦- មហាវិថីព្រះនរោត្តម, ៧- មហាវិថីសម្តេចមុនីរ៉េត, ៨- ផ្លូវឧកញ៉ាទេពផន, ៩- មហាវិថីហ្សាលនីហ្គោល, ១០- មហាវិថីយោធពលខេមរភូមិន្ទ (ផ្លូវ២៧១) និងផ្លូវឧកញ៉ាឃ្លាំងមឿង (ផ្លូវលេខ៧០) និង ១១- តីរវិថីព្រះស៊ីសុវត្ថិ។

ដូចនេះ ដើម្បីដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវអាទិភាពខាងលើ រដ្ឋបាលរាជធានីភ្នំពេញ ដាក់ចេញនូវសេចក្តីណែនាំដូចខាងក្រោម៖

**ក. ចំពោះបងប្អូនប្រជាពលរដ្ឋ ម្ចាស់លំនៅដ្ឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន មន្ទីរពេទ្យ សាលារៀនវិស័យឯកជន អគារសាធារណៈ និងអ្នកប្រើប្រាស់ផ្លូវថ្នល់ ត្រូវអនុវត្តដូចខាងក្រោម៖**

១. ហាមចតយានយន្តគ្រប់ប្រភេទនៅលើទ្រូងផ្លូវ។

៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

២. ហាមដាច់ខាតមិនឱ្យម្ចាស់ការដ្ឋានសំណង់គ្រប់ប្រភេទ ធ្វើការហ៊ុំមព័ទ្ធការដ្ឋានលើចិញ្ចើមផ្លូវលើសពី១/៣ (មួយភាគបី) និងឬប្រើប្រាស់ទ្រូងផ្លូវដើម្បីទុកដាក់សម្ភារៈសំណង់របស់ខ្លួន ដូចជា ដែក ខ្សាច់ គ្រួស ថ្ម ជាដើម។

៣. រថយន្តដឹកទំនិញធំៗ រថយន្តកុងតឺន័រ រថយន្តបាញ់បេតុង និងរថយន្តក្រឡុកស៊ីម៉ង់ត៍ ត្រូវចេញ-ចូល គោរពតាមការណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ និងចៀសវាងការប្រើប្រាស់ទ្រូងផ្លូវក្នុងការលើកដាក់ ផ្ទេរទំនិញ និងបាញ់បេតុង។ ក្នុងករណីចៀសវាងមិនបាន ត្រូវអនុវត្តការលើកដាក់ទំនិញ និងការបាញ់បេតុង ចាប់ពីម៉ោង២១:០០នាទី រហូតដល់ម៉ោង០៦:០០នាទីព្រឹក។

៤. ការរៀបចំសម្ភារៈ ទំនិញ ម៉ូតូ និងរថយន្តដាក់តាំងលក់ អាចប្រើប្រាស់ចំណែកចិញ្ចើមផ្លូវត្រឹម ១/៣ (មួយភាគបី) ជាលក្ខណៈបណ្ដោះអាសន្នតែប៉ុណ្ណោះ ដោយទុក២/៣ (ពីរភាគបី) សម្រាប់ថ្មើរជើង និងបម្រើឱ្យការងារសណ្ដាប់ធ្នាប់ និងចរាចរណ៍។

៥. រាល់ការប្រើប្រាស់ចិញ្ចើមផ្លូវជាទីតាំងផ្ញើកង់ ម៉ូតូ មិនត្រូវឱ្យលើសពី១/៣ (មួយភាគបី) ឡើយ។

**ខ. ចំពោះគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌទាំង១២ ត្រូវអនុវត្តដូចខាងក្រោម៖**

១. ត្រូវចុះធ្វើការអប់រំណែនាំដល់ប្រជាពលរដ្ឋ ដែលបាននឹងកំពុងប្រើប្រាស់ទ្រូងផ្លូវ ចិញ្ចើមផ្លូវដោយរំលោភបំពាន ដោយប្រើប្រាស់វិធីសាស្ត្រទន់ភ្លន់ តែម៉ឺងម៉ាត់ ឱ្យចូលរួមអនុវត្តតាមស្មារតីនៃសេចក្ដីណែនាំនេះ។ ក្នុងករណីនៅតែមិនអនុវត្តតាមការណែនាំនេះ មន្ត្រីអនុវត្តត្រូវធ្វើកំណត់ហេតុ និងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

២. ត្រូវណែនាំដល់ម្ចាស់ទីតាំងភោជនីយដ្ឋាន និងម្ចាស់ទីតាំងអាជីវកម្មនានាឱ្យគោរពតាមខ្លឹមសារនៃសេចក្ដីណែនាំនេះ ក្នុងករណីពុំព្រមអនុវត្តតាម អាជ្ញាធរខណ្ឌត្រូវសហការជាមួយកម្លាំងមានសមត្ថកិច្ច និងជំនាញពាក់ព័ន្ធធ្វើការផាកពិន័យតាមច្បាប់ និងអាចឈានទៅបិទទីតាំងអាជីវកម្ម។

៣. ត្រូវធ្វើការណែនាំ និងធ្វើកំណត់ហេតុឱ្យបានត្រឹមត្រូវជាមួយម្ចាស់ការដ្ឋានដែលរំលោភបំពានទ្រូងផ្លូវ និងចិញ្ចើមផ្លូវ ក្នុងករណីមិនរាងចាល ត្រូវផ្អាកការដ្ឋាននោះភ្លាម។

៤. ត្រូវចុះល្បាត និងឃ្លាំមើលជាប្រចាំចំពោះរថយន្តដឹកទំនិញធំៗ រថយន្តកុងតឺន័រ រថយន្តបាញ់បេតុង និងរថយន្តក្រឡុកស៊ីម៉ង់ត៍ និងត្រូវមានវិធានការឱ្យបានម៉ឺងម៉ាត់ក្នុងករណីការចេញ-ចូលរាជធានីភ្នំពេញខុសពីសេចក្ដីណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ។

៥. ត្រូវអនុវត្តការងារតាមការណែនាំខាងលើនេះ ឱ្យបានត្រឹមត្រូវ ហ្មត់ចត់ និងទន់ភ្លន់ និងត្រូវរាយការណ៍ប្រចាំសប្ដាហ៍អំពីលទ្ធផលនៃការងារនេះ មកគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញឱ្យបានទៀងទាត់ និងទាន់ពេលវេលា។

**គ. ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញត្រូវ៖**

១. បន្ថែមកម្លាំងនគរបាលចរាចរណ៍ ដោះស្រាយបញ្ហាចរាចរណ៍តាមគោលដៅដែលមានការកកស្ទះនៅចន្លោះម៉ោងមមាញឹក គឺម៉ោង ០៧:៣០នាទី ដល់ម៉ោង ០៨:៣០នាទី, ម៉ោង ១១:៣០នាទី ដល់ម៉ោង ១២:៣០នាទី និងម៉ោង ១៧:០០នាទី ដល់ម៉ោង ១៨:៣០នាទី។

២. រៀបចំរថយន្តស្ទូច ដើម្បីសហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌទាំង១២ ដើម្បីអនុវត្តវិធានការច្បាប់។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

ទទួលបានសេចក្តីណែនាំនេះ ប្រជាពលរដ្ឋ គ្រឹះស្ថានឯកជន ស្ថាប័នសាធារណៈ និងអ្នកប្រើប្រាស់ផ្លូវ មានរយៈពេល ០២ (ពីរ)សប្តាហ៍ គិតចាប់ពីថ្ងៃចេញសេចក្តីណែនាំនេះ ដើម្បីធ្វើការកែសម្រួល និងរៀបចំទីតាំងរបស់ខ្លួនឱ្យស្របតាមស្មារតីនៃសេចក្តីណែនាំនេះ។

នាយករដ្ឋបាលសាលារាជធានីភ្នំពេញ អភិបាលខណ្ឌទាំង១២ ស្នងការនគរបាលរាជធានីភ្នំពេញ មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ បងប្អូនប្រជាពលរដ្ឋ អ្នកប្រើប្រាស់ផ្លូវទាំងអស់ត្រូវរួមអនុវត្តសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

កន្លែងទទួល៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសាធារណការ និងដឹកជញ្ជូន

  "ដើម្បីជូនជ្រាប"
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌទាំង ១២
- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ

  "ដើម្បីអនុវត្ត"
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ

  "ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized





# ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា





ក្រុមធនាគារពិភពលោក

## ប្រអប់ទី ១៖ សេវាហេដ្ឋារចនាសម្ព័ន្ធទីក្រុងដែលមានកម្រិតខុសៗគ្នាក្នុងទីក្រុងភ្នំពេញ

***ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍៖*** ចំនួនយានយន្តដែលត្រូវបានចុះបញ្ជី បានកើនចំនួនយ៉ាងច្រើន នៅពេលដែលបណ្តាញផ្លូវថ្នល់នៅមានសមត្ថភាពនៅមានកម្រិតនៅឡើយ ហើយទាមទារឱ្យមានការជួសជុលកែលំអជាច្រើន។ មធ្យោបាយធ្វើដំណើរសាធារណៈទើបតែត្រូវបានដាក់ឱ្យអនុវត្តសាកល្បងប៉ុណ្ណោះ ហើយចំនួនអ្នកប្រើប្រាស់មធ្យោបាយសាធារណៈទាំងនេះនៅមានតិចតួច ដោយសារតែចរាចរណ៍ពុំមានស្ថានភាពល្អប្រសើរ កាលវិភាគមិនទៀងទាត់ និងរថយន្តក្រុងដែលប្រើមានគុណភាពទាប។ កង្វះការភ្ជាប់ទំនាក់ទំនងរវាងទីតាំងចេញដំណើរដំបូង និងទីតាំងចុងក្រោយ ក៏ជាកត្តាដែលបង្កការរារាំងដល់ការប្រើប្រាស់មធ្យោបាយធ្វើដំណើរសារធាណៈផងដែរ ជាពិសេស ដោយសារតែភាពងាយស្រួលនៃការធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ តាមរយៈទោចក្រយានយន្ត និងរម៉កកង់បី (ទុកទុក)។ បើតាមផែនការ នឹងមានការបន្ថែមរថយន្តក្រុងចំនួន ១៨០ គ្រឿងទៀត ដើម្បីដោះស្រាយបញ្ហាមួយចំនួន ដែលរកឃើញក្នុងកំឡុងពេលអនុវត្តសាកល្បងនេះ។ ជម្រើសផ្សេងទៀត ដូចជារថយន្តក្រុងអគ្គិសនី ប្រព័ន្ធតាក់ស៊ីតាមផ្លូវទឹក និងរថភ្លើងអាកាស ក៏កំពុងត្រូវបានពិចារណាផងដែរ ដើម្បីសម្រួលដល់បញ្ហាកកស្ទះចរាចរណ៍មួយចំនួន។

***ប្រព័ន្ធលូរំដោះទឹកភ្លៀង៖*** ទីក្រុងភ្នំពេញងាយរងការលិចលង់ខ្លាំង ដោយសារតែបណ្តាញលូរំដោះទឹកភ្លៀង និងបណ្តាញលូទឹកស្អុយ ពុំគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការក្នុងទីក្រុងទាំងមូលបាន លើកលែងតែខណ្ឌកណ្តាលក្រុងចំនួនបួន ដែលបានទទួលប្រយោជន៍ពីជំនួយរបស់អ្នកផ្តល់ជំនួយ។ ផ្ទុយទៅវិញ តំបន់នៅសេសសល់ផ្សេងទៀតក្នុងទីក្រុងពុំមានប្រព័ន្ធលូរំដោះទឹកភ្លៀង និងប្រព័ន្ធការពារទឹកជំនន់ពេញលេញឡើយ ដែលនាំឱ្យទីក្រុងនេះងាយរងគ្រោះដោយសារតែការលិចលង់ដែលឧស្សាហ៍កើតឡើងញឹកញាប់។ ប្លង់គោលប្រព័ន្ធលូរំដោះទឹកភ្លៀងត្រូវបានរៀបចំឡើងដោយ JICA ប៉ុន្តែមិនទាន់មានការកំណត់ឱ្យបានច្បាស់លាស់នៅឡើយពីស្ថាប័នដែលនឹងមានតួនាទីដឹកនាំការអនុវត្តផែនការនេះ។

***ប្រព័ន្ធលូទឹកស្អុយ និងការសំអាតទឹកស្អុយ៖*** បច្ចុប្បន្ននេះ នៅមិនទាន់មានប្រព័ន្ធសំអាតទឹកស្អុយជាផ្លូវការក្នុងទីក្រុងភ្នំពេញនៅឡើយទេ។ ទឹកស្អុយ និងទឹកសំណល់ផ្សេងទៀត ហូរលាយឡំជាមួយនឹងទឹកភ្លៀង តាមប្រឡាយលូមានគំរប និងប្រឡាយលូបើកចំហជាច្រើន ដែលបន្ទាប់មក ហូរចូលទៅក្នុងទន្លេ បឹង និងដីទំនាបលិចទឹករបស់ទីក្រុងនេះ។ បន្ថែមពីលើកង្វះហេដ្ឋារចនាសម្ព័ន្ធ ការពុំមានបទដ្ឋានគតិយុត្តិ និងការពង្រឹងការអនុវត្ត នាំឱ្យទឹកស្អុយដែលពុំបានឆ្លងកាត់ការសំអាតត្រូវហូរចូលទៅក្នុងទន្លេបឹងធម្មជាតិ ដែលបង្កជាការគំរាមកំហែងដល់បរិស្ថានទីក្រុង ជាពិសេស ដល់ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ចំណូលទាបជុំវិញប្រឡាយលូ និងបឹងបួរនានា។ ខណៈពេលដែលការសិក្សាក្រោមការឧបត្ថម្ភរបស់អ្នកផ្តល់ជំនួយនានាបានបង្ហាញឱ្យឃើញពីតម្រូវការនៃការសំអាតទឹកសំណល់ និងទឹកស្អុយក្នុងទីក្រុងភ្នំពេញ មានការសម្រេចវឌ្ឍនភាពបានតិចតួចប៉ុណ្ណោះ ក្នុងការផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគទាំងនេះ។

***ការប្រមូលសំណល់រឹង៖*** ក្រុមហ៊ុនឯកជនមួយបានទទួលកិច្ចសន្យាជាអ្នកផ្តល់សេវាប្រមូលសំណល់រឹងតែមួយគត់រយៈពេល ៤៩ ឆ្នាំ បើទោះបីជាមានកិច្ចខិតខំប្រឹងប្រែងធ្វើការកែសម្រួលក៏ដោយ។ សេវានេះមានលក្ខណៈរដិបរដុបខ្លាំង ដោយសារតែការកកស្ទះចរាចរណ៍ បញ្ហាកម្លាំងពលកម្ម និងការរីកចម្រើនយ៉ាងឆាប់រហ័សរបស់ទីក្រុង ដែលធ្វើឱ្យមានសំណល់រឹងរហូតដល់ ១០០-២០០ តោន មិនត្រូវបានប្រមូលជារៀងរាល់ថ្ងៃ ក្នុងទីក្រុងភ្នំពេញ ហើយចុងក្រោយសំណល់រឹងទាំងនេះត្រូវបានគេដុត ឬកប់ចោល ឬដាក់ចោលលើផ្លូវតែម្តង។ ការចោលសំណល់រឹងទៅក្នុងបណ្តាញលូធ្វើឱ្យបញ្ហាពាក់ព័ន្ធនឹងប្រព័ន្ធលូរំដោះទឹកភ្លៀង និងការពារទឹកជំនន់ កាន់តែធ្ងន់ធ្ងរបន្ថែមទៀត។

***ការផ្គត់ផ្គង់ទឹក៖*** ការផ្គត់ផ្គង់ទឹកក្នុងទីក្រុងភ្នំពេញបានទទួលជោគជ័យយ៉ាងច្រើន មួយផ្នែកធំ ដោយសារតែការដឹកនាំរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលជាស្ថាប័នស្វយ័តទទួលថវិកាពីអ្នកផ្តល់ជំនួយនានា។ ដោយសារតែមានការផ្លាស់ប្តូររបៀបទទួលហិរញ្ញប្បទានសម្រាប់ស្ថាប័នរដ្ឋ ធនធានហិរញ្ញប្បទានត្រូវឆ្លងកាត់តាមក្រសួងវិញ ដែលនាំឱ្យមានការពន្យារពេលការអនុវត្តគម្រោងជាច្រើន។

**តារាង ១.១៖** ចំនួនប្រជាជននៅតំបន់ក្រុង និងតំបន់ជនបទនៅអាស៊ីអាគ្នេយ៍ និងភាគរយប្រជាជននៅតំបន់ក្រុង (២០១៤)

| តំបន់ធំៗ ភូមិភាគ និងប្រទេស | ប្រជាជន (គិតជាពាន់នាក់) | | | ភាគរយប្រជាជននៅតំបន់ក្រុង |
|---|---|---|---|---|
| | ចំនួនប្រជាជនក្នុងតំបន់ក្រុង | ចំនួនប្រជាជនក្នុងតំបន់ជនបទ | សរុប | |
| អាស៊ីអាគ្នេយ៍ | 294,409 | 331,573 | 625,982 | 47 |
| ប្រ៊ុយណេ | 325 | 98 | 423 | 77 |
| កម្ពុជា | 3,161 | 12,247 | 15,408 | 21 |
| ឥណ្ឌូនេស៊ី | 133,999 | 118,813 | 252,812 | 53 |
| ឡាវ | 2,589 | 4,305 | 6,894 | 38 |
| ម៉ាឡេស៊ី | 22,342 | 7,846 | 30,188 | 74 |
| មីយ៉ាន់ម៉ា | 18,023 | 35,696 | 53,719 | 34 |
| ហ្វីលីពីន | 44,531 | 55,566 | 100,096 | 44 |
| សឹង្ហបុរី | 5,517 | - | 5,517 | 100 |
| ថៃ | 33,056 | 34,167 | 67,223 | 49 |
| ទីម័រខាងកើត | 370 | 782 | 1,152 | 32 |
| វៀតណាម | 30,495 | 62,053 | 92,548 | 33 |

*ប្រភព៖ សហប្រជាជាតិ សក្តានុពលនៃនគរូបនីយកម្មរបស់ពិភពលោក កែសម្រួលឆ្នាំ ២០១៤*

៥. គេរំពឹងថា ការអភិវឌ្ឍ និងការពង្រីកទីក្រុងរបស់ប្រទេសកម្ពុជា នឹងបន្តកើនឡើងក្នុងអត្រាជាមធ្យមប្រចាំឆ្នាំប្រមាណជា ២,៥ភាគរយ ក្នុងរយៈពេល ៣៥ ឆ្នាំទៀត។ ត្រឹមឆ្នាំ ២០៥០ គេរំពឹងថា ៣៦ ភាគរយនៃប្រជាជនទាំងអស់ នឹងរស់នៅក្នុងតំបន់ក្រុង (**តារាង ១.២**)។ អត្រានគរូបនីយកម្មរបស់ប្រទេសមួយ មានទំនាក់ទំនងជាវិជ្ជមានខ្លាំងជាមួយនឹងកម្រិត ផសស សម្រាប់ប្រជាជនម្នាក់។ ដូចបង្ហាញក្នុង**រូបភាព ១.១** កម្រិតនៃនគរូបនីយកម្មរបស់ប្រទេសកម្ពុជា (២១%) គឺទាបឆ្ងាយជាងកម្រិតដែលត្រូវបានគេព្យាករទុក ដោយផ្អែកទៅតាម ផសស សម្រាប់ប្រជាជនម្នាក់របស់ប្រទេសនេះ។ ប្រទេសដែលមាន ផសស សម្រាប់ប្រជាជនម្នាក់ ដូចជា ប្រទេសបង់ក្លាដេស ឬគីហ្ស៊ីស្ថាន ជាដើម មានអត្រានគរូបនីយកម្មជិត ៣៥%។ តំបន់ក្រុងរបស់ប្រទេសកម្ពុជានៅ "មិនទាន់មានការអភិវឌ្ឍ និងពង្រីកខ្លួន" ឱ្យដល់កម្រិតនៅឡើយ បើទោះបីជាភាគរយនៃប្រជាជនរស់នៅទីក្រុងមានការកើនឡើង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ ដែលនេះបង្ហាញថានឹងមានការអភិវឌ្ឍ និងការពង្រីកទីក្រុងកាន់តែឆាប់រហ័ស ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។

**តារាង ១.២៖** ការព្យាករពីចំនួនប្រជាជននៅប្រទេសកម្ពុជា និងភាគរយប្រជាជនរស់នៅតំបន់ក្រុង ១៩៩៥-២០៥០ (គិតជាពាន់នាក់)

| ឆ្នាំ | 1995 | 2000 | 2005 | 2010 | 2015 | 2020 | 2025 | 2030 | 2040 | 2050 |
|---|---|---|---|---|---|---|---|---|---|---|
| ចំនួនប្រជាជននៅតំបន់ក្រុង | 1,864 | 2,272 | 2,561 | 2,846 | 3,249 | 3,723 | 4,274 | 4,900 | 6,433 | 8,167 |
| ចំនួនប្រជាជននៅតំបន់ជនបទ | 8,905 | 9,951 | 10,795 | 11,519 | 12,428 | 13,223 | 13,846 | 14,244 | 14,590 | 14,402 |
| ចំនួនប្រជាជនសរុប | 10,769 | 12,223 | 13,356 | 14,365 | 15,677 | 16,946 | 18,120 | 19,144 | 21,023 | 22,569 |
| ភាគរយប្រជាជននៅតំបន់ក្រុង (%) | 17.3 | 18.6 | 19.2 | 19.8 | 20.7 | 22.0 | 23.6 | 25.6 | 30.6 | 36.2 |
| ចំនួនប្រជាជនក្នុងទីក្រុងភ្នំពេញ | 836 | 1,149 | 1,317 | 1,510 | 1,731 | 1,979 | 2,262 | 2,584 | - | - |

*ប្រភព៖ សហប្រជាជាតិ សក្តានុពលនៃនគរូបនីយកម្មរបស់ពិភពលោក កែសម្រួលឆ្នាំ ២០១៤*

**ក្រុមធនាគារពិភពលោក**

ការិយាល័យប្រចាំនៅកម្ពុជា
អគារ Exchange Square
ជាន់ទី10 IBRD និងជាន់ទី 11 IFC
ផ្លូវលេខ 51-61 និងផ្លូវលេខ 102-106
សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ
ភ្នំពេញ កម្ពុជា
www.worldbank.org/cambodia



# ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព
# សម្រាប់រាជធានីភ្នំពេញ
# ២០១៨-២០៣០

Global Green Growth Institute

# ១. សេចក្តីផ្តើម

ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ គឺជាផែនទីបង្ហាញផ្លូវមួយសម្រាប់អ្នករៀបចំគោលនយោបាយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិនានា ដើម្បីបន្តការអភិវឌ្ឍទីក្រុងប្រកបដោយនិរន្តរភាពក្នុងគោលដៅប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុនៅក្នុងដំណើរការអភិវឌ្ឍកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងពង្រឹងបរិយាប័ន្នសង្គម[1] ។ ដូច្នេះ ផែនការនេះមានសារៈប្រយោជន៍សម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់រាជធានី វិស័យឯកជន ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នសិក្សាស្រាវជ្រាវក្នុងការអភិវឌ្ឍរាជធានីភ្នំពេញ។

ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ មានភ្ជាប់មកជាមួយនូវវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព ដែលជាគោលការណ៍ណែនាំជាជំហានៗសម្រាប់មន្ត្រី ពាក់ព័ន្ធនានាទាំងនៅថ្នាក់រាជធានី ក្រុង/ស្រុក ឃុំ/សង្កាត់ ព្រមទាំងភាគីពាក់ព័ន្ធនៃទីក្រុងនីមួយៗនៅទូទាំងប្រទេសកម្ពុជា ដែលកំពុងបន្តអនុវត្តដំណើរការអភិវឌ្ឍន៍ទីក្រុងរបស់ខ្លួន សំដៅឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព។ វិធីសាស្ត្រនេះគាំទ្រដល់ទីក្រុងនានាក្នុងការសិក្សាវាយតម្លៃ និងកំណត់អាទិភាពអភិវឌ្ឍន៍និរន្តរភាព (គម្រោងវិនិយោគ និងកំណែទម្រង់គោលនយោបាយ) សម្រាប់អនុវត្ត។ វិធីសាស្ត្រនេះបានពិចារណាយ៉ាងគ្រប់ជ្រុងជ្រោយទៅលើគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព ដូចជាការអភិវឌ្ឍដែលបំភាយកាបូនតិច ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការប្រើប្រាស់ប្រសិទ្ធភាពធនធាន ព្រមទាំងបរិយាប័ន្នសង្គម និងការកាត់បន្ថយភាពក្រីក្រ។ វិធីសាស្ត្រនេះមាន ១០ ជំហាន ដូចខាងក្រោម៖

- **ជំហានទី ១៖** ការបង្កើតក្រុមការងារសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព
- **ជំហានទី ២៖** ការសិក្សាវាយតម្លៃបឋម ដើម្បីធ្វើជាមូលដ្ឋានវិភាគទៅលើបរិបទទីក្រុង
- **ជំហានទី ៣៖** ការកំណត់ចក្ខុវិស័យទីក្រុងនិរន្តរភាព បេសកកម្ម និងគោលដៅអភិវឌ្ឍន៍
- **ជំហានទី ៤៖** ការវិភាគវិស័យសំខាន់ៗសម្រាប់ការអភិវឌ្ឍនិរន្តរភាពក្នុងទីក្រុង
- **ជំហានទី ៥៖** ការបង្កើតវត្ថុបំណងអាទិភាពនៃការអភិវឌ្ឍបៃតងនៅទីក្រុង និងសកម្មភាពសម្រាប់វិស័យគន្លឹះៗនៃទីក្រុង
- **ជំហានទី ៦៖** ការកំណត់គម្រោងវិនិយោគសក្តានុពលសម្រាប់អភិវឌ្ឍន៍ទីក្រុងនិរន្តរភាព
- **ជំហានទី ៧៖** ការកំណត់អាទិភាពគម្រោងវិនិយោគសម្រាប់អភិវឌ្ឍន៍ទីក្រុងនិរន្តរភាព
- **ជំហានទី ៨៖** ការវិភាគសេណារីយ៉ូសម្រាប់ការអភិវឌ្ឍនិរន្តរភាពនៅទីក្រុង
- **ជំហានទី ៩៖** ការរៀបចំបញ្ជីគម្រោងអាទិភាពទីក្រុងនិរន្តរភាព
- **ជំហានទី ១០៖** ការរៀបចំរចនាសម្ព័ន្ធសម្រាប់អនុវត្តន៍ផែនការទីក្រុងនិរន្តរភាព

រាជធានីភ្នំពេញ គឺជាទីក្រុងដំបូងគេនៅប្រទេសកម្ពុជាដែលអនុវត្តវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងបៃតងនេះ និងបានបង្កើតជាផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពរបស់ខ្លួនដើម្បីធ្វើជាគម្រូឱ្យទីក្រុងផ្សេងទៀតអនុវត្តតាម។ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ការអនុវត្តផែនការមេរាជធានីភ្នំពេញស្តីពីការប្រើប្រាស់ដីធ្លី ឆ្នាំ២០៣៥ តាមរយៈការបង្កើតសកម្មភាពគម្រោងវិនិយោគអភិវឌ្ឍន៍បៃតងជាក់លាក់មួយចំនួនដែលឆ្លើយតបទៅនឹងយុទ្ធសាស្ត្រអាទិភាពកំណត់នៅក្នុងផែនការមេ។ លើសពីនេះទៀតផែនការអភិវឌ្ឍន៍ ទីក្រុងនិរន្តរភាពនេះ នឹងគាំទ្រដល់ការសម្រេចបានគោលដៅជាយុទ្ធសាស្ត្រដែលមានចែងនៅក្នុងផែនការមេរាជធានីភ្នំពេញស្តីពីការរៀបចំប្រព័ន្ធដឹកជញ្ជូនទីក្រុង និងផែនការមេរាជធានីភ្នំពេញស្តីពី បណ្តាញលូទឹក និងប្រព័ន្ធលូទឹកកខ្វក់។

[1] បរិយាប័ន្នសង្គម (Social Inclusion) គឺជាការគិតគូរពីបញ្ហាសង្គមបានគ្រប់ជ្រុងជ្រោយ នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនានារបស់ថ្នាក់ដឹកនាំ ឬអ្នកធ្វើគោលនយោបាយ នៅលើគ្រប់វិស័យទាំងអស់ដែលពាក់ព័ន្ធ។

ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ត្រូវបានសហការរៀបចំឡើងមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយមានរួមបញ្ចូលនូវការពណ៌នាអំពីគោលគំនិតនៃគម្រោងវិនិយោគបៃតងសម្រាប់រាជធានីភ្នំពេញចំនួន ៤៨ គម្រោង ដែលមានការវិភាគលម្អិតដើម្បីគាំទ្រដល់ដំណើរការជ្រើសរើស ការផ្តល់អាទិភាព និងការអនុវត្តគម្រោងទាំងនោះ ក្នុងនោះក៏មានការវិភាគលម្អិតទៅលើកត្តាប្រឈម និងកាលានុវត្តភាពតាមវិស័យសំខាន់ៗនៃការអភិវឌ្ឍនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ។

រូបភាពទី១៖ ទំនាក់ទំនងនៃផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ទៅនិងផែនការមេរាជធានីភ្នំពេញស្តីពីការប្រើប្រាស់ដីឆ្នាំ២០៣៥។



# ២. ចក្ខុវិស័យសម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាព

ដើម្បីឈានទៅសម្រេចការអភិវឌ្ឍទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ផែនការនេះបានកំណត់ចក្ខុវិស័យដូចខាងក្រោមៈ

**ចក្ខុវិស័យ**

នៅឆ្នាំ២០៣០ រាជធានីភ្នំពេញនឹងក្លាយជាទីក្រុងស្អាត បៃតង និងប្រកបដោយការប្រកួតប្រជែង ដែលផ្តល់នូវរបៀបរស់នៅមានសុវត្ថិភាព និងគុណភាពដល់ប្រជាជន។



# ៣. គោលដៅ និងគោលបំណងសម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាព

ដើម្បីសម្រេចបាននូវចក្ខុវិស័យសម្រាប់ការអភិវឌ្ឍទីក្រុងប្រកបដោយនិរន្តរភាព គោលដៅនិងគោលបំណងធំៗ ដូចខាងក្រោមត្រូវបានគេស្នើឡើង។ គោលដៅជាក់លាក់និងសូចនាករនឹងត្រូវបង្កើតឡើងដោយក្រុមការងារបច្ចេកទេស (TWGs) ដូចដែលបានរៀបរាប់នៅក្នុងផ្នែករៀបចំការអនុវត្ត (ផ្នែកទី ៧) នៃផែនការនេះ។

## ៣.១ គោលដៅជារួមនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព

ក. ធ្វើឱ្យមានកំណើនសេដ្ឋកិច្ចដោយមិនប៉ះពាល់លើបរិស្ថាន

ខ. ពង្រឹងបរិយាប័ន្នសង្គម កាត់បន្ថយភាពក្រីក្រ និងបង្កើនសុខុមាលភាពទីក្រុង

គ. ផ្តល់ដល់ប្រជាពលរដ្ឋទាំងអស់នៅក្នុងទីក្រុង នូវការរស់នៅដែលមានភាពបន្សាំទៅនឹងហានិភ័យគ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ និងហានិភ័យផ្សេងៗទៀត

ឃ. បង្កើនភាពប្រកួតប្រជែង និងភាពទាក់ទាញសម្រាប់កិច្ចការជំនួញ និងវិនិយោគ

## ៣.២ គោលបំណងនៅតាមវិស័យសំខាន់ៗនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព

### ក. គោលបំណងនៅក្នុងវិស័យ "ការរៀបចំផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព"

- អនុវត្តអោយបាននូវផែនការមេរាជធានីភ្នំពេញស្តីពីការប្រើប្រាស់ដីធ្លី ឆ្នាំ២០៣៥ ស្របទៅតាមទិសដៅដែលបានគ្រោងទុក (ភាគរយដែលត្រូវបានអនុវត្តរួចស្របទៅតាមផែនការមេ)
- រៀបចំផែនទីលម្អិតស្តីពីការប្រើប្រាស់ដីធ្លី និងការបែងចែកតំបន់ប្រើប្រាស់ដីធ្លី (ភាគរយនៃវិសាលភាពតំបន់ទីក្រុងដែលបានកំណត់នៅក្នុងផែនទីលម្អិត)
- ធ្វើឱ្យមាននិរន្តរភាពនៃការអនុវត្តគម្រោងអភិវឌ្ឍន៍ទីក្រុងរណបទាំងប្រាំពីរដែលបានគ្រោងនឹងបញ្ចប់នៅឆ្នាំ២០៣០ (គម្រោងនីមួយៗមានប្រព័ន្ធគ្រប់គ្រងសំណល់រឹង និងរាវ និងការអនុវត្តស្របតាមបទដ្ឋានសាងសង់បៃតង)

### ខ. គោលបំណងនៅក្នុងវិស័យ "ភាពងាយរងគ្រោះរបស់ទីក្រុង"

- ការពារប្រជាជនក្នុងរាជធានីភ្នំពេញពីទឹកជំនន់ធ្ងន់ធ្ងរ (ភាគរយនៃប្រជាជនដែលទទួលរងផលប៉ះពាល់អវិជ្ជមាន)
- កែលម្អបឹងធម្មជាតិ និងតំបន់ដីសើមនៅទីក្រុងដែលអាចប្រើប្រាស់ជាប្រព័ន្ធគ្រប់គ្រងទឹកជំនន់ធម្មជាតិ និងទឹកកខ្វក់ឱ្យបានច្រើនដូចក្នុងឆ្នាំ២០០៣ (ក្រឡាផ្ទៃបឹងធម្មជាតិ និងតំបន់ដីសើមគិតជាហិកតា ឬជាអារ)
- បង្កើត ឬស្តារឡើងវិញនូវរបៀងបៃតងនៅក្នុងទីក្រុងទាំងមូល (ចំនួនរបៀង)
- ប្រព្រឹត្តកម្មសំណល់រាវទំហំតូចៗតាមតំបន់ ដែលនឹងត្រូវបង្កើតឡើងនៅក្នុងតំបន់ទីក្រុង (លានម៉ែត្រគូប / គិតជាភាគរយនៃបរិមាណសរុប)
- គ្រួសារនៅតំបន់ជុំវិញទីក្រុងប្រើប្រាស់ប្រព័ន្ធអនាម័យដែលមានការកែលម្អ និងមានសុវត្ថិភាព ដែលនឹងការពារការរាលដាលនៃការបំពុលនៅក្នុងករណីមានភ្លៀង និងមានការជន់លិចខ្លាំង (ចំនួនគ្រួសារជុំវិញទីក្រុងដែលមានប្រព័ន្ធអនាម័យល្អ និងមានសុវត្ថិភាព រួមជាមួយនឹងប្រព្រឹត្តកម្មទឹកកខ្វក់ គិតជាភាគរយនៃបរិមាណសរុប)

## គ. គោលបំណងក្នុងវិស័យ "ថាមពល"

- បង្កើនបរិមាណប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យនៅក្នុងការផ្គត់ផ្គង់អគ្គិសនី (ភាគរយកំណើនពីបច្ចុប្បន្ន < ១%)
- កាត់បន្ថយការប្រើប្រាស់អគ្គិសនីនៅក្នុងក្រុមហ៊ុនអាជីវកម្ម និងសេវាកម្មតាមរយៈការដាក់បញ្ចូលនូវវិធានការប្រសិទ្ធភាពថាមពល (ភាគរយនៃការកាត់បន្ថយធៀបនឹងទិន្នន័យមូលដ្ឋានស្តីពីការប្រើប្រាស់បច្ចុប្បន្ន)
- កាត់បន្ថយការប្រើប្រាស់អគ្គិសនីនៅក្នុងគ្រួសារ តាមរយៈការនាំមកនូវវិធានការប្រសិទ្ធភាពថាមពល (ភាគរយនៃការកាត់បន្ថយធៀបនឹងទិន្នន័យមូលដ្ឋានស្តីពីការប្រើប្រាស់បច្ចុប្បន្ន)
- អគាររដ្ឋបាលក្រុង និងរដ្ឋបាលផ្សេងទៀតដែលមានដំបូលសមស្របត្រូវបំពាក់ ផ្ទាំងកញ្ចក់ស្រូបថាមពលព្រះអាទិត្យ (ចំនួនអគាររដ្ឋបាលដែលបានរៀបចំ និងបំពាក់ផ្ទាំងកញ្ចក់ស្រូបថាមពលព្រះអាទិត្យ ធៀបនឹងចំនួនអគាររដ្ឋបាលសរុប)

## ឃ. គោលបំណងនៅក្នុងវិស័យ "ដឹកជញ្ជូន"

- កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់នៅក្នុងវិស័យដឹកជញ្ជូន (ភាគរយនៃការកាត់បន្ថយលើទិន្នន័យមូលដ្ឋានបច្ចុប្បន្ន)
- ប្រព័ន្ធមធ្យោបាយដឹកជញ្ជូនសាធារណៈរថយន្តក្រុងត្រូវបានបង្កើតឡើងដោយគ្របដណ្តប់លើច្រកដឹកជញ្ជូនសំខាន់ៗនៅក្នុងទីក្រុង (ភាគរយនៃច្រកសរុប)
- កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ (ភាគរយនៃការកាត់បន្ថយធៀបនឹងទិន្នន័យមូលដ្ឋានប្រចាំឆ្នាំបច្ចុប្បន្ន)
- កាត់បន្ថយការកកស្ទះចរាចរណ៍តាមដងផ្លូវ (កំណើនល្បឿនយានយន្តជាមធ្យមធៀបនឹងទិន្នន័យមូលដ្ឋានបច្ចុប្បន្ន)

## ង. គោលបំណងនៅក្នុងវិស័យ "បរិស្ថានសំណង់ (សំណង់អគារ)"

- អនុម័តបទដ្ឋានសាងសង់បៃតងសម្រាប់អគារដែលត្រូវសាងសង់ចាប់ពីឆ្នាំ២០២០ តទៅ (ចំនួនគម្រោងសាងសង់បៃតងធៀបនឹងចំនួនលិខិតអនុញ្ញាតសាងសង់ដែលត្រូវបានស្នើសុំ)
- កាត់បន្ថយការប្រើប្រាស់ថាមពលនៅក្នុងអគារបច្ចុប្បន្ន (ភាគរយនៃការកាត់បន្ថយធៀបនឹងទិន្នន័យមូលដ្ឋានបច្ចុប្បន្ន)
- លំនៅដ្ឋានសម្រាប់គ្រួសារមានចំណូលទាបត្រូវបានបង្កើតឡើង ឬបំពាក់បរិក្ខារឡើងវិញដើម្បីឱ្យធន់នឹងគ្រោះធម្មជាតិ (ចំនួនលំនៅដ្ឋានដែលត្រូវបានធ្វើឱ្យប្រសើរឡើងធន់នឹងគ្រោះធម្មជាតិ ធៀបនឹងបរិមាណលំនៅដ្ឋាននៅទីក្រុងសរុប)

## ច. គោលបំណងក្នុងវិស័យ "កម្មន្តសាល"

- បង្កើតតំបន់ឧស្សាហកម្មដែលមានហេដ្ឋារចនាសម្ព័ន្ធគាំទ្របៃតង (ចំនួនតំបន់ឧស្សាហកម្មដែលត្រូវបានរៀបចំ និងបំពាក់បរិក្ខារដែលគាំទ្របៃតង)
- កាត់បន្ថយការបំពុលទឹកនៅក្នុងវិស័យកម្មន្តសាល (ភាគរយនៃបរិមាណទឹកកខ្វក់សរុបដែលត្រូវបានធ្វើប្រព្រឹត្តកម្ម)
- បង្កើនប្រសិទ្ធភាពថាមពលនៅក្នុងឧស្សាហកម្មកម្មន្តសាល (ការកាត់បន្ថយចំនួនគីឡូវ៉ាត់ដែលត្រូវបានប្រើប្រាស់ក្នុងមួយតម្លៃនៃធាតុចេញ)
- ធ្វើសវនកម្មប្រសិទ្ធភាពថាមពល និងបង្កើតផែនការគ្រប់គ្រងទៅលើប្រសិទ្ធភាពថាមពលសម្រាប់រោងចក្រកម្មន្តសាលធំៗ (ចំនួនសវនកម្ម និងផែនការគ្រប់គ្រងធៀបនឹងចំនួនសរុបនៃរោងចក្រធំៗ)
- ក្រុមហ៊ុនកម្មន្តសាលធំៗបានអនុវត្តសវនកម្មលើការប្រើប្រាស់ទឹក និងបានបង្កើតផែនការគ្រប់គ្រងការប្រើប្រាស់ទឹក (ចំនួនសវនកម្ម និងផែនការគ្រប់គ្រងធៀបនឹងចំនួនសរុបនៃរោងចក្រធំៗ)

## ឆ. គោលបំណងនៅក្នុងវិស័យ "គ្រប់គ្រងសំណល់រឹង"

- ពង្រីកសេវាប្រមូល និងគ្រប់គ្រងសំណល់រឹងប្រកបដោយគុណភាព (ចំនួនខណ្ឌដែលត្រូវបានគ្របដណ្តប់)
- កាត់បន្ថយសំណល់សរីរាង្គដែលយកទៅចោលនៅកន្លែងចាក់សំរាម ឬកន្លែងដុតសំរាម (ភាគរយនៃសំណល់សរីរាង្គសរុប)
- ញែកសំណល់រឹងដើម្បីអាចធ្វើការកែច្នៃឡើងវិញនៅតាមផ្ទះប្រជាពលរដ្ឋ តាមទីផ្សារ និងតាមសហគ្រាសពាណិជ្ជកម្ម (ភាគរយនៃសំណល់ដែលត្រូវបានញែកធៀបនឹងចំនួនបរិមាណសរុប)
- អនុវត្តគោលការណ៍ 4R រួមមាន៖ កាត់បន្ថយ (reduce) ប្រើប្រាស់ឡើងវិញ (reuse) ជួសជុល (repair) កែច្នៃឡើងវិញ (recycle) (ភាគរយនៃការកាត់បន្ថយបរិមាណសំណល់ដែលត្រូវបានប្រមូល)

## ជ. គោលបំណងនៅក្នុងវិស័យ "ទីធ្លាសាធារណៈ និងបេតិកភណ្ឌវប្បធម៌"

- បង្កើនវិសាលភាពគម្របបៃតងទីក្រុង (ចំនួនដើមឈើក្នុងស្រុកដែលត្រូវបានដាំថ្មី)
- បង្កើនទីធ្លាសាធារណៈបៃតងនៅក្នុងទីក្រុង (ចំនួនផ្ទៃដីគិតជាហិកតាពីទិន្នន័យ មូលដ្ឋានបច្ចុប្បន្ន ៧០ ហត)
- បង្កើតផែនការយុទ្ធសាស្ត្រដើម្បីអភិរក្សបេតិកភណ្ឌវប្បធម៌ទីក្រុង (ចំនួនអគារប្រវត្តិសាស្ត្រដែលត្រូវបានធ្វើបញ្ជីសារពើភ័ណ្ឌ និងការពារ)
- កំណើនភ្ញៀវទេសចរជាលទ្ធផលនៃការកែលម្អការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ (ចំនួនសំបុត្រដែលត្រូវបានលក់នៅតាមតំបន់រមណីយដ្ឋានក្នុងទីក្រុងសំខាន់)

## ៤.២ ផែនការមេរៀបចំប្រព័ន្ធដឹកជញ្ជូនទីក្រុងនៅរាជធានីភ្នំពេញ ឆ្នាំ២០៣៥

សាលារាជធានីភ្នំពេញ ដោយមានជំនួយពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ក៏បានបង្កើតផែនការមេរៀបចំប្រព័ន្ធដឹកជញ្ជូនទីក្រុងនៅរាជធានីភ្នំពេញ ឆ្នាំ២០៣៥ ផងដែរ ដើម្បីដោះស្រាយបញ្ហាចរាចរណ៍ពេលបច្ចុប្បន្ន និងគាំទ្រដល់ចក្ខុវិស័យទីក្រុងឆ្នាំ២០៣៥ ដែលកំណត់នៅក្នុងផែនការមេស្តីពីការប្រើប្រាស់ដីធ្លីឆ្នាំ២០៣៥។ ផែនការមេរៀបចំប្រព័ន្ធដឹកជញ្ជូនទីក្រុងមានគោលដៅការពារ និងរៀបចំវិស័យដឹកជញ្ជូនតំបន់ទីក្រុងដែលអំណោយផលដល់ប្រជាជន បរិស្ថាន និងផ្តល់ភាពរស់រវើកដល់សកម្មភាពទីក្រុងនៅរាជធានីភ្នំពេញ។

បេសកកម្មនៃផែនការមេរៀបចំប្រព័ន្ធដឹកជញ្ជូនទីក្រុង ឆ្នាំ២០៣៥ មានពីរផ្នែក៖

១. ផ្លាស់ប្តូរពីប្រព័ន្ធដឹកជញ្ជូនក្នុងទីក្រុងដែលមានការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនឯកជនច្រើនលើសលុប ទៅជាប្រព័ន្ធដឹកជញ្ជូនសាធារណៈ និងឯកជនដែលមានតុល្យភាពគ្នា តាមរយៈការគ្រប់គ្រងជាប្រព័ន្ធទៅលើបណ្តាញផ្លូវថ្នល់ មធ្យោបាយដឹកជញ្ជូនសាធារណៈ និងការគ្រប់គ្រងចរាចរណ៍ដើម្បីកែលម្អការធ្វើដំណើររបស់ពលរដ្ឋ និង

២. សម្រេចសក្តានុពលអភិវឌ្ឍន៍របស់រាជធានីភ្នំពេញ។

ដើម្បីសម្រេចបេសកកម្មនេះ ផែនការមេមធ្យោបាយដឹកជញ្ជូនទីក្រុងឆ្នាំ២០៣៥ ស្នើឡើងនូវយុទ្ធសាស្ត្រចំនួនប្រាំ៖

- **យុទ្ធសាស្ត្រទី១៖** ការបង្កើតប្រព័ន្ធដឹកជញ្ជូនទីក្រុងដែលអំណោយផលដល់ប្រជាជន និងបរិស្ថាន ដែលនឹងធ្វើអោយប្រជាពលរដ្ឋមានលទ្ធភាពធ្វើដំណើរស្រួល
- **យុទ្ធសាស្ត្រទី២៖** ការបង្កើតក្របខណ្ឌរូបវន្តទីក្រុង និងការបង្កើតការតភ្ជាប់រលូនរវាងទីក្រុងធំៗនៅក្នុងអនុតំបន់មេគង្គ
- **យុទ្ធសាស្ត្រទី៣៖** ការប្រើប្រាស់អោយបានជាអតិបរមានូវទីធ្លាដែលមានស្រាប់សម្រាប់អភិវឌ្ឍន៍វិស័យដឹកជញ្ជូនបច្ចុប្បន្នក្នុងនោះ រួមមានតំបន់ក្រោមដី និងខ្ពង់រាបដែលមាននៅកណ្តាលទីក្រុង
- **យុទ្ធសាស្ត្រទី៤៖** ប្រសិទ្ធភាពនៃលំហូរចរាចរណ៍ដឹកជញ្ជូនទំនិញ
- **យុទ្ធសាស្ត្រទី៥៖** ការពិចារណាទៅលើបរិស្ថាន/សង្គម និងការរៀបចំស្ថាប័នគ្រប់គ្រងវិស័យដឹកជញ្ជូន គឺជាទស្សនទានមូលដ្ឋាននៃការធ្វើផែនការមេនេះ។

## តារាងទី២៖ ផែនការមេមធ្យោបាយដឹកជញ្ជូនទីក្រុងឆ្នាំ២០៣៥ ដែលស្នើឡើង

<table>
<tr><td rowspan="5">(១)<br>ប្រព័ន្ធដឹកជញ្ជូនសាធារណៈ</td><td>(១) ការកើនឡើងនូវមធ្យោបាយដឹកជញ្ជូនដើម្បីកែលម្អការធ្វើដំណើរនៅក្នុងទីក្រុង</td></tr>
<tr><td>(២) ការនាំមកនូវប្រព័ន្ធមធ្យោបាយដឹកជញ្ជូនសាធារណៈ តាមផ្លូវទឹក មានដូចជាទូក កាណូតដឹកអ្នកដំណើរ</td></tr>
<tr><td>(៣) សមាហរណកម្មទូលំទូលាយនៃមធ្យោបាយដឹកជញ្ជូនសាធារណៈ និងប្រតិវិធានការពាក់ព័ន្ធ ដូចជាការផ្ទេរលួនរវាងមធ្យោបាយដឹកជញ្ជូនដោយអភិវឌ្ឍតំបន់ផ្ទេរអ្នកដំណើរ និងការរៀបចំរចនាសម្ព័ន្ធឡើងវិញនូវការធ្វើដំណើររួមគ្នា ជាផ្លូវតភ្ជាប់នៃមធ្យោបាយដឹកជញ្ជូនសាធារណៈ</td></tr>
<tr><td>(៤) សមាហរណកម្មជាមួយផែនការប្រើប្រាស់ដីធ្លី</td></tr>
<tr><td>(៥) ការចងភ្ជាប់ជាមួយការអភិវឌ្ឍវិស័យទេសចរណ៍</td></tr>
<tr><td rowspan="2">(២) ប្រព័ន្ធផ្លូវថ្នល់<br>(បណ្តាញផ្លូវថ្នល់)</td><td>(១) ប្រព័ន្ធបណ្តាញផ្លូវថ្នល់ក្រវ៉ាត់ក្រុង</td></tr>
<tr><td>(២) ផែនការអភិវឌ្ឍន៍ផ្លូវថ្នល់ដែលពង្រឹងរបៀងកើត-លិច (ផ្លូវសម្រាប់រថយន្តមានទូអ្នកដំណើរ កើត-លិចភាគខាងជើង និងភាគខាងត្បូង) និងជើង-ត្បូង (មហាវិថីហាណូយ និងមហាវិថីសម្តេច ហ៊ុន សែន)។</td></tr>
<tr><td rowspan="6">(៣)<br>វិធានការគ្រប់គ្រងចរាចរណ៍ - ដើម្បីគាំទ្រដល់ប្រព័ន្ធផ្លូវថ្នល់ និងដឹកជញ្ជូនសាធារណៈ</td><td>(១) វិធានការផ្សេងៗសម្រាប់ការបង្កើនភាពទាក់ទាញ និងផាសុខភាពនៃប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដូចជាតំបន់ផ្ទេរអ្នកដំណើរងាយស្រួល (ស្ថានីយអ្នកដំណើរ ស្ថានីយ និងចំណតរថយន្តក្រុង)</td></tr>
<tr><td>(២) វិធានការគ្រប់គ្រងចរាចរណ៍ផ្សេងៗ ដូចជាការកែលម្អផ្លូវបំបែក ការកែលម្អសញ្ញាចរាចរណ៍ និងការនាំមកនូវប្រព័ន្ធផ្លូវឯកទិស។</td></tr>
<tr><td>(៣) គោលនយោបាយ និងវិធានការស្តីពីចំណត</td></tr>
<tr><td>(៤) ការអភិវឌ្ឍបរិស្ថានសម្រាប់ថ្មើរជើង</td></tr>
<tr><td>(៥) ការរៀបចំរចនាសម្ព័ន្ធឡើងវិញនូវការធ្វើដំណើររួមគ្នា ដូចជា ម៉ូតូឌុប ម៉ូតូរ៉ឺម៉កទំនើប (ម៉ូតូកង់បី) និងស៊ីក្លូ។</td></tr>
<tr><td>(៦) ការនាំមកនូវការគ្រប់គ្រងតម្រូវការចរាចរណ៍ ដែលរួមបញ្ចូលទាំងការគ្រប់គ្រងការធ្វើដំណើរ ដូចជាការគ្រប់គ្រងតម្រូវការចរាចរណ៍នៃប្រព័ន្ធឧទ្យាន និងមធ្យោបាយធ្វើដំណើរ។</td></tr>
<tr><td rowspan="3">(៤)<br>ការដឹកជញ្ជូនទំនិញ</td><td>(១) ប្រព័ន្ធដឹកជញ្ជូនទំនិញឆ្លងកាត់តំបន់ (អន្តរតំបន់)</td></tr>
<tr><td>(២) ប្រព័ន្ធការងារដឹកជញ្ជូនទំនិញ (Logistics) ក្នុងទីប្រជុំជន</td></tr>
<tr><td>(៣) ប្រព័ន្ធដឹកជញ្ជូនទំនិញនៅក្នុងតំបន់កណ្តាលទីក្រុង</td></tr>
</table>

ផែនការមេទាំងពីរត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការរៀបចំបង្កើតផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ដែលមានគោលដៅគាំទ្រដល់ផែនការមេ និងដើម្បីលើកកម្ពស់ការអភិវឌ្ឍនិរន្តរភាពនៅរាជធានីភ្នំពេញ ដែលនឹងរួមចំណែកដល់ការសម្រេចឱ្យបាននូវចក្ខុវិស័យដែលបានគូសបញ្ជាក់នៅក្នុងផែនការមេ។

## ៤.៣ ក្របខណ្ឌគោលនយោបាយសម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាពនៅប្រទេសកម្ពុជា

គោលនយោបាយស្តីពីការអភិវឌ្ឍបៃតងរបស់ប្រទេសកម្ពុជា ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៅខែមីនា ឆ្នាំ២០១៣។ គោលនយោបាយនេះមានទស្សនៈវិស័យ *"រក្សាឱ្យបាននូវតុល្យភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចជាមួយនឹងបរិស្ថាន សង្គម វប្បធម៌ និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវធនធានជាតិតាមរយៈសមាហរណកម្ម ការបន្សាំ និងការសម្របសម្រួល ព្រមទាំងសុខដុមនីយកម្មរវាងគោលការណ៍អភិវឌ្ឍន៍បៃតង និងគោលនយោបាយជាតិ"*។[2] គោលនយោបាយនេះមានគោលដៅធ្វើឱ្យប្រសើរឡើងដល់សុខុមាលភាព និងមុខរបរចិញ្ចឹមជីវិតរបស់ប្រជាជនទាំងអស់ដោយធ្វើឱ្យមានសុខដុមនីយកម្មជាមួយប្រព័ន្ធអេកូឡូស៊ីតាមរយៈការអភិវឌ្ឍបៃតង ការផ្តេកលើសេដ្ឋកិច្ចបៃតង និងខៀវ កិច្ចការការពារបរិស្ថាន ប្រព័ន្ធសុវត្ថិភាពសង្គម និងរក្សាអត្តសញ្ញាណវប្បធម៌ជាតិ។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០ ក៏ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៅខែមីនា ឆ្នាំ២០១៣ផងដែរ។ ផែនការនេះផ្តោតសំខាន់លើសេចក្តីណែនាំយុទ្ធសាស្ត្រពាក់ព័ន្ធចំនួនប្រាំបួន[3] ៖

- ការវិនិយោគបៃតង និងការបង្កើតការងារបៃតង
- ការគ្រប់គ្រងសេដ្ឋកិច្ចបៃតងដែលមានតុល្យភាពជាមួយបរិស្ថាន
- ការអភិវឌ្ឍសេដ្ឋកិច្ចខៀវប្រកបដោយនិរន្តរភាព
- ការគ្រប់គ្រងបរិស្ថានបៃតង និងធនធានធម្មជាតិ
- ការអភិវឌ្ឍធនធានមនុស្ស និងការអប់រំបៃតង
- ការគ្រប់គ្រងបច្ចេកវិទ្យាបៃតងប្រកបដោយប្រសិទ្ធភាព
- ការលើកកម្ពស់ប្រព័ន្ធសុវត្ថិភាពសង្គមបៃតង
- ការរក្សា និងការការពារបេតិកភណ្ឌវប្បធម៌បៃតង និងអត្តសញ្ញាណជាតិ
- អភិបាលកិច្ចល្អនៃការអភិវឌ្ឍបៃតង

"ការអភិវឌ្ឍទីក្រុងនិរន្តរភាព" ត្រូវបានកំណត់ថាជាវិស័យអាទិភាពមួយសម្រាប់ការរៀបចំផែនការ និងអនុវត្តការអភិវឌ្ឍបៃតងដោយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.)។ ការអភិវឌ្ឍទីក្រុងនិរន្តរភាពមានគោលដៅផ្តល់វិធីសាស្ត្រពេញលេញ និងគ្រប់ជ្រុងជ្រោយនៃការរៀបចំក្រុង ការផ្តល់អាទិភាពដល់ការវិនិយោគ និងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងបរិបទទីក្រុង ហើយក្នុងពេលជំណាលគ្នានោះដោះស្រាយការប្រែប្រួលអាកាសធាតុ អនុវត្តនូវប្រសិទ្ធភាព ធនធាននិរន្តរភាពបរិស្ថាន សមាហរណកម្មក្នុងសង្គម និងការកាត់បន្ថយភាពក្រីក្រ។

## ៤.៤ ការវាយតម្លៃជាមូលដ្ឋាននៃស្ថានភាព/បរិបទទីក្រុងនៅរាជធានីភ្នំពេញ

ភ្នំពេញ គឺជារាជធានី និងជាទីក្រុងធំជាងគេបំផុតនៃប្រទេសកម្ពុជា និងមានទីតាំងស្ថិតនៅលើច្រាំងទន្លេសាប និងទន្លេមេគង្គ។ ភ្នំពេញ គឺជារាជធានីជាតិតាំងពីសម័យបារាំងដាក់អាណានិគមលើប្រទេសកម្ពុជា និងបានរីកចម្រើនក្លាយជាមជ្ឈមណ្ឌលកណ្តាលនៃសកម្មភាពជាតិផ្នែកសេដ្ឋកិច្ច និងឧស្សាហកម្ម ព្រមទាំងជាមជ្ឈមណ្ឌលនយោបាយ បេតិកភណ្ឌវប្បធម៌ និងការទូត។

**ទីតាំងភូមិសាស្ត្រ៖** រាជធានីភ្នំពេញមានផ្ទៃក្រឡា ៦៧៨,៤៦ គីឡូម៉ែត្រការ៉េ និងត្រូវបានបែងចែកជាតំបន់រដ្ឋបាលចំនួន ១២ ហៅថាខណ្ឌ។ ខណ្ឌត្រូវបានបែងចែកបន្តជា ១០៥ សង្កាត់។

**អភិបាលកិច្ច៖** នាពេលបច្ចុប្បន្ន រាជធានីភ្នំពេញត្រូវបានគ្រប់គ្រងដោយគណៈអភិបាល ដែលក្នុងនោះរួមមានអភិបាលមួយរូប និងអភិបាលរងប្រាំមួយរូប។ គណៈអភិបាលទទួលខុសត្រូវផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋដើម្បីបំពេញតាមតម្រូវការរបស់ពួកគេ និងស្តារហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទដើម្បីកែលម្អកម្រិតជីវភាពរបស់ប្រជាជននៅទីក្រុង[4] ។

---

[2] គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង បោះពុម្ព ឆ្នាំ ២០១៣ ដោយក្រសួងបរិស្ថាននៃរាជរដ្ឋាភិបាលកម្ពុជា

[3] ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ ២០១៣-២០៣០ បោះពុម្ព ឆ្នាំ ២០១៣ ដោយក្រសួងបរិស្ថាននៃរាជរដ្ឋាភិបាលកម្ពុជា

[4] គេហទំព័ររបស់សាលារាជធានីភ្នំពេញ http://phnompenh.gov.kh/en/about-us/governor-message/

**ប្រជាជន៖** ប្រជាជនរាជធានីភ្នំពេញបានកើនឡើងច្រើនជាងបីដងគឺចាប់ពីប្រមាណ ០,៥៧ លាននាក់នៅឆ្នាំ១៩៩៨ ដល់ប្រមាណ ១,៥ លាននាក់នៅឆ្នាំ២០១៥។[5] ការពង្រីកទីក្រុង និងការបង្កើតខណ្ឌបន្ថែមចំនួនបី គឺដើម្បីសម្របតាមកំណើនចំនួនប្រជាជន។ នៅក្នុងព្រំដែនរដ្ឋបាលថ្មីនៃរាជធានីភ្នំពេញ ប្រជាជនត្រូវបានប៉ាន់ស្មានថាអាចមានចំនួនកើនឡើងដល់ ២,៨៦លាននាក់នៅឆ្នាំ២០៣៥ បើយោងតាមការព្យាករណ៍កំណើនប្រជាជននៅក្នុងការសិក្សារបស់ JICA សម្រាប់រៀបចំផែនការមេប្រព័ន្ធដឹកជញ្ជូន។[6]

**សេដ្ឋកិច្ច៖** ភាគច្រើននៃកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជាប្រមូលផ្តុំនៅរាជធានីភ្នំពេញក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។ អត្រាកំណើនសេដ្ឋកិច្ចពីរខ្ទង់ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ បានបង្កើតនូវការរីកដុះដាលសេដ្ឋកិច្ចយ៉ាងរហ័សនៅរាជធានីភ្នំពេញ ជាពិសេសការវិនិយោគនៅក្នុងវិស័យ សំណង់រួមទាំងសណ្ឋាគារ ភោជនីយដ្ឋាន ក្លឹបកំសាន្ត អគារស្នាក់នៅ និងអាគារពាណិជ្ជកម្មខ្ពស់ៗ។ អត្រាកំណើនខ្ពស់នៃវិស័យឧស្សាហកម្មផ្នែកកម្មន្តសាល ក្នុងនោះវិស័យកាត់ដេររួមចំណែក ៧៥% នៃទិន្នផលសរុបនៃវិស័យកម្មន្តសាលរបស់ជាតិនៅឆ្នាំ២០១០។[7] ទីក្រុងទទួលបានការវិនិយោគបរទេសប្រមាណជា ៧៥% ទៅលើវិស័យឧស្សាហកម្ម និងការមកដល់របស់ភ្ញៀវទេសចរណ៍ប្រមាណជាមួយលាននាក់នៅឆ្នាំ២០១៥។[8] ការរីកលូតលាស់នៅក្នុងវិស័យសេវាកម្មត្រូវបានជំរុញដោយកំណើនពាណិជ្ជកម្ម និងសេវាកម្មផ្សេងទៀត ភាគច្រើននៅរាជធានីភ្នំពេញដែលរួមបញ្ចូលជាមួយវិស័យហិរញ្ញវត្ថុ កើនឡើងយ៉ាងឆាប់រហ័ស (ក្នុងអត្រា១៩,៤% ក្នុងឆ្នាំ២០១៨)។[9]

**កម្រិតភាពក្រីក្រ៖** អត្រាភាពក្រីក្រនៅរាជធានីភ្នំពេញមានកម្រិតទាបជាងតំបន់ផ្សេងទៀតក្នុងប្រទេស។ គ្រួសារនីមួយៗនៅរាជធានីភ្នំពេញមានចំណូលកើនឡើងជិតពីរដងនៃកម្រិតជាមធ្យមថ្នាក់ជាតិ។ ទិន្នន័យដែលមានស្តីពីវិសមភាពនៃប្រាក់ចំណូលបង្ហាញនូវការធ្លាក់ចុះបន្តិចនៃកម្រិតវិសមភាពនៃប្រាក់ចំណូលនៅរាជធានីភ្នំពេញចន្លោះពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៤។ ប៉ុន្តែទោះបីជាមានការធ្លាក់ចុះវិសមភាពក៏ដោយ អត្រាភាពក្រីក្រនៅរាជធានីភ្នំពេញបានកើនឡើងក្នុងអំឡុងឆ្នាំ២០០៨-២០១២ ដែលឆ្លុះបញ្ចាំងនូវការកើនឡើងនៃតម្លៃទំនិញ និងសេវាប្រើប្រាស់ជាមូលដ្ឋាន។ គ្រួសារនៅរាជធានីភ្នំពេញក៏បានជួបប្រទះអត្រាកំណើនប្រាក់ចំណូលយឺតដែលមានអត្រាកំណើនមធ្យមប្រចាំឆ្នាំរវាងចន្លោះឆ្នាំ២០០៩ និងឆ្នាំ២០១៤ ប្រហែល៦,៨% និងកំណើនសរុបប្រហែល ៤១%។[10]

**បញ្ហាប្រឈមនៃការអភិវឌ្ឍទីក្រុង និងការប្រែប្រួលអាកាសធាតុ៖** ដោយសារការរីកលូតលាស់យ៉ាងឆាប់រហ័សនៃវិស័យនគរូបនីយកម្ម រាជធានីភ្នំពេញកំពុងប្រឈមមុខនឹងបញ្ហាជាច្រើន រួមមានការសាងសង់សំណង់អគារដោយមិនមានការត្រួតពិនិត្យស្តង់ដារត្រឹមត្រូវ ការកកស្ទះចរាចរណ៍ ការគ្រប់គ្រងសំណល់ ការបំពុល និងការជន់លិច។ បញ្ហាប្រឈមទាំងនេះអាចមានសភាពកាន់តែធ្ងន់ធ្ងរបន្ថែមទៀតដោយការគំរាមកំហែងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ក្នុងចំណោមបណ្តាប្រទេសនៃទន្លេមេគង្គក្រោម ប្រទេសកម្ពុជារួមជាមួយនឹងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ត្រូវបានកំណត់ថាជាប្រទេសងាយរងគ្រោះបំផុតដោយសាររយៈកម្ពស់ទាបខ្លាំង និងនៅជិតមហាសមុទ្រ និងទន្លេមេគង្គ និងសមត្ថភាពនៅមានកម្រិតក្នុងការសម្របតាមហានិភ័យពីការប្រែប្រួលអាកាសធាតុ។[11] ទឹកជំនន់និងការប្រែប្រួលកម្រិតទឹកភ្លៀងក៏អាចមានផលប៉ះពាល់មិនល្អទៅលើបរិមាណ និងគុណភាពនៃការផ្គត់ផ្គង់ទឹកដល់ទីក្រុង និងបណ្តាលឱ្យមានផលអវិជ្ជមានដល់ប្រជាជនរាប់លាននាក់ផងដែរ។ ការគំរាមកំហែងផ្សេងៗទៀតរួមមានផលប៉ះពាល់នៃខ្យល់ព្យុះត្រូពិច ដែលបានកើនឡើងរួចហើយក្នុង រយៈពេលពីរបីទសវត្សរ៍ចុងក្រោយនេះ។ កម្រិតខ្យល់ព្យុះត្រូពិចត្រូវបានព្យាករថានឹងមានការកើនឡើងជាញឹកញាប់បន្តទៀត និងមានសន្ទុះ (អាំងតង់ស៊ីតេ) ខ្លាំងជាងមុន។ ការឡើងកម្ពស់ទឹកសមុទ្រ

---

[5] ព្រឹត្តិបត្រសាលារាជធានីភ្នំពេញលេខ៣៥ ខែកញ្ញា ឆ្នាំ២០១៧

[6] របាយការណ៍សិក្សារបស់ JICA ឆ្នាំ២០១៤ ស្តីពីការរៀបចំផែនការមេប្រព័ន្ធដឹកជញ្ជូនរាជធានីភ្នំពេញ

[7] របាយការណ៍របស់ធនាគារពិភពលោកស្តីពីបច្ចុប្បន្នភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា ឆ្នាំ២ ០១៥(a) តាមរយៈគេហទំព័រ៖ http://documents.worldbank.org/curated/en/2015/04/24427602/cambodia-economic-update-maintaining-high-growth

[8] របាយការណ៍ស្ថិតិវិស័យទេសចរណ៍ ឆ្នាំ ២០១៥ របស់ក្រសួងទេសចរណ៍ តាមរយៈគេហ៍ទំព័រ http://www.tourismcambodia.org/images/mot/statistic_reports/tourism_statistics_2015.pdf

[9] របាយការណ៍របស់ធនាគាជាតិនៃកម្ពុជា ឆ្នាំ២០១៨

[10] ការគណនាអត្រាភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជារួមបញ្ចូលបន្ទាត់ក្រីក្រផ្នែកស្បៀង ដោយគិត 2.200 កាឡូរីក្នុងម្នាក់ក្នុងមួយថ្ងៃ និងធាតុផ្សំមិនមែនស្បៀងដែលត្រូវបានប៉ាន់ស្មានដាច់ដោយឡែកពីគ្នាសម្រាប់រាជធានីភ្នំពេញ ព្រមទាំងតំបន់ទីក្រុង និងជនបទផ្សេងទៀត។ ទទួលបានតាមរយៈរបាយការណ៍វិភាគពីភាពក្រីក្រនៅប្រទេសកម្ពុជាដោយ ADB ឆ្នាំ ២០១៤ ពីគេហទំព័រ http://www.adb.org/documents/cambodia-country-poverty-analysis-2014. ទិន្នន័យភាពក្រីក្ររាជធានីភ្នំពេញ មិនអាចរកបាននៅឆ្នាំបន្តបន្ទាប់។

[11] របាយការណ៍ស្តីពីភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុនៅបណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ ដោយ Yusuf and Francisco ឆ្នាំ ២០០៩ https://www.idrc.ca/sites/default/files/sp/Documents%20EN/climate-change-vulnerability-mapping-sa.pdf

ក៏នឹងប៉ះពាល់ដល់ទឹកសាបរបស់រាជធានីភ្នំពេញផងដែរ ដោយបង្កើនការជន់លិចទឹកប្រៃនៅតំបន់ដែលមានរយៈកម្ពស់ទាប ហើយវារួមចំណែកធ្វើឱ្យសឹកច្រាំងសមុទ្រ។[12]

**បរិស្ថាន និងការបំពុលៈ** តាមរយៈទិន្នន័យតាមដានគុណភាពខ្យល់នក្នុងរយៈពេល ២៤ម៉ោង (real time air quality monitoring) នៅក្រសួងបរិស្ថានឃើញថាកម្រិតភាគល្អិតនិចល នៅក្នុងខ្យល់ជាមធ្យម ១០,២៤ ug/m ៣ ធៀបទៅនឹងកម្រិតស្តង់ដារ PM ២,៥ គឺ ៥០ ug/m ៣ ក្នុងរយៈពេល២៤ម៉ោងគិតចាប់ពីថ្ងៃទី ០៣ ដល់ ០៩ ខែមិថុនា ឆ្នាំ២០១៨ នេះ។[13] បើកម្រិតស្តង់ដានេះតំណាងឱ្យការវាស់គុណភាពខ្យល់នៅទូទាំងរាជធានី នេះបញ្ជាក់ថាគុណភាពខ្យល់នៅរាជធានីភ្នំពេញ មិនមានផលប៉ះពាល់អាក្រក់ដល់ការដកដង្ហើម និងសុខភាពរបស់ប្រជាពលរដ្ឋក្នុងរាជធានីទេ។ ទាក់ទងទៅនឹងបញ្ហាទឹកកខ្វក់ រាជធានីភ្នំពេញនៅមានកន្លែងមួយចំនួននៃប្រព័ន្ធទន្លេ និងបឹង នៅមានការបំពុលខ្លាំងដោយសារមិនមាននូវប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅឡើយ។ ទឹកសំណល់ចេញពីផ្ទះ និងអគារអាជីវកម្មកំពុងត្រូវបានបញ្ចេញចោលដោយមិនមានការធ្វើប្រព្រឹត្តកម្ម ហើយចុងក្រោយទឹកសំណល់ទឹកទាំងនោះនឹងត្រូវបញ្ចេញទៅក្នុងទន្លេ ឬប្រឡាយសាធារណៈ។

## ៤.៥ ការវិភាគវិស័យទីក្រុងសំខាន់ៗសម្រាប់ការអភិវឌ្ឍនិរន្តរភាពនៅក្នុងទីក្រុង

យោងតាមវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតងរបស់ប្រទេសកម្ពុជា មានវិស័យគន្លឹះចំនួនប្រាំបីដែលមានសារៈសំខាន់នៃការអភិវឌ្ឍនិរន្តរភាពនៅក្នុងទីក្រុង (រូបភាពទី២)[14] ។ ការប្រើប្រាស់វិធីសាស្ត្រនេះ គឺដើម្បីកំណត់ពីបញ្ហាប្រឈម និងឱកាសនៃការអភិវឌ្ឍនិរន្តរភាពនៅក្នុងបរិបទ នៃការប្រែប្រួលអាកាសធាតុ ប្រសិទ្ធភាពធនធាន និរន្តរភាពបរិស្ថាន កំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងបរិយាប័ន្នសង្គម។ ជាលទ្ធផលនៃការវិភាគ និងវាយតម្លៃបានឱ្យឃើញថា រាជធានីភ្នំពេញកំពុងមានបញ្ហាប្រឈមនៅក្នុងវិស័យទាំងប្រាំបីដូចខាងក្រោមៈ

- ការកើនឡើងនូវការចំណាយលើហេដ្ឋារចនាសម្ព័ន្ធ និងកង្វះលទ្ធភាពទទួលបានសេវាជា
- មូលដ្ឋានជាពិសេសសម្រាប់គ្រួសារដែលមានប្រាក់ចំណូលទាប
- ការរីកលូតលាស់នៃវិស័យនគរូបនីយកម្មឆាប់រហ័ស ប៉ុន្តែការរៀបចំផែនការនៅមានកម្រិត
- ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនមានកម្រិត និងការកើនឡើងនូវការកកស្ទះចរាចរណ៍
- ការចំណាយខ្ពស់លើថាមពល ចំណែកឯការប្រើប្រាស់ថាមពលកកើតឡើងវិញ និង បច្ចេកវិទ្យាបៃតងដែលមានប្រសិទ្ធភាពថាមពល នៅមានកម្រិត
- ការកើនឡើងសម្ពាធកាន់តែខ្លាំងទៅលើប្រព័ន្ធអេកូឡូស៊ីក្នុងទីក្រុង រួមបញ្ចូលទាំងលំហបៃតង បឹងធម្មជាតិ និងតំបន់ដីសើម
- ការកើនឡើងនូវភាពងាយរងគ្រោះទីក្រុងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ក្នុងនោះរួមបញ្ចូលទាំងបញ្ហាទឹកជំនន់ និងគ្រោះរាំងស្ងួតធ្ងន់ធ្ងរ
- ការកើនឡើងនូវអត្រាភាពក្រីក្រនៅក្នុងទីក្រុង បើទោះជាមានការថយចុះនូវអត្រាភាពក្រីក្រទូទាំងប្រទេសក៏ដោយ
- លទ្ធភាពទទួលបានប្រកបដោយសមធម៌នូវលំនៅដ្ឋានដែលមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ គឺនៅមានកម្រិតជាពិសេសសម្រាប់គ្រួសារក្រីក្រ
- កំណើនកម្រិតសារធាតុបំពុលបរិយាកាសពីឧស្សាហូបនីយកម្ម ជាពិសេសពីវិស័យកម្មន្តសាល
- បញ្ហាប្រឈមរបស់ទីក្រុងក្នុងការការពារសម្បត្តិបេតិកភណ្ឌវប្បធម៌ដែលបម្រើដល់វិស័យ ទេសចរណ៍ មានដូចជា អាគារបេតិកភណ្ឌជាដើម។

[12] ប្រភពព័ត៌មានដូចក្នុងចំណុចទី ១១

[13] គម្រោងស្តីពីការតាមដានគុណភាពខ្យល់នៅកម្ពុជា ឆ្នាំ ២០១៦ តាមរយៈ http://aqicn.org/country/cambodia និង តាមរយៈសេចក្តីជូនដំណឹងអំពីស្ថានភាពគុណភាពខ្យល់នៅក្នុងរាជធានីភ្នំពេញ http://www.moe.gov.kh/index/6143

[14] វិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង ត្រូវបានអនុម័តផ្លូវការនៅឆ្នាំ២០១៦ ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.)

រូបភាពទី២៖ វិស័យអាទិភាពទាំង ៨ សម្រាប់ការអភិវឌ្ឍន៍បៃតងក្នុងទីក្រុង




### ៤.៥.១ ការរៀបចំផែនការអភិវឌ្ឍន៍ទីក្រុង

នៅខែធ្នូ ឆ្នាំ២០១៥ គណៈរដ្ឋមន្ត្រីបានអនុម័តលើផែនការមេ (ប្លង់គោល) ប្រើប្រាស់ដីរាជធានីភ្នំពេញ ឆ្នាំ២០៣៥ ដែលបានកែសម្រួល ហើយមានចក្ខុវិស័យ "ប្រែក្លាយរាជធានីភ្នំពេញឱ្យក្លាយជាបេះដូងនៃប្រទេសកម្ពុជា ដែលស្ថិតនៅចំណុចប្រសព្វនៃទន្លេចំនួនបួន ជាមជ្ឈមណ្ឌលប្រកួតប្រជែងផ្នែកនយោបាយ ជំនួញ និងវប្បធម៌ដោយមានការអភិវឌ្ឍប្រកបដោយសមធម៌ និងមានចីរភាពនៅត្រឹមឆ្នាំ២០៣៥"។

ផែនការមេប្រើប្រាស់ដីរាជធានីភ្នំពេញ ឆ្នាំ២០៣៥ បង្ហាញពីមហិច្ឆតានៃការចង់មើលឃើញតំបន់រាជធានីរីកចម្រើនលូតលាស់ ដែលអាចឆ្លើយតបការកើនឡើងចំនួនប្រជាជនបច្ចុប្បន្នដែលតិចជាង២លាននាក់ ទៅជាង៦លាននាក់ នៅឆ្នាំ២០៣៥ ដោយសារចំណាកស្រុកពីជនបទមកទីក្រុងនិងឆ្ពោះមកកាន់តំបន់រាជធានី។ ប្រការនេះបង្ហាញនូវតម្រូវការ និងជម្រើសជាផែនការយុទ្ធសាស្ត្រគ្រប់គ្រងទីក្រុង ក្នុងនោះមានចាប់ពីការរៀបចំតំបន់ក្រុងដែលរួមបញ្ចូលគ្នារវាងតំបន់នៃខេត្តកណ្ដាល និងរាជធានីភ្នំពេញ រហូតដល់ការពង្រីកព្រំដែនទីក្រុងរួមជាមួយ នឹងការកាត់បញ្ចូលខេត្តកណ្ដាលជិតពាក់កណ្ដាល។ ក្រសួងមហាផ្ទៃនឹងសម្របសម្រួលដំណើរការរៀបចំផែនការចម្រុះនៃការកាត់បញ្ចូលខេត្តនេះ ហើយនឹងត្រូវធ្វើបច្ចុប្បន្នភាពព្រំដែនរដ្ឋបាលរាជធានីភ្នំពេញ។

### រូបភាពទី៣៖ ផែនទីរដ្ឋបាលរាជធានីភ្នំពេញ (ប្រភព៖ ផែនការមេសាលារាជធានីភ្នំពេញ)




ផែនការមេប្រើប្រាស់ដីរាជធានីភ្នំពេញ ឆ្នាំ២០៣៥ ក៏មានបញ្ជីគម្រោងអាទិភាពដែលនឹងត្រូវអនុវត្តនៅក្នុងរាជធានី ព្រមទាំងបទប្បញ្ញត្តិនានាទាក់ទងទៅនឹងការរស់នៅក្នុងទីក្រុងដែលនឹងត្រូវបង្កើត ឡើងក្នុងរយៈពេលដ៏ខ្លីខាងមុខ ដែលរួមមាន៖

- ផែនទីប្រើប្រាស់ដីធ្លី និងការបែងចែកតំបន់ប្រើប្រាស់ដីធ្លី
- ការរៀបចំក្រុងសម្រាប់ការអភិវឌ្ឍនៅភាគខាងជើង និងភាគខាងលិចរាជធានីភ្នំពេញ
- ការរៀបចំក្រុងសម្រាប់ការអភិវឌ្ឍនៅភាគខាងត្បូងទីក្រុង និងសម្រាប់ផែនការរៀបចំអាងប្រព្រឹត្តកម្មទឹកកខ្វក់នៅបឹងជើងឯក
- ការរៀបចំផែនការទីធ្លាសាធារណៈ (បឹង ព្រៃ ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ព្រលានយន្តហោះ និងតំបន់បៃតង)
- ផែនទីតំបន់អភិវឌ្ឍន៍ពិសេស/ដែលត្រូវបានផ្តល់អាទិភាព
- ផែនទីសម្រាប់ការកំណត់ និងបង្ហាញពីអគារដែលមានកម្ពស់ខ្ពស់ និងការធ្វើសវនកម្មកម្ពស់របស់អគារនានាសម្រាប់សុវត្ថិភាពការហោះហើររបស់យន្តហោះ
- ផែនទីសម្រាប់អគារបេតិកភណ្ឌក្នុងទីក្រុង
- ផែនទីកំណត់តំបន់ និងបទប្បញ្ញត្តិនានាសម្រាប់អនុវត្តផែនការមេ ដើម្បីអភិរក្ស ឬការពារតំបន់ក្នុងទីក្រុងសម្រាប់ការដាំដើមឈើ ការគ្រប់គ្រងទីធ្លា និងទ្រព្យសម្បត្តិសាធារណៈ។

## គោលនយោបាយ និងក្របខណ្ឌបទប្បញ្ញត្តិ

ការរៀបចំផែនការមេគឺជាលក្ខខណ្ឌតម្រូវនៃច្បាប់*នគរូបនីយកម្មរបស់កម្ពុជា (១៩៩៤)* ។បច្ចុប្បន្នក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់កំពុងធ្វើបច្ចុប្បន្នភាពច្បាប់នគរូបនីយកម្មតាមរយៈសេចក្ដីព្រាងច្បាប់របស់ខ្លួនស្ដីពី*ការរៀបចំដែនដី និងនគរូបនីយកម្ម (២០១៣) បានគាំទ្រយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍ទីប្រជុំជន* (កំពុងរៀបចំ) ដែលក្របខណ្ឌជាតិនេះត្រូវបានបង្កើតនៅក្នុងឆ្នាំ២០១៥-២០១៦។ បទប្បញ្ញត្តិក្រុងរបស់ប្រទេសកម្ពុជាត្រូវបានពង្រឹងតាមរយៈអនុក្រឹត្យលេខ ៤២ ស្ដីពី នគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន (២០១៥) ដែលកំណត់ទំហំតំបន់ និងអនុតំបន់ សម្រាប់ការអភិវឌ្ឍនៅនឹងកន្លែង និងគម្រោងសំណង់ប្រភេទខុសៗគ្នា (លំនៅដ្ឋាន ពាណិជ្ជកម្ម ឬឧស្សាហកម្ម)។ កម្ពស់សំណង់ក៏ត្រូវបានបញ្ជាក់ រួមជាមួយនឹងលក្ខខណ្ឌចំណតនៅនឹងកន្លែងផងដែរ។ ដោយសារអនុក្រឹត្យលេខ៤២ មិនបានបញ្ជាក់អំពីបញ្ហាកំណត់តំបន់ ឬការប្រើប្រាស់ដី អនុក្រឹត្យនេះពង្រឹងនូវបទប្បញ្ញត្តិសម្រាប់សកម្មភាពសាងសង់នាពេលអនាគត។ គោលនយោបាយដីធ្លីរបស់ប្រទេសកម្ពុជា (២០០៩) ក៏ចែងផងដែរអំពីក្របខណ្ឌជាតិសម្រាប់រដ្ឋបាល និងការគ្រប់គ្រងដីក្នុងប្រទេសកម្ពុជា ដែលគាំទ្រដោយ *គោលនយោបាយជាតិស្ដីពីការរៀបចំផែនការតំបន់ (២០១១) និងសៀវភៅណែនាំស្ដីពីការរៀបចំតំបន់ (២០១៣)*។ ក្រៅពីនេះ យោងតាមច្បាប់ស្ដីពី*ការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិចែងអំពីការរៀបចំផែនការ ការផ្ដល់ហិរញ្ញប្បទាន និងការគ្រប់គ្រងកាន់តែប្រសើរនូវសេវានៅកម្រិតរដ្ឋាភិបាលថ្នាក់ក្រោមជាតិ។*

## បញ្ហាប្រឈមសំខាន់ៗ

*នៅមុនការអនុម័តផែនការមេប្រើប្រាស់ដីធ្លីរាជធានីភ្នំពេញ ឆ្នាំ២០៣៥* ទីក្រុងភ្នំពេញមាន គម្រោងកម្មវិធីអភិវឌ្ឍន៍ពីវិស័យឯកជនជាច្រើន ប៉ុន្តែមានបទប្បញ្ញត្តិតិចតួចចែងអំពីការការពាររចនាសម្ព័ន្ធទីក្រុង ការបែងចែកតំបន់បេតិកភ័ណ្ឌ តំបន់ធនធានធម្មជាតិ និងតំបន់សម្រាប់ប្រជាជនក្រីក្រ។ គេបានធ្វើការប៉ាន់ស្មានថា ចាប់តាំងពីឆ្នាំ១៩៩៩ មក ប្រជាជនប្រហែល១៥០.០០០នាក់បានត្រូវបានផ្លាស់ទីលំនៅពីទីតាំងកណ្ដាលនៅក្នុងរាជធានីភ្នំពេញដើម្បីសម្របតាមការអភិវឌ្ឍទីក្រុង។[15] ការបន្តការអភិវឌ្ឍជាឯកជននៅតែជាហានិភ័យ សម្រាប់ប្រជាជនក្រីក្រក្នុងទីក្រុងដដែល។

ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះទីក្រុងភ្នំពេញមានការរីកចម្រើនយ៉ាងឆាប់រហ័សនូវសំណង់អគារថ្មីៗ អគារខុនដូខ្ពស់ៗ ផ្សារទំនើប កាស៊ីណូ សហគមន៍ និងភូមិគ្រឹះទំនើបស្ដឹមស្ដែសម្រាប់គ្រួសារដែលមានប្រាក់ចំណូលខ្ពស់។ គម្រោងអភិវឌ្ឍន៍ទីក្រុងរណបចំនួនប្រាំពីរត្រូវបានគ្រោងបញ្ចប់នៅក្នុងរយៈពេល១០ ទៅ ១៥ឆ្នាំ បន្ទាប់ដែលនឹងគ្របដណ្ដប់លើផ្ទៃដីចំនួន ៨០០០ហិចតា ឬស្មើ ១២% នៃផ្ទៃដីសរុបរបស់ទីក្រុង។ ការសាងសង់សំណងដោយមិនអនុទ្បោមតាមច្បាប់សាងសង់អាចមានផលប៉ះពាល់អវិជ្ជមានដល់ការបំពេញមុខងាររបស់ទីក្រុងទាំងមូល។ កង្វះការគ្រប់គ្រងទៅលើការវិនិយោគឯកជនអាចធ្វើឱ្យមានការរាំងស្ទះដល់ការអនុវត្តផែនការមេប្រើប្រាស់ដីធ្លីឆ្នាំ២០៣៥។

[15] សៀវភៅសរសេរដោយ Sebatian Strangio នៅឆ្នាំ២០១៤ ស្ដីពីនាយករដ្ឋមន្ត្រីហ៊ុនសែន និងប្រទេសកម្ពុជា

រូបភាពនៃរាជធានីភ្នំពេញកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័សដោយសារការរីកដុះដាលនៃវិស័យ សំណង់ អគារ និងការវិនិយោគឯកជនដ៏ច្រើន ។




### ៤.៥.២ ភាពងាយរងគ្រោះរបស់ទីក្រុង

រាជធានីភ្នំពេញ មានភាពងាយរងគ្រោះខ្លាំងចំពោះការជន់លិចដោយសារស្ថិតនៅក្នុងតំបន់ទំនាបដីល្បាប់ទន្លេមេគង្គ។ ប្រព័ន្ធលូរំដោះទឹកជំនន់មានភាពស្មុគស្មាញដោយសាររាជធានីភ្នំពេញមានសណ្ឋានទាបកណ្តាល។ ពេលខ្លះកម្រិតទឹកនៅរដូវវស្សាអាចឡើងដល់ជាង១០ម៉ែត្រ ដែលអាចបណ្តាលឱ្យមានការជន់លិចនៅផ្នែកជាច្រើននៃទីក្រុង។ ការសិក្សាមួយបានបង្ហាញថា ៣០% នៃតំបន់ក្រុងមានកម្ពស់ទាបជាង ៨ ម៉ែត្រ ៤៥% នៃតំបន់ក្រុង ទាបជាង ៩ ម៉ែត្រ និង ៦០%នៃតំបន់ក្រុង ទាបជាង ១០ម៉ែត្រ កម្រិតទឹកទន្លេ។[16] ការជន់លិចអាចបង្កឡើងដោយសារភ្លៀងមូសុងដែលអូសបន្លាយរយៈពេលយូរ ហេតុការណ៍ខ្យល់ព្យុះបោកបក់ញឹកញាប់ កម្រិតទឹកឡើងខ្ពស់តាមរដូវនៅទន្លេសាប និងទន្លេមេគង្គ ឬដោយសារហេតុការណ៍ផ្សេងទៀតបណ្តាលមកពីអាកាសធាតុប្រែប្រួល។ ផលប៉ះពាល់កាន់តែខ្លាំង និងធ្ងន់ធ្ងរពីការជន់លិចដោយសារការអភិវឌ្ឍវិស័យអចលនទ្រព្យដែលគ្មានការត្រួតពិនិត្យលើហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធលូ និងប្រព្រឹត្តកម្មទឹកកខ្វក់មិនគ្រប់គ្រាន់។

រាជធានីភ្នំពេញកំពុងកែលម្អហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធលូមេ ដោយសហការជាដៃគូជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)។ ប្រព័ន្ធបណ្តាញលូរឹងមាំដែលត្រូវបានសាងសង់នៅតំបន់កណ្តាលរាជធានីអាចការពារអគារបានមួយចំនួន ប៉ុន្តែតំបន់ជុំវិញទីក្រុង និងជាយក្រុងនៅតែប្រឈមហានិភ័យខ្លាំងដដែលចំពោះការជន់លិច។ ចាប់តាំងពីឆ្នាំ១៩៩៨មក ជំនួយឥតសំណងជាទឹកប្រាក់របស់ JICA បានជួយកាត់បន្ថយទឹកជំនន់នៅផ្នែកកណ្តាលទីក្រុងតាមរយៈការអនុវត្តគម្រោងបន្តបន្ទាប់ជាច្រើន។ ដំណាក់កាលទី១ និងទី២ បានទទួលជោគជ័យនៅក្នុងការកាត់បន្ថយការខូចខាតពីទឹកជំនន់នៅប៉ែកនិរតី ប៉ែកអាគ្នេយ៍ និងប៉ែកឥសាន្តរាជធានីភ្នំពេញ។ គម្រោងកម្ចីរបស់ ADB ចន្លោះឆ្នាំ២០០០ ដល់ឆ្នាំ ២០០៣ ក៏បានគាំទ្រដល់បណ្តាញលូការពារទឹកជំនន់ផងដែរ។

[16] របាយការណ៍វឌ្ឍនភាពពីការសិក្សាគម្រោងធ្វើអោយប្រសើរឡើងនៃប្រព័ន្ធលូទឹកកខ្វក់ និងទឹកភ្លៀងក្នុងតំបន់ទីប្រជុំជនរាជធានីភ្នំពេញ របស់ JICA បោះពុម្ភខែវិច្ឆិកា ឆ្នាំ ២០១៥ ។

ផែនការមេដឹកជញ្ជូនទីក្រុង ឆ្នាំ២០៣៥ ផ្អែកលើផែនការមេដឹកជញ្ជូនទីក្រុងដំបូង ឆ្នាំ២០១៥ នៅរាជធានីភ្នំពេញ ដែលត្រូវបានបង្កើតនៅឆ្នាំ២០០១ ដោយមានជំនួយពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន។ ផែនការមេឆ្នាំ ២០០១ ត្រូវបានអនុវត្តមួយផ្នែក ដែលនាំឱ្យមានការដំឡើងសញ្ញាចរាចរណ៍នៅផ្លូវបំបែកសំខាន់ៗ។ ការដំឡើងនេះបានជួយសម្រួលបញ្ហាចរាចរណ៍បានមួយកម្រិត ប៉ុន្តែកង្វះមធ្យោបាយដឹកជញ្ជូនសាធារណៈមិនត្រូវបានដោះស្រាយនៅឡើយ។ ផែនការមេដឹកជញ្ជូនក្នុងទីក្រុង ឆ្នាំ២០៣៥ ព្យាយាមបង្កើនការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈអោយបានច្រើនជាង ៣០% នៃប្រភេទមធ្យោបាយដឹកជញ្ជូនសរុបនៅឆ្នាំ២០៣៥។ កិច្ចការនេះអាចសម្រេចបានដោយការបង្កើតនូវវិធានការមួយចំនួន ដូចជាការបង្កើត (ក្នុងចំណោមវិធានការផ្សេងទៀត) ផ្លូវរត់សម្រាប់តែរថយន្តក្រុងចំនួន១០ខ្សែ នៅឆ្នាំ២០២០ ដែលជាផ្នែកមួយនៃផែនការរៀបចំប្រព័ន្ធចរាចរណ៍រហ័សរបស់រថយន្តក្រុង (bus rapid transit scheme) និងប្រព័ន្ធផ្លូវរថភ្លើងដឹកជញ្ជូន សាធារណៈក្រោមដី (underground elevated rail transit system) នៅឆ្នាំ២០៣៥។

នៅកម្រិតថ្នាក់ជាតិ ការគ្រប់គ្រងចំណត និងចិញ្ចើមផ្លូវមានចែងនៅក្នុងច្បាប់ចរាចរណ៍ផ្លូវគោក (២០១៥) ច្បាប់ផ្លូវគោក (២០១៤) និងអនុក្រឹត្យ លេខ៨៤២ ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន (២០១៥)។ ក្រសួងសាធារណការ និងដឹកជញ្ជូនក៏បានបង្កើតផែនការសកម្មភាពស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់វិស័យដឹកជញ្ជូនផងដែរ (២០១៤-២០១៨) ដែលកំណត់នូវសកម្មភាពអាទិភាពជាច្រើនសម្រាប់ការដឹកជញ្ជូនបៃតង រួមទាំងតម្រូវការប្រព័ន្ធដឹកជញ្ជូនសារធាតុរួមបញ្ចូលនៅក្នុងទីក្រុងធំៗក៏ដូចជាការលើកកម្ពស់ការថែទាំ និងការត្រួតពិនិត្យយានយន្តផងដែរ។

## បញ្ហាប្រឈមសំខាន់ៗ

ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន មិនអាចតាមទាន់ការកើនឡើងយ៉ាងឆាប់រហ័សនូវបរិមាណចរាចរណ៍ឡើយ។ ដោយធៀបនឹងទីក្រុងផ្សេងទៀតនៅក្នុងតំបន់រាជធានីភ្នំពេញមានដង់ស៊ីតេផ្លូវថ្នល់ទាប ជាពិសេសនៅខាងក្រៅតំបន់កណ្តាលទីក្រុង (ខណ្ឌកណ្តាលក្រុងមានផ្លូវថ្នល់ ៩៤%)។ គម្រោងលំនៅដ្ឋានមួយចំនួនកំពុងត្រូវបានបន្តធ្វើនៅតំបន់ជាយក្រុង ដោយមិនបានធ្វើការពិចារណាដល់លទ្ធភាពប្រើប្រាស់បណ្តាញផ្លូវថ្នល់ និងការរីកសាយចរាចរណ៍។ ស្រដៀងគ្នានេះដែរ កង្វះខាតការធ្វើផែនការសម្រាប់យានយន្តធុនធ្ងន់ដែលបម្រើដល់រោងចក្រ និងដេប៉ូគ្រឿងសំណង់បាននាំឱ្យមានការចុះទ្រុឌទ្រោមផ្លូវថ្នល់នៅតំបន់មួយចំនួន។

មានបញ្ហាប្រឈមជាច្រើនដែលត្រូវបានកំណត់នៅក្នុងការគ្រប់គ្រងចរាចរណ៍នៅរាជធានីភ្នំពេញ ដូចជា៖ ផ្លូវបំបែកដែលចោទជាបញ្ហា ប្រព័ន្ធដាក់សញ្ញាធ្វើដំណើរមិនគ្រប់គ្រាន់ កង្វះការដាក់សញ្ញាសម្គាល់ផ្លូវថ្នល់ និងចំណតមិនមានការត្រួតពិនិត្យ។ កន្លែងចតមិនគ្រប់គ្រាន់នៅតំបន់កណ្តាលទីក្រុងកំពុងក្លាយជាបញ្ហាចោតខ្លាំងដែលនាំឱ្យអ្នកបើកបរចតនៅលើផ្លូវថ្នល់ ឬនៅលើចិញ្ចើមផ្លូវ ដែលធ្វើឱ្យរាំងស្ទះផ្លូវថ្មើរជើង។ លើសពីនេះទៀត ចិញ្ចើមផ្លូវសម្រាប់ថ្មើរជើងនៅរាជធានីភ្នំពេញត្រូវបានបាត់បង់មួយចំនួនដោយសារការពង្រីកផ្លូវសម្រាប់រថយន្ត។ ការអនុវត្តបទប្បញ្ញត្តិស្តីពីការចតយានយន្ត គឺជាបញ្ហាប្រឈមចម្បង។ ការដឹកជញ្ជូនទំនិញក៏កំពុងប្រឈមមុខនឹងបញ្ហា ដូចជាការខូចខាតផ្លូវថ្នល់ និងកង្វះលំហក្រៅផ្លូវសាធារណៈសម្រាប់ការរើទំនិញចុះ។

ប្រព័ន្ធបណ្ដាញដឹកជញ្ជូនកំពុងស្ថិតក្រោមសម្ពាធកាន់តែខ្លាំងនៅរាជធានីភ្នំពេញដែលមានផលប៉ះពាល់កើនឡើងសម្រាប់សេដ្ឋកិច្ច (រូបថតដោយ GGGI)។




## ៤.៥.៥ បរិស្ថានសំណង់

បរិស្ថានសំណង់នៅរាជធានីភ្នំពេញរួមមាន រចនាបទស្ថាបត្យកម្ម និងរចនាបទលំនៅដ្ឋានជាច្រើនប្រភេទ។ សំណង់អគារ និងវីឡាដែលមានរចនាបទសម័យអាណានិគមបារាំងគឺមានច្រើននៅពាសពេញទីក្រុងផងដែរ។ ពេលនេះ អគារទាំងនេះមួយចំនួនត្រូវបានស្ដារឡើងវិញ ប៉ុន្តែអគារជាច្រើនត្រូវបានបំផ្លាញ ឬមានភាពទ្រុឌទ្រោម។ បច្ចុប្បន្ន សំណង់ផ្ទះសម្បែងទូទៅ គឺរួមមានផ្ទះបើកអាជីវកម្មតាមរចនាបទចិន ឬវីឡាទោលនៅដាច់តែឯង។ ផ្ទះបើកអាជីវកម្មមានចំនួនច្រើនជាងគេបំផុត ព្រោះផ្ទះប្រភេទនេះមានតម្លៃធូរថ្លៃ និងអាចប្រើប្រាស់បានសម្រាប់បើកអាជីវកម្មផង និងជួលបន្តជាបន្ទប់តូចៗផង។

ថ្មីៗនេះ មានការវិនិយោគយ៉ាងច្រើនទៅលើប្រភេទអគារប្រណិតខ្ពស់ៗ (Apartments) មណ្ឌលកម្សាន្ត អគារពាណិជ្ជកម្ម និងទីក្រុងរណប។ ហេដ្ឋារចនាសម្ព័ន្ធសំណង់ប្រភេទទាំងនេះនឹងមានតម្រូវការប្រើប្រាស់ថាមពលច្រើនបើមិនមានវិធានការ ឬគោលការណ៍សន្សំសំចៃថាមពល និងប្រសិទ្ធភាពថាមពលត្រូវបានបញ្ចូលទៅក្នុងបែបបទ ឬបទដ្ឋាននៃការសាងសង់ និងប្រតិបត្តិការរបស់សំណង់អគារប្រភេទនេះទេ តម្រូវការថាមពលក្នុងវិស័យនេះនឹងបន្តកើនឡើងជាលំដាប់។ ឧទាហរណ៍គម្រោងសាងសង់ថ្មីៗនៅរាជធានីភ្នំពេញរួមមានសំណង់អគារនៅតំបន់កោះពេជ្រ អគារស្នាក់នៅ Bodaiju និងក្រុង Booyoung ជាដើម។ ការប្រែប្រួលអាកាសធាតុ ការកើនឡើងសីតុណ្ហភាព និងការជន់លិចដែលបានព្យាករណ៍ទុកមុននោះអាចកាត់បន្ថយភាពធន់របស់អគារក្នុងទីក្រុង។ ការខូចខាតផ្នែករចនាសម្ព័ន្ធអាចកើតឡើងដោយសារហេតុការណ៍នៃការជន់លិចធ្ងន់ធ្ងរ និងញឹកញាប់នៅពេលអនាគត។ បទដ្ឋានគតិយុត្តនៃសំណង់គេហដ្ឋានមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ អាចកាត់បន្ថយហានិភ័យដល់ប្រជាជនក្នុងរាជធានីភ្នំពេញ។ នេះគឺជាបញ្ហាប្រឈមដោយឡែកមួយសម្រាប់លំនៅដ្ឋាននៅតំបន់ជាយក្រុង ដែលគេហដ្ឋានសម្រាប់ស្នាក់នៅសមរម្យមានភាពខ្វះខាត។ គ្រួសារដែលត្រូវបានបណ្ដេញចេញជាញឹកញាប់ត្រូវសាងសង់ផ្ទះរបស់ខ្លួនពីសម្ភារដែលត្រូវបានកែច្នៃឡើងវិញ ដែលនេះកាន់តែមានភាពងាយរងគ្រោះខ្លាំងចំពោះហេតុការណ៍នៃការជន់លិចទីក្រុង។

## គោលនយោបាយ និងក្របខណ្ឌបទប្បញ្ញត្តិ

អនុក្រឹត្យលេខ៤៣ស្តីពីការរៀបចំរាជធានី ក្រុង និងតំបន់ទីក្រុង គ្របដណ្តប់ការប្រើប្រាស់ដីធ្លី នៅក្នុងដីឡូត៍សាងសង់ និងកំណត់ព្រំដែននៃកន្លែងដាក់សម្ភារសំណង់នៅក្នុងក្បាលដី ដើម្បីធានាថាមានកន្លែងទំនេរគ្រប់គ្រាន់សម្រាប់ដើមឈើ និងសួនច្បារ។ អត្ថប្រយោជន៍នៃអនុក្រឹត្យនេះ មានដូចតទៅ៖ បរិស្ថានសំណង់មានលក្ខណៈត្រជាក់ និងបរិយាកាសល្អ ទីធ្លាអាចបំពាក់ប្រព័ន្ធរំដោះទឹកភ្លៀងនៅនឹងទីតាំងផ្ទាល់ដែលអាចជួយកាត់បន្ថយការជន់លិច អគារលំនៅដ្ឋានត្រូវបានសាងសង់ជាប្លុកៗមានទីធ្លាទំនេរដោយបញ្ចៀសការរស់នៅកកកុញ ពោលគឺបង្កើតទីធ្លាទំនេរអោយច្រើនដើម្បីបង្កើតជាច្រករបៀងខ្យល់ចេញចូលធម្មជាតិ។

បច្ចុប្បន្ន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កំពុងកែសម្រួលច្បាប់សំណង់ដើម្បីដាក់បញ្ចូលក្ខខណ្ឌស្តីពីសុខភាព និងសុវត្ថិភាព។[52] រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថា កង្វះលំនៅដ្ឋានមានតម្លៃសមរម្យ គឺជាបញ្ហានៃការអភិវឌ្ឍវិស័យនគរូបនីយកម្ម ហើយបានអនុម័តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍលំនៅដ្ឋានតម្លៃសមរម្យ (ឆ្នាំ២០១៧)។ គោលដៅនៃគោលនយោបាយនេះគឺដើម្បីផ្តល់ដល់គ្រួសារដែលមានប្រាក់ចំណូលទាប និងមធ្យម និងក្រុមងាយរងគ្រោះនូវលទ្ធភាពទទួលបានលំនៅដ្ឋានសមរម្យ ឬការកែលម្អលំនៅដ្ឋានបច្ចុប្បន្ន។ គោលនយោបាយនេះមានលក្ខណៈបរិយាប័ន្ន និងអំពាវនាវឱ្យមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល អង្គការមនុស្សធម៌ វិស័យឯកជន និងអាជ្ញាធរថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិផងដែរ។ [53 & 54]

ថ្មីៗនេះក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) ក៏បានប្រឹងប្រែងដោះស្រាយ និងបំពេញតម្រូវការរបស់គ្រួសារងាយរងគ្រោះក្នុងទីក្រុង តាមរយៈផែនការសកម្មភាពស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៥-២០១៨ របស់ខ្លួនផងដែរ។ ផែនការសកម្មភាពនេះ បានជំរុញឱ្យមានទីជម្រកសមរម្យសម្រាប់គ្រួសារដែលមានប្រាក់ចំណូលទាប និងងាយរងគ្រោះ ព្រមទាំងកំណត់ចក្ខុវិស័យថា ការរៀបចំអគារបៃតង និងបច្ចេកទេសកាបូនទាបត្រូវតែកំណត់នៅក្នុងក្រមស្តីពីការសាងសង់នាពេលអនាគត។

## បញ្ហាប្រឈមសំខាន់ៗ

ទោះបីមានកិច្ចខិតខំប្រឹងប្រែងនៅក្នុងក្របខណ្ឌគោលនយោបាយដើម្បីការអភិវឌ្ឍលំនៅដ្ឋានតម្លៃសមរម្យក៏ដោយ ក៏ការផ្គត់ផ្គង់លំនៅដ្ឋានប្រភេទនេះនៅតែមានចំនួនមិនគ្រប់គ្រាន់នៅឡើយ។ គម្រោងអភិវឌ្ឍលំនៅដ្ឋានថ្មីៗស្ទើរតែទាំងអស់នៅក្នុងរាជធានីភ្នំពេញគឺបានផ្តោតទៅលើអ្នកដែលមានប្រាក់ចំណូលខ្ពស់ និងជនបរទេស ដែលវាជាកត្តាប្រឈមធ្វើអោយការផ្គត់ផ្គត់លំនៅដ្ឋានតម្លៃសមរម្យនៅមានកម្រិត។ ដំណោះស្រាយ គឺត្រូវធ្វើយ៉ាងណាឱ្យគម្រោងវិនិយោគសាងសង់លំនៅដ្ឋានមានតម្លៃសមរម្យ និងមានលក្ខណៈបៃតងក្លាយជាអាទិភាពមួយរបស់រាជរដ្ឋាភិបាល ដើម្បីអោយមានភាពទាក់ទាញចំពោះវិនិយោគិនឯកជន។ ផ្ទះបើកអាជីវកម្មបច្ចុប្បន្នដែលមានតម្លៃសមរម្យ គឺមិនបានរចនាសាងសង់អោយស្របទៅនឹងបទដ្ឋានពាក់ព័ន្ធនឹងប្រសិទ្ធភាពថាមពល និងការតម្រូវអោយមានខ្យល់ចេញចូលធម្មជាតិឡើយ។ អ្នកធ្វើការដែលមានប្រាក់ចំណូលទាបមាននិន្នាការជួលបន្ទប់នៅក្នុងផ្ទះដែលមានមនុស្សច្រើនកុះករ និងបញ្ហាហប់ខ្យល់ដែលអាចបង្កឱ្យមានគ្រោះថ្នាក់ដល់អ្នកស្នាក់នៅ។ លើសពីនេះទៀត ផ្ទះបើកអាជីវកម្មភាគច្រើនត្រូវបានសាងសង់នៅជាប់នឹងចិញ្ចើមផ្លូវ ដោយមិនទុកលំហសម្រាប់តំបន់បៃតង ឬដើមឈើឡើយ។[55]

ខណៈពេលដែលការរីកដុះដាលយ៉ាងរហ័សនៃវិស័យសំណង់ មានឯកសារតិចតួចបំផុតដែលត្រូវបានចងក្រងស្តីអំពីទស្សនទាននៃការរចនាសំណង់អគារបៃតង[56] ហើយបញ្ចូលទៅក្នុងផែនការជាតិស្តីពីស្ថាបត្យកម្ម និងការគ្រប់គ្រងសំណង់អគារ។ ដោយមានការធ្វើបច្ចុប្បន្នភាពក្រមស្តីពីសំណង់អគារ គឺយើងមានឱកាសក្នុងការដាក់បញ្ចូលទស្សនទានស្តីពីអគារបៃតងទៅក្នុងក្រម។

52 ឯកសារបទបង្ហាញរបស់តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីបទប្បញ្ញត្តិនៃការកំណត់ក្រមនៃសំណង់អគារ

53 ឯកសារស្តីពីការតាំងទីលំនៅថ្មី ដោយ UNOHCHR ប្រចាំនៅប្រទេសកម្ពុជា ឆ្នាំ ២០១២ ដែលទទួលបានតាមរយៈ http://cambodia.ohchr.org/WebDOCs/DocProgrammes/Resettlement_Study-28_Feb_2012_Eng.pdf

54 គោលនយោបាយស្តីពីលំនៅដ្ឋាន ឆ្នាំ២០១៤ តាមរយៈ http://giz-cambodia.com/wordpress/wp-content/uploads/9-Summer-School_Beng-Hong-Socheat-Khemaro.pdf

55 ប្រភពដូចកំណត់សំគាល់លេខខាងលើ

### ៤.៥.៧ ការគ្រប់គ្រងសំរាម/សំណល់រឹង

សំរាមនៅរាជធានីភ្នំពេញមានប្រហែល ១,៨៦៨ តោនក្នុងមួយថ្ងៃ (ទិន្នន័យឆ្នាំ២០១៥)។ ការសិក្សាមួយបានសន្និដ្ឋានថា សំរាមប្រហែល ៧២% គឺជាសំរាមសរីរាង្គ។[66] ការវិភាគលម្អិតផ្នែកបច្ចេកទេសបានបង្ហាញពីលក្ខណៈសំរាមនៅរាជធានីភ្នំពេញដូចខាងក្រោម៖

- ចំណុះសារធាតុឆេះ = ៩០% (ដោយសារចំណុះម្ហូបអាហារខ្ពស់នៅក្នុងសំណល់)
- ចំណុះសំណើម = ៦៤%
- តម្លៃកាឡូរី = ១.៥៩៨ គីឡូកាឡូរីក្នុងមួយគីឡូក្រាម និង
- សមាមាត្រកាបូន / អាស៊ូត = ២០:១[67]

ស្ថិតិពីលក្ខណៈរបស់សំរាមអាចបញ្ជាក់ថា សំរាមនៅរាជធានីមានភាពសមស្របក្នុងការធ្វើជាប្រភពបង្កើតថាមពល ឬសម្រាប់ការធ្វើជីកំប៉ុស្ត៍ប្រើប្រាស់ឡើងវិញបាន។

ការគ្រប់គ្រងសំរាមនៅក្នុងតំបន់ទីក្រុង ត្រូវបានទទួលស្គាល់ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ថាជាបញ្ហាប្រឈមផ្នែកបរិស្ថានដ៏ចម្បងមួយ ជាពិសេសពាក់ព័ន្ធទៅនឹងកង្វះការប្រមូលសំរាមឱ្យបានគ្រប់ជ្រុងជ្រោយនៅរាជធានីភ្នំពេញ ព្រោះការប្រមូលនៅតំបន់មួយចំនួនក្នុងទីក្រុង គឺនៅមិនទាន់មានសេវាប្រមូលសំរាមទៅដល់ ឬការប្រមូលមានភាពយឺតយ៉ាវ។ ជាលទ្ធផល សំណល់សំរាមជាច្រើនតោនត្រូវបានចាក់គរចោល ឬបោះទៅក្នុងទន្លេ ស្រះ ប្រឡាយ ឬត្រូវបានកប់ក្នុងរណ្តៅនៅតាមផ្ទះ។ សំរាមដែលមិនបានប្រមូល គឺនៅរាយប៉ាយតាមទីធ្លាផ្លូវសាធារណៈ ហើយជាញឹកញាប់ធ្វើឱ្យស្ទះប្រព័ន្ធលូនៅតាមមូលដ្ឋាន និងបង្កើតជាបរិយាកាសខ្វះអនាម័យ។

ការប្រមូលសំរាមនៅមានកម្រិតនៅតំបន់ជាយរាជធានីភ្នំពេញ ដែលជាតំបន់ប្រជាជនរស់នៅមានមានប្រាក់ចំណូលទាបភាគច្រើន។ តាមរបាយការណ៍សិក្សាមួយបង្ហាញថា ប្រជាជនភាគច្រើនដែលរស់នៅក្នុងខណ្ឌជាយរាជធានីភ្នំពេញ មិនបានទទួលសេវាប្រមូលសំរាមគ្រប់គ្រាន់នៅឡើយ។ ខណ្ឌដែលមានការខ្វះខាតក្នុងការប្រមូលសំរាមជាងគេបំផុតរួមមាន៖ ខណ្ឌឫស្សីកែវ ខណ្ឌមានជ័យ ខណ្ឌច្បារអំពៅ ខណ្ឌជ្រោយចង្វារ និងខណ្ឌដង្កោ។ នៅកន្លែងដែលមិនមានសេវាប្រមូលសំរាម ឬមិនទាន់ពេល ប្រជាពលរដ្ឋជាទូទៅធ្វើការជីករណ្តៅកប់ទុកចោលតាមដងផ្លូវ ឬដុតចោល។

សំរាមដែលមិនត្រូវបានប្រមូលជាញឹកញាប់បានកកស្ទះនៅក្នុងប្រព័ន្ធបណ្តាញលូមេ និង បណ្តាញផ្លូវទឹក (ប្រឡាយធម្មជាតិ)។ នៅពេលមានភ្លៀងខ្លាំង សមត្ថភាពលូបង្ហូរគឺនៅមានកម្រិតដោយសារការស្ទះសំរាមទាំងនោះ។ គេព្យាករណ៍ថា ដោយសារការប្រែប្រួលអាកាសធាតុ ភ្លៀងធ្លាក់កាន់តែខ្លាំង និងមានភាពញឹកញាប់ជាងមុន ដូច្នេះការប្រមូលសំរាម ចាំបាច់ត្រូវធ្វើការកែលម្អឱ្យបានគ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលា ដើម្បីធានាថាបណ្តាញលូក្នុងរាជធានីអាចដំណើរការយ៉ាង ត្រឹមត្រូវដោយមិនមានការកកស្ទះដោយសារសំរាមមិនបានប្រមូល។

សំរាមដែលបានប្រមូល ត្រូវបានដឹកជញ្ជូនទៅកន្លែងចាក់នៅទីលានចាក់សំរាមក្នុងខណ្ឌដង្កោ ដែលមានចម្ងាយ ១៥គម ពីតំបន់កណ្តាលទីក្រុង។ នៅកន្លែងទីលានចាក់សំរាម សំរាមត្រូវបានចាក់លាយឡំគ្នា។ អ្នករើសសំរាមប្រហែល ៥០០ នាក់ ក្នុងនោះ ៨០% គឺជាស្ត្រីប្រកបរបរចិញ្ចឹមជីវិតតាមរយៈការកែច្នៃឡើងវិញមិនផ្លូវការ (ក្រៅប្រព័ន្ធ) នៅនឹងកន្លែងចាក់សំរាម។[68] ជាញឹកញាប់ គឺមានឃើញកុមារមកតាមម្តាយរបស់ពួកគេនៅកន្លែងចាក់សំរាម។ នៅខែតុលា ឆ្នាំ២០០៩ រដ្ឋបាលរាជធានីភ្នំពេញបានសាកល្បងធ្វើការកំណត់

[66] ឯកសារបទបង្ហាញស្តីពី ការគ្រប់គ្រងសំណល់រឹងនៅប្រទេសកម្ពុជា ដោយក្រសួងបរិស្ថាន ឆ្នាំ២០១៥(b) នៅក្នុងសិក្ខាសាលាថ្នាក់តំបន់ស្តីពីយុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រងសំណល់រឹងដែលបានប្រព្រឹត្តទៅនៅប្រទេសវៀតណាម កាលពីថ្ងៃទី ២៨-២៩ កក្កដា ២០១០។

[67] របាយការណ៍សិក្សាស្តីពីការគ្រប់គ្រងសំណល់រឹងទីក្រុងភ្នំពេញ រាជធានីនៃព្រះរាជាណាចក្រកម្ពុជា រៀបចំដោយ លោកបណ្ឌិត សេង ប៊ុនរិទ្ធ, Hidehiro Kaneko, Kimiaki Hirayama និង Keiko Katayama-Hirayama ឆ្នាំ ២០១១។

[68] កិច្ចប្រជុំជាមួយទីចាត់ការគ្រប់គ្រងកាកសំណល់រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦។

តួនាទី តាមរយៈការចុះបញ្ជីអ្នករើសសំរាមជាផ្លូវការដោយកំណត់តួនាទីរបស់ពួកគេនៅក្នុងវិស័យគ្រប់គ្រងសំរាម ប៉ុន្តែផែនការនេះមិនបានឈានទៅដល់ការចុះបញ្ជីជាផ្លូវការរបស់ក្រុមអ្នករើសសំរាមទេ។[69]

នៅរាជធានីភ្នំពេញ ក្រុមហ៊ុនឯកជន ស៊ីនទ្រី (Cintri Ltd) គឺជាអ្នកគ្រប់គ្រងការប្រមូល និងដឹកជញ្ជូនសំរាម។ នៅឆ្នាំ២០០២ ក្រុមហ៊ុនស៊ីនទ្រី បានចុះកិច្ចព្រមព្រៀងបន្ថែមជាមួយរដ្ឋបាលរាជធានីភ្នំពេញ ដែលផ្តល់ឱ្យក្រុមហ៊ុននេះនូវសិទ្ធិបន្តពីក្រុមហ៊ុន PSBK លើការគ្រប់គ្រងការសម្អាតប្រមូល និងដឹកជញ្ជូនសំណល់រឹងក្នុងទីក្រុងយកទៅចាក់នៅទីលានចាក់សំរាម ដែលមានរយៈពេលរហូតទៅដល់ចុងឆ្នាំ២០៤៨។

## គោលនយោបាយ និងក្របខណ្ឌបទប្បញ្ញត្តិ

មានអាជ្ញាធរ និងស្ថាប័នជាច្រើនធ្វើការពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងសំណល់រឹងក្នុងរាជធានីភ្នំពេញ (រូបភាពទី ៦)។ ក្រសួងបរិស្ថានទទួលខុសត្រូវក្នុងការរៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសំណល់ដែលរួមមានការប្រមូល ការដឹកជញ្ជូន ការរក្សាទុក និងការកែច្នៃឡើងវិញ។ ទោះជាយ៉ាងនេះក្តី លទ្ធភាពក្នុងការអនុវត្ត និងតាមដានគោលការណ៍ណែនាំនេះនៅមានកម្រិត។ នៅកម្រិតមូលដ្ឋានទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថាន នៃរដ្ឋបាលរាជធានីភ្នំពេញ គឺទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់នៅក្នុងរាជធានីភ្នំពេញ។ នៅក្រោមទីចាត់ការមានការិយាល័យចំនួនពីរផ្សេងៗទៀតគឺការិយាល័យបច្ចេកទេសនិងត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន និងការិយាល័យគ្រប់គ្រងសំណល់។ ការិយាល័យគ្រប់គ្រងសំណល់ ជាអង្គភាពទទួលខុសត្រូវលើការគ្រប់គ្រងសំណល់ទាំងអស់នៅក្នុង រាជធានីភ្នំពេញ រួមទាំងការសម្អាត ការប្រមូល ការដឹកជញ្ជូន ការចោលសំរាម និងការតាមដានក្រុមហ៊ុនឯកជនប្រមូលសំរាមផងដែរ។ នៅក្រោមរដ្ឋបាលរាជធានីភ្នំពេញ មានអង្គភាពគ្រប់គ្រងទីលានចាក់សំរាមដែលទទួលខុសត្រូវលើប្រតិបត្តិការទីលានចាក់សំរាមក្នុងខណ្ឌដង្កោ។

មន្ទីរបរិស្ថានរាជធានីភ្នំពេញ បានរៀបចំផែនការចំនួន ៨ សម្រាប់កែលម្អការគ្រប់គ្រងសំណល់រឹងនៅក្នុងរាជធានីភ្នំពេញ។ ផែនការទាំងនេះរួមមានដូចខាងក្រោម[70] ៖

- ប្រព័ន្ធទិន្នន័យគ្រប់គ្រងសំណល់
- ការបែងចែកសំណល់
- ការបញ្ចេញ និងការប្រមូលសំណល់
- ការបោះចោលសំណល់នៅទីលានចាក់សំរាមទៅតាមផែនការបែងចែកសំណល់
- ការកែច្នៃ និងការប្រើប្រាស់សំរាមឡើងវិញ
- ការធ្វើប្រព្រឹត្តកម្មសំណល់
- ការកសាងសមត្ថភាព និង
- ការអនុវត្ត និងការដាក់ពិន័យ

[69] ឯកសារក្របខណ្ឌគតិយុទ្ធ និងការរៀបចំស្ថាប័នស្តីពីការគ្រប់គ្រងសំណល់រឹង និងការអភិវឌ្ឍទីលានចាក់សំរាមនៅរាជធានីភ្នំពេញ ដោយអង្គការអប់រំ និងគ្រប់គ្រងសំណល់កម្ពុជា (Cambodia Education and Waste Management Organization) ឆ្នាំ២០១៤

[70] របាយការណ៍សិក្សាស្តីពីការកកើតសំណល់រឹង និងវដ្តនៃជីវិតសំណល់រឹង នៅរាជធានីភ្នំពេញ ដោយ KUOK Federo, IM Makara, HUL Seingheng, and SOY Ty, ឆ្នាំ ២០១៥។

រូបភាពទី៦៖ អាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធគ្រប់គ្រងសំណល់រឹងក្នុងរាជធានីភ្នំពេញ




*ប្រភព៖ ព័ត៌មានពីអង្គការមូលនិធិអាស៊ី និងតាមការប្រជុំពិភាក្សាជាមួយរដ្ឋបាលរាជធានីភ្នំពេញ*

នៅក្នុងអនុក្រឹត្យលេខ ១១៣ អនក្រ/បក ដែលត្រូវបានអនុម័តនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងក្នុងទីប្រជុំជន ត្រូវបានផ្ទេរវិមជ្ឈការទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយមានគោលដៅពង្រឹងការទទួលខុសត្រូវ ដោយបានផ្លាស់ប្តូរទៅថ្នាក់រាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ។ ជាលទ្ធផល រដ្ឋបាលរាជធានីភ្នំពេញបានផ្ទេរការទទួលខុសត្រូវលើការប្រមូល និងចោលសំរាមទៅឱ្យខណ្ឌទាំង១២។ អនុក្រឹត្យនេះ មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅ ធានានូវសោភ័ណ្ឌភាព កិច្ចគាំពារ សុខភាពសាធារណៈ និងបរិស្ថាន។[71]

មានអង្គការជាច្រើនដូចជា UNEP, IGES, COMPED, និង Nexus បានសហការជាមួយនឹងក្រសួងបរិស្ថាន នាយកដ្ឋានសេដ្ឋកិច្ចបៃតងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (អ.ក.អ.ច.) និងរដ្ឋបាលរាជធានីភ្នំពេញ បច្ចុប្បន្នកំពុងធ្វើការសិក្សាពីស្ថានភាព និងរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងសំរាម សំណល់រឹងសម្រាប់រាជធានីភ្នំពេញដើម្បីគ្រប់គ្រង និងដោះស្រាយហានិភ័យពីការប្រែប្រួលអាកាសធាតុ និងហានិភ័យលើបរិស្ថាន ដែលអាចកើតមាននៅក្នុងដំណើរការទាំងមូលនៃការគ្រប់គ្រងសំរាម ពោលគឺដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីទីលានចាក់សំរាម និង កែលម្អបែបបទនៃការចោលសំណល់ដែលប្រមូលបានឱ្យមានលក្ខណៈ

[71] អនុក្រឹត្យលេខ ១១៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅទីប្រជុំជន ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៥

# ៥. សកម្មភាពអាទិភាពនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព

ផ្នែកនេះពិពណ៌នាអំពីសកម្មភាពអភិវឌ្ឍន៍បៃតង ដើម្បីឈានទៅសម្រេចឱ្យបានចក្ខុវិស័យ គោលដៅ និងគោលបំណងទាំងមូល ដូចដែលបានរៀបរាប់នៅក្នុងផ្នែកទី២ និងទី៣ ខាងលើ។

## ៥.១ សកម្មភាពអាទិភាពនៅក្នុងវិស័យ រៀបចំផែនការអភិវឌ្ឍន៍ក្រុង

- ផ្សព្វផ្សាយផែនការមេ (ប្លង់គោល) ស្តីពីការប្រើប្រាស់ដីឆ្នាំ២០៣៥ ដើម្បីបង្ហាញពីហេដ្ឋារចនាសម្ព័ន្ធ/តំបន់សម្រាប់ពេលអនាគតនៃទីប្រជុំជនក្នុងទីក្រុង ទីតាំងនិងមុខងារនៃការកំណត់តំបន់ ដង់ស៊ីតេបរិស្ថាន អគារសំណង់ដែលនឹងត្រូវបានបង្កើត ទិសដៅនៃការរីកលូតលាស់ និងការបែងចែកតំបន់ជុំវិញរាជធានី
- កំណត់តំបន់អភិរក្ស (ធនធានធម្មជាតិ ទីធ្លាសាធារណៈ បេតិកភណ្ឌវប្បធម៌ និងបូជនីយដ្ឋានដែលត្រូវបានការពារអភិរក្ស) ដែលមិនអនុញ្ញាតិឱ្យមានសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ឬអគារណាមួយអាចធ្វើឡើងបានឡើយ
- កំណត់ទិសដៅនៃការពង្រីកទីប្រជុំជនក្រុង បញ្ចៀសទិសដៅដែលមានហានិភ័យធម្មជាតិ និងអាកាសធាតុ ដូចជាការជន់លិច ឬការសឹកច្រាំងទន្លេ
- រៀបចំផែនការសម្រាប់អភិវឌ្ឍន៍ទីក្រុងដែលបញ្ចេញកាបូនទាប ដែលនឹងបង្កើនដង់ស៊ីតេទីប្រជុំជនខ្ពស់ និងសម្រាប់ការប្រើប្រាស់ជាអតិបរមានូវហេដ្ឋារចនាសម្ព័ន្ធទីក្រុង
- ជៀសវាងការប្រើតែមធ្យោបាយដឹកជញ្ជូនដែលមានការចំណាយច្រើន គ្មានប្រសិទ្ធភាពថាមពល និងមានការបំពុលបរិយាកាស
- ផ្តល់ដីដល់តំបន់លំនៅដ្ឋានសម្រាប់គ្រួសារមានប្រាក់ចំណូលទាប និងកំណត់តំបន់ប្រមូលផ្តុំរោងចក្រឱ្យនៅឆ្ងាយពីលំនៅដ្ឋាន
- កែលម្អការប្រមូល និងការគ្រប់គ្រង ទិន្នន័យមូលដ្ឋាន សម្រាប់ការធ្វើគោលនយោបាយ
- អភិវឌ្ឍន៍ទីក្រុងប្រកបដោយភាពជាក់លាក់ និងមានការវិភាគត្រឹមត្រូវ
- ពង្រឹងកិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងតម្លាភាពនៃដំណើរការរៀបចំផែនការ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ និងសាធារណជន (ជាពិសេសអ្នកដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីសេចក្តីសម្រេចចិត្ត)
- អនុវត្តយុទ្ធនាការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ តាមរយៈអាជ្ញាធរមូលដ្ឋានអំពីដំណើរការរៀបចំផែនការអភិវឌ្ឍន៍ទីក្រុង
- កែលម្អអភិបាលកិច្ចមូលដ្ឋាន និងការអនុវត្តបទប្បញ្ញត្តិនានាទាក់ទងនឹងសណ្តាប់ធ្នាប់ និងការរក្សាអនាម័យទីក្រុង ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

## ៥.២ សកម្មភាពអាទិភាពនៅក្នុងវិស័យ ភាពងាយរងគ្រោះរបស់ទីក្រុង

- ការពារបឹងធម្មជាតិ ស្ទឹង ប្រឡាយ និងតំបន់ដីសើមក្នុងទីក្រុង និងមិនត្រូវអនុញ្ញាតិឱ្យមានការប្រើប្រាស់សម្រាប់ការវិនិយោគពាណិជ្ជកម្មបន្ថែមទៀតឡើយ
- ស្តារឡើងវិញច្រករបៀងបៃតង ឬបង្កើតច្រករបៀងទាំងនោះនៅក្នុងទីក្រុង
- បង្កើនទ្វេដងនូវទីធ្លាបៃតង ធៀបទៅនឹងពេលបច្ចុប្បន្នក្នុងមនុស្សម្នាក់ ១,១$m^2$ ដើម្បីជាប្រព័ន្ធផ្ទុក (ស្រូប) ជំនន់ទឹកភ្លៀង កាត់បន្ថយការជន់លិច និងបង្កើនជីវៈចម្រុះ
- ស្តារឡើងវិញប្រព័ន្ធជលវិទ្យាធម្មជាតិ ដើម្បីប្រើប្រាស់បានច្រើនមុខងារ (នេសាទ វារីវប្បកម្ម កម្សាន្ត និងការកែលម្អជីវៈចម្រុះ)
- ធ្វើឱ្យកាន់តែរឹងមាំ ប្រព័ន្ធបណ្តាញលូនៅតំបន់ងាយជន់លិច ដោយប្រើប្រាស់ប្រព័ន្ធទប់ស្កាត់ ទឹកភ្លៀង ប្រមូលទឹកភ្លៀង ការស្តារប្រព័ន្ធជលវិទ្យាធម្មជាតិ តំបន់បៃតង និងវិធានការវិស្វកម្ម
- ធ្វើជីវវិស្វកម្មដោយប្រើប្រាស់ប្រភេទរុក្ខជាតិដើមក្នុងស្រុកដើម្បីការពារការសឹក ការពារទឹកជំនន់ និងផ្ទុក (ស្រូប) ទឹកភ្លៀង

- ធ្វើប្រព្រឹត្តកម្ម (ចម្រោះ) ទឹកកខ្វក់ដែលកើតមាននៅក្នុងតំបន់ប្រជុំជនក្រុង ដោយប្រើប្រាស់យ៉ាងហោចណាស់ប្រព័ន្ធប្រព្រឹត្តកម្មបន្ទាប់បន្សំ
- បង្កើតប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់វិមជ្ឈការ (ខ្នាតតូចតាមតំបន់) និងពង្រឹងការអនុវត្តនៅក្នុងសហគមន៍ក្រីក្រដែលនៅជាយរាជធានី
- កាត់បន្ថយការខូចខាតផ្នែកទ្រព្យសម្បត្តិ ការបាត់បង់អាយុជីវិត និងការខូចខាតសេដ្ឋកិច្ចដែលបណ្តាលមកពីការជន់លិចនៅក្នុងទីក្រុង
- ជម្លៀសប្រជាជនដែលរស់នៅក្នុងតំបន់លិចទឹក ទៅតំបន់ទីតាំងលំនៅដ្ឋានដែលមានសុវត្ថិភាព និងសន្តិសុខជាងនៅក្នុងទីក្រុង
- ជំរុញ និងលើកទឹកចិត្តគ្រួសារទាំងអស់ដែលរស់នៅតំបន់ជុំវិញទីក្រុងប្រើប្រាស់ប្រព័ន្ធអនាម័យដែលមានការកែលម្អ និងមានសុវត្ថិភាព

## ៥.៣ សកម្មភាពអាទិភាពនៅក្នុងវិស័យថាមពល

- បង្កើនសកម្មភាពក្នុងវិស័យថាមពល គាំទ្រដល់ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់
- អនុវត្តសវនកម្មប្រសិទ្ធភាពថាមពលនៅគ្រប់ស្ថាប័នក្រុងទាំងអស់ ហើយកំណត់ និងអនុវត្តផែនការគ្រប់គ្រងថាមពល និងប្រសិទ្ធភាពថាមពលដែលសមស្រប
- គ្រឿងអគ្គិសនី និងចង្គ្រានអគ្គិសនីទាំងអស់ដែលត្រូវបានធ្វើតេស្ត និងបិទស្លាកសញ្ញាស្របតាមបទដ្ឋានជាតិ ស្លាកពិពណ៌នាប្រសិទ្ធភាពថាមពលសរសេរជាភាសាខ្មែរ
- បង្កើតទីផ្សារសម្រាប់សេវាប្រសិទ្ធភាពថាមពល និងហិរញ្ញវត្ថុដើម្បីបម្រើសេវាដល់វិស័យពាណិជ្ជកម្ម និងវិស័យឧស្សាហកម្ម
- បំពាក់បរិក្ខាដែលគាំទ្រទៅដល់ថាមពលកកើតឡើងវិញ នៅលើដំបូលអគារ និង/ឬស្ថាប័ន រាជរដ្ឋាភិបាល អគារពាណិជ្ជកម្ម និងឧស្សាហកម្មថ្មីទាំងអស់

## ៥.៤ សកម្មភាពអាទិភាពនៅក្នុងវិស័យដឹកជញ្ជូន

- បង្កើតប្រព័ន្ធគ្រប់គ្រងចរាចរណ៍ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ មានប្រសិទ្ធភាពធនធាន និងមានបុគ្គលិកគ្រប់គ្រាន់សម្រាប់ការអនុវត្ត
- អនុវត្ត បទប្បញ្ញត្តិនានាទាក់ទងនឹងការគ្រប់គ្រងចំណត
- កំណត់កម្រិតចំណុះសារធាតុស៊ុលហ្វួរសម្រាប់ឥន្ធនៈមធ្យោបាយដឹកជញ្ជូន ស្របតាមបទដ្ឋានតំបន់ (ក្នុងតំបន់៥0 ppm ត្រូវបានកាត់បន្ថយពីចំណុះបច្ចុប្បន្ន ១.000 ppm)
- បង្កើតប្រព័ន្ធតាមដានគុណភាពខ្យល់ប្រចាំថ្ងៃ (កើនឡើងពីស្ថានីយតាមដានដែលមានក្នុងពេលបច្ចុប្បន្នចំនួនបី) នៅទូទាំងរាជធានីដែលតាមដានសារធាតុបំពុលខ្យល់សំខាន់ៗ (PM១០ PM២.៥ SOx NOx CO និង O3)
- កាត់បន្ថយការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលប្រើម៉ាស៊ីន
- បង្កើតផែនការលើកទឹកចិត្តការប្រើប្រាស់ទោចក្រយានយន្ត (កង់) ឬថ្មើរជើង ដោយរួមបញ្ចូលទាំងការរៀបចំគន្លងផ្លូវសម្រាប់អ្នកជិះកង់ និងអ្នកថ្មើរជើង ដើម្បីបង្កភាពងាយស្រួលសម្រាប់ពួកគាត់
- លើកទឹកចិត្តការប្រើប្រាស់យានយន្ត ដែលមានការបំភាយឧស្ម័នទាប (ដូចជា យានយន្តដែលមានស្តង់ដារសមត្ថភាពបំភាយល្អប្រសើរក្នុងផ្នែក gCO2/km ឬស្រដៀងគ្នានេះ យានយន្តដែលមានប្រព័ន្ធហាយប្រ៊ីដ ឬយានយន្តដើរដោយអគ្គិសនី)

## ៥.៥ សកម្មភាពអាទិភាពនៅក្នុងវិស័យបរិស្ថានសំណង់

- បង្កើតលំនៅដ្ឋានដែលមានតម្លៃសមរម្យ និងមានភាពធន់នឹងគ្រោះធម្មជាតិនៅក្នុងទីក្រុង
- ជំរុញសំណង់លំនៅដ្ឋានទីក្រុងដែលរួមបញ្ចូលពីរចនាបទស្ថាបត្យកម្មទំនើប និងបុរាណលាយគ្នាដើម្បីថែរក្សាអត្តសញ្ញាណវប្បធម៌របស់ក្រុង
- ណែនាំតាមគ្រួសារ និងសហគ្រាសពាណិជ្ជកម្មនានាអំពីវិធានការណ៍ការពារទឹកជំនន់
- ណែនាំអំពីការសាងសង់ ឬការបំពាក់បរិក្ខារឡើងវិញនូវលំនៅដ្ឋាន និងអគារដែលមានប្រសិទ្ធភាពថាមពល
- គម្រោងសាងសង់ធំថ្មីៗត្រូវបែងចែកទីធ្លាគ្រប់គ្រាន់សម្រាប់របៀងបៃតង និងប្រកាន់ខ្ជាប់នូវបទដ្ឋានសំណង់អគារបៃតង
- អនុវត្តច្បាប់ថ្មីស្តីពីនគរូបនីយកម្ម ពាក់ព័ន្ធនឹងការបែងចែកទីធ្លាគ្រប់គ្រាន់នៅលើដីឡូត៍សាងសង់សម្រាប់ផ្ទៃបៃតង ។

## ៥.៦ សកម្មភាពអាទិភាពនៅក្នុងវិស័យផលិតកម្ម (កម្មន្តសាល)

- តាមដាន និងអនុវត្តបទប្បញ្ញត្តិស្តីពីប្រសិទ្ធភាពថាមពល ការប្រើប្រាស់ទឹក និងការបំភាយ សារធាតុពុលក្នុងវិស័យកម្មន្តសាល
- បង្កើតយន្តការហិរញ្ញប្បទានសម្រាប់ផ្តល់ឱ្យគម្រោងវិនិយោគប្រើប្រាស់ប្រសិទ្ធភាពថាមពល និងគ្រប់គ្រងការបំពុលនៅក្នុងវិស័យកម្មន្តសាល
- បង្កើតក្រុមហ៊ុនសេវាប្រើប្រាស់ថាមពល (ESCO) នៅក្នុងទីក្រុងដើម្បីជំរុញឱ្យមានប្រសិទ្ធភាពនៃការប្រើប្រាស់ថាមពល និងធនធាននៅតាមសហគ្រាសកម្មន្តសាល
- តម្រូវឱ្យរោងចក្រ ឬសហគ្រាសដែលមានការបញ្ចេញទឹកកខ្វក់ទាំងអស់ ត្រូវមានអាង ប្រព្រឹត្តកម្មទឹកកខ្វក់នៅនឹងកន្លែង
- ការវាយតម្លៃលើការប្រើប្រាស់ធនធាន ត្រូវបានធ្វើឡើងសម្រាប់វិស័យឧស្សាហកម្មធំៗនៅក្នុងទីក្រុង ដោយក្រឡេកមើលជាពិសេសទៅលើលំហូរសម្ភារ និងកាលានុវត្តភាពសម្រាប់ការ ប្រើប្រាស់សំណល់ពីរោងចក្រមួយចំនួនជាធាតុចូលទៅក្នុងឧស្សាហកម្មផ្សេងទៀត
- បង្កើនការងារបៃតងនៅក្នុងវិស័យកម្មន្តសាល រួមបញ្ចូលទាំងនៅក្នុងវិស័យសិប្បកម្ម។

## ៥.៧ សកម្មភាពអាទិភាពនៅក្នុងវិស័យនៃការគ្រប់គ្រងសំណល់រឹង

- បង្កើនធនធាន និងសមត្ថភាពសម្រាប់ខណ្ឌនីមួយៗក្នុងការគ្រប់គ្រងការប្រមូលសំរាម
- បង្កើតការប្រកួតប្រជែង ដើម្បីឱ្យខណ្ឌទាំងអស់ជ្រើសរើសក្រុមហ៊ុនប្រមូលសំរាមដែល សមស្របបំផុតចំពោះតម្រូវការគ្រប់គ្រងសំរាមរបស់ខ្លួន
- បង្កើតឱ្យមានសហគ្រិនភាពដើម្បីប្រមូលសំរាមនៅខណ្ឌមួយចំនួន ប្រសិនបើមិនទាន់មានក្រុមហ៊ុនប្រមូលសំរាមទៅដល់ទេនោះ
- បង្កើតយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈដើម្បីណែនាំគ្រួសារ សហគ្រាស ពាណិជ្ជកម្ម និងអាជីវករតាមផ្សារអំពីវិធីសាស្ត្រញែកសំរាម និងអត្ថប្រយោជន៍
- ជំរុញការញែកសំរាមតាមទីតាំងឧស្សាហកម្ម
- យុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ ដើម្បីផ្តល់ព័ត៌មានដល់ពលរដ្ឋអំពីជម្រើសផ្សេងៗជំនួសឱ្យការប្រើប្រាស់ថង់ផ្លាស្ទិច និងផលវិបាកទៅលើបរិស្ថានពីការបន្តប្រើប្រាស់ថង់ផ្លាស្ទិចទាំងនោះ
- ហាមឃាត់ការប្រើប្រាស់ថង់ផ្លាស្ទិច និងជំនួសដោយថង់អាចប្រើឡើងវិញបាន (ថង់ដែលមានមេត្រីភាពបរិស្ថាន - Eco Bags)

## ៥.៨ សកម្មភាពអាទិភាពក្នុងវិស័យអភិវឌ្ឍន៍ទីធ្លាសាធារណៈ និងបេតិកភណ្ឌវប្បធម៌

- ពង្រីកបន្ថែមឧទ្យាន សួនច្បារ និងរបៀងបៃតងសាធារណៈ នៅទូទាំងទីក្រុង
- សាងសង់ឬរចនាឡើងវិញតំបន់សាធារណៈដែលមានស្រាប់មួយចំនួន ដើម្បីបញ្ចូលដើមឈើដែលផ្តល់ម្លប់ ជីវៈចម្រុះ ផ្ទៃជ្រាបទឹក និងបន្លែដែលអាចស្រូបយកទឹកភ្លៀងបន្ថែមទៀតដើម្បីគ្រប់គ្រងការហូរទឹកភ្លៀង
- បង្កើតតំបន់បៃតងបន្ថែមទៀតដើម្បីកាត់បន្ថយដោយឥទ្ធិពលតំបន់ក្តៅក្នុងទីក្រុង
- អភិវឌ្ឍតំបន់កម្សាន្តពហុមុខងារបន្ថែមទៀត ដើម្បីគាំទ្រដល់ការហាត់ប្រាណ សកម្មភាពកីឡា និងការរាប់អានគ្នាក្នុងសង្គម
- អភិរក្ស ជួសជុលនិងកែលម្អ តំបន់ អគារបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រនៅរាជធានីភ្នំពេញ
- អនុម័ត និងអនុវត្ត បទបញ្ញា ដើម្បីការពារ និងជួសជុលកែលម្អអគារ និងតំបន់បេតិកភណ្ឌវប្បធម៌សំខាន់ៗ
- បង្កើតថវិកាទីក្រុង ឬជាតិ តាមរយៈការបង់ថ្លៃរបស់ភ្ញៀវទេសចរ ឬថ្លៃអ្នកប្រើប្រាស់ផ្សេងទៀត ដើម្បីអភិរក្សអគារ និងតំបន់បេតិកភណ្ឌវប្បធម៌
- យុទ្ធនាការវិស័យទេសចរណ៍ដើម្បីបង្កើនការយល់ដឹងអំពីបេតិកភណ្ឌវប្បធម៌។



© GGGI

Global
Green Growth
Institute

Follow our activities
on Facebook and Twitter

www.gggi.org